## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការវិភាគផលប៉ះពាល់សេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| ស្រាវជ្រាវដោយ៖ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ចាន់ រ៉ាស៊ី** | បណ្ឌិត **ស្រ៊ុន សុភ័ក្ត្រ** |
| **អ៊ុត សុខា** | |
| ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ឆ្នាំចូលសិក្សា ២០១៨ |
| ជំនាន់ទី៦ | ឆ្នាំសរសេរសារណា ២០២២ |

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ចាន់ រ៉ាស៊ី** និង **អ៊ុត សុខា** ជានិស្សិតបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី៤ ជំនាន់ទី៦ ក្នុងឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋមយើងខ្ញុំទាំងពីរនាក់ សូមសម្ដែងនូវការដឹងគុណនិងការគោរពដ៏ខ្ពង់ខ្ពស់ចំពោះ លោកឪពុក និងអ្នកម្ដាយ ដែលជាអ្នកបានផ្ដល់កំណើតចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅយើងខ្ញុំពោរពេញដោយក្ដីស្រឡាញ់ការសន្ដោសប្រណីនិងព្រហ្មវិហារធម៌ ជាពិសេសលោកទាំងពីរតែងតែជួយជ្រោមជ្រែងគ្រប់សព្វបែបយ៉ាងទាំងស្មារតី និងធនធានដើម្បីទំនុកបម្រុងការសិក្សាយើងខ្ញុំទាំងពីររូប ចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្ដមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ និងលោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយទាំងពេលវេលា និងកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន ផ្ទេរចំណេះដឹងជាច្រើនដល់សិស្សនិស្សិត។

ជាពិសេសយើងខ្ញុំសូមធ្វើការថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកសាស្ត្រាចារ្យ **បណ្ឌិត ស្រ៊ុន សុភ័ក្ត្រ** ដែលបានខិតខំយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំដាស់តឿនផ្ដល់យោបល់ល្អៗ និងកែតម្រូវនូវកំហុសឆ្គងទាំងលើខ្លឹមសារ និងអក្ខរាវិរុទ្ធដែលកើតមានក្នុងដំណើរការសរសេរសារណាមួយនេះ ចាប់តាំងពីចំណុចចាប់ផ្ដើមរហូតទទួលបានជោគជ័យបើទោះបីជាបិតក្នុងស្ថានភាពយ៉ាងណាក៏ដោយ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះ លោកសាស្ត្រចារ្យ **បណ្ឌិត ម៉ាន់ ស៊ុនដេត** ដែលបានផ្ដល់ជាដំបូន្មាន និងគន្លឹះសម្រាប់ការសរសេរសារណា ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់សូមគោរពជូនពរដល់លោកឪពុកអ្នកម្ដាយព្រមទាំងឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យណែនាំ លោកលោកស្រី ដែលជាសាស្ត្រាចារ្យនិងបុគ្គលិកទាំងអស់សូមជួបប្រទះនូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាអស់រយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចលើមុខជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍រួចមក យើងខ្ញុំទាំងពីរនាក់ដែលជាសិស្សរួមជំនាន់គ្នាបានពិភាក្សា និងសម្រេចចាប់ដៃគូគ្នា ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០២២នេះ ។ ចំពោះសារណាបញ្ចប់ការសិក្សានេះជាការស្រាវជ្រាវកម្រិតបឋមក្នុងរយៈពេលកំណត់មួយដែលអាចអោយពួកយើងបានធ្វើការសិក្សាស្រាវជ្រាវបន្ថែមលើចំណុច ដែលខ្វះខាតកំឡុងពេលសិក្សាកន្លងមកនិងសម្រាប់បន្សល់ទុកស្នាដៃនេះ ជាគុណប្រយោជន៍ដល់សិស្សនិស្សិតជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្តទៀត។

ដោយសារតែស្ថានភាពក្នុងប្រទេសកម្ពុជាចាប់តាំងពីចុងឆ្នាំ២០១៩ រហូតនាពេលបច្ចុប្បន្នភាពបានទទួលរងនូវផលប៉ះពាល់ខ្លាំងពីបញ្ហានៃការឆ្លងជម្ងឺកូវីដ-១៩ បានធ្វើឲ្យវិស័យមួយចំនួនមានការរាំងស្ទះហើយប្រជាពលរដ្ឋខ្លះបានបាត់បង់ការងារធ្វើគ្មានប្រាក់ចំណូល ចំណាយកាន់តែច្រើនជាងមុន។ ជាក់ស្តែងក្នុងកាលៈទេសៈបែបនេះក្រុមយើងសង្កេតឃើញថាប្រជាជនកម្ពុជាកំពុងមានការប្រឈមនូវហានិភ័យខ្ពស់ ទាក់ទងទៅនឹងការបាត់បង់ប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ខណៈពេលដែលការរីករាលដាលជាសហគមន៍នៃជម្ងឺឆ្លងដ៏កាចសាហាវនេះ ទើបតែមានការចុះអន់ថយបន្តិច។ ដោយហេតុនេះហើយទើបពួកយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទបញ្ចប់ការសិក្សា ដែលនិយាយទាក់ទងនឹង " **ការវិភាគផលប៉ះពាល់សេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩** " ដោយលើកយកមកធ្វើជាករណីសិក្សា។ មូលហេតុនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ក្នុងគោលបំណងចង់ធ្វើការពង្រីកចំណេះដឹង និងស្វែងយល់បន្ថែមទៀតលើវិស័យនានាដែលកំពុងតែប្រឈមជាមួយបញ្ហាកូវីដ១៩ ដែលកំពុងត្រូវបានដោះស្រាយ។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំ និងជឿជាក់ថាបើទោះបីជាសារណានេះនៅមានភាពខ្វះខាតតែវាអាចក្លាយទៅជាឯកសារសម្រាប់ការសិក្សា និងការស្រាវជ្រាវសម្រាប់មិត្តអ្នកអាន និងមិត្តនិស្សិតទាំងឡាយដែលមានបំណងចង់ស្វែងយល់និងរៀនសូត្រព្រមទាំងអាចចងជាឯកសារយោងបានជាក់ជាពុំខាន។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមអរគុណអ្នកទាំងអស់គ្នាសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នាមកអានអត្ថបទសៀវភៅនេះ។ យើងខ្ញុំទាំងពីរនាក់ក៏សូមខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គងទាំងឡាយណា ដែលកើតចេញដោយអចេតនាហើយពួកយើងក៏រីករាយស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងអស់ទៅអត្ថន័យឃ្លារ និងអក្ខរាវិរុទ្ធណាមួយដែលបានកើតឡើងដោយអចេតនានៅក្នុងសៀវភៅនេះ។

# មាតិកា

ទំព័រ


១. បញ្ជីអក្សរកាត់ .................................................... v
២. បញ្ជីតារាង .................................................... vi
៣. បញ្ជីក្រាហ្វិក .................................................... vii
៤. បញ្ជីរូបភាព .................................................... viii


# សេចក្តីផ្តើម


១. សាវតានៃការស្រាវជ្រាវ .................................................... ០១
២. កម្មវត្ថុនៃការស្រាវជ្រាវ .................................................... ០៣
៣. ចំណោទបញ្ហានៃការស្រាវជ្រាវ .................................................... ០៣
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .................................................... ០៤
៥. សារៈសំខាន់នៃការស្រាវជ្រាវ .................................................... ០៤
៦. វិធីសាស្រ្តនៃការស្រាវជ្រាវ .................................................... ០៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .................................................... ០៤


# ជំពូកទី១

# ការរំលឹកទ្រឹស្តីពាក់ព័ន្ធប្រព័ន្ធសេដ្ឋកិច្ច


១.១ និយមន័យសេដ្ឋកិច្ច .................................................... ០៦
១.២ ប្រភេទនៃប្រព័ន្ធសេដ្ឋកិច្ច .................................................... ០៦
  ១.២.១ ប្រព័ន្ធសេដ្ឋកិច្ចបែបប្រពៃណី .................................................... ០៦
  ១.២.២ ប្រព័ន្ធសេដ្ឋកិច្ចបែបទីផ្សារសេរី .................................................... ០៦
  ១.២.៣ ប្រព័ន្ធសេដ្ឋកិច្ចបែបផែនការ .................................................... ០៧
  ១.២.៤ ប្រព័ន្ធសេដ្ឋកិច្ចបែបចំរុះ .................................................... ០៨
១.៣ ស្ថានភាពសេដ្ឋកិច្ចកម្ពុជាមុនសម័យកូវីដ-១៩ .................................................... ០៨
  ១.៣.១ ស្ថានភាពវិស័យទេសចរណ៍កម្ពុជាមុនកូវីដ-១៩ .................................................... ០៨
  ១.៣.២ វិស័យអចលនទ្រព្យ .................................................... ០៩
  ១.៣.៣ វិស័យហិរញ្ញវត្ថុ .................................................... ១១

១.៣.៣.១. ស្ថានភាពវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ..... ១១
១.៣.៤ ផ្នែកការងារ និងមុខរបរ ..... ១៦
១.៣.៤.១. ការងារក្នុងវិស័យឧស្សាហកម្ម ..... ១៦
១.៣.៤.២. ការងារ និងមុខរបរក្នុងវិស័យទេសចរណ៍ ..... ១៧
១.៣.៤.២.១. ស្ថានភាពទីផ្សារការងារទេសចរណ៍កម្ពុជា ..... ១៨
ក. តម្រូវការការងារ ..... ១៩
ខ. ការផ្គត់ផ្គង់ការងារ ..... ២០

## ជំពូកទី២

## ស្ថានភាពផលប៉ះពាល់សេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩

២.១. ព្រឹត្តិការណ៍ជាតិក្នុងអំឡុងពេលកូវីដ-១៩ ..... ២២
២.២. ឥទ្ធិពលកូវីដ-១៩ ទៅលើការងារ និងប្រាក់ចំណូលនៅកម្ពុជា ..... ២៣
២.២.១. ផលប៉ះពាល់លើការងារ ..... ២៤
២.២.២. ផលប៉ះពាល់លើប្រាក់ចំណូល ..... ២៥
២.២.៣. យុទ្ធសាស្ត្រទប់ទល់ទូទៅ ..... ២៧
២.៣. ផលប៉ះពាល់លើវិស័យទេសចរណ៍ ..... ២៨
២.៣.១. ផលប៉ះពាល់លើវិស័យទេសចរណ៍ ..... ២៨
២.៣.២. បញ្ហាប្រឈមក្នុងវិស័យទេសចរណ៍ ..... ៣៤
២.៣.២.១. កង្វះគោលដៅទេសចរណ៍ ..... ៣៤
២.៣.២.២. កង្វះមគ្គុទេសចរណ៍ ..... ៣៥
២.៣.២.៣. ខ្វះភាពទាក់ទាញលើសេវាកម្មទេសចរណ៍ ..... ៣៧
២.៣.២.៤. កង្វះខាតការរៀបចំរមណីយដ្ឋាន ..... ៣៧
២.៣.២.៥. អនាម័យសណ្តាប់ធ្នាប់ និងសុវត្ថិភាព ..... ៣៧
២.៣.២.៦. អំពើរកេងប្រវ័ញ្ចលើភ្ញៀវ ..... ៣៨
២.៣.២.៧. បញ្ហាសំណុំលិខិតទិដ្ឋាការ ..... ៣៩
២.៣.២.៨. ចម្ងាយ និងស្ថានផ្លូវគមនាគមន៍ ..... ៣៩
២.៣.២.៩. កង្វះការផ្សព្វផ្សាយនៅក្រៅប្រទេស ..... ៣៩

២.៤. ផលប៉ះពាល់លើវិស័យអចលនទ្រព្យ ........ ៤០
២.៤.១. ផលប៉ះពាល់លើវិស័យអចលនទ្រព្យ ........ ៤០
២.៤.២.បញ្ហាប្រឈមក្នុងវិស័យអចលនទ្រព្យកម្ពុជា ........ ៤៣
២.៤.២.១. នីតិវិធីក្នុងការចេញប្លង់កម្មសិទ្ធិ ........ ៤៣
២.៤.២.២. កង្វះការត្រួតពិនិត្យភាពស្របច្បាប់ ........ ៤៤
២.៤.២.៣. អត្រាការប្រាក់ធនាគារខ្ពស់ ........ ៤៥
២.៤.២.៤. អតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការ ........ ៤៥
២.៥. ផលប៉ះពាល់លើវិស័យហិរញ្ញវត្ថុ ........ ៤៥
២.៥.១. ផលប៉ះពាល់លើអាជីវកម្មហិរញ្ញវត្ថុ ........ ៤៦
២.៥.២. ផលប៉ះពាល់លើហិរញ្ញវត្ថុជាតិ ........ ៤៨
២.៥.២.១. ការបាត់បង់ចំណូលជាតិដោយការលើកលែងពន្ធ ........ ៤៩
២.៥.២.២. ការត្រៀមទុនបម្រុងសម្រាប់ទប់ទល់ និងឌីនភាពសេដ្ឋកិច្ច ........ ៥០
២.៥.២.៣. កម្មវិធីជំនួយហិរញ្ញវត្ថុសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ........ ៥១
២.៥.២.៤. ការឧបត្ថម្ភកម្មករនិយោជិតដែលត្រូវបានព្យួរពីការងារ ........ ៥១
២.៥.២.៥. ការចំណាយទៅលើការបង្ការជំងឺកូវីដ-១៩ ........ ៥៤
២.៥.២.៦. ការចំណាយសម្រាប់គោលដៅផ្សេងៗទៀត ........ ៥៥
២.៦. ផលប៉ះពាល់លើការងារ និងមុខរបរ ........ ៥៥
២.៦.១. ផលប៉ះពាល់លើការងារក្នុងវិស័យឧស្សាហកម្ម ........ ៥៦
២.៦.២. ផលប៉ះពាល់លើមុខរបរ និងអាជីវកម្មក្នុងវិស័យទេសចរណ៍ ........ ៥៨
២.៦.៣. ផលប៉ះពាល់លើមុខរបរ និងការងារក្រៅប្រព័ន្ធ ........ ៦០

## ជំពូកទី៣

## ការវិភាគ និងការពិភាក្សាធ្វើយុទ្ធសាស្ត្រសេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩

៣.១. មេរៀនយុទ្ធសាស្ត្រសម្រាប់កម្ពុជា ........ ៦១
៣.១.១. យុទ្ធសាស្ត្រក្នុងវិស័យទេសចរណ៍ ........ ៦១
៣.១.២. យុទ្ធសាស្ត្រសម្រាប់វិស័យអចលនទ្រព្យ ........ ៦៧
៣.២. លទ្ធផលនៃការស្រាវជ្រាវ ........ ៧១

៣.៣. ការបកស្រាយលទ្ធផលនៃការស្រាវជ្រាវ ............................................................ ៧២

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ............................................................ ៧៥
២. អនុសាសន៍............................................................ ៧៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

## ពាក្យកាត់៖

| | | |
|---|---|---|
| **SARS** | : Severe Acute Respiratory Syndrome | រោគសញ្ញាផ្លូវដង្ហើមធ្ងន់ធ្ងរ |
| **IMF** | : International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **CVEA** | **:** Copper Valley Electric Associaltion | សមាគមន៍អ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា |
| **WB** | : WORLD BANK | ធនគារពិភពលោក |
| **SWOT** | **:** Strengths, Weaknesses, Opportunities, and Threats | ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមមំហែង |
| **GDP** | : Gross domestic product | ផលិតផលក្នុងស្រុកសរុប |
| **RDA** | : Recommended Dietary Allowances | ប្រាក់ឧបត្ថម្ភរបបអាហារដែលបានណែនាំ |
| **ROE** | : Return on Equity | អនុបាតប្រាក់ចំនេញធៀបនិងមូនិធិ |
| **IFRS** | : International Financial Reporting Standards | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ |
| **LPCO** | : Liquidity-providing Collateralized Operation | ប្រតិបត្តិការផ្តល់ទស្សនីយភាពដោយមានការធានា |
| SMEs | : Small and Medium Enterprises | សហគ្រាសធុនតូចនិងមធ្យម |
| **AFD** | : Alliance forFreedom and Democracy | សម្ព័នដើម្បីសេរីភាពនិងលិទ្ធិប្រជាធិបតេយ្យ |
| **EIF** | : Enhanced Integration Framework | ក្របខ័ណ្ឌសមាហរណកម្មដែលប្រសើឡើង |
| **EBA** | : European Banking Authority | អាជ្ញាធរធនគារអឺរ៉ុប |
| **FAO** | : The Food and Agriculture Organization | អង្គការស្បៀងអាហារ និងកសិកម្ម |
| **COVID 19** | : Coronavirus disease 2019 | ជំងឺវីរុសកូរ៉ូណា ឬវីរុសកូវីដ-១៩ |

## សញ្ញាសម្គាល់៖

(%) : ភាគរយ

(,) : កាត់ខ្ទង់ពាន់

(.) : ទសភាគ ឬ ក្បៀស

(៖) : សញ្ញាភ្នែកមាន់

# បញ្ជីតារាង

តារាងទី១ ៖ ទីផ្សារទេសចរណ៍សំខាន់ៗទាំង១០ របស់កម្ពុជា ....................................................៣០
តារាងទី២ ៖ ទេសចរណ៍ទិញប័ណ្ណ ....................................................................................................៣១
តារាងទី៣ ៖ ភ្ញៀវទេសចរណ៍ដែលធ្វើដំណើរកំសាន្តក្នុងអំឡុងបុណ្យភ្ជុំបិណ្ឌឆ្នាំ២០២០ ...................... ៣៣
តារាងទី៤ ៖ ទិន្នន័យការឧបត្ថម្ភបុគ្គលិក កម្មករ ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ .................. ៥១
តារាងទី៥ ៖ ទិន្នន័យសហគ្រាសរបស់ក្រុមហ៊ុនដែលរងផលប៉ះពាល់កូវីដ-១៩ ................................៥៧
តារាងទី៦ ៖ ការប៉ាន់ស្មាន និងព្យាករមកលើសេដ្ឋកិច្ចកម្ពុជា គិតជា (%) .......................................៧១

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១ ៖ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........................................................ ១៤
ក្រាហ្វិកទី២ ៖ ឥណទានតាមវិស័យរបស់គ្រឹះមីក្រូហិរញ្ញវត្ថុ ........................................................ ១៥
ក្រាហ្វិកទី៣ ៖ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........................................................ ១៥
ក្រាហ្វិកទី៤ ៖ ចំនួនរោងចក្រសរុប ........................................................ ១៧
ក្រាហ្វិកទី៥ ៖ សមាមាត្រផលិតផលនាំចេញធៀបនិងការនាំចូល ........................................................ ១៧
ក្រាហ្វិកទី៦ ៖ អត្រាកំណើននៃផលិតផលសរុបក្នុងស្រុក មុននិងក្រោយកូវីដ-១៩ ........................... ២៣
ក្រាហ្វិកទី៧ ៖ វិស័យការងាររបស់អ្នកឆ្លើយតបដែលបាត់បង់ការងារ ............................................ ២៥
ក្រាហ្វិកទី៨ ៖ ទំហំនៃការផ្លាស់ប្តូរប្រាក់ចំណូលគ្រួសារ ........................................................ ២៦
ក្រាហ្វិកទី៩ ៖ សមាមាត្រនៃការបាត់បង់ប្រាក់ចំណូលស្មើនិង ឬធំជាង ៥០% ក្នុងចំណោមអ្នកឆ្លើយតបតាមទីតាំង យេនឌ័រ និង ID Poor ........................................................ ២៦
ក្រាហ្វិកទី១០ ៖ សមាមាត្រនៃគ្រួសារដែលចូលរួមក្នុងយុទ្ធសាស្ត្រដោះស្រាយទូទៅ ........................... ២៧
ក្រាហ្វិកទី១១ ៖ ចំនួនភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិ ២០១៥-២០១៩ ........................................ ២៩
ក្រាហ្វិកទី១២ ៖ អត្រាកំណើនភ្ញៀវទេសចរណ៍អន្តរជាតិ ........................................................ ២៩
ក្រាហ្វិកទី១៣ ៖ ការនាំចេញផលិតផលកាត់ដេរ និងស្បែកជើង ( ២០១០-២០១៩ ) ........................... ៥៦

# បញ្ជីរូបភាព


រូបភាពទី១-២ ៖ ទិន្នភាពផ្សាររាត្រីអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ .................................. ៣២

រូបភាពទី៣ ៖ កិច្ចសម្ភាស៍លោក ង៉ែត ពិទូ ប្រធានមន្ទីទេសចរណ៍ខេត្តរតនៈគិរី .............................៣៦

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. សាវតានៃការស្រាវជ្រាវ

កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចជាតិខ្ពស់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយ ហើយបើតាមទិន្នន័យរបស់រាជរដ្ឋាភិបាលកម្ពុជា ធនាគារពិភពលោក ក៏ដូចជាធនាគារអភិវឌ្ឍន៍អាស៊ីបាន បង្ហាញថាប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំប្រមាណ ៧.៧% ក្នុងចន្លោះឆ្នាំ១៩៩៥-២០១៨។ អត្រាកំណើនប្រចាំឆ្នាំដ៏ខ្ពស់នេះ បានធ្វើឱ្យកម្ពុជាក្លាយទៅជាប្រទេសមួយដែលមានកំណើនសេដ្ឋកិច្ចលឿន។ បើតាមរបាយការណ៍ប្រចាំឆ្នាំ២០១៩ របស់ធនាគារជាតិនៃកម្ពុជាបានបង្ហាញថាកំណើនសេដ្ឋកិច្ចកម្ពុជានៅ ក្នុងឆ្នាំ២០១៩ បានកើនឡើងនៅក្នុងរង្វង់ ៧,១% ដោយមានការចូលរួមពីវិស័យនានាជាច្រើនដូចជាវិស័យ ឧស្សាហកម្មប្រមាណ ៣៨,៣% វិស័យសេវាកម្មប្រមាណ ៣៨,១% និងវិស័យកសិកម្មប្រមាណ ១៦% ។[1] យើងសង្កេតឃើញថាមានកត្តាជាច្រើនបានរួមចំណែកក្នុងការថែរក្សាកំណើនសេដ្ឋកិច្ចកម្ពុជាដែលមានដូចជា កត្តាសុខសន្តិភាពកំណើននៃការវិនិយោគទុនបរទេស ព្រមទាំងការរីកចម្រើននៃវិស័យសេវាកម្មឧស្សាហកម្ម កាត់ដេរ អចលនទ្រព្យ ទេសចរណ៍ ពាណិជ្ជកម្ម និងកសិកម្មជាដើម។ ជាមួយនឹងការរីកចម្រើនព្រមទាំងកិច្ច ប្រឹងប្រែងដ៏សកម្មនេះកម្ពុជាបានប្រែក្លាយខ្លួនទៅជាប្រទេស មានប្រាក់ចំណូលទាបកម្រិតមធ្យមក្នុងឆ្នាំ២០១៥ និងមានមហិច្ឆតាក្លាយខ្លួនទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ថែមទៀត។

ដោយឡែកចាប់តាំងពីចុងឆ្នាំ២០១៩កន្លងមក ប្រទេសជាច្រើននៅលើពិភពលោករួមទាំងកម្ពុជាផង ដែរបានជួបប្រទះនឹងស្ថានការណ៍នៃការរាតត្បាតជម្ងឺឆ្លងកូវីដ-១៩ហើយបានក្លាយជាព្រឹត្តិការណ៍សោកនាដ្ឋ កម្មសកលមួយ ដែលគ្មាននរណាម្នាក់អាចទស្សន៍ទាយបាន។ ដោយជម្ងឺនេះជាវីរុសថ្មីមួយដែលទើបតែរក ឃើញនៅចុងឆ្នាំ ២០១៩ និងមានប្រភពដំបូងមកពីទីក្រុង អ៊ូហាន នៃប្រទេសចិន។ ជម្ងឺកូវីដ-១៩ ឬ វីរុសកូណា នេះត្រូវបានចម្លងតាមរយៈការប៉ះពាល់ផ្ទាល់ទៅនឹងដំណក់ទឹកតូចៗ ដែលចេញពីប្រព័ន្ធផ្លូវដង្ហើមរបស់អ្នក ដែលបានឆ្លងវីរុស (តាមរយៈការក្អក និងកណ្តាស់) និងការប៉ះផ្ទាល់ទៅលើផ្ទៃនានាដែលមានវីរុសនោះ។ វីរុសកូ វីដ-១៩ នេះអាចរស់នៅផ្ទៃខាងក្រៅបានជាច្រើនម៉ោង ហើយវាឆ្លងទៅមនុស្សគ្រប់វ័យបានទាំងអស់ថែមទាំង មានគ្រោះថ្នាក់ដល់អាយុជីវិតទៀតផង ជាពិសេសនោះគឺមនុស្សវ័យចំណាស់ដែលមានជម្ងឺប្រចាំកាយស្រាប់។ ដោយសារតែភាពកាចសាហាវ និងការឆ្លងយ៉ាងលឿននៃជម្ងឺកូវីដ-១៩ នេះហើយទើបវាបានជះឥទ្ធិពល អវិជ្ជមានយ៉ាងខ្លាំងដល់សេដ្ឋកិច្ចពិភពលោកជាពិសេសគឺ ប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍន៍។ ការកើន

[1] (២០២០,១២ កុម្ភៈ ) វិភាគ៖ ផលប៉ះពាល់សេដ្ឋកិច្ចកម្ពុជាពីវីរុសកូរ៉ូណាថ្មី. ស្រង់ចេញពីគេហទំព័រសំឡេងប្រជាធិបតេយ្យ VOD៖ https://vodkhmer.news/2020/02/12/affect-of-coronavirus-to-cambodia-economy/

ឡើងនៃវិបត្តិនេះបានផ្តល់ផលប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍មិនត្រឹមតែទៅលើភាពអាសន្នផ្នែកសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លាញដល់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចដល់ប្រទេសទាំងនោះយ៉ាងធ្ងន់ធ្ងរផងដែរ។ ខណៈការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ជាសកលបាននាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កការរាំងស្ទះទៅដល់តម្រូវការព្រមទាំងលំហូរនៃការធ្វើដំណើរពាណិជ្ជកម្ម និងការវិនិយោគដែលជាហេតុបាននាំមកនូវការរំខានទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ច នៅក្នុងបណ្តាប្រទេសអាស៊ាន។ គិតត្រឹមថ្ងៃទី២៤ ខែវិច្ឆិកាឆ្នាំ២០២០ នេះចំនួនអ្នកឆ្លងមេរោគកូវីដ-១៩ មានជិត៦០លាននាក់ និងមានអ្នកបាត់បង់ជីវិតច្រើនជាង ១,៤លាននាក់រួចទៅហើយ។ ដោយឡែកនៅក្នុងប្រទេសកម្ពុជាក៏មានអ្នកឆ្លងមេរោគកូវីដ-១៩ នេះសរុបចំនួន ៣០៦នាក់ ដែលក្នុងនោះអ្នកជាសះស្បើយមានចំនួន២៩៥នាក់។[2] ទោះបីជាមានមនុស្សស្លាប់យ៉ាងច្រើននៅទូទាំងពិភពលោកដោយសារជម្ងឺកូវីដ-១៩នេះប៉ុន្តែ អ្នកជំនាញខាងសេដ្ឋកិច្ចជាច្រើននៅតែចាត់ទុកថាវិបត្តិសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាតមួយនេះអាចបង្កើតជាបញ្ហាធំជាងបញ្ហាសុខភាពទៅទៀត ។[3]

រយៈពេលប្រមាណ៤០ឆ្នាំកន្លងទៅនេះ ពិភពលោកបានឆ្លងកាត់វិបត្តិសង្គម-សេដ្ឋកិច្ចជាច្រើនដូចជាវិបត្តិប្រាក់សន្សំ និងកម្ចីនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ វិបត្តិផ្សារភាគហ៊ុននៅឆ្នាំ១៩៨៧ និងវិបត្តិហិរញ្ញវត្ថុសកលក្នុងឆ្នាំ ២០០៧-២០០៨ ជាដើម។[4] មិនខុសពីវិបត្តិមុនៗការកើតឡើងនៃជំងឺកូវីដ-១៩ នេះបានជះឥទ្ធិពលធ្ងន់ធ្ងរដល់សេដ្ឋកិច្ចពិភពលោកជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍មិនត្រឹមតែទៅលើសុខភាពសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានប៉ះពាល់ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចផងដែរ ។[5] ជាមួយគ្នានេះធនាគារអភិវឌ្ឍន៍អាស៊ីបានធ្វើការទស្សន៍ទាយថាសេដ្ឋកិច្ចសកលលោកនឹងប្រឈមមុខជាមួយ នឹងឱនភាពចន្លោះពី ៧៧ ប៊ី

[2] Worlddometers. (2020). COVID-19 CORONAVIRUS PANDEMIC. Retrieved from https://www.worldometers.info/coronavirus/#countries

[3] Laura Oliver. (2020, March 18). Most people see COVID-19 as an economic crisis first, health risk second, survey finds, retrieved on September 02, 2020 from https://www.weforum.org/agenda/2020/03/covid-19-public-perception-economic-health-crisis-coronavirus-pandemic-ipsos/

[4] Spencer Anderson. (2013, August 20). A history of the past 40 years in financial crises. Retrieved on September 02, 2020 from https://www.ifre.com/story/1291951/a-history-of-the-past-40-years-in-financial-crises-0dxjlzsrcx.

[5] Open Development Cambodia. (2020, ២៩ កញ្ញា). ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមនៃជំងឺកូវីដ ១៩ មកលើប្រទេសកម្ពុជា. ដកស្រង់ចេញពីគេហទំព័រ៖ https://opendevelopmentcambodia.net/km/profiles/socio-economic-impact-of-covid-19-on-cambodia/

លានដុល្លាទៅ ៣៤៧ ប៊ីលានដុល្លា ឬស្មើនឹង 0,1% – 0,4% នៃផលទុនសរុបរបស់ពិភពលោក។[6] ម្យ៉ាងទៀតបើតាមការប្រមើលមើលរបស់អ្នកសេដ្ឋវិទូជាច្រើនបានបញ្ជាក់ថាការវាយប្រហារលើសេដ្ឋកិច្ចសកលលោកដោយជំងឺកូវីដ-១៩ នឹងមានលក្ខណៈធ្ងន់ធ្ងរជាងវិបត្តិជំងឺ SARS ដែលបានកើតឡើងក្នុងកំឡុងឆ្នាំ២០០២-២០០៣ ទៅទៀត។ ធនាគារពិភពលោកបានប៉ាន់ស្មានថាវិបត្តិជំងឺកូវីដ-១៩ នឹងធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាយ៉ាងខ្លាំងក្នុងឆ្នាំ២០២០ នេះជាពិសេសទៅលើវិស័យទេសចរណ៍ និងវិស័យអចលនទ្រព្យជាដើម។[7]

## ២. គម្មវត្ថុនៃការស្រាវជ្រាវ

នៅដើមឆ្នាំ២០២១ សង្កេតឃើញដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩នៅទូទាំងពិភពលោកហើយបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចពិភពលោក ក៏ដូចជាប្រទេសកម្ពុជាផងដែរទាំងក្នុងទម្រង់ម៉ាក្រូសេដ្ឋកិច្ចក៏ដូចជាមីក្រូសេដ្ឋកិច្ច។ ដូច្នេះក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទនេះមកធ្វើការសិក្សាស្វែងយល់ដូចមានគោលបំណងចម្បងដូចខាងក្រោម៖

- សិក្សាស្វែងយល់ពីមូលហេតុនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ ទៅលើសេដ្ឋកិច្ចជាតិ
- សិក្សាស្វែងយល់ពីផលប៉ះពាល់និងហានិភ័យនៃជម្ងឺកូវីដ-១៩ មកលើវិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ វិស័យអចលនទ្រព្យ និង ការងារនិងមុខរបរ
- សិក្សាស្វែងយល់ពីការវិភាគនូវផលប៉ះពាល់នានាដែលកើតមានពីការរីករាលដាលនៃជំងឺកូវីដ-១៩ មកលើសង្គមនិងសេដ្ឋកិច្ចកម្ពុជា
- ជួយស្វែករកដំណោះស្រាយក្នុងការកែប្រែស្ថានភាពឡើងវិញនូវឱនភាពសេដ្ឋកិច្ចក៏ដូចជាពង្រឹងកម្រិតជីវភាព

## ៣. ចំណោទបញ្ហានៃការស្រាវជ្រាវ

ខណៈពេលដែលប្រទេសជាតិកំពុងតែជួបនូវផលប៉ះពាល់ដោយសារតែបញ្ហាជម្ងឺកូវីដ-១៩ ដែលផលប៉ះពាល់នេះបានជះឥទ្ធិពល និងហានិភ័យទៅលើគ្រប់វិស័យទាំងអស់ដូចជា វិស័យឧស្សាហកម្ម វិស័យវាយណភ័ណ្ឌ ស្បែកជើង កាត់ដេរ វិស័យសេវាកម្មបានទទួលរងគ្រោះយ៉ាងខ្លាំងដោយសារតែជម្ងឺដ៏កាចសាហាវ

[6] Cambodianess. (2020). The Asian Development Bank maps out economic impacts of various scenarios as the coronavirus spreads to over 70 countries. Retrieved on April 20th, 2020 from https://cambodianess.com/article/how-will-covid-19-affect-cambodias-economy.

[7] WB. (2020, Oct 14). Cambodia Overview. Retrieved from: https://www.worldbank.org/en/country/cambodia/overview

នេះ។ទន្ទឹមនឹងនេះវិស័យផ្សេងៗទៀតក៏ទទួលរងផលប៉ះពាល់ពីជម្ងឺកូវីដ-១៩ផងដែរតើជម្ងឺកូវីដ-១៩បានផ្តល់ផលប៉ះពាល់យ៉ាងដូចម្តេចខ្លះដល់វិស័យទេសចរណ៍ វិស័យអចនទ្រព្យ វិស័យហិរញ្ញវត្ថុនិងការងារនិងមុខរបរ ?

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនេះ យើងនឹងធ្វើការសិក្សាជាលំអិតអំពីផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ទៅលើវិស័យទេសចរណ៍ វិស័យអចលនទ្រព្យ វិស័យហិរញ្ញវត្ថុ និងការងារនិងមុខរបរនៅប្រទេសកម្ពុជានៅចន្លោះឆ្នាំ ២០១៩ ដល់ ២០២១ ព្រមទាំងការវិភាគតាមបែបពិព័ណនាផងដែរ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

បន្ទាប់ពីបានសិក្សាអំពីប្រធានបទនេះ យើងនឹងស្វែងយល់កាន់តែច្បាស់អំពីស្ថានភាពសេដ្ឋកិច្ចជាតិកម្ពុជាក្នុងអំឡុងពេលការរីករាលដាលជងឺកូវីដ-១៩។ ម៉្យាងវិញទៀតយើងនឹងយល់ដឹងអំពីផលប៉ះពាល់ទាំងឡាយទៅលើវិស័យទេសចរណ៍ វិស័យអចលនទ្រព្យ វិស័យហិរញ្ញវត្ថុ និងការងារនិងមុខរបរ ក្នុងអំឡុងពេលឆ្លងរីករាលដាលជំងឺកូវីដ-១៩។ លើសពីនេះទៅទៀតការសិក្សាស្រាវជ្រាវនេះក៏អាចក្លាយជាប្រភពព័ត៌មានចម្បងមួយដល់អ្នកស្រាវជ្រាវដ៏ទៃទៀតឲ្យធ្វើការស្រាវជ្រាវអំពីបញ្ហានេះបន្ថែមទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសិក្សាអំពីប្រធានបទ ការវិភាគផលប៉ះពាល់សេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩យើងប្រើប្រាស់ភាគច្រើនគឺ វិធីសាស្ត្រពិពណ៌នា និងបំពេញបន្ថែមដោយវិធីសាស្ត្របរិមាណខ្លះ។

តម្រូវការទិន្នន័យ៖ ដោយក្រុមយើងខ្ញុំស្វែងរកទិន្នន័យក៏ដូចជារបាយការណ៍តាមប្រភពផ្សេងគ្នាដែលជាពិសេសនោះយើងខ្ញុំបានទាញយកទិន្នន័យពីរាជបណ្ឌិត្យសភា ដែលបានធ្វើការចុះស្រាវជ្រាវដោយផ្ទាល់ក្នុងអំឡុងពេល២០២១ លើប្រធានបទ " **ផលប៉ះពាល់កូវីដ-១៩ នៅលើសេដ្ឋកិច្ចនិងសង្គម** " ហើយក្រុមយើងខ្ញុំបានទាញដកស្រង់យកមកធ្វើជាទិន្នន័យសម្រាប់ធ្វើការអត្ថាធិប្បាយពន្យល់អំពីផលប៉ះពាល់ទាំងនោះ។ សម្រាប់ការស្រាវជ្រាវឯកសារទាំងនោះ ដែលប្រភេទឯកសារមានទាំងជាភាសាខ្មែរនិងភាសាបរទេសផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានបែងចែកចំណុចសំខាន់ៗដូចខាងក្រោម៖

ជំពូកទី១៖ យើងនឹងធ្វើការរំលឹកឡើងវិញទៅលើការសិក្សាពីនិយមន័យជាលក្ខណៈទូទៅ និងស្ថានភាពរបស់វិស័យមួយចំនួនមុនសម័យកូវីដ-១៩

ជំពូកទី២៖ ស្ថានភាពផលប៉ះពាល់សេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩ ជំពូកនេះធ្វើការបង្ហាញពីស្ថានភាពផលប៉ះពាល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាអំឡុងពេលកូវីដ-១៩ ដែលបានរៀបរាប់អំពីផលប៉ះពាល់លើវិស័យទេសចរណ៍ វិស័យអចលនទ្រព្យ វិស័យហិរញ្ញវត្ថុ និងវិស័យការងារនិងមុខរបរអំឡុងពេលកូវីដ-១៩ ដែលកំពុងតែមានបញ្ហាប្រឈមការរាំងស្ទះដល់សេដ្ឋកិច្ចជាតិ ។

ជំពូកទី៣៖ យើងនឹងធ្វើការវិភាគ និងពិភាក្សាតាមរយៈការវិភាគតាមបែបពិពណ៌នានិងបកស្រាយលទ្ធផលស្រាវជ្រាវ និងការផ្តល់ជាអនុសាសន៍ផងដែរ។ ការស្រាវជ្រាវនេះយើងបានបែងចែកចំណុចសំខាន់ៗដូចខាងក្រោម៖

- មេរៀនយុទ្ធសាស្ត្រសម្រាប់កម្ពុជា
- លទ្ធផលនៃការស្រាវជ្រាវ
- ការបកស្រាយលទ្ធផលនៃការស្រាវជ្រាវ។

# ជំពូកទី១
# ការរំលឹកទ្រឹស្តីពាក់ព័ន្ធប្រព័ន្ធសេដ្ឋកិច្ច

# ជំពូកទី១

# ការរំលឹកទ្រឹស្តីពាក់ព័ន្ធប្រព័ន្ធសេដ្ឋកិច្ច

## ១.១. និយមន័យសេដ្ឋកិច្ច

សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រសង្គមដែលទាក់ទងនឹងការផលិតការចែកចាយនិងការប្រើប្រាស់ទំនិញ និងសេវាកម្ម។ វាសិក្សាអំពីរបៀបដែលបុគ្គលអាជីវកម្ម រដ្ឋាភិបាល និងប្រជាជាតិនានាធ្វើការជ្រើសរើសអំពីរបៀបបែងចែកធនធាន។ សេដ្ឋកិច្ចផ្តោតលើសកម្មភាពរបស់មនុស្សដោយផ្អែកលើការសន្មត់ថាមនុស្សធ្វើសកម្មភាពដោយអាកប្បកិរិយាសមហេតុផលស្វែងរកកម្រិតនៃអត្ថប្រយោជន៍ឬអត្ថប្រយោជន៍ដ៏ប្រសើរបំផុត។[8]

## ១.២. ប្រភេទនៃប្រព័ន្ធសេដ្ឋកិច្ច

ប្រព័ន្ធសេដ្ឋកិច្ច គឺជាប្រព័ន្ធនៃផលិតកម្មការលៃលកធនធាន និងការបែងចែកទំនិញឬសេវាកម្មនៅក្នុងសង្គមឬទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយ។ វាក៏យោងទៅតាមប្រព័ន្ធនៃសង្គមផងដែរ ដើម្បីកត់សម្គាល់ទៅលើចំណុចអាទិភាពណាខ្លះ ដែលសង្គមនៅអាចសម្រេចបានក្នុងគោលបំណងបង្កើតយុទ្ធសាស្ត្រសេដ្ឋកិច្ចដ៏មានប្រសិទ្ធភាពនិងទទួលបានភាពជោគជ័យ។ ប្រព័ន្ធនៃសេដ្ឋកិច្ចត្រូវកំណត់ថាអ្វីដែលគេត្រូវផលិតដោយរបៀបណានិងផលិតទៅឲ្យអ្នកណា? ហើយប្រព័ន្ធសេដ្ឋកិច្ចបានបែងចែកជាបួនប្រព័ន្ធគឺមានដូចខាងក្រោម៖

### ១.២.១ ប្រព័ន្ធសេដ្ឋកិច្ចបែបប្រពៃណី (Traditional Economy System )

ប្រព័ន្ធសេដ្ឋកិច្ចបែបប្រពៃណី គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលគ្រួសារកុលសម្ព័ន្ធធ្វើការសំរេចចិត្តលើមូលដ្ឋាននៃទំលាប់ និងជំនឿដែលបានប្រកាន់យកពីជំនាន់មួយទៅជំនាន់មួយ ។ គោលដៅមួយរបស់សង្គមនេះគឺ មានជីវិតរស់នៅហើយមនុស្សម្នាក់ៗមានការកំណត់តួនាទីសំរាប់ឃ្វាលសត្វ ។ មនុស្សស្រីថែទាំដំណាំនិងចិញ្ចឹមកូន ហើយក្មេងៗជួយការងារផ្ទះប្រចាំថ្ងៃនៅពេលដែលពួកគេកំពុងហាត់រៀនជំនាញដែលគេត្រូវការសំរាប់តួនាទីយុវវ័យរបស់គេលើទំនិញសេវាកម្ម និងការងារដែលទាំងអស់នេះធ្វើតាមនិន្នាការដែលបានបង្កើតឡើងជាក់លាក់និង គ្មានអ្វីធ្វើអោយពួកគេងាកចេញពីទម្រង់នេះទេ។

### ១.២.២ ប្រព័ន្ធសេដ្ឋកិច្ចបែបទីផ្សារសេរី (Free Market Economy System )

ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី គឺជាប្រព័ន្ធសេដ្ឋកិច្ចដែលធនធានសេដ្ឋកិច្ច ឬកត្តាផលិតកម្មមួយភាពធំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភ្នាក់ងារឯកជនមាននីតិបុគ្គល និងរូបវន្តបុគ្គល ។ ចំពោះយន្តការគ្រប់គ្រង និងសម្របសម្រួលក្នុងសេដ្ឋកិច្ច គឺអាស្រ័យទៅនឹងយន្តការទីផ្សារ។ មានន័យថារាល់ការសម្រេចចិត្តសំខាន់ៗរបស់

[8] ប្រវត្តិសង្ខេបនៃសេដ្ឋកិច្ច (June 22, 2022) ដកស្រង់ចេញពី៖
https://www.investopedia.com/articles/economics/08/economic-thought.asp

ភ្នាក់ងារឯកជនក្នុងសេដ្ឋកិច្ច ដូចជាត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្ដេច ? និង ផលិតសំរាប់អ្នកណា ? ត្រូវបានកំណត់តាមរយៈទីផ្សារក្រោមឥទ្ធិពលនៃកំលាំងពីរគឺកម្លាំងផ្គត់ផ្គង់ និងកម្លាំងតម្រូវការ ។ រដ្ឋមាន តួនាទីតិចតួចបំផុតក្នុងសេដ្ឋកិច្ច។ ប្រព័ន្ធសេដ្ឋកិច្ចនេះផ្អែកទៅលើការជ្រើសរើសរបស់បុគ្គលមិនមែនតាមរយៈការបង្គាប់របស់រដ្ឋាភិបាលដូចក្នុងសេដ្ឋកិច្ចបញ្ជាទ ។ តាមន័យម្យ៉ាងទៀតនៅក្នុងប្រព័ន្ធនេះអ្នកប្រើប្រាស់ និងអ្នកផលិតជាអ្នកដឹកនាំសេដ្ឋកិច្ច។ អ្នកប្រើប្រាស់មានសិទ្ធិនៅក្នុងការចំណាយលុយរបស់ពួកគេទៅតាមបំណងពួកគេអាចប្រើប្រាស់លុយរបស់គេដើម្បីធ្វើអាជីវកម្មឬក៏មានសិទ្ធិលក់នូវកំលាំងពលកម្មរបស់ខ្លួនអោយទៅនរណាក៏បាន។ អ្នកផលិតធ្វើការសម្រេចចិត្តថាតើទ្រព្យ ឬ សេវាកម្មអ្វីដែលពួកគេត្រូវផលិតផ្គត់ផ្គង់អោយទៅទីផ្សារ ។ ពួកគេធ្វើការសម្រេចចិត្តថា តើពួកគេត្រូវប្រើប្រាស់ធនធានដែលមានកំរិតរបស់ពួកគេយ៉ាងណា ដើម្បីទទួលបានផលច្រើនបំផុតតាមដែលអាចធ្វើបាន។ដូច្នេះនៅក្នុងសេដ្ឋកិច្ចទីផ្សារបុគ្គលគ្រប់រូបធ្វើសកម្មភាពដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គនៅពេលដែលពួកគេធ្វើការជ្រើសរើសសេដ្ឋកិច្ច។ ទោះបីជាដូច្នេះក៏ដោយក្នុងខណៈដែលគេស្វែងរកផលប្រយោជន៍អោយខ្លួនគេនោះគេក៏បង្កើតផលប្រយោជន៍ ឬអោយអ្នកដទៃផងដែរ។[9]

### ១.២.៣ ប្រព័ន្ធសេដ្ឋកិច្ចបែបផែនការ (Planned Economic System)

ប្រព័ន្ធសេដ្ឋកិច្ចផែនការ (Planned Economic System) ៖ រដ្ឋមានកម្មសិទ្ធិលើធនធាននិងកត្តាផលិតស្ទើរតែទាំងអស់ឯយន្តការគ្រប់គ្រង និងសម្របសម្រួលផ្អែកលើមូលដ្ឋានផែនការរបស់រដ្ឋមានន័យថាដំណើរផលិតកម្មស្ថិតនៅក្រោមការការពាររបស់រដ្ឋស្ទើរតែទាំងអស់ ។ ដំណោះស្រាយធំៗទាក់ទងទៅនឹងផលិតកម្មការគ្រប់គ្រងការបែងចែកធនធានផ្សេងៗត្រូវស្ថិតនៅក្រោមការកំណត់របស់រដ្ឋ។ វិនិយោគនិងទំនិញប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋត្រូវបានគ្រប់គ្រង និងកំណត់ដោយផែនការរដ្ឋ ។ នៅក្នុងសេដ្ឋកិច្ចបញ្ជារដ្ឋជាម្ចាស់កម្មសិទ្ធិលើធនធាន ឬកត្តាផលិតកម្មស្ទើរតែទាំងអស់ហើយយន្តការគ្រប់គ្រង និងសំរបសំរួលសកម្មភាពក្នុងសេដ្ឋកិច្ចគឺធ្វើទៅតាមផែនការកំណត់របស់រដ្ឋ។ ក្នុងប្រព័ន្ធសេដ្ឋកិច្ចនេះសហគ្រាសជាកម្មសិទ្ធិរបស់រដ្ឋហេតុនេះសកម្មភាព ដែលទាក់ទងទៅនឹងការផលិតបែងចែក និងប្រើប្រាស់បានគ្រប់គ្រងអនុវត្តន៍ទៅតាមផែនការដែលបានកំណត់របស់រដ្ឋ។ មានន័យថាក្នុងផែនការដែលមានការចាត់ចែង និងត្រួតពិនិត្យដោយរដ្ឋបានកំណត់រួចស្រេចថាតើត្រូវផលិតអ្វី ? ផលិតយ៉ាងដូចម្ដេច? និង ផលិតសំរាប់អ្នកណា ?

នៅក្នុងសេដ្ឋកិច្ចបញ្ជា មន្ត្រីរដ្ឋាភិបាលពិនិត្យមើលទៅលើធនធាន និងសេចក្ដីត្រូវការរបស់ប្រទេសជាតិហើយបែងចែកធនធានទាំងនោះទៅតាមការវិនិច្ឆ័យរបស់ខ្លួន ។ ក្នុងករណីនេះចំណង់របស់អ្នកប្រើប្រាស់ម្នាក់ៗត្រូវ

[9] ប្រភេទសំខាន់ៗនាំប្រព័ន្ធសេដ្ឋកិច្ច, ដកស្រង់ចេញពីគេហទំព័រ៖ https://gocs.4ru/km/contribution/osnovnye-tipy-ekonomicheskih-sistem-tradicionnaya-rynochnaya-komandnaya/

បានគេយកចិត្តទុកដាក់តិចតួច។ រដ្ឋាភិបាល ជាទូទៅជាម្ចាស់នៃមធ្យោបាយផលិតកម្មមានដូចជាធនធាននិង រោងចក្រ ។ **ឧទាហរណ៍៖** ប្រទេសកូរ៉េខាងជើង និង គុយបាសព្វថ្ងៃនេះកំពុងអនុវត្តន៍ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា ។ មុនពេលដែលលទ្ធិកុម្មុយនីស្តត្រូវបានដួលរលំនៅក្នុងបណ្តាប្រទេសនៅអឺរ៉ុបដូចជា សហភាពសូវៀត ប្រទេសប៉ូឡូញនិង ប្រទេសអាល្លឺម៉ង់ខាងកើតពួកគេក៏អនុវត្តន៍ប្រព័ន្ធសេដ្ឋកិច្ចបញ្ជានេះដែរ។

### ១.២.៤ ប្រព័ន្ធសេដ្ឋកិច្ចបែបចំរុះ (Mixed Economy System)

សេដ្ឋកិច្ចចម្រុះ (Mixed Economy System) គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលកើតឡើងពីការបញ្ចូលធាតុពីរនៃសេដ្ឋកិច្ចផែនការ និងសេដ្ឋកិច្ចទីផ្សារសេរីឲ្យទៅជាប្រព័ន្ធសេដ្ឋកិច្ចមួយបែបថ្មី។ ហើយការរួមបញ្ចូលគ្នានូវយន្តការទីផ្សារ និងយន្តការរដ្ឋដែលមានតួនាទីសំខាន់ដូចគ្នាក្នុងការដោះស្រាយបញ្ហា តើត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្តេច? ផលិតសម្រាប់អ្នកណា? ផលិតកម្មក្នុងតម្លៃប៉ុន្មាន? តើប្រព័ន្ធសេដ្ឋកិច្ចចម្រុះជាអ្វី?

នេះមានន័យថាលក្ខណៈមួយចំនួនរបស់សេដ្ឋកិច្ចទីផ្សារសេរី និងសេដ្ឋកិច្ចផែនការត្រូវបានមកផ្គុំទៅជាប្រព័ន្ធសេដ្ឋកិច្ចចម្រុះនេះ។ ប្រព័ន្ធសេដ្ឋកិច្ចនេះត្រូវបានប្រើក្នុងប្រទេសជាច្រើនដែលគ្មានរដ្ឋ ឬសហគ្រាសឯកជនតែឯងគ្រប់គ្រងទៅលើសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសជាតិទេ។ ភ្នាក់ងារទាំងពីរមានតួនាទីសំខាន់ក្នុងការសម្រេចចិត្តលើសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ ក្នុងសេដ្ឋកិច្ចចំរុះវាមានភាពបត់បែននៅផ្នែកខ្លះ ហើយរដ្ឋគ្រប់គ្រងនៅផ្នែកខ្លះដែរមានន័យថារដ្ឋមិនគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ចទាំងអស់នោះទេ។[10]

## ១.៣ ស្ថានភាពសេដ្ឋកិច្ចកម្ពុជាមុនសម័យកូវីដ-១៩

### ១.៣.១.ស្ថានភាពវិស័យទេសចរណ៍កម្ពុជាមុនសម័យកូវីដ-១៩

វិស័យទេសចរណ៍ គឺជាវិស័យសេដ្ឋកិច្ចនិងសង្គម។ នៅឆ្នាំ២០១៩ វិស័យទេសចរណ៍កម្ពុជាបានចូលរួមចំណែកប្រមាណ ១៣% នៃ GDP ដោយបង្កើតបាននូវចំណូល ៤,៩១៩ លានដុល្លារអាមេរិក និងបានបង្កើតការងារដោយផ្ទាល់ប្រមាណ ៦៣ ម៉ឺននាក់។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជាវិស័យទេសចរណ៍ត្រូវបានចាត់ទុកថាជា **"មាស បៃតង"** រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមតាមរយៈការបង្កើតនិងបង្កើនឱកាសការងារបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់ និងរួមចំណែកដល់ការកាត់បន្ថយនូវភាពក្រីក្រនិងបានចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយប្រភពនៃការកើនឡើងកំដៅនៃភពផែនដី ដែលជាបញ្ហាប្រឈមជាសកលនាពេលបច្ចុប្បន្ន។ ប្រការដែលគួរអោយរីករាយគឺផលិតផលក្នុងស្រុកផ្នែកកសិកម្មសហ

[10] ដកស្រង់ចេញពីសៀវភៅសេដ្ឋកិច្ចនយោបាយ )POLITICAL ECONOMY)

គ្រាសធុនតូចមធ្យមបាន នឹងកំពុងរីកលូតលាស់បង្កើនចំណូលបន្ថែមដល់ប្រជាពលរដ្ឋតាមរយៈវិស័យទេសចរណ៍ដែលជាការនាំចេញនៅនឹងកន្លែង។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយឆ្នាំ២០១៩កន្លងទៅនេះ យើងបានរួមគ្នាអនុវត្តយ៉ាងសកម្មនៃគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍កម្ពុជាប្រកបដោយឆន្ទៈមោះមុតមិនចេះនឿយហត់ក្នុងការងារសំដៅជំរុញ និងអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាដោយនៅបន្តរក្សាបានកំណើនក្នុងអត្រា ៦,៦% ជាមួយនឹងការមកដល់ភ្ញៀវទេសចរណ៍អន្តរជាតិសរុបចំនួន ៦,៦លាននាក់ ខណៈដែលភ្ញៀវទេសចរណ៍ក្នុងស្រុកនៅទូទាំងប្រទេសមានចំនួនជាង ១១,៥ លាននាក់ក្នុងកំណើនប្រមាណ ២%។

សមិទ្ធផលក្នុងឆ្នាំ២០១៩ នេះសម្រេចបានក៏អាស្រ័យដោយក្រោមកិច្ចសហការដ៏ល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធវិស័យឯកជន និងដៃគូរអភិវឌ្ឍក៏ដូចជាការអនុវត្តបានយ៉ាងខ្ជាប់ខ្ជួនតាមស្មារតីនៃច្បាប់ស្តីពីទេសចរណ៍ (ដែលបានអនុម័តកាលពីឆ្នាំ ២០០៩) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍កម្ពុជា (២០១២-២០២០) ដែលបានដាក់ចេញទិសដៅយ៉ាងច្បាស់ថា៖ "**ការអភិវឌ្ឍទេសចរណ៍កម្ពុជាប្រកបដោយនិរន្តភាព ការទទួលខុសត្រូវ និងបរិយាប័ន្ន**" ។

ជាក់ស្តែងឧស្សាហកម្មទេសចរណ៍កម្ពុជាមានសម្បទាទេសចរណ៍ជាសណ្ឋាគារសរុបប្រមាណជាង ១,០៤៤ ( ស្មើនឹង៤៨,៧៨១ បន្ទប់) ផ្ទះភ្ញៀវសរុបប្រមាណជាង ២,៦៤៣ ( ស្មើនឹង ៣៤,៨៥៧បន្ទប់ ) ភោជនីយដ្ឋានអាហារដ្ឋានសរុបប្រមាណជាង ៣,៤១៥ ( ស្មើនឹង១៦៧, ៦៣៨ កៅអី ) ម៉ាស្សា និងស្ប៉ាសរុបប្រមាណជាង ៥៦៦ ( ស្មើនឹង៤,៨៣៤គ្រែ កីឡាទេសចរណ៍សរុបប្រមាណជាង១០០អាជីវកម្ម សេវាកម្មកម្សាន្តទេសចរណ៍មនុស្សពេញវ័យប្រមាណចំនួន ១,២០៧ អាជីវកម្មសេវាកម្មដឹកជញ្ជូនទេសចរណ៍ចំនួន៩៤ អាជីវកម្មទីភ្នាក់ងារទេសចរណ៍សរុប ៧៥១ អាជីវកម្មមគ្គុទ្ទេសក៏ទេសចរណ៍ចំនួន ៦,៣៤២ នាក់រមណីយដ្ឋានទេសចរណ៍ចំនួន ២៥៥កន្លែងសហគមន៍ទេសចរណ៍អេកូទេសចរណ៍ចំនួន៨៣កន្លែនិងមានកន្លែងដែលមានសក្តានុពលដែលអាចអភិវឌ្ឍជារមណីយដ្ឋានទេសចរណ៍សហគមន៍ទេសចរណ៍ប្រមាណ២១៨ កន្លែងទៀត។[11]

### ១.៣.២.វិស័យអចលនទ្រព្យ

យោងតាមការសិក្សាមួយបានបង្ហាញថាវិស័យសំណង់និងអចលនទ្រព្យកម្ពុជានៅតែបន្តរឹងមាំនិងមានភាពធន់ខ្ពស់នៅឆ្នាំ ២០១៩នេះ។ តែអ្នកជំនាញច្រើនរំឭកថា អ្នកវិនិយោគត្រូវប៉ាន់ប្រមាណពីលទ្ធភាពទិញផ្ទាល់ខ្លួនឲ្យបានច្បាស់លាស់ ជាពិសេសគួរចៀសវាងការវិនិយោគច្រើនហួសពេកដែលពឹងលើប្រាក់កម្ចី។

[11] ក្រសួងទេសចរណ៍ (សេចក្តីព្រាង ថ្ងៃទី១២ សីហា ២០២០ ) ៖ ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយកូវីដ ១៩

របាយការណ៍បច្ចុប្បន្នភាពទីផ្សារអចលទ្រព្យរបស់ក្រុមហ៊ុន V Trust Appraisal ការសាងសង់និងផ្គត់ផ្គង់អគារពាណិជ្ជកម្មសម្រាប់ប្រើប្រាស់ក្នុងវិស័យលក់ដុំ និងលក់រាយរក្សាបានកំណើនខ្ពស់នៅឆ្នាំ២០១៩ នេះស្របពេលការផ្គត់ផ្គង់អគារការិយាល័យនៅមានសន្ទុះខ្លាំង។ បន្ថែមពីលើនេះការសាងសង់ និងផ្គត់ផ្គង់អគារលំនៅស្ថានដូចជា គម្រោងខុនដូ និងសំណង់ផ្ទះជាប់ដី ក៏សុទ្ធសឹងមានសកម្មភាពរស់រវើកនៅឆ្នាំ ២០១៩នេះដែរ។ ក្នុងរយៈពេលពីខែមករា ដល់ខែមិថុនាឆ្នាំនេះ ចំនួនផ្ទះជាប់ដីដែលក្រុមហ៊ុនអភិវឌ្ឍន៍បានប្រកាសបើកលក់មានចំនួនសរុប ១៣៩០០ផ្ទះ (ផ្ទះល្វែង និងផ្ទះវីឡា) ហើយក្នុងនោះផ្ទះចំនួន៤៦០០ខ្នងបានសាងសង់ចប់និងរួចរាល់សម្រាប់អ្នកទិញចូលនៅ។ ក្នុងរយៈពេលដូចគ្នានេះដែរខុនដូចំនួន ៦៦០០យូនីត ត្រូវបានប្រកាសដាក់លក់ដោយក្រុមហ៊ុនអភិវឌ្ឍន៍ហើយក្នុងនោះខុនដូចំនួន ៦២០០យូនីត បានសាងសង់ចប់និងរួចរាល់សម្រាប់ការចូលនៅ។

លោក **ហ៊ឹម សីហា** នាយកផ្នែកស្រាវជ្រាវនៃក្រុមហ៊ុន V Trust Appraisal បានអះអាងថាលទ្ធភាពនៃការស្រូបយករបស់ទីផ្សារផ្ទះជាប់ដីបានកើនដល់ ១០ភាគរយ នៅឆ្នាំ២០១៩ នេះដែលមានន័យថាក្រុមហ៊ុនអភិវឌ្ឍន៍ត្រូវការពេលត្រឹមតែ ១២ខែជារយៈពេលខ្លី ដែលវាឆ្លុះបញ្ចាំងថាទីផ្សារផ្ទះជាប់ដីមានការទិញលក់រឹតតែល្អនៅឆ្នាំនេះ ខណៈកាលពីឆ្នាំមុនលទ្ធភាពនៃការស្រូបយកនៅលើទីផ្សារមួយចំនួនត្រឹមតែ ៨ភាគរយប៉ុណ្ណោះឬមានន័យថា ក្រុមហ៊ុនសាងសង់ត្រូវរង់ចាំដល់ទៅ១៥ខែដើម្បីលក់ចេញសំណង់ផ្ទះរបស់គេឲ្យអស់។ លោកបន្តថាទីផ្សារខុនដូត្រូវការពេលយូរជាងផ្ទះជាប់ដីបន្តិចដែលត្រូវការរយៈពេល៣២ខែ ដើម្បីឲ្យអ្នកអភិវឌ្ឍន៍អាចលក់ចេញអស់។ យ៉ាងណាក៏ដោយលោកបញ្ជាក់ថាវានៅតែជារយៈពេលដ៏ល្អមួយ ដោយសារទីផ្សារខុនដូជាទីផ្សារនៅកម្ពុជាធៀបនឹងផ្ទះជាប់ដី។ លោក **ច្រឹក សុខនីម** ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា (CVEA) បានមានប្រសាសន៍ថា វិស័យសំណង់ និងអចលនទ្រព្យកម្ពុជា នឹងបន្តកើនឡើងចន្លោះពី ១០ ភាគរយទៅ ១៥ភាគរយក្នុងមួយឆ្នាំ ដែលជាអត្រាកំណើនល្អមួយហើយប្រជាពលរដ្ឋកម្ពុជានៅតែមានឱកាសល្អក្នុងការវិនិយោគដើម្បីទទួលបានផលចំណេញពីការរីកចម្រើននេះ។ តែទន្ទឹមនឹងនេះលោកក្រើនរំឭកថាទោះបីជាទីផ្សារអចលនទ្រព្យនៅល្អ ហើយសង្កេតឃើញមានឱកាសចំណេញល្អក៏ដោយអ្នកវិនិយោគក៏ត្រូវគិតគូរពីលំហូរសាច់ប្រាក់ផ្ទាល់ខ្លួនឲ្យបានហ្មត់ចត់ផងដែរ និងត្រូវចៀសវាងការប្រមូលទិញហួសពីលទ្ធភាពខ្លាំងពេកដែលអាចបង្កជាការលំបាកទៅវិញ។ យ៉ាងណាក៏ដោយថ្មីៗនេះមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រើនរំឭកពីហានិភ័យចំពោះការផ្តល់ឥណទាននៅក្នុងវិស័យអចលនទ្រព្យ និងសំណង់នៅតែមានកម្រិតខ្ពស់គួរឲ្យព្រួយបារម្ភដែលស្ថាប័នជំនាញពាក់ព័ន្ធគួរបង្កើនយកចិត្តទុកដាក់បន្ថែមទៀតខណៈ ដែលការផ្តល់កម្ចីដល់អ្នកអភិវឌ្ឍន៍វិស័យនេះមិនទាន់មានការត្រួតពិនិត្យច្បាស់លាស់ និងទិន្នន័យផ្លូវការស្តីពីតម្លៃអចលនៈទ្រព្យមិនទាន់

មាននៅឡើយ។ ឥណទានផ្នែកឯកជនដែលប្រមូលផ្តុំកាន់តែខ្លាំងឡើងនៅក្នុងវិស័យអចលនទ្រព្យ និងសំណង់ត្រូវបានបង្កើនល្បឿនហើយគេរំពឹងថា នឹងកើនឡើងប្រហែល ២៨ភាគរយនៅក្នុងឆ្នាំ ២០១៩។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗបានព្យាករថាសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០១៩ នេះនឹងនៅតែរឹងមាំមានកំណើនប្រមាណ៧ភាគរយ និងក្រោម ៧ភាគរយនៅឆ្នាំ ២០២០។[12] ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់អំពីវិស័យអចលនទ្រព្យកម្ពុជា យើងគួរស្វែងយល់ពីកត្តាសំខាន់ៗមួយចំនួនដូចជា សេដ្ឋកិច្ច វិស័យលំនៅដ្ឋាន ការិយាល័យ ឧស្សាហកម្ម និងការលក់រាយ។ តើសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដូចម្តេច? កត្តាសេដ្ឋកិច្ចកម្ពុជាទទួលបានស្ថេរភាពនៃកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ប៉ុន្តែយោងតាមរបាយការណ៍របស់ធនាគារពិភពលោកកំណើនសេដ្ឋកិច្ចកម្ពុជាអាចធ្លាក់ចុះបន្តិច គឺថយមកត្រឹម ៦.៨ %ក្នុងឆ្នាំ ២០១៩។ ទោះយ៉ាងណាដោយសារតែស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចអត្រាអតិផរណាអំណោយផលនិងអត្រាប្តូរប្រាក់មានស្ថេរភាពកត្តាទាំងនេះបាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតបរិយាកាសល្អសម្រាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ ជាមួយគ្នានេះដែរ វិស័យដែលជំរុញសេដ្ឋកិច្ចជាងគេគឺស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ នៅក្នុងឆ្នាំ ២០១៩ វិស័យឧស្សាហកម្មរបស់ប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ១០.២% ដែលត្រូវបានគាំទ្រជាសំខាន់ដោយវិស័យឧស្សាហកម្ម និងសំណង់។ រីឯវិស័យសំណង់វិញត្រូវបានគេរំពឹងថានឹងរក្សាបាននូវកំណើនដ៏រឹងមាំដដែល។[13]

### ១.៣.៣. វិស័យហិរញ្ញវត្ថុ

#### ១.៣.៣.១. ស្ថានភាពវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ និងប្រកបដោយនិរន្តរភាពទាំងវិសាលភាពទំហំប្រតិបត្តិការ និងប្រាក់ចំណេញ។ ក្នុងឆ្នាំនេះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសរុបមាន ៧៩ គ្រឹះស្ថានដែលក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាន ៧ រួមមាន៖ ប្រាសាក់ ហត្ថាកសិករ អម្រឹត ក្រេឌីត អេអឹមអិលអូអិលស៊ី និងដាប់ប៊ែលយូប៊ីហ្វាយនែន ( អតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់)។

វិស័យនេះបានផ្តល់ឥណទានសរុបប្រមាណ ២១,៨ ទ្រីលានរៀល (៥,៤ប៊ីលានដុល្លារអាមេរិក) ដល់អតិថិជនសរុប ១,៨ លាននាក់ព្រមទាំងបានកេណ្ឌប្រមូលប្រាក់បញ្ញើសរុបប្រមាណ ១០,១ ទ្រីលានរៀល (២,៥

---

[12] (២០១៩,៣០ តុលា) ទីផ្សារអចលនទ្រព្យកម្ពុជាស្ថិតក្នុងដំណើរលូតលាស់ដោយភាពរឹងមាំនៅឆ្នាំ ២០១៩ .ទីផ្សារអចលនទ្រព្យកម្ពុជាស្ថិតក្នុងដំណើរលូតលាស់ដោយភាពរឹងមាំនៅឆ្នាំ ២០១៩នេះ -CNC News

[13] (May 16, 2019) ដកស្រង់ចេញពីគេហទំព័រ៖ របាយការណ៍ CBRE៖ ទស្សនវិស័យនៃទីផ្សារអចលនទ្រព្យកម្ពុជាឆ្នាំ២០១៩ )realestate.com.kh)

ប៊ីលានដុល្លារអាមេរិក) ពីអ្នកដាក់ប្រាក់បញ្ញើសរុប ២,១ លាននាក់។ ទន្ទឹមនឹងការបន្តពង្រីកបណ្តាញប្រតិបត្តិការទូទាំងប្រទេសវិស័យនេះបានធ្វើពិពកម្មសេវានិងផលិតផលមីក្រូហិរញ្ញវត្ថុថ្មីៗ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុទំនើបៗផងដែរ ដែលបានជួយអតិថិជនមីក្រូហិរញ្ញវត្ថុជាពិសេសប្រជាជននៅតំបន់ជនបទកាន់តែមានភាពងាយស្រួល និងសុវត្ថិភាពក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុផ្លូវការ។ ជាមួយគ្នានេះវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជានៅតែបន្តនិរន្តរភាពប្រតិបត្តិការហិរញ្ញវត្ថុឆ្លុះបញ្ចាំងតាមរយៈស្ថិរភាពអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (RDA) ៣,៦% និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុន (ROE) ១៧,៧% រួមទាំងអនុបាតឥណទានមិនដំណើរការ ១,៣%។ ទោះបីវិស័យនេះបានបន្តការរីកចម្រើនប្រកបដោយមោទនភាពយ៉ាងណាក្តី ប៉ុន្តែនៅប្រឈម នឹងបញ្ហាចម្បងៗមួយចំនួនដូចជា៖

១.ការប្រកួតប្រជែងទីផ្សារកាន់តែខ្លាំងក្លាជាងមុនទាំងគ្រឹះស្ថានផ្លូវការ និងមិនផ្លូវការ

២.ការកសាងសមត្ថភាពធនធានមនុស្សឱ្យស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ

៣.ការអនុវត្តឱ្យបានពេញលេញតាម IFRS

៤.ការស្វែងរកប្រភពទុនដែលមានតម្លៃកាន់តែសមរម្យ។

ក្នុងនាមជាអាជ្ញាធរត្រួវត្រួតពិនិត្យធនាគារជាតិនៃកម្ពុជានៅតែបន្តដាក់ចេញបទប្បញ្ញត្តិត្រួតពិនិត្យទាំងលើឯកសារនិងដល់ទីកន្លែងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុចំណេះដឹងហិរញ្ញវត្ថុ និងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការរបស់ប្រជាជន។ ចំពោះគ្រឹះស្ថានឥណទានជនបទបច្ចុប្បន្នមានចំនួន ២៧៣ គ្រឹះស្ថាន និងមានសំពៀតឥណទានសរុបប្រមាណ ៤៤២ ប៊ីលានរៀល (១០៩,១ ប៊ីលានដុល្លារអាមេរិក) ដោយបានផ្តល់ដល់អតិថិជន ២១៣.៥៧៤នាក់ និងមានអនុបាតឥណទានមិនដំណើរការ ១១%។ ទោះបីជាមានគ្រឹះស្ថានឥណទានជនបទជាច្រើនបានដាក់ពាក្យស្នើសុំវិញ្ញាប័ណ្ណបត្រពីធនាគារជាតិនៃកម្ពុជា ហើយយ៉ាងណាក្តីក៏មានគ្រឹះស្ថានមួយចំនួនទៀតនៅតែបន្តធ្វើប្រតិបត្តិការហិរញ្ញវត្ថុដោយពុំមានច្បាប់អនុញ្ញាតនៅឡើយ។ ក្នុងបរិការណ៍នេះធនាគារជាតិនៃកម្ពុជានៅតែបន្តកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីចាត់វិធានការទប់ស្កាត់សកម្មភាពអាជីវកម្មខុសច្បាប់ទាំងនោះ។

នៅក្នុងឆ្នាំ២០១៨ នេះធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាទាំងថ្នាក់ខេត្ត និងស្រុកចំនួន ៤ លើកដែលមានអ្នកចូលរួមសរុប ១.៧៥៤នាក់ ក្នុងគោលបំណងផ្សព្វផ្សាយជូនអាជ្ញាធរដែនដីប្រជាពលរដ្ឋគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនិងគ្រឹះស្ថានឥណទានជនបទឱ្យយល់ដឹងអំពី៖

- សារៈសំខាន់ និងផលប្រយោជន៍នៃវិស័យមីក្រូហិរញ្ញវត្ថុ

- តួនាទីភារៈកិច្ចរបស់ធនាគារជាតិនៃកម្ពុជា
- កាតព្វកិច្ចនិងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន
- ការយល់ដឹងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ។

❖ **អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

អត្រាការប្រាក់ឥណទានជាប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀលមាននិន្នាការធ្លាក់ចុះខណៈ ដែលអត្រាការប្រាក់បញ្ញើមានការកើនឡើងបន្តិចដោយសារការអនុវត្តគោលនយោបាយរូបិយវត្ថុ និងបទប្បញ្ញត្តិដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចទទួលបានសន្ទនីយភាពជាប្រាក់រៀលដោយមានកាលវសានផ្សេងៗគ្នាក្នុងអត្រាទាបតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាព ដែលមានការធានា (LPCO)។ តាមរយៈប្រតិបត្តិការនេះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចទទួលបានសន្ទនីយភាពក្នុងតម្លៃទាបដែលជួយបន្ទាបអត្រាកម្ចីជាប្រាក់រៀលផងដែរ។ លើសពីនេះការដាក់ពីដានអត្រាការប្រាក់ឥណទាន ដែលតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ឥណទានក្នុងអត្រាការប្រាក់មិនលើសពី ១៨% (មានប្រសិទ្ធភាពចាប់ពីខែមេសា ឆ្នាំ២០១៧) ទទួលបានសន្ទនីយភាពជាប្រាក់រៀលដោយមានកាលវសានផ្សេងៗគ្នា ក្នុងអត្រាទាបតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដែលមានការធានា (LPCO) ។ តាមរយៈប្រតិបត្តិការនេះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចទទួលបានសន្ទនីយភាពក្នុងតម្លៃទាប ដែលជួយបន្ទាបអត្រាកម្ចីជាប្រាក់រៀលផងដែរ។ លើសពីនេះការដាក់ពីដានអត្រាការប្រាក់ឥណទានដែលតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ឥណទាន ក្នុងអត្រាការប្រាក់មិនលើសពី ១៨% (មានប្រសិទ្ធភាពចាប់ពីខែមេសា ឆ្នាំ២០១៧) ជាកត្តាដែលធ្វើឱ្យអត្រាការប្រាក់ឥណទានថយចុះផងដែរ។ ចំពោះអត្រាការប្រាក់ឥណទានជាដុល្លារអាមេរិកមាននិន្នាការថយចុះ គឺបណ្តាលមកពីភាពប្រកួតប្រជែងក្នុងវិស័យហិរញ្ញវត្ថុ និងអាចទាក់ទងនឹងតម្លៃមូលនិធិកម្ចីពីក្រៅប្រទេស។ អត្រាឥណទានជាប្រាក់រៀល និងដុល្លារអាមេរិកមានអត្រា ១៧,៥៨% និង ១៥,៩២% រៀងគ្នានៅឆ្នាំ២០១៨។ ដូចគ្នានេះអត្រាការប្រាក់បញ្ញើជាប្រាក់រៀល និងដុល្លារអាមេរិកមានអត្រាដូចគ្នា ៧,៩២% ពោលគឺបានកើនឡើងបន្តិចធៀបនឹងឆ្នាំមុនដែលឆ្លុះបញ្ចាំងពីភាពប្រកួតប្រជែងកាន់តែសកម្មក្នុងទីផ្សារ។[14]

[14] របាយការណ៍ប្រចាំឆ្នាំ២០១៨ ធនាគាជាតិនៃកម្ពុជា៖ ទំព័រទី៦ https://www.nbc.org.kh/publications/annual_reports.php

ក្រាហ្វិកទី ១ ៖ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ




ប្រភពទិន្នន័យ ៖ ក្រសួងហិរញ្ញវត្ថុ

- **ការគណនាអត្រាការប្រាក់ឥណទាន**

នៅឆមាសទី១ឆ្នាំ២០១៨ អត្រាការប្រាក់មធ្យមថ្លឹងចំពោះឥណទានតាមទម្រង់ថ្មីត្រូវបានគណនាដោយប្រើប្រាស់កិច្ចព្រមព្រៀងផ្តល់ឥណទានថ្មី (ទិន្នន័យលំហូរ) ដែលគ្រឹះស្ថានផ្តល់ឱ្យអតិថិជននៅក្នុងគ្រា (ក្នុងខែ) តាមប្រភេទឥណទាន និងឥណប្រតិទាននៃឥណទាននីមួយៗ។

$$\text{អត្រាការប្រាក់ថ្លឹងលើប្រាក់កម្ចីថ្មី} = \frac{\Sigma\left(\text{អត្រាការប្រាក់លើប្រាក់កម្ចីថ្មីក្នុងគ្រា} \times \text{ចំនួនប្រាក់កម្ចីថ្មីក្នុងគ្រា}\right)}{\Sigma\left(\text{ចំនួនប្រាក់កម្ចីថ្មីក្នុងគ្រា}\right)}$$

នៅឆមាសទី១ ឆ្នាំ២០១៤ ដល់ឆមាសទី២ឆ្នាំ២០១៧អត្រាការប្រាក់មធ្យមថ្លឹងតាមទំហំឥណទានសរុបត្រូវបានគណនាដោយប្រើប្រាស់កិច្ចព្រមព្រៀងផ្តល់ឥណទានសរុប(ទិន្នន័យស្តុក) ដែលគ្រឹះស្ថានផ្តល់ឱ្យអតិថិជនតាមប្រភេទឥណទាន និងឥណប្រតិទាននៃឥណទាននីមួយៗ ) ។

$$\text{អត្រាការប្រាក់កម្ចីថ្លឹងតាមទំហំឥណទានសរុប} = \frac{\Sigma\left(\text{អត្រាការប្រាក់លើប្រាក់កម្ចីសរុប} \times \text{ចំនួនប្រាក់កម្ចីសរុប}\right)}{\Sigma\left(\text{ចំនួនប្រាក់កម្ចីសរុប}\right)}$$

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាក្នុងឆ្នាំ២០១៩ បានបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ប្រកបដោយនិរន្តរភាព និងបរិយាបន្ន។គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកេណ្ឌប្រមូលប្រាក់បញ្ញើសរុប ១៦,៤ ទីលានរៀល (៣,៩ ប៊ីលានដុល្លារអាមេរិក) និងបានផ្តល់ឥណទាន ៣០,១ទ្រីលានរៀល(៧,២ ប៊ីលានដុល្លារអាមេរិក) ទៅកាន់វិស័យសេដ្ឋកិច្ចសំខាន់ៗរួមមានក្រុមគ្រួសារ ៣៤% កសិកម្ម ២០% ពាណិជ្ជកម្ម ១៨%សេវាកម្ម ១៤% ដឹកជញ្ជូន ៦% សំណង់ ៣% និងផ្សេងៗ ៥%) ។

ក្រាហ្វិកទី២៖ ឥណទានតាមវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ឆ្នាំ២០១៩)



ក្រាហ្វិកទី៣៖ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គិតជាភាគរយ.ឆមាស២ ឆាំ២០១៤-២០១៩



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជាមួយគ្នានេះគ្រឹះស្ថានឥណទានជនបទដែលទទួលបានវិញ្ញាប័ណ្ណបត្រពីធនាគារជាតិនៃកម្ពុជាមាន២៤៨ និងមានសមតុល្យឥណទានសរុប ៤០១.៥០ ប៊ីលានរៀល (0,១ ប៊ីលានដុល្លារអាមេរិក) ដោយបានផ្តល់ដល់អតិថិជន (១៩៤.០១៥ នាក់)។ អត្រាការប្រាក់បញ្ញើជារៀល និងដុល្លារអាមេរិកមានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំមុន ដោយមានកម្រិតប្រែប្រួលតិចក្នុងអត្រាជាមធ្យម ៨%និង៧,៨% រៀងគ្នា។ ទន្ទឹមនេះអត្រាការប្រាក់ឥណទានជារៀល និងដុល្លារអាមេរិកមានការថយចុះ ១៧ និងមកត្រឹម ១៥%និង១៦% រៀងគ្នាក្នុងឆ្នាំ២០១៩ បន្ទាប់ពីការដាក់ចេញនូវប្រកាសស្តីពីការកំណត់ពិដានជាលំដាប់ពី ៣៤,៥%និង២៩,៦%រៀងគ្នាក្នុងឆ្នាំ២០១៦ មកត្រឹម ២២,៩% និង ២០% រៀងគ្នាក្នុងឆ្នាំ២០២០នេះអត្រាការប្រាក់ឥណទាន១៨%ដែលការណ៍នេះបានផ្តល់ផលវិជ្ជមានច្រើនដល់អតិថិជនមីក្រូហិរញ្ញវត្ថុ។ ជាមួយគ្នានេះការកំណត់ពិដានអត្រាការប្រាក់ឥណទាននេះ បានជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយកចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការបន្ថែម និងការកាត់បន្ថយចំណាយតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុជាដើម។

### ១.៣.៤. ផ្នែកការងារ និងមុខរបរ

#### ១.៣.៤.១ ការងារក្នុងវិស័យឧស្សាហកម្ម

វិស័យឧស្សាហកម្មបន្តគាំទ្រជាចម្បងដោយកំណើនក្នុងវិស័យកម្មន្តសាល និងការបន្តកំណើនក្នុងវិស័យសំណង់។ វិស័យនេះមានកំណើន ១០,៤% ធៀបនឹង ៩,៧% នៅឆ្នាំ២០១៧ហើយបានរួមចំណែកប្រមាណ ៣៤,៩% ក្នុងផ.ស.ស.។

❖ **វិស័យកម្មន្តសាល**

វិស័យកម្មន្តសាលបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាកំណើនសេដ្ឋកិច្ចកម្ពុជា ដែលវិស័យនេះអាចផ្តល់ការងារជូនប្រជាពលរដ្ឋប្រមាណ១លាននាក់ ក្នុងនោះចំនួនពលកម្មផ្នែកកាត់ដេរសម្លៀកបំពាក់និងស្បែកជើងមានចំនួនប្រមាណ ៨០ម៉ឺននាក់។ ចំនួនរោងចក្រសរុបមានប្រមាណ ១.៥៨៥ រោងចក្រកើនឡើង ៤,១% ធៀបនឹងឆ្នាំ២០១៧ ក្នុងនោះរោងចក្រដែលបានបើកថ្មីមាន១៤៦ រោងចក្រ។ ទន្ទឹមនេះរោងចក្រផលិតទំនិញសម្រាប់ការធ្វើដំណើរបានកើនឡើងគួរកត់សម្គាល់ ដែលបង្ហាញពីឥទ្ធិពលវិជ្ជមានពីសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិនមកលើវិស័យនេះ។ ការនាំចេញផលិតផលកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងនៅឆ្នាំនេះសម្រេចបានប្រមាណ១០ ប៊ីលានដុល្លារអាមេរិក (៧៣,៧% នៃការនាំចេញសរុប) និងបានកើនឡើងគួរកត់សម្គាល់ក្នុងអត្រា ២៤,៧% ស្របពេលដែលការនាំចេញផលិតផលកម្មន្តសាលផ្សេងទៀតបានបន្តកើនឡើងដូចជាគ្រឿងបន្លាស់យានយន្ត (៣ដង) និងទោចក្រយាន (១២%)។ កំណើននៃការនាំចេញផលិតផលកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងត្រូវបានជំរុញដោយភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកជាពិសេសប្រទេសគោលដៅនាំចេញចម្បងៗដូចជា សហភាពអឺរ៉ុប (៤៦% ការនាំចេញផលិតផលកាត់ដេរសរុប) សហរដ្ឋអាមេរិក (២៤%) កាណាដា (៩%) និងជប៉ុន (៨%)។[15]

[15] របាយការណ៍ប្រចាំឆ្នាំ ធានាគាជាតិនៃកម្ពុជា៖ https://www.nbc.org.kh/publications/annual_reports.php

**ក្រាហ្វិកទី៤ ៖ ចំនួនរោងចក្រសរុប**
(ឆ្នាំ២០១៣-ខែតុលា ឆ្នាំ២០១៨)




ប្រភព ៖ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

**ក្រាហ្វិកទី៥ ៖ សមាមាត្រផលិតផលនាំចេញធៀបនឹងការនាំចេញសរុប**
(ឆ្នាំ២០១៨ ប៉ាន់ស្មាន់)




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

### ១.៣.៤.២. ការងារ និងមុខរបរក្នុងវិស័យទេសចរណ៍

តួលេខទេសចរណ៍អន្តរជាតិបានបង្ហាញថាភ្ញៀវទេសចរណ៍អន្តរជាតិចំនួន ៦,២ លាននាក់បានចូលមក ប្រទេសនេះក្នុងឆ្នាំ ២០១៨។ នៅឆ្នាំនេះមានភ្ញៀវទេសចរណ៍ចំនួន ៤,៨ លាននាក់បានមកដល់ប្រទេសកម្ពុជារួចហើយនៅខែកញ្ញាឆ្នាំ ២០១៩ ។ តួលេខភ្ញៀវទេសចរអន្តរជាតិដែលបានមកដល់ប្រទេសនៅចុងឆ្នាំទៅមិញមានចំនួន ៥.៦ លាននាក់។ តួលេខនៅក្នុងឆ្នាំនេះមានចំនួនលើសពី ៦លាននាក់ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅកម្ពុជាទទួលបានភ្ញៀវទេសចរប្រចាំឆ្នាំប្រមាណជា១ លាននាក់ ដែលនេះជាសញ្ញាបង្ហាញថាសក្ដានុពលពិតប្រាកដរបស់កម្ពុជាដែលគោលដៅទេសចរណ៍ងទើបតែចាប់ផ្ដើមតែប៉ុណ្ណោះ។ សៀមរាប និងភ្នំពេញនៅតែជាមជ្ឈមណ្ឌលដ៏សំខាន់សម្រាប់កំណើននេះ ដោយខេត្តសៀមរាបនាំមុខក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ រាជធានីភ្នំពេញបានទាក់ទាញភ្ញៀវទេសចរណ៍ចំនួនជិត ៣០ ម៉ឺននាក់នៅត្រឹមត្រីមាសទី ៣ ឆ្នាំ២០១៩ ជាលើកដំបូងក្នុងឆ្នាំនេះនេះ បើយោងតាមទិន្នន័យពីក្រសួងទេសចរណ៍។

របាយការណ៍ដដែលពីក្រសួងទេសចរណ៍ក៏បានបង្ហាញផងដែរថា៧០% នៃភ្ញៀវទេសចរណ៍ក្នុងប្រទេសបានមកដល់អាកាសចរណ៍តាមរយៈអាកាសយានដ្ឋានអន្តរជាតិចំនួន៣ដែលមានដូចជា អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (PNH) ដែលទទួលភ្ញៀវទេសចរភាគច្រើនគឺ ៣២,៦% ។ អាកាសយានដ្ឋានអន្តរជាតិសៀមរាប (REP) ស្ថិតនៅលេខ ២ ជិត ២៦.៥% ។ ហើយចុងក្រោយគឺ កុងខេងអាកាសយានដ្ឋានក្នុងក្រុងព្រះសីហនុ (ខេអេសអេស) មានអត្រា១១,៤% នៃចំនួនភ្ញៀវទេសចរណ៍មកដល់ត្រីមាសទី ៣ ឆ្នាំ ២០១៩

។ អាកាសយានដ្ឋានអន្តរជាតិក្រុងព្រះសីហនុលោកគង់កេង (KOS) មានការកើនឡើងដល់ភ្ញៀវទេសចរចំនួន ៣០០% ពីចំនួនភ្ញៀវចំនួន ១៣៤.៦៦៣ នាក់នៅឆ្នាំ ២០១៨ ដល់ចំនួន ៥៤៩.៤៨១ នាក់នៅត្រីមាសទី ៣ ឆ្នាំ ២០១៩ ដែលមានទិសដៅដូចជា ខេត្តព្រះសីហនុ និងកោះជុំវិញនោះ គឺខេត្តកំពត កែប ឧទ្យានជាតិគិរីរម្យ ខេត្តមណ្ឌលគិរី និងកន្លែងជាច្រើនទៀត។ គោលដៅទេសចរណ៍នៅតែជាការចាប់ផ្តើមមើលឃើញការអភិវឌ្ឍវិស័យទេសចរណ៍នៅដំណាក់កាលដំបូង។ ខេត្តព្រះសីហនុមានភាពល្បីល្បាញដោយសារការអភិវឌ្ឍ និងភាពរីកចម្រើនយ៉ាងឆាប់រហ័ស និងជាគោលដៅទេសចរណ៍តំបន់ឆ្នេរសមុទ្រដ៏សំខាន់បំផុតរបស់កម្ពុជា។ ការវិនិយោគក្នុងវិស័យទេសចរណ៍ ការស៊ីណូ និងហេដ្ឋារចនាសម្ព័ន្ធ ដែលពាក់ព័ន្ធបានហូរចូលក្នុងខេត្តតំបន់ឆ្នេរសមុទ្រមួយនេះ។ មូលហេតុចម្បងមួយនៃភាពរីកចម្រើននេះ គឺការពង្រីកអាកាសយានដ្ឋានអន្តរជាតិក្រុងព្រះសីហនុដើម្បីបង្កើនជើងហោះហើរអន្តរជាតិបន្ថែមទៀតពីប្រទេសចិន វៀតណាម ហ្វីលីពីន និងម៉ាឡេស៊ី។

វិស័យទេសចរណ៍មាន ១២.៣ % នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជាកាលពីឆ្នាំមុន។ ចំនួននេះត្រូវបានគេរំពឹងថានឹងកើនឡើង ១០.៧ % នៅដំណាច់ឆ្នាំនេះហើយសកម្មភាពសេដ្ឋកិច្ចធំៗនៅក្នុងវិស័យនេះមានដូចជា៖ សណ្ឋាគារភ្នាក់ងារទេសចរណ៍ សកម្មភាពទេសចរណ៍ និងការដឹកជញ្ជូនអ្នកដំណើរ។ យោងតាមទស្សនវិស័យសេដ្ឋកិច្ចរបស់ក្រុមប្រឹក្សាទេសចរណ៍ និងទេសចរណ៍ពិភពលោកឆ្នាំ២០១៨ វិស័យទេសចរណ៍កម្ពុជាបានបង្កើតការងារដោយផ្ទាល់ចំនួន ១,១៩១,០០០ កន្លែងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៧។ របាយការណ៍នេះបានប៉ាន់ប្រមាណថានឹងមានការងារប្រហែល ១០០,០០០ បន្ថែមទៀតនៅដំណាច់ឆ្នាំ ២០១៩។វាទំនងជាថាវិស័យទេសចរណ៍នឹងបន្តជាកត្តាជំរុញសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលអនាគតរបស់ព្រះរាជាណាចក្រជាពិសេសផ្នែកផលិតផលក្នុងស្រុកសរុបនិងការងាររបស់ប្រជាពលរដ្ឋក្នុងវិស័យនេះ។ ជាមួយនឹងគំនិតផ្តួចផ្តើមហេដ្ឋារចនាសម្ព័ន្ធធំៗដែលកំពុងដំណើរការរួចហើយ (កំណត់គោលដៅភាពងាយស្រួលទាំងក្នុងស្រុក និងអន្តរជាតិ) និងគោលនយោបាយទេសចរណ៍រយៈពេលវែងរបស់រដ្ឋាភិបាលវាគ្រាន់តែជាបញ្ហានៃពេលវេលាប៉ុណ្ណោះ។[16]

### ១.៣.៤.២.១. ស្ថានភាពទីផ្សារការងារទេសចរណ៍កម្ពុជា

ស្របពេលជាមួយនឹងកំណើនឡើងជាលំដាប់របស់ភ្ញៀវទេសចរអន្តរជាតិវិស័យទេសចរណ៍បានផ្តល់នូវឱកាសការងារជាច្រើនដល់យុវជនកម្ពុជា នឹងចូលរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ស្របតាមផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជាកំពុងតែមានការការចាប់អារម្មណ៍កាន់តែខ្លាំងឡើងលើជំនាញវិជ្ជាជីវៈទេសចរណ៍ ប៉ុន្តែកង្វះសាលាបណ្តុះបណ្តាលជំនាញនេះធ្វើឲ្យការ

[16] វិស័យទេសចរណ៍នៅកម្ពុជា. ដកស្រង់ចេញពីគេហទំព័រ៖ អំពីកម្ពុជា -Realestate.com.kh

ផ្គត់ផ្គង់ជំនាញមិនបានគ្រប់គ្រាន់ឆ្លើយតបនឹងសេចក្តីត្រូវការទីផ្សារ។ ក្នុងន័យនេះក្រសួងទេសចរណ៍បានខិតខំជំរុញឲ្យមានការបង្កើតសាលាបណ្តុះបណ្តាលនិងវគ្គបណ្តុះណ្តាលខ្លី ឬវែងគ្រប់ទម្រង់។

**ក.តម្រូវការការងារ**

នៅឆ្នាំ២០២០ កម្ពុជាត្រូវការអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ប្រមាណជិត ១លាននាក់ ដើម្បីបម្រើការងារដោយផ្ទាល់ជូនភ្ញៀវទេសចរដែលនឹងកើនឡើងប្រមាណ ៧ លាននាក់។ ដូចនេះក្រសួងទេសចរណ៍ត្រូវជំរុញឲ្យមានការបណ្តុះបណ្តាលកម្លាំងពលកម្មថ្មីចំនួនប្រមាណជាង ៥ម៉ឺននាក់ ក្នុងមួយឆ្នាំចាប់ពីឆ្នាំ២០១៧ តទៅ។ ទន្ទឹមនឹងនេះដែរនាពេលបច្ចុប្បន្ន អ្នកកំពុងបម្រើការងារមានចំនួនប្រមាណ ២០% ប៉ុណ្ណោះ ដែលបានឆ្លងកាត់ការសិក្សាជំនាញទេសចរណ៍តាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ សាកលវិទ្យាល័យទេសចរណ៍និងវគ្គសិក្សាខ្លីៗ (ដោយមិនគិតការបណ្តុះណ្តាលខាងក្នុង)។ ដូចនេះក្រសួងទេសចរណ៍ត្រូវដោះស្រាយបញ្ហាប្រឈមខាងលើ ពោលគឺត្រូវជំរុញការបណ្តុះបណ្តាលកម្លាំងពលកម្មថ្មី និងបំពាក់បំប៉នជំនាញបន្ថែមទៀតដល់អ្នកកំពុងបម្រើការងារ។ កម្ពុជាសម្បូរធនធានមនុស្សដែលអាចបម្រើការងារក្នុងវិស័យទេសចរណ៍កម្ពុជានិងអាចទៅបម្រើការងារនៅក្នុងតំបន់ ប៉ុន្តែយើងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជាកង្វះសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលមិនអាចផ្គត់ផ្គងពលកម្មជំនាញបានគ្រប់គ្រាន់ក្នុងវិស័យទេសចរណ៍កម្ពុជា។ ក្នុងន័យនេះក្រសួងទេសចរណ៍ បានជំរុញឲ្យមានការបង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជិវៈទេសចរណ៍ដោយរដ្ឋនិងឯកជនធ្វើការតម្រង់ទិសស្តីអំពីការអប់រំបណ្តុះបណ្តាលឲ្យស្របទៅតាមក្របខ័ណ្ឌគុណវុឌ្ឍជាតិ និងអាស៊ានដែលធានានូវការអភិវឌ្ឍសមត្ថភាពរបស់អ្នកជំនាញទេសចរណ៍ស្របតាមសេចក្តីត្រូវការជំនាញក្នុងប្រទេសនិងតំបន់។ ជាមួយគ្នានេះដែរដោយប្រតិបត្តិករទេសចរណ៍មួយចំនួននៅតែគិតថាជំនាញវិជ្ជាជីវៈទេសចរណ៍ជាការងារតាមរដូវកាលធ្វើឲ្យតម្រូវការជ្រើសរើសបុគ្គលិកសម្រាប់តែបំពេញសេចក្តីត្រូវការរយៈពេលខ្លីប្រាក់បៀវត្សនៅមានកម្រិតនិងមិនបានយកចិត្តទុកដាក់ខ្ពស់ដល់ការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិករបស់ខ្លួន។ កត្តានេះធ្វើឲ្យអ្នកជំនាញទេសចរណ៍មិនអាចមានឱកាសអភិវឌ្ឍន៍សមត្ថភាពខ្លួននៅកន្លែងការងារ។ ការផ្គត់ផ្គងពលកម្មជំនាញអាចនឹងកើនឡើង តាមរយៈការលើកកម្ពស់ការយល់ដឹងពីជំនាញវិជ្ជាជីវៈទេសចរណ៍ដល់ប្រជាជនជាពិសេសយុវជនអំពីវិធីអភិវឌ្ឍន៍ជំនាញទេសចរណ៍ និងឱកាសការងារក្នុងវិស័យទេសចរណ៍។ តម្រូវការការងារក្នុងវីស័យទេសចរណ៍អាចមានការប្រែប្រួលទៅតាមទីផ្សារទេសចរណ៍ ដែលទាមទារឲ្យគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់សម្របខ្លួន និងពង្រឹងការយល់ដឹងពីទីផ្សារទេសចរណ៍ថ្មីៗប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែងប៉ុន្មានឆ្នាំចុងក្រោយនេះ ទីផ្សារទេសចរណ៍ចិនបានកើនឡើងហើយក្លាយជាទីផ្សារធំបំផុតទី០១ធំជាងគេលើពិភពលោក ហើយក៏ជាទីផ្សាធំជាងគេបំផុតរបស់កម្ពុជា

ផងដែរ។ ដូចនេះតម្រូវការអ្នកចេះភាសាចិនមានការកើនឡើងដែលទាមទារឲ្យមានការបង្កើនការបណ្តុះបណ្តាលភាសា និងវប្បធម៌ចិនបន្ថែមទៀតស្របពេលនឹងការបណ្តុះបណ្តាលជំនាញដើម្បីចូលរួមបម្រើនិងទាក់ទាញទីផ្សារនេះ។

## ខ. ការផ្គត់ផ្គង់ការងារ

ការផ្គត់ផ្គង់ការងារក្នុងវិស័យទេសចរណ៍មានច្រើនសណ្ឋានរាប់ចាប់ពីជំនាញកម្រិតទាបដល់ជំនាញកម្រិតខ្ពស់។ ការយល់ដឹងអំពីឱកាសការងារ និងវិថីអភិវឌ្ឍន៍អាជីពការងារនៅក្នុងជំនាញវិជ្ជាជីវៈទេសចរណ៍មិនទាន់ទូលំទូលាយ ។ យុវជនដែលបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សាបានទទួលការអប់រំលើផ្នែកទ្រឹស្តី ប៉ុន្តែភាគច្រើនខ្វះការអនុវត្តជាក់ស្តែងខណៈដែលការងារក្នុងវិស័យទេសចរណ៍ទាមទារទាំងចំណេះដឹង ជំនាញ និងអត្តចរិកការងារក្នុងវិស័យទេសចរណ៍មានការប្រែប្រួលតាមរដូវកាល (Seasonality) ដែលជាហេតុធ្វើឲ្យម្ចាស់អាជីវកម្មមួយចំនួនមិនបានយកចិត្តទុកដាក់ខ្ពស់លើការផ្តល់ការបណ្តុះបណ្តាលបន្ថែម និងរក្សាបុគ្គលិកឲ្យបានយូរអង្វែង។ កង្វះសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ គឺជាបញ្ហាប្រឈមមួយក្នុងការបណ្តុះបណ្តាលនិងផ្គត់ផ្គង់ជំនាញទេសចរណ៍ផងដែរ។ បច្ចុប្បន្នមានតែសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ខ្នាតតូចមួយចំនួនប៉ុណ្ណោះ ដែលកំពុងបណ្តុះបណ្តាលជំនាញទេសចរណ៍បានប្រមាណ ១៧០០ នាក់ក្នុងមួយឆ្នាំ។ ជាផ្នែកមួយនៃដំណោះស្រាយរាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឲ្យក្រសួងទេសចរណ៍បង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍ចំនួន០២ នៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុក្រោមកិច្ចសហប្រតិបត្តិការឥណទានជាមួយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ដែលមានសមត្ថភាពបណ្តុះបណ្តាលកម្លាំងពលកម្មថ្មីបាន ១៣០០ នាក់ ក្នុងមួយឆ្នាំ។ រាជរដ្ឋាភិបាលក៏បានទទួលជំនួយក្នុងក្របខណ្ឌ EIF (Enhanced Integration Framework) និងបានបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈចម្អិនម្ហូបកម្ពុជា (Academy of Culinary Arts - Cambodia) ដោយមានមូលនិធិ Shift. 360 របស់ប្រទេសស្វីសជាអ្នកទទួលបន្ទុកអនុវត្តគម្រោង ហើយសាលាអាចបណ្តុះបណ្តាលចុងភៅប្រមាណ ៣០០នាក់ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៧តទៅ។ ម៉្យាងទៀតក្រសួងទេសចរណ៍បានផ្តោតលើការពង្រឹងគុណភាពបណ្តុះបណ្តាលអ្នកជំនាញថ្មី និងអ្នកកំពុងបម្រើការតាមស្តង់ដារសមត្ថភាពអាស៊ាន។ យោងតាមការសិក្សាដើម្បីឆ្លើយតបទៅនឹងស្តង់ដាសមត្ថភាពអាស៊ានក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN RATP) កម្ពុជាត្រូវធ្វើការបណ្តុះបណ្តាលបន្ថែមដល់អ្នកជំនាញកំពុងបម្រើការងារ បច្ចុប្បន្នប្រមាណ ៦៣% លើសមត្ថភាពចំនួន ៦២ត្រូវជា ១៨៦០ ម៉ោងក្នុងផ្នែកការិយាល័យជួរមុខ ផ្នែកគេហកិច្ច ផ្នែកសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ និងផ្នែកផលិតកម្មម្ហូបអាហារនៃសេវាកម្មសណ្ឋាគារ ។ ចំណែកឯសេវាកម្មធ្វើដំណើរដែលរួមមានទីភ្នាក់ងារទេសចរណ៍ និងការី

ទេសចរណ៍ត្រូវធ្វើការបណ្តុះបណ្តាលបន្ថែមដល់អ្នកកំពុងបម្រើការងារបច្ចុប្បន្នប្រមាណ ៤៥% លើសមត្ថភាព ចំនួន ៥១ ត្រូវជា ១៥៣០ម៉ោង ។ ការដោះស្រាយបញ្ហាប្រឈមនេះទាមទារកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ។[17]

[17] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥ ទំព័រទី១០ https://www.tourismecertificate.org/upload/files/1568954247_2736_.35715pdf

# ជំពូកទី២
# ស្ថានភាពផលប៉ះពាល់សេដ្ឋកិច្ចជាតិអំឡុងពេល
# កូវីដ-១៩

# ជំពូកទី២

# ស្ថានភាពផលប៉ះពាល់សេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩

## ២.១. ព្រឹត្តិការណ៍ជាតិក្នុងអំឡុងពេលកូវីដ-១៩

❖ **កម្ពុជាក្នុងអំឡុងពេលកូវីដ-១៩**

ដោយសារតែការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ហើយបានឆ្លងរាលដាលនៅស្ទើរតែគ្រប់ប្រទេសទាំងអស់នៅជុំវិញពិភពលោក បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចប្រទេសនានាលើសកលលោកបូករួមទាំងប្រទេសកម្ពុជាផងដែរ។ បើតាមកាសែតកោះសន្តិភាពដែលចុះផ្សាយកាលពីថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០២០នេះបានបញ្ជាក់ថាការរីករាលដាលនៃជំងឺកូវីដ-១៩ បានបញ្ឈប់ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជាហើយបើតាមតួលេខពីរដ្ឋាភិបាលបានគូសបញ្ជាក់ថាសេដ្ឋកិច្ចជាតិនឹងអាចធ្លាក់ដល់ -១,៩% នៅឆ្នាំ២០២០នេះ។[18] វិបត្តិកូវីដ-១៩ នេះបានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងររួចទៅហើយទៅលើវិស័យទេសចរណ៍ ការដឹកជញ្ជូននានា និងបាននាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការព្រមទាំងលំហូរនៃការធ្វើដំណើរពាណិជ្ជកម្ម និងការវិនិយោគដែលជាហេតុបាននាំមកនូវការរំខានទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ចរបស់កម្ពុជា។[19] តាមរយៈការប៉ាន់ប្រមាណពីការប៉ះពាល់នេះគេហទំព័រ Aseantoday.com បានធ្វើការគូសបញ្ជាក់ថាសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈផុយស្រួយបំផុត ដោយសារកម្លាំងចលករសេដ្ឋកិច្ចជាតិពឹងផ្អែកខ្លាំងទៅលើវិស័យទេសចរណ៍ និងជាពិសេសអ្នកទេសចរណ៍ជនជាតិចិន ។[20]

ក្រាហ្វិកខាងក្រោមនេះ បង្ហាញពីការរួមចំណែកនៃវិស័យសេដ្ឋកិច្ចនានាក្នុងផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា (GDP) ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២១។ តាមរយៈរូបភាពនេះយើងសង្កេតឃើញថាក្នុងឆ្នាំ២០១៩ វិស័យកសិកម្មបានចូលរួមចំណែកលើផលិតផលក្នុងស្រុកសរុបប្រមាណ២០,៧១%វិស័យឧស្សាហកម្ម៣៤,២៣%និងវិស័យសេវាកម្មប្រហែល៣៨,៨៥%។[21] ដោយឡែកទិន្នន័យរបស់គេហទំព័រ (Knoema.com) បានបង្ហាញថាក្នុងឆ្នាំ២០១៩ កន្លងទៅវិស័យទេសចរណ៍បានចូលរួមចំណែកប្រមាណ ៣២,៧% នៃផលិតផល

---

[18] កោះសិន្តភាព. (២០២០) .កូវីដ-១៩ បញ្ឈប់ភាពរីកចម្រើនខ្លាំងរបស់កម្ពុជាក្នុងរយៈពេលពីទសវត្សរ៍

[19] OpenDevelopment Cambodia. (2020, June 3). Small and medium enterprises (SME). Retrieved from: https://opendevelopmentcambodia.net/topics/small-and-medium-enterprises-sme/#return-note-136409-14

[20] Asean Today. (2020). COVID-19 lessons for Cambodia: Boosting resilience and economic recovery. Retrieved on April 20th, 2020 from https://www.aseantoday.com/2020/04/covid-19-lessons-for-cambodia-boosting-resilience-and-economic-recovery/.

[21] H. Plecher. (2020, Nov 18). Cambodia: Share of economic sectors in the gross domestic product (GDP) from 2009 to 2019.

ក្នុងស្រុកសរុប និងមានការកើនឡើងពី១៤,៩% នៅក្នុងឆ្នាំ២០០០ ដល់៣២,៧% ក្នុងឆ្នាំ២០១៩។ តាមរយៈអត្រាកំណើននេះបើតាមគេហទំព័រដដែលបានបង្ហាញថាវិស័យទេសចរណ៍របស់កម្ពុជាមានអត្រាកំណើនប្រចាំឆ្នាំប្រមាណ ៤,៦៧% និងបានក្លាយទៅជាវិស័យចម្បងជាងគេក្នុងការទ្រទ្រង់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។[22]

ក្រាហ្វិកទី៦ ៖ អត្រាកំណើននៃផលិតផលសរុបក្នុងស្រុកមុន និងក្រោយវិបត្តិកូវីដ-១៩




ប្រភព៖ ធនាគារអភិវឌ្ឍអាស៊ី

## ២.២. ឥទ្ធិពលកូវីដ-១៩ នៅលើការងារ និងប្រាក់ចំណូលនៅកម្ពុជា

នៅក្នុងប្រទេសកម្ពុជាផលប៉ះពាល់នៃជំងឺរាតត្បាត គឺមានសារៈសំខាន់បំផុតលើសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជនជាចម្បងតាមរយៈការផ្លាស់ប្តូរគំរូការងារ និងការកាត់បន្ថយប្រាក់ចំណូល។ នេះប៉ះពាល់ជាងពាក់កណ្តាលនៃគ្រួសារ។ មានសញ្ញានៃការងើបឡើងវិញនៅក្នុងខែធ្នូ ឆ្នាំ២០២០និង ខែមករាឆ្នាំ ២០២១ ប៉ុន្តែវាបានផ្លាស់ប្តូរនៅក្នុងខែបន្ទាប់ បន្ទាប់ពីការផ្ទុះឡើងនៃសហគមន៍ ២០ ខែកុម្ភៈ ។ ការកាត់បន្ថយប្រាក់ឈ្នួល និងការបាត់បង់ការងារ គឺជាមូលហេតុចម្បងនៃការផ្លាស់ប្តូរប្រាក់ចំណូលនិងការងារ។ មនុស្សភាគច្រើនយល់ថាការបាត់បង់ការងាររបស់ពួកគេ ក៏ដូចជាការកាត់បន្ថយប្រាក់ឈ្នួលរបស់ពួកគេ គឺជាបណ្តោះអាសន្ននិងជាការឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃ COVID-19 លើការរឹតបន្តឹងអាជីវកម្មហើយដូច្នេះរំពឹងថា នឹងចាប់ផ្តើមធ្វើការ

[22] Knoema.com. (nd). Cambodia - Contribution of travel and tourism to GDP as a share of GDP
Sovannou Pich. (2019, 29 May). Tourism's Contribution to the GDP. Retrieved from: https://cambodianeconomy.org/topic/latest-post/tourism/1021/

ម្តងទៀតនៅពេលដែលស្ថានភាពអនុញ្ញាត។ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃ COVID-19 លើគ្រួសារនិងការលើកទឹកចិត្តឱ្យមានការកាត់បន្ថយអវិជ្ជមានយុទ្ធសាស្ត្រទប់ទល់រដ្ឋាភិបាល បានបញ្ចេញការផ្ទេរប្រាក់តាមសង្គម សាច់ប្រាក់អោយច្រើនបំផុតគ្រួសារដែលរងផលប៉ះពាល់ខ្លាំងដោយកូវីដ-១៩។

**២.២.១. ផលប៉ះពាល់លើការងារ**

វិស័យការងារដែលងាយរងគ្រោះបំផុតចំពោះការបាត់បង់ការងារ គឺកសិកម្ម និងបសុសត្វ (២៤ ភាគរយ និង ៣៦ ភាគរយ) បន្ទាប់មកអ្នកឆ្លើយសំណួរដែលវិស័យការងារគ្មានការងារធ្វើនៅពេលសម្ភាសន៍ (១៧ ភាគរយទៅ២០ ភាគរយ) ។ ដើម្បីយល់ពីសេចក្តីថ្លែងការណ៍ចុងក្រោយនេះចាំបាច់ត្រូវផ្តល់ការបំភ្លឺអំពីរចនាសម្ព័ន្ធទីផ្សារការងារនៅក្នុងប្រទេសកម្ពុជាគ្រួសារជាច្រើននៅក្នុងប្រទេសកម្ពុជា មានការងារច្រើនដំណើរការអាជីវកម្មច្រើនឬ កំពុងធ្វើការក្រៅផ្លូវការ។ លក្ខខណ្ឌទាំងនេះដែលបានបង្កើតបញ្ហាប្រឈមក្នុងការកំណត់ស្ថានភាពការងាររបស់បុគ្គលម្នាក់ៗដោយសារវិស័យ ឬស្ថានភាពនៃមុខរបរចម្បងអាចខុសពីលក្ខខ័ណ្ឌបន្ទាប់បន្សំ ឬលក្ខណៈនៃការងារ។ ដូច្នេះអ្នកឆ្លើយសំណួរប្រហែលជាបានចុះឈ្មោះចម្លើយខុសៗគ្នាទៅតាមពេលវេលានៃការសម្ភាសន៍ និងការងារយោង។

នៅក្នុងខែមីនាឆ្នាំ២០២១ មានការកើនឡើងយ៉ាងឆាប់រហ័សក្នុងចំណោមអ្នកឆ្លើយសំណួរដែលធ្វើការដោយខ្លួនឯងដែលបានប្រកាសថាបាត់បង់ការងារ។ នេះលើសពីវិស័យផ្សេងទៀតទាំងអស់ហើយឈានដល់ ៣១ ភាគរយ។ ផ្ទុយទៅវិញអ្នកដែលធន់ នឹងការបាត់បង់ការងារបំផុតគឺ បុគ្គលិកជាប់កិច្ចសន្យា។

ក្រាហ្វិកទី៧ ៖ វិស័យការងាររបស់អ្នកឆ្លើយតបដែលបាត់បង់ការងារ




ប្រភពទិន្នន័យ៖ COVID-19 SOCIO-ECONOMIC IMPACT ASSESSEMT

### ២.២.២. ផលប៉ះពាល់លើប្រាក់ចំណូល

យ៉ាងហោចណាស់ ៦៣% នៃគ្រួសារបានជួបប្រទះការបាត់បង់ប្រាក់ចំណូល ។ តួលេខនេះគឺ ៧៥% ភាគរយនៅក្នុងខែសីហា ហើយវាបានឈានដល់កម្រិតខ្ពស់បំផុត ៨០%នៅក្នុងខែតុលា ឆ្នាំ២០២០ ។ នេះស្របពេលជាមួយនឹងទឹកជំនន់ភ្លាមៗ ដែលប៉ះពាល់ដល់ខេត្តជាច្រើនក្នុងប្រទេស។ លើសពីនេះទៅទៀត ៦០% នៃគ្រួសារដែលរងផលប៉ះពាល់ដោយការកាត់បន្ថយប្រាក់ចំណូលនៅក្នុងខែតុលាបានរាយការណ៍ថាបានបាត់បង់ប្រាក់ចំណូលរបស់ពួកគេ៥០% ឬច្រើនជាងនេះដូចដែលបានបង្ហាញក្នុងរូបភាព។ ខាងក្រោមបានបង្ហាញពីនិន្នាការប្រសើរឡើងទាំងផ្នែកភាគរយនៃគ្រួសារដែលរងផលប៉ះពាល់ដោយការបាត់បង់ប្រាក់ចំណូលក៏ដូចជាទំហំនៃការបាត់បង់ផងដែរ។ នៅក្នុងខែកុម្ភៈ ឆ្នាំ ២០២១ ភាគរយនេះបានថយចុះមកត្រឹម ៦៣% ជារួមហើយ ៤២% នៃអ្នកទាំងនោះបានជួបប្រទះនឹងការថយចុះនៃប្រាក់ចំណូលរបស់ពួកគេ ៥០% ឬច្រើនជាងនេះ។ នៅខែមីនា ឆ្នាំ២០២០ មានការកើនឡើងមួយទៀតនៃសមាមាត្រនៃគ្រួសារដែលជួបប្រទះការបាត់បង់ប្រាក់ចំណូល ដែលអាចត្រូវបានកំណត់គុណលក្ខណៈដោយព្រឹត្តិការណ៍ COVID-19 ចាប់ពីចុងខែកុម្ភៈ។

ក្រាហ្វិកទី៨ ៖ ទំហំនៃការផ្លាស់ប្តូរប្រាក់ចំណូលគ្រួសារ




ប្រភពទិន្នន័យ៖ COVID-19 SOCIO-ECONOMIC IMPACT ASSESSEMT

ជំងឺរាតត្បាតបានវាយប្រហារទាំងទីក្រុង និងជនបទដោយមិនមានភាពខុសគ្នារវាងស្ថិតិទាំងពីរក្នុង។ មានតែនៅក្នុងខែកុម្ភៈប៉ុណ្ណោះ ដែលផលប៉ះពាល់ហាក់ដូចជាកាន់តែខ្លាំងលើគ្រួសារនៅជនបទដោយ ១២ ភាគរយ។ សមាមាត្រនៃគ្រួសារដែលរាយការណ៍ពីការបាត់បង់ប្រាក់ចំណូល គឺខ្ពស់ជាងក្នុងចំណោមអ្នកឆ្លើយសំណួរជាស្ត្រី។ គ្រួសារ ID Poor 2 បានឃើញកម្រិតនៃការថយចុះប្រាក់ចំណូលខ្ពស់ជាងបន្តិចបើប្រៀបធៀបទៅនឹងគ្រួសារ ID Poor 1 និងគ្រួសារដែលមិនមែនជា ID Poor ។

ក្រាហ្វិកទី៩ ៖ សមាមាត្រនៃការបាត់បង់ប្រាក់ចំណូលស្មើនឹង ឬធំជាង ៥០ភាគរយក្នុងចំណោមអ្នកឆ្លើយតបតាមទីតាំងយេនឌ័រ និង ID Poor




ប្រភពទិន្នន័យ៖ COVID-19 SOCIO-ECONOMIC IMPACT ASSESSEMT

### ២.២.៣. យុទ្ធសាស្ត្រទប់ទល់ទូទៅ

ដើម្បីទប់ទល់នឹងការថយចុះនៃប្រាក់ចំណូលយ៉ាងសំខាន់បែបនេះ គ្រួសារបានអនុម័តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រទប់ទល់រវាងខែសីហា ឆ្នាំ២០២០ ដល់ខែមីនា ឆ្នាំ២០២១ ។ ក្នុងខែសីហា ឆ្នាំ២០២០ គ្រួសារ ១៩% បានលក់ទំនិញ ឬទ្រព្យសម្បត្តិហើយ ៣០% បានខ្ចីប្រាក់។ កម្រិតកំពូលនៃការអនុម័តយុទ្ធសាស្ត្រដោះស្រាយទាំងពីរនេះត្រូវបានគេសង្កេតឃើញនៅចន្លោះខែសីហា និងខែធ្នូ ឆ្នាំ២០២០ (ក្នុងរូបភាព )។ គ្រួសារតិចជាងមុន (១៤ភាគរយបានប្រើយុទ្ធសាស្ត្រដំបូងក្នុងកំឡុងខែមីនាឆ្នាំ២០២១ )ដូចដែលអាចរំពឹងទុកជាមួយនឹងទ្រព្យសកម្មមានកម្រិត និងការថយចុះសក្តានុពលរបស់ពួកគេ។ គ្រួសារ ID Poor ជាពិសេស ID Poor 2 ទំនងជាខ្ចីលុយខណៈដែលគ្រួសារដែលមិនមែនជា ID Poor ទំនងជាលក់ទ្រព្យសកម្មភាពខុសប្លែកគ្នានៅក្នុងយុទ្ធសាស្ត្រត្រូវបានគេសង្កេតឃើញក្នុងចំណោមគ្រួសារមកពីតំបន់ផ្សេងៗគ្នា គ្រួសារនៅជនបទទំនងជានឹងខ្ចីប្រាក់ខណៈដែលគ្រួសារនៅទីក្រុងទំនងជាលក់ទំនិញឬទ្រព្យសម្បត្តិ ដើម្បីទប់ទល់នឹងផលប៉ះពាល់អវិជ្ជមាននៃ COVID-19 លើស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេចាប់ពីខែតុលាដល់ខែកុម្ភៈគេសង្កេតឃើញថាគ្រួសារដែលដឹកនាំដោយស្ត្រីមាន ១០ទៅ១២ភាគរយ ទំនងជាទទួលបានប្រាក់កម្ចីច្រើនជាងគ្រួសារដែលដឹកនាំដោយបុរស។[23]

ក្រាហ្វិកទី១០ ៖ សមាមាត្រនៃគ្រួសារដែលចូលរួមក្នុងយុទ្ធសាស្ត្រដោះស្រាយទូទៅ




[23] Covid-19 Socio-Economic Impact Assessment https://www.unicef.org/cambodia/reports/covid-19-socio-economic-impact-assessment

ប្រភពទិន្នន័យ៖ COVID-19 SOCIO-ECONOMIC IMPACT ASSESSEMT

## ២.៣. ផលប៉ះពាល់លើវិស័យទេសចរណ៍

### ២.៣.១. ផលប៉ះពាល់លើវិស័យទេសចរណ៍

ទេសចរណ៍ គឺជាវិស័យដ៏សំខាន់មួយដែលចូលរួមក្នុងកម្លាំងចលករសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែដោយសារតែទទួលរងនូវការវាយប្រហារខ្លាំងពីការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆមាសទី១ នៃឆ្នាំ ២០២០ នេះធ្វើឱ្យវិស័យមួយនេះមានការធ្លាក់ចុះយ៉ាងខ្លាំង។ ដោយមានការប្រកាសបិទនូវការធ្វើដំណើរឆ្លងប្រទេសកាលពីដើមឆ្នាំ២០២០ នេះបូកផ្សំជាមួយនឹងតម្រូវជាក់ស្តែងនៃគម្លាតសង្គមជាដើមបានធ្វើឱ្យសកម្មភាពទេសចរណ៍កម្ពុជាជួបប្រទះនូវភាពអសកម្មយ៉ាងគំហុគ។ បើទោះបីជាមានភ្ញៀវទេសចរណ៍ចាប់ផ្តើមចូលមកកម្ពុជាវិញខ្លះៗ ក្នុងអំឡុងខែ កក្កដា២០២០ ក្តីប៉ុន្តែបើធៀបនឹងរយៈពេលដូចគ្នាកាលពី ឆ្នាំ២០១៩ ភ្ញៀវទេសចរណ៍អន្តរជាតិមានការថយចុះប្រមាណ ៩៥,៩% ។[24] ការធ្លាក់ចុះនៃអ្នកទេសចរណ៍ទាំងជាតិ និងអន្តរជាតិមិនត្រឹមតែបានធ្វើឱ្យអាជីវកម្មគ្រប់ប្រភេទទាំងតូចទាំងធំទទួលរងនូវផលប៉ះពាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាទាំងមូលយ៉ាងធ្ងន់ធ្ងរផងដែរ។ ក្នុងមួយឆ្នាំៗ វិស័យទេសចរណ៍កម្ពុជាអាចរកចំណូលបានយ៉ាងហោចណាស់ក្នុងរង្វង់ពី ៥-៦ ពាន់លានដុល្លារអាមេរិកដែលទទួលបានពីភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។ ក្នុងឆ្នាំ២០២០ នេះដោយសាររងឥទ្ធិពលនៃជំងឺកូវីដ-១៩ ភ្ញៀវទេសចរណ៍អន្តរជាតិបានបាត់បង់ស្ទើរតែទាំងស្រុងដែលធ្វើឱ្យកម្ពុជាអាចបាត់បង់ឱកាសរកប្រមាណ ៣ពាន់លានដុល្លារអាមេរិក ។[25] ចំណែកតាមសារព័ត៌មានហ្វេសញូវិញបានបង្ហាញថាការបាត់បង់ចំណូលពីវិស័យទេសចរណ៍នៅក្នុងឆ្នាំ២០២០ នឹងឈានដល់៥ពាន់លានដុល្លារ។[26] ដូចដែលយើងបានដឹងហើយថាសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកខ្លាំងទៅលើវិស័យទេសចរណ៍ដូចនេះវិបត្តិកូវីដ-១៩ នេះបានធ្វើឱ្យប៉ះពាល់លើវិស័យមួយនេះខ្លាំងជាងវិស័យណាៗទាំងអស់។ តាមទិន្នន័យរបស់ក្រសួងទេសចរណ៍មុនការកើតឡើងនៃវិបត្តិកូវីដ-១៩ភ្ញៀវទេសចរណ៍អន្តរជាតិដែលចូលមកទស្សនាប្រទេសកម្ពុជាតាមគ្រប់រូបភាពមានការកើនឡើងគួរឱ្យកត់សម្គាល់ ។

ក្រាហ្វិកទី១១ ៖ ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិចូលមកទស្សនាកម្ពុជា

[24]Focus Economics. (2020, November 17). Cambodia Economic Outlook.

[25] CPC-News. ( ថ្ងៃទី 6 ខែ November ឆ្នាំ 2020) វិស័យទេសចរណ៍ឆ្នាំ ២០២០ កម្ពុជាខាតចំណូល ៣ពាន់លានដុល្លារ ស្របពេលអាជីវកម្មទេសចរណ៍ត្រូវបិទទ្វាជិត ៣ពាន់ទីតាំង ប៉ះពាល់បុគ្គលិកជិត ៥ម៉ឺននាក់

[26] Fresh News. (2020, September 3rd) គិតត្រឹមខែសីហានេះ វិស័យទេសចរណ៍កម្ពុជា បាត់ចំណូលប្រមាណ៥ពាន់លានដុល្លារ




ប្រភពទិន្នន័យ៖ ក្រសួងទេសចរណ៍មុនការកើតឡើងនៃវិបត្តិកូវីដភ្ញៀវទេសចរណ៍អន្តរជាតិដែលចូលមកទស្សនាប្រទេសកម្ពុជា

តាមទិន្នន័យខាងលើយើងសង្កេតឃើញថាភ្ញៀវទេសចរណ៍អន្តរជាតិដែលចូលមកទស្សនាប្រទេសកម្ពុជាមាន ប្រមាណ ៥៧៩៩៤២៧នាក់ ក្នុងឆ្នាំ២០១៥ និងបន្តកើតឡើងរហូតដល់ ៨ ៣៣៩ ៧៣២ នាក់ក្នុងឆ្នាំ២០១៩ កន្លងទៅ ។

ក្រាហ្វិកទី១២ ៖ អត្រាកំណើនភ្ញៀវទេសចរណ៍អន្តរជាតិ



ប្រភពទិន្នន័យៈ ក្រសួងទេសចរណ៍មុនការកើតឡើងនៃវិបត្តិកូវីដភ្ញៀវទេសចរណ៍អន្តរជាតិដែលចូលមកទស្សនាប្រទេសកម្ពុជា

ក្រោយពីមានការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ចំនួនភ្ញៀវទេសចរណ៍អន្តរជាតិដែលធ្វើដំណើរមកទស្សនាប្រទេសកម្ពុជាមានការថយចុះយ៉ាងគំហុគ។ បើតាមតួលេខរបស់ក្រសួងទេសចរណ៍បានបង្ហាញថាចំនួនភ្ញៀវទេសចរណ៍អន្តរជាតិដែលចូលមកទស្សនាប្រទេសកម្ពុជារយៈពេល៩ខែដើមឆ្នាំ២០២០នេះ មានប្រមាណ១ ២៤៧ ៦៨០នាក់ ថយចុះ៧១,៤% ធៀបនឹងរយៈពេលដូចគ្នាកាលពី ឆ្នាំ២០១៩កន្លងទៅ។ ជាមួយគ្នានឹងការថយចុះនៃភ្ញៀវទេសចរណ៍អន្តរជាតិក្នុងរយៈពេលនេះដូចគ្នាកម្ពុជាទទួលបានទេសចរណ៍ក្នុងស្រុកតែប្រមាណ ៥៥៦២ ៥៣១នាក់ប៉ុណ្ណោះ ដែលតួលេខនេះបញ្ជាក់ពីការថយចុះប្រហែល ៣៨,២% ។

ដោយឡែកប្រសិនបើយើងពិនិត្យទៅលើចំនួនភ្ញៀវទេសចរណ៍ចំពោះជាតិសាសន៍សំខាន់ៗ ក្នុងរយៈពេល៩ខែតាមជាតិសាសន៍នីមួយៗ វិញយើងសង្កេតឃើញថាបើគិតជាភាគរយភ្ញៀវជនជាតិឡាវមានការថយចុះច្រើនជាងគេ។ ទិន្នន័យជាក់ស្តែងមានដូចតារាងខាងក្រោម៖

| តារាង ទី១៖ ទីផ្សារទេសចរណ៍សំខាន់ៗទាំង១០ របស់កម្ពុជា | | |
|---|---|---|
| ជាតិសាសន៍ | ចំនួនភ្ញៀវ | អត្រាប្រែប្រួលធៀបនិងពេលដូចគ្នា |
| ចិន | ៣០២ ៨២៦ នាក់ | ស្មើនិង២៤,៣% នៃចំនួនសរុប ថយចុះ៨៣,៨% |
| ថៃ | ១៨៩ ៤៤២ នាក់ | ស្មើនិង១៥,២% នៃចំនួនសរុប ថយចុះ៣៤,២% |
| វៀតណាម | ១៨០ ៧៦១ នាក់ | ស្មើនិង១៤,៥% នៃចំនួនសរុប ថយចុះ៧១,៦% |
| អាមេរិក | ៥៤ ៦៦៦ នាក់ | ស្មើនិង៤,៤% នៃចំនួនសរុប ថយចុះ៦៩,២% |
| កូរ៉េ | ៥៤ ៤១៤ នាក់ | ស្មើនិង៤,៤% នៃចំនួនសរុប ថយចុះ៧០,៩% |
| អង់គ្លេស | ៤៤ ៥៧៩ នាក់ | ស្មើនិង៣,៦% នៃចំនួនសរុប ថយចុះ៥៩,៥% |
| បារាំង | ៤២ ៥៨១ នាក់ | ស្មើនិង៣,៤% នៃចំនួនសរុប ថយចុះ៦២,៥% |
| ជប៉ុន | ៤០ ៦១៩ នាក់ | ស្មើនិង៣,៣% នៃចំនួនសរុប ថយចុះ៧២,៨% |
| ឡាវ | ៣៤ ៣១៣ នាក់ | ស្មើនិង២,៨% នៃចំនួនសរុប ថយចុះ៨២,២% |
| អាឡឺម៉ង់ | ២៧ ១៤០ នាក់ | ស្មើនិង២,២% នៃចំនួនសរុប ថយចុះ៥៣,៨% |
| ប្រភព៖ ក្រសួងទេសចរណ៍ | | |

ក្នុងដំណាក់កាលវិបត្តិកូវីដ-១៩ ចាប់ពីខែមេសាដល់ខែកញ្ញានិន្នាការទេសចរណ៍មានការប្រែប្រួលយ៉ាងខ្លាំងជាក់ស្តែងទេសចរណ៍សម្រាកលំហែកម្សាន្តមាន ៤៣,៤% ទេសចរណ៍បែបធុរកិច្ចនិងការទូត មាន ៥៤,៤% និងក្នុងគោលបំណងផ្សេងៗទៀតប្រមាណ ២,៣%។ កាលពីឆ្នាំ២០១៩ កន្លងទៅទេសចរណ៍សម្រាកលំហែកម្សាន្តមានរហូតដល់ ៧៦,២% ទេសចរណ៍បែបធុរកិច្ចនិងការទូតមាន២០,៧% និងប្រភេទផ្សេងទៀតប្រមាណ ៣,១%។

ជាមួយគ្នានេះទិន្នន័យដែលបញ្ចេញដោយគ្រឹះស្ថានអង្គរបានបង្ហាញថា ក្នុងរយៈពេល១១ខែនៃឆ្នាំ ២០២០ នេះចំនួនភ្ញៀវទេសចរណ៍អន្តរជាតិដែលបានទិញប័ណ្ណចូលទស្សនារមណីយដ្ឋាននានា ក្នុងតំបន់អង្គរមានចំនួនសរុប ៣៩៩,៧២០នាក់ ដែលចំនួននេះថយចុះជិត៨០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៩។ ដូចគ្នាដែរចំណូលដែលទទួលបានពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរមានចំនួន ១៨,៦០២,២៨៥ដុល្លារដោយមានការថយចុះជាង ៧៩,២៣% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៩ កន្លងទៅ។ ម្យ៉ាងទៀតយើងសង្កេតឃើញថាពេញមួយខែវិច្ឆិកា នេះកម្ពុជាទទួលបានភ្ញៀវទេសចរណ៍អន្តរជាតិដែលបានទិញប័ណ្ណចូលទស្សនារមណីយដ្ឋាននានាក្នុងតំបន់អង្គរមានតែចំនួន១២៣៥នាក់ ប៉ុណ្ណោះដែលតួលេខដ៏ទាបបំផុតមួយក្នុងឆ្នាំ២០២០ នេះ។ ភ្ញៀវទេសចរណ៍អន្តរជាតិដែលនៅបន្តដំណើរកម្សាន្តក្នុងការប្តូរ និងខេត្តសៀមរាបទាំងមូលភាគច្រើន គឺជាភ្ញៀវស្នាក់នៅក្នុងស្រុកភ្ញៀវដែលចូលមកក្នុងគោលបំណងធុរកិច្ចដែលស្នាក់នៅរយៈពេលយូរ ឬភ្ញៀវដែលជាប់គាំងដោយសារតែការផ្អាកជើងហោះហើរឆ្លងប្រទេសជាដើម។

តារាងទី២ ៖ ចំនួនភ្ញៀវទេសចរណ៍ទិញប័ណ្ណ

| ទេសចរណ៍ទិញប័ណ្ណ | | ចំណូល ( គិតជាដុល្លា ) | |
|---|---|---|---|
| ចំនួនភ្ញៀវ | ប្រៀបធៀបខែវិច្ឆកា ២០១៩ | ចំណូល | ប្រៀបធៀបខែវិច្ឆកា ២០១៩ |
| ១ ២៣៥ | -៩៩,៣៦% | ៥២ ៣៨០ | -៩៩,៤១% |
| | | | |
| ចំនួនភ្ញៀវសរុប | ប្រៀបធៀបពេលដូចគ្នា ២០១៩ | ចំណូល | ប្រៀបធៀបពេលដូចគ្នា ២០១៩ |
| ៣៩៩ ៧២០ | -៧៩,៩៩% | ១៨ ៦០២ ២៨៥ | -៧៩,៣២៣% |

ប្រភពទិន្នន័យ៖ របាយការណ៍របស់គ្រឹះស្ថានអង្គរ





រូបភាពទី១-២ ៖ ទិដ្ឋភាពផ្សាររាត្រីអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩

ក្រៅពីខេត្តសៀមរាបដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំភ្ញៀវទេសចរណ៍អន្តរជាតិធំជាងគេរបស់កម្ពុជាតំបន់ប៉ូលទេសចរណ៍ដទៃទៀតក៏ទទួលរងនូវផលប៉ះពាល់ដូចគ្នា គ្រាន់តែទំហំនៃការប៉ះពាល់អាស្រ័យលើស្ថានភាពជាក់ស្តែងនៃសក្តានុពលវិស័យដែលជំរុញសេដ្ឋកិច្ចនៃតំបន់នីមួយៗ។ ខេត្តព្រះសីហនុជាខេត្តដែលទទួលរងផលប៉ះពាល់លើវិស័យទេសចរណ៍ដែលបណ្តាលមកពីជំងឺកូវីដ-១៩ខ្លាំង បន្ទាប់ពីខេត្តសៀមរាបដោយសារតែវិស័យទេសចរណ៍នៅក្នុងខេត្តនេះបានដើរតួយ៉ាងសំខាន់ផងដែរលើចរន្តសេដ្ឋកិច្ចរបស់ខេត្តទាំងមូល។តាមរយៈការជួបសម្ភាសដោយផ្ទាល់ជាមួយនឹងប្រធានមន្ទីរទេសចរណ៍ ក៏ដូចជាក្រុមគោលដៅដទៃទៀតក្នុងខេត្តនេះបានធ្វើការកត់សម្គាល់ថា ជារួមភ្ញៀវទេសចរណ៍អន្តរជាតិដែលចូលមកខេត្តព្រះសីហនុក្នុងគោលបំណងទេសចរណ៍មានការធ្លាក់ចុះសឹងតែដល់សូន្យភាគរយដោយចំនួន ដែលនៅសេសសល់ច្រើនតែជាភ្ញៀវជនជាតិចិន និងចូលមកក្នុងគោលបំណងផ្សេងក្រៅពីទេសចរណ៍ដូចជាធ្វើការសំណង់ជាដើម។ ដោយឡែកប្រធានមន្ទីរទេសចរណ៍ខេត្តបានបញ្ជាក់បន្ថែមថាចំនួនភ្ញៀវទេសចរណ៍ជនជាតិចិនបានចាប់ផ្តើមធ្លាក់ចុះមុនការរីករាលដាលនៃជំងឺកូវីដ-១៩ទៅទៀត គឺចាប់ពីការបិទនូវល្បែងអនឡាញក្នុងអំឡុងខែសីហា ឆ្នាំ២០១៩ មកម្ល៉េះ។ ជាមួយនឹងផលប៉ះពាល់លើវិស័យទេសចរណ៍នេះ ខេត្តរតនគិរីក៏ទទួលរងនូវផលប៉ះពាល់ខ្លាំងជាពិសេសចំនួនភ្ញៀវទេសចរណ៍អន្តរជាតិ។ លោក **ង៉ែត វិទូ** ប្រធានមន្ទីរទេសចរណ៍ខេត្តរតនៈគិរី បានឱ្យដឹងថាវិស័យទេសចរណ៍ក្នុងខេត្តនេះមានការថយចុះច្រើនទាំងភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ។ ដោយឡែកភ្ញៀវទេសចរអន្តរជាតិការធ្លាក់ចុះមានរហូតដល់សូន្យភាគរយក្នុងខែខ្លះ និងភ្ញៀវជាតិមានការថយចុះច្រើនក្នុងអំឡុងពេលនៃការផ្ទុះជំងឺដំបូងដែលរាជរដ្ឋាភិបាលបានរឹតត្បិតការធ្វើដំណើរទាំងឆ្លង ខេត្ត និងឆ្លងប្រទេសមួយរយៈ។ ភ្ញៀវ

ទេសចរណ៍ក្នុងស្រុកចាប់ផ្តើមធ្វើដំណើរមកទស្សនាតាមរម្មណីយដ្ឋាននានាក្នុងខេត្តវិញ ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌ និងការឈប់សងបុណ្យចូលឆ្នាំខ្មែរប៉ុណ្ណោះ។ ក្នុងរូបភាពរួមយើងសង្កេតឃើញថាការធ្លាក់ចុះនៃភ្ញៀវនេះកើតមានច្រើនជាងគេ គឺនៅខេត្តសៀមរាប និងខេត្តព្រះសីហនុ ដោយសារតែខេត្តទាំងពីនេះវិស័យទេសចរណ៍ពឹងផ្អែកខ្លាំងទៅលើភ្ញៀវពីក្នុងប្រទេស។ ដោយឡែកខេត្តផ្សេងទៀតដូចជា ខេត្តបាត់ដំបង កំពត និងកំពង់ចាមជាដើមដែលវិស័យទេសចរណ៍ពឹងផ្អែកច្រើន ទៅលើទេសចរណ៍ក្នុងស្រុកផលប៉ះពាល់នេះមានលក្ខណៈធូរស្រាលជាងនិងមាននិន្នាការប្រសើរឡើងដោយសារភ្ញៀវក្នុងស្រុកចាប់ផ្តើមធ្វើដំណើរទេសចរណ៍ឡើងវិញ។

ជាមួយគ្នានេះ បើតាមរបាយការណ៍បឋមរបស់មន្ទីរទេសចរណ៍រាជធានីខេត្តនានាបានឲ្យដឹងថាភ្ញៀវទេសចរណ៍ដែលបានធ្វើដំណើរកម្សាន្តនៅតាមគោលដៅទេសចរណ៍នានាទូទាំងប្រទេសក្នុងរយៈពេល ៣ថ្ងៃនៃការឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ (១៦-១៨ ខែកញ្ញា ឆ្នាំ២០២០) មានចំនួនប្រមាណ ១,១១២,៤០៣ នាក់។ របាយការណ៍ដដែលបានបញ្ជាក់ថា ក្នុងចំណោមភ្ញៀវទេសចរណ៍ជាង១លាននាក់ដែលបានធ្វើដំណើរកម្សាន្តរួមមានភ្ញៀវជាតិមានចំនួនប្រមាណ ១,១០៥ ,៦១១ នាក់ និងភ្ញៀវអន្តរជាតិមានប្រមាណ ៦,៧៩២ នាក់។[27] ខេត្តដែលទទួលបានភ្ញៀវទេសចរណ៍ច្រើនរួមមាន៖

តារាងទី ៣៖ ភ្ញៀវទេសចរណ៍ដែលធ្វើដំណើរកំសាន្តក្នុងអំឡុងបុណ្យភ្ជុំបិណ្យឆ្នាំ២០២០

| ខេត្ត | ចំនួនភ្ញៀវ | ខេត្ត | ចំនួនភ្ញៀវ |
|---|---|---|---|
| ខេត្តបាត់ដំបង | ១៣៤ ៤៤០ នាក់ | ខេត្តពោធិ៍សាត់ | ៧២ ៣៨៩ នាក់ |
| ខេត្តសៀមរាប | ១២២ ៣៧០ នាក់ | ខេត្តព្រះសីហនុ | ៦៥ ៨២៥ នាក់ |
| ខេត្តកំពត | ៩៤ ៤៧៩ នាក់ | ខេត្តកែប | ៦៨ ០៥៤ នាក់ |
| ខេត្តកំពង់ឆ្នាំង | ៨៥ ៥៩៨ នាក់ | ខេត្តកណ្តាល | ៦២ ៧៤១ នាក់ |

ប្រភពទិន្នន័យ៖ រាជបណ្ឌិត្យសភាកម្ពុជា ក្នុងសៀវភៅផលប៉ះពាល់នៃវិបត្តកូវិដ ១៩

ដោយឡែកក្នុងអំឡុងពេលថ្ងៃឈប់សម្រាកពិធីបុណ្យអុំទូក រយៈពេល៤ថ្ងៃកាលពីចុងខែតុលា និងដើមខែវិច្ឆិកាកន្លងទៅចំនួនភ្ញៀវទេសចដែលបានធ្វើដំណើរកម្សាន្តទូទាំងប្រទេសកម្ពុជាមានប្រមាណជាង៦៤

[27] (២០២០ ១៩ កញ្ញា) ៣ថ្ងៃនៃបុណ្យភ្ជុំបិណ្ឌមានភ្ញៀវទេសចរណ៍ដើរកម្សាន្តជាង ១លាននាក់. ដកស្រង់ចេញពីគេហទំព័រ:https://vayofm.com/news/detail/104628-446316336.html

ម៉ឺននាក់ ដោយក្នុងនោះខេត្តសៀមរាបទទួលបានភ្ញៀវទេសចរច្រើនជាងគេរហូតដល់១៦ម៉ឺននាក់។[28] យើងសង្កេតឃើញថាទេសចរណ៍ក្នុងស្រុកប្រមាណ ៣-៤ ខែចុងក្រោយហាក់មានសកម្មភាពឡើងវិញខ្លះៗ ដែលធ្វើឱ្យស្ថានភាពទេសចរណ៍ក្នុងខេត្តមួយចំនួនទទួលបានភាពប្រសើរបន្តិចម្តងៗ ប៉ុន្តែបានធ្លាក់ចុះបន្តិចទៅវិញដោយសារតែព្រឹត្តិការណ៍កូវីដ-១៩ ចំនួនពីរដែលរាជរដ្ឋាភិបាលបានដាក់ឈ្មោះថាព្រឹត្តិការណ៍៣វិច្ឆិកា និងព្រឹត្តិការណ៍ ២៨វិច្ឆិកា ដែលទើបនឹងកើតឡើងនាពេលថ្មីៗនេះ។[29]

### ២.៣.២. បញ្ហាប្រឈមក្នុងវិស័យទេសចរណ៍

បើតាមការឱ្យដឹងរបស់ក្រុមគោលដៅមួយចំនួនដែលជាមគ្គុទេសក៍ទេសចរណ៍ក៏ដូចជា អ្នកប្រកបការងារនិងអាជីវកម្មនានា នៅក្នុងវិស័យទេសចរណ៍ក្រុមការងារគម្រោងបានធ្វើការសន្និដ្ឋានថាមុនពេលមានការផ្ទុះឡើងនៃជំងឺកូវីដ-១៩ វិស័យទេសចរណ៍នៅកម្ពុជាបានចាប់ផ្តើមមានការប៉ះទង្គិចបន្តិចបន្តួចរួចហើយជាពិសេសការថយចុះនៃភ្ញៀវជនជាតិចិន។ ការប៉ះពាល់នេះដោយសារតែបញ្ហាប្រឈមមួយចំនួនទាក់ទង នឹងសេវាទេសចរណ៍ Zero Package និងការបាត់បង់ទំនុកចិត្តពីសំណាក់ភ្ញៀវដោយសារការចរាចរនៃវត្ថុអនុស្សាវរីយ៍ក្លែងក្លាយលើទីផ្សារ ឬទំនិញដែលមានតម្លៃខ្ពស់ជាងធម្មតាជាដើម។ ដោយឡែករដ្ឋមន្ត្រីក្រសួងទេសចរណ៍ក៏បានគាំទ្រដែរថា **"សេវាទេសចរណ៍ Zero Package Tour"** ពិតជាបានចូលរួមក្នុងការធ្វើឱ្យប៉ះពាល់ដល់វិស័យទេសចរណ៍របស់កម្ពុជាក៏ដូចជាបំផ្លាញកេរ្តិ៍ឈ្មោះកម្ពុជាក្នុងវិស័យនេះផងដែរ។[30] លទ្ធផលនៃការសិក្សានេះបង្ហាញថាក្នុងបរិបទទូទៅនៅវិស័យទេសចរណ៍កម្ពុជាកំពុងជួបប្រទះនូវបញ្ហាប្រឈមចម្បងៗ មួយចំនួនដែលបញ្ហាទាំងនេះក៏បានចូលរួមមួយចំណែកផងដែរ ក្នុងការបង្អាក់នូវការរីកចម្រើននៃវិស័យទេសចរណ៍ជាតិ។ គេអាចធ្វើការកំណត់នូវបញ្ហាប្រឈមដែលកើតមានក្នុងវិស័យទេសចរណ៍កម្ពុជាដូចខាងក្រោម៖

#### ២.៣.២.១. ខ្វះគោលដៅទេសចរណ៍

កម្ពុជាជាប្រទេសមួយស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលសម្បូរទៅដោយសម្បត្តិធម្មជាតិប្រាសាទបុរាណព្រមទាំងធនធានផ្សេងៗ ទៀតដែលបម្រើឱ្យវិស័យទេសចរណ៍ជាតិ។ទោះជាយ៉ាងណាតាមរយៈការសម្ភាសក្រុមគោលដៅដែលធ្វើការនិងប្រកបអាជីវកម្មក្នុងវិស័យទេសចរណ៍នេះយើងអាចកំណត់បានថា

---

[28] (២០២០, ៣ វិច្ឆកា) អ្នកទេសចរណ៍ជាង៦មឺននាក់ធ្វើដំណើរកំសាន្តនៅថ្ងៃឈប់សម្រាកនៃព្រះរាជពិធីគ្រង់រាជសម្បិត្តនិងបុណ្យអុំទូក. ដកស្រង់ចេញពីគេហទំព័រ៖http://news.pnn.com.kh/news/3454

[29] (២០២០, ៣ វិច្ឆកា). អ្នកទេសចរណ៍ជាង៦៤ នាក់ធ្វើដំណើរកម្សាន្តនៅថ្ងៃឈប់សំរាកនៃព្រះរាជពិធីគ្រងសម្បិត្តនិងបុណ្យអុំទូក

[30] (២០១៩). ក្រសួងទេសចរណ៍ និងចាត់វិធានការក្តៅ ចំពោះប្រតិបត្តិករទេសចរណ៍ "ការរកស៊ីកាប់ភ្ញៀវ"ដោយផ្តល់បែបសេវាបែប Zero Package Tour.

[25] Sheith Khidhir. (2019, 22 July). Made in China: Zero-dollar tourists. https://theaseanpost.com/article/made-china-zero-dollar-tourists

ប្រទេសកម្ពុជាមានកង្វះខាតនូវគោលដៅទេសចរណ៍ដែលមានលក្ខណៈចម្រុះនៅតាមតំបន់ប៉ូលទេសចរណ៍នីមួយៗ។ ជាឧទាហរណ៍៖ ក្នុងខេត្តសៀមរាបយើងសម្បូរទៅដោយប្រាសាទបុរាណ និងរមណីយដ្ឋានទេសចរណ៍បែបធម្មជាតិមួយចំនួនក៏ប៉ុន្តែយើងពុំមានគោលដៅទេសចរណ៍ បែបកែច្នៃធម្មជាតិកែច្នៃជាដើម ដើម្បីបំពេញតម្រូវការរបស់ភ្ញៀវបាននោះទេ។ កង្វះខាតនូវរមណីយដ្ឋានបែបចម្រុះនេះជាពិសេសក្នុងតំបន់ទេសចរណ៍តែមួយធ្វើឱ្យប្រទេសកម្ពុជាពុំមានលទ្ធភាពពេញលេញក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកធ្វើដំណើរកម្សាន្ត ឬស្នាក់នៅក្នុងតំបន់តែមួយនេះបានច្រើនថ្ងៃ ។ តួយ៉ាងសម្រាប់ខេត្តសៀមរាបភ្ញៀវទេសចរណ៍ខ្លះមកលេងត្រឹមមួយថ្ងៃ ឬមួយថ្ងៃកន្លះបន្ទាប់មកគេបន្តដំណើរទៅកម្សាន្តនៅតំបន់ផ្សេង ឬអាចចាកចេញទៅប្រទេសជិតខាងយើងដោយបន្តស្នាក់នៅទីនោះរយៈពេលយូរជាង។ បន្ថែមពីលើកង្វះខាតគោលដៅទេសចរណ៍ថ្មីៗយើងក៏សង្កេតឃើញថាគោលដៅទេសចរណ៍ដែលមានស្រាប់ហើយក៏ពុំមានការរៀបចំឱ្យថ្មីប្លែក ដើម្បីទាក់ទាញភ្ញៀវឱ្យត្រឡប់មកទស្សនាប្រទេសយើងម្តងហើយម្តងទៀតបាននោះដែរ។

**២.៣.២.២.កង្វះមគ្គុទេសចរណ៍**

មគ្គុទេសក៍ទេសចរណ៍ក៏ដូចជាប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍នៅតាមបណ្តាខេត្តគោលដៅទេសចរណ៍ទាំងឡាយបានធ្វើការគូសបញ្ជាក់ថាបញ្ហាកង្វះខាតមគ្គុទេសក៍ទេសចរណ៍ដែលមានគុណភាព គឺជាបញ្ហាធំមួយរបស់ជាតិ ជាពិសេសនៅតំបន់ប៉ូលទេសចរណ៍ប៉ែកឥណ្ឌាន។ បញ្ហាប្រឈមដែលទាក់ទងនឹងមគ្គុទេសក៍ទេសចរណ៍នេះមានដូចខាងក្រោម៖

- កង្វះមគ្គុទ្ទេសក៍ទេសចរណ៍ដែលមានគុណភាពមានចំណេះច្បាស់លាស់ទាក់ទងនឹងវប្បធម៌ តំបន់ភូមិសាស្ត្រ និងប្រវត្តិសាស្ត្ររបស់ខ្លួន។
- កង្វះមគ្គុទេសក៍ទេសចរណ៍ដែលអាចផ្តល់សេវាកម្មដល់ភ្ញៀវដោយភាពកក់ក្តៅ ដែលបញ្ហានេះកើតមានច្រើនជាងគេក្នុងចំណោមមគ្គុទេសក៍ភាសាចិន ។
- មានករណីមគ្គុទេសក៍ធ្វើការកេងប្រវ័ញ្ចភ្ញៀវបរទេសកើតឡើងតាមរយៈ រូបភាពជូនភ្ញៀវទៅទិញវត្ថុអនុស្សាវរីយ៍ក្លែងក្លាយ ឬចូលហាងដែលមានតម្លៃថ្លៃៗជាដើម។

លោក **ង៉ែត ពិទូ** ប្រធានមន្ទីរទេសចរណ៍ខេត្តរតនគីរីក៏បានធ្វើការគូសបញ្ជាក់ផងដែរថា នៅក្នុងខេត្តរបស់គាត់ពុំទាន់មានមគ្គុទេសក៍ទេសចរណ៍ដែលមានកម្រិតចំណេះដឹងបទពិសោធន៍ និងឆ្លងកាត់ការបណ្តុះបណ្តាលតាមបែបស្តង់ដារបច្ចេកទេសនៅឡើយទេ។

រូបភាពទី ៣៖ កិច្ចសម្ភាសលោក ង៉េត ពិទូ ប្រធានមន្ទីទេសចរណ៍ខេត្តរតនៈគិរី



ប្រភពទិន្នន័យ៖ រាជបណ្ឌិត្យសភាកម្ពុជា ក្នុងសៀវភៅផលប៉ះពាល់នៃវិបត្តកូវីដ-១៩

លោកបានបញ្ជាក់បន្ថែមទៀតដោយសារតែតម្រូវការជាក់ស្តែងនៃការកើនឡើងនៃភ្ញៀវទេសចរណ៍អន្តរជាតិមគ្គុទេសក៍ដែលមានស្រាប់ គឺជាប្រជាជនមូលដ្ឋានដែលមានចំណេះដឹងបន្តិចបន្តួចជាពិសេសលើវប្បធម៌អរិយធម៌និងប្រវត្តិទីតាំងភូមិសាស្ត្រនានាជាដើម។ មគ្គុទេសក៍ទាំងនោះពុំបានទទួលការបណ្តុះបណ្តាលច្បាស់លាស់និងពុំបានសិក្សាស៊ីជម្រៅខ្លាំងទៅលើវប្បធម៌ខ្មែរ ឬជនជាតិដើមភាគតិចនៅតាមតំបន់ទេសចរណ៍នានាព្រមទាំងសមត្ថភាពផ្នែកភាសាបរទេសក្នុងការទំនាក់ទំនងជាមួយភ្ញៀវបរទេសក៏នៅមានកម្រិតផងដែរ។

ជាមួយនឹងចំណុចខ្វះខាតទាំងនេះ ក្រុមគោលដៅដែលធ្វើការក្នុងវិស័យទេសចរណ៍តាមក្រុមហ៊ុនប្រតិបត្តិករទេសចរណ៍មួយចំនួន ក៏ដូចជាមគ្គុទេសក៍ទេសចរណ៍ផ្ទាល់បានធ្វើការសង្កត់ធ្ងន់ថា ឬសគល់នៃបញ្ហាទាំងនេះកើតឡើងដោយសារតែកត្តាពីរធំៗគឺ៖

- ទីមួយ៖ កម្មវិធីបណ្តុះបណ្តាលមគ្គុទេសក៍ទេសចរណ៍របស់ក្រសួងពុំមានស្តង់ដារច្បាស់លាស់ដែលខ្លឹមសារមេរៀនមួយចំនួនមានការប្រែប្រួលទៅតាមគ្រូបណ្តុះបណ្តាលជាពិសេសខ្លឹមសារមេរៀនទាក់ទងនឹង ប្រវត្តិសាស្ត្រវប្បធម៌ប្រវត្តិ ឬ រឿងព្រេងទាក់ទងនឹងគោលដៅទេសចរណ៍មួយចំនួន។ ឧទាហរណ៍៖ ខ្លឹមសារប្រវត្តិសាស្ត្រ និងវប្បធម៌ទាក់ទងនឹងតំបន់ទេសចរណ៍មួយចំនួននៅតាមបណ្តាខេត្តនានាមានការបកស្រាយផ្សេងៗគ្នា ទៅតាមគ្រូបណ្តុះបណ្តាលម្នាក់ៗដែលធ្វើឱ្យមគ្គុទេសក៍ទេសចរណ៍ក្នុងជំនាន់ខុសគ្នាអាចបកស្រាយខុសគ្នាខ្លះទៅកាន់ភ្ញៀវផងដែរ។

- ទីពីរៈ ការគ្រប់គ្រងនិងត្រួតពិនិត្យក្រមសីលធម៌ និងការអនុវត្តការងារក្នុងនាមជាមគ្គុទេសក៍ទេសចរណ៍មានការធូររលុងច្រើនទាំងពីសំណាក់ក្រុមហ៊ុនដែលប្រើប្រាស់មគ្គុទេសក៍ ក៏ដូចជាអាជ្ញាធរទទួលបន្ទុកផ្ទាល់។

**២.៣.២.៣. ខ្វះភាពទាក់ទាញលើសេវាកម្មទេសចរណ៍**

ចំពោះចំណុចនេះចង់សំដៅដល់សេវាកម្មទេសចរណ៍បន្ថែម ដែលរៀបចំឡើងដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ដូចជា ការបង្កើតឱ្យមានសេវាកម្មជិះស៊ីក្លូ ជិះទូកកម្សាន្តក្នុងតំបន់កសិណអង្គរ ការជិះកន្រ្តក ឬបាឡុងដើម្បីទស្សនាតាមតំបន់ទេសចរណ៍នានា។ ជាក់ស្តែងយើងមានសកម្មភាពទាំងនេះខ្លះៗក្នុងខេត្តសៀមរាប បើទោះបីជាពុំទាន់សម្បូរបែបក៏ដោយចុះក៏ប៉ុន្តែនៅតាមតំបន់ផ្សេងទៀតពុំទាន់មានការរៀបឱ្យមានការកម្សាន្តបែបនេះឱ្យបានច្រើននៅឡើយទេ។ បន្ថែមពីលើនេះវិស័យទេសចរណ៍កម្ពុជាក៏ខ្វះភាពទាក់ទាញក្នុងការធ្វើឱ្យភ្ញៀវអាចស្នាក់នៅបានយូរតាមរយៈកម្មវិធីបែបសង្គមនិងវប្បធម៌ (Social & Cultural Events/Festival) នៅតាមស្រុកខេត្តនានាក៏ដូចជាតំបន់ ប៉ូលទេសចរណ៍ធំៗជាដើម ។មគ្គុទេសក៍ទេសចរណ៍ក៏ដូចជាក្រុមគោលដៅផ្សេងទៀតបានបញ្ជាក់ប្រាប់ថា ភ្ញៀវទេសចរណ៍បរទេសជាច្រើនដែលមកកម្សាន្តក្នុងប្រទេសកម្ពុជាតែងតែត្អូញត្អែរពួកគេពុំមានឱកាសបានសិក្សាស្វែងយល់ពីវប្បធម៌ ប្រពៃណី និងការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ ឬតាមតំបន់ជនជាតិភាគតិចជាដើមដោយសារតែយើងពុំមានការរៀបចំជាសេវាកម្ម ទេសចរណ៍ ឬសកម្មភាពសង្គម-វប្បធម៌ ដើម្បីបង្ហាញនិងផ្សព្វផ្សាយពីវប្បធម៌និងការរស់នៅរបស់ប្រជាជនកម្ពុជាឱ្យបានទូលំទូលាយដល់ពួកគេ ។ ភ្ញៀវទេសចរអន្តរជាតិជាច្រើនចង់មានឱកាសដោយផ្ទាល់ក្នុងការចូលរួមលេងកម្សាន្តសប្បាយក្នុងសកម្មភាពសង្គមណាមួយដែលអាចឆ្លុះបញ្ចាំងពីវប្បធម៌ និងការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។

**២.៣.២.៤. កង្វះខាតការរៀបចំរមណីដ្ឋាន**

ក្រៅពីកង្វះនូវសេវាកម្មនានា ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ដូចដែលបានរៀបរាប់ខាងលើគេក៏សង្កេតឃើញថានៅតាមរមណីយដ្ឋានជាច្រើនក្នុងប្រទេសកម្ពុជាពុំទាន់មានការរៀបចំឱ្យមានភាពទាក់ទាញ និងបង្កើតនូវអារម្មណ៍រីថ្មមានចំពោះភ្ញៀវទេសចរណ៍។ ជាក់ស្តែងនៅតាមដងផ្លូវ និងបរិវេណនានានៅតាមតំបន់ទេសចរណ៍ជាច្រើនខ្វះការរៀបចំ ឬតុបតែងឱ្យមានសម្រស់ទាក់ទាញខ្វះការរៀបចំឱ្យមានជាប្លង់សម្រាប់ផ្តិតយករូបភាពអនុស្សាវរីយ៍ជាដើម។ ដើម្បីបង្កើននូវភាពទាក់ទាញកម្ពុជាត្រូវវិនិយោគទៅលើការរៀបចំរមណីយដ្ឋានរបស់ខ្លួនឱ្យបានស្អាតមានប្លង់ចាប់រូបភាពនានាដូចជា នៅតាមតំបន់ប្រាសាទជាដើម។

**២.៣.២.៥. អនាម័យ សណ្តាប់ធ្នាប់ និងសុវត្ថិភាព**

តាមការសង្កេតឃើញថាបញ្ហាសណ្តាប់ធ្នាប់អនាម័យ និងសន្តិសុខនៅតាមគោលដៅទេសចរណ៍នីមួយៗនៅតែជាបញ្ហាចោទសម្រាប់កម្ពុជា ។ ជាក់ស្តែងនៅតាមរមណីយដ្ឋាន ឬគោលដៅកម្សាន្តជាច្រើនក្នុង

ប្រទេសកម្ពុជាមានការចោលសំរាមពាសវាលពាសកាល ខ្វះអនាម័យនិងពុំមានធុងសំរាមដើម្បីទុកដាក់ឱ្យបានហ្មត់ចត់ ។ គោលដៅទេសចរណ៍ភាគច្រើនពុំមានការរៀបចំបង្គន់សារធារណៈឱ្យបានគ្រប់គ្រាន់ ឬសមស្របតាមនិយាមអនាម័យ។ ដោយឡែកគោលដៅទេសចរណ៍ខ្លះទៀតមានការរៀបចំដែរ ប៉ុន្តែមានចំនួនតិចនិងពេលខ្លះភ្ញៀវទេសចរណ៍ត្រូវធ្វើដំណើរឆ្ងាយ ឬត្រឡប់មកដើមផ្លូវវិញដើម្បីអាចប្រើប្រាស់បង្គន់អនាម័យបាន។ ក្រៅពីបញ្ហាអនាម័យគេក៏សង្កេតឃើញមានរូបភាពមួយចំនួន ដែលអាចធ្វើឱ្យប៉ះពាល់អារម្មណ៍របស់ភ្ញៀវក្នុងការដើរកម្សាន្តផងដែរ។ រូបភាពអវិជ្ជមានទាំងនោះមានដូចជា ការរៀបចំឱ្យមានអាសនៈបែបសាសនាច្រើនពេក? ការបណ្តោយឱ្យមានអ្នកសុំទាននៅតាមរមណីយដ្ឋាន ឬតាមជណ្តើរឡើងតំបន់ទេសចរណ៍មួយចំនួនជាដើម។

ដោយឡែកបញ្ហាសុខសុវត្ថិភាពនៅតាមតំបន់ទេសចរណ៍នានា ក្នុងប្រទេសកម្ពុជានៅតែជាបញ្ហាចោទបើទោះបីជាតំបន់មួយចំនួនពិតជាមានការរក្សាសន្តិសុខ ឬសុវត្ថិភាពជូនភ្ញៀវទេសចរណ៍បានច្រើនក៏ដោយចុះ។ បើតាមការសាកសួរប្រតិបត្តិករទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ក៏ដូចជា ប្រជាពលរដ្ឋដែលប្រកបមុខរបរនៅក្នុងវិស័យទេសចរណ៍បញ្ហាសុវត្ថិភាពតាមតំបន់ទេសចរណ៍កម្ពុជាកើតឡើងក្នុងរូបភាពជាច្រើនដូចជា៖

- ចោរកម្មលួចទ្រព្យសម្បត្តិភ្ញៀវនៅតាមតំបន់កម្សាន្តនានា (មាត់សមុទ្រ តាមផ្សារនិង តំបន់ប្រជុំជនមួយចំនួនទៀត)
- ចោរឆក់កាបូបតាមយានជំនិះនានា ដែលធ្វើឱ្យភ្ញៀវជាតិនិងអន្តរជាតិជួបគ្រោះថ្នាក់ជាញឹកញាប់ និងខ្លះឈានទៅដល់បាត់បង់ជីវិតក៏មាន។

### ២.៣.២.៦. អំពើកេងប្រវ័ញ្ចលើភ្ញៀវ

ចាប់តាំងពីមានការដាក់ឱ្យមានកញ្ចប់សេវាតម្លៃសូន្យ (Zero Package Tour) មកគេឃើញមានអំពើកេងប្រវ័ញ្ចកើតឡើងច្រើនចំពោះភ្ញៀវទេសចរណ៍ជាពិសេសភ្ញៀវជនជាតិចិនតាមរូបភាពដូចជា ការលក់ទំនិញថ្លៃលើសតម្លៃជាក់ស្តែង ២-៣ដង ការលក់ផលិតផលក្លែងក្លាយការជំរុញឱ្យភ្ញៀវទិញផលិតផលដែលភ្ញៀវមិនចង់ទិញជាដើម។ ជាក់ស្តែងនៅក្នុងកញ្ចប់សេវាទេសចរណ៍បែបនេះ បានកំណត់ថាភ្ញៀវមិនចាំបាច់ចំណាយទៅលើកញ្ចប់ទេសចរណ៍ប៉ុន្តែត្រូវដើរផ្សារ ឬទិញទំនិញនៅតាមហាងដែលមគ្គុទេសក៍ទេសចរណ៍ទាំងឡាយបាននាំទៅ។ ប្រធានសមាគមន៍មគ្គុទេសក៍ទេសចរណ៍មួយក្នុងខេត្តសៀមរាបក៏ដូចជា ក្រុមគោលដៅដទៃទៀតបានធ្វើការគូសបញ្ជាក់ថាភាគច្រើននៃហាងលក់ទំនិញទាំងនោះមានម្ចាស់ជាជនជាតិចិន និងជាទូទៅមានការត្រូវរ៉ូវគ្នាជាមួយក្រុមហ៊ុនទេសចរណ៍ព្រមទាំងមគ្គុទេសក៍ភាសាចិន ដើម្បីរៀបចំសេវាទេសចរណ៍ប្រភេទនេះ និងបង្កើតឱ្យមានអំពើកេងប្រវ័ញ្ចនានាទៅលើភ្ញៀវដែលជាជនជាតិចិនជាពិសេស។ មានករណីខ្លះ

ក្រុមហ៊ុនទេសចរណ៍នានា ដែលរៀបចំនូវកញ្ចប់សេវាកម្មទេសចរណ៍តម្លៃសូន្យមានម្ចាស់ ឬថៅកែតែមួយជាមួយនឹងហាងលក់ទំនិញភោជនីយដ្ឋាន ឬផ្ទះសំណាក់ជាដើម។[31]

**២.៣.២.៧. បញ្ហាសំណុំលិខិតនិដ្ឋភារ**

តាមរយៈការសម្ភាសជាមួយមគ្គុទេសក៍ទេសចរណ៍ និងម្ចាស់ប្រតិបត្តិករទេសចរណ៍ជាច្រើនរកឃើញថាភាពមិនប្រក្រតីនៅតាមច្រកចេញចូលប្រទេសជាច្រើននៅតែជាបញ្ហាចោទ ហើយបញ្ហាទៀតសោតកើតឡើងក្រោមរូបភាពដូចជា៖

- ការសុំកម្រៃក្រៅផ្លូវការពីមន្ត្រីអន្តោប្រវេសន៍ដើម្បីសម្រួលបែបបទឯកសារឱ្យបានកាន់តែឆាប់រហ័សជាងមុន។
- បញ្ជរត្រួតពិនិត្យមានចំនួនតិចធ្វើឱ្យលំហូរនៃការត្រួតពិនិត្យយឺត ហើយភ្ញៀវមួយចំនួនត្រូវចំណាយពេលរង់ចាំទទួលសេវាកម្មយូរជាដើម។
- ប្រព័ន្ធត្រួតពិនិត្យនៅតាមច្រកព្រំដែនព្រលានយន្តហោះជាដើមមានភាពស្មុគស្មាញ និងបង្កការលំបាកដល់ភ្ញៀវ។

**២.៣.២.៨. ចម្ងាយ និងស្ថានភាពផ្លូវគមនាគមន៍**

តាមការសង្កេតឃើញថាចម្ងាយពីប៉ូលទេសចរណ៍មួយទៅប៉ូលទេសចរណ៍មួយទៀត (ប៉ូលធំៗទាំងបួន) មានរយៈចម្ងាយឆ្ងាយគឺជាបញ្ហាប្រឈមមួយដែរ ជាពិសេសសម្រាប់ភ្ញៀវដែលមានពេលមកកំសាន្តក្នុងរយៈពេលខ្លី។ ដោយសារតែចម្ងាយផ្លូវធ្វើដំណើរឆ្ងាយ និងជាពិសេសស្ថានភាពផ្លូវមានការពិបាកធ្វើឱ្យការធ្វើដំណើរទេសចរណ៍ត្រូវចំណាយពេលច្រើនដែលធ្វើឱ្យភ្ញៀវទេសចរណ៍ជាច្រើនពុំអាចធ្វើដំណើរកំសាន្តនៅតាមតំបន់គោលដៅនានា តាមប៉ូលទេសចរណ៍ផ្សេងៗបាន។ បន្ថែមពីលើនេះស្ថានភាពផ្លូវនានាទៅកាន់រមណីយដ្ឋានមួយចំនួនតាមប៉ូលនីមួយៗ ក៏មានសភាពពិបាកក្នុងការធ្វើដំណើរដែលនេះជាបញ្ហាប្រឈមខ្លាំងមួយក្នុងការទាក់ទាញភ្ញៀវឱ្យមកទស្សនាម្តងហើយម្តងទៀត។ ជាក់ស្តែងផ្លូវមួយចំនួននៅតាមប្រាសាទនានារបស់យើងមានស្ថានភាពពិបាកក្នុងការធ្វើដំណើរកន្លែងខ្លះទៀត ផ្លូវមានការដក់ទឹកភក់ជ្រាំនៅរដូវវស្សាដែលជារឿយៗធ្វើឱ្យមានការប្រឡាក់ប្រឡូកលើសម្លៀកបំពាក់របស់ភ្ញៀវដែលមកលេងកម្សាន្តជាដើម។

**២.៣.២.៩. កង្វះការផ្សព្វផ្សាយនៅក្រៅប្រទេស**

[31] (២០១៩). ក្រសួងទេសចរណ៍ និងចាត់វិធានការក្តៅ ចំពោះប្រតិបត្តិករទេសចរណ៍ "ការរកស៊ីកាប់ភ្ញៀវ"ដោយផ្តល់បែបសេវាបែប Zero Package Tour.

តាមរយៈទិន្នន័យរបស់រាជបណ្ឌិត្យសភាដែលបានធ្វើការការសម្ភាសជាមួយប្រតិបត្តិករទេសចរណ៍ក៏ដូចជាមគ្គុទេសក៍ទេសចរណ៍នៅតាមប៉ូលទាំង៤ និងខេត្តមួយចំនួនទៀតជាលទ្ធផលយើងអាចសន្និដ្ឋានបានបង្ហាញថាកម្ពុជាពុំសូវមានសកម្មភាពផ្សព្វផ្សាយពីទេសចរណ៍ជាតិ ក៏ដូចជាគោលដៅទេសចរណ៍នានាឱ្យបានទូលំទូលាយនៅក្រៅប្រទេស។ ការដែលពុំសូវមានសកម្មភាពផ្សព្វផ្សាយនានាពីកម្ពុជាក៏អាចជាកត្តារាំងស្ទះមួយផងដែរ ដល់ការអភិវឌ្ឍនិងភាពរីកចម្រើនលើវិស័យនេះ។ ជាក់ស្តែងក្រុមគោលដៅដែលបានចូលរួមក្នុងការសិក្សាបានបញ្ជាក់ថាភ្ញៀវទេសចរណ៍អន្តរជាតិ ដែលមកទទួលសេវាកម្មរបស់គាត់ពុំទទួលបានព័ត៌មានច្រើនពីកម្ពុជាដូចប្រទេសជិតខាងរបស់យើងដែលប្រទេសគេមានភាពសកម្មទាំងនៅក្នុងប្រទេស និងក្រៅប្រទេសលើកិច្ចការងារផ្សព្វផ្សាយពីគោលដៅទេសចរណ៍ សកម្មភាពទេសចរណ៍ ព្រមទាំងវប្បធម៌របស់ជាតិគេក្នុងគោលបំណងទាក់ទាញភ្ញៀវបរទេសឱ្យបានកាន់តែច្រើន។ ជាការពិតជនជាតិបរទេសជាច្រើនពុំសូវស្គាល់កម្ពុជាហើយបើស្គាល់ក៏ដោយសារតែយើងមានអង្គរវត្តប៉ុណ្ណោះ ប៉ុន្តែភ្ញៀវទាំងនោះពុំទទួលបានព័ត៌មានគ្រប់គ្រាន់ទាក់ទង នឹងគោលដៅទេសចរណ៍តំបន់ទេសចរណ៍វប្បធម៌ ឬសកម្មភាពទេសចរណ៍ដែលមានលក្ខណៈពិសេសដើម្បីទាក់ទាញពួកគេនោះទេ។

## ២.៤. ផលប៉ះពាល់លើវិស័យអចលនទ្រព្យ

វិស័យអចលនទ្រព្យ បានដើរតួយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយនេះ។ គេសង្កេតឃើញថាកំណើននៃតម្រូវការអចលនទ្រព្យគ្រប់ប្រភេទនៅកម្ពុជាស្តែងចេញក្រោមហេតុផលមួយចំនួនដូចជា (១) កំណើនប្រជាជននៅតាមទីក្រុង និង តំបន់ទីប្រជុំជននានា (២) ការធ្វើចំណាកស្រុករបស់ពលរដ្ឋកម្ពុជាមកទីក្រុងក្រោមរូបភាពស្វែងរកឱកាសការងារ មុខរបរនិងសិក្សាជាដើម និង (៣) កំណើននៃវិនិយោគិនបរទេសជាដើម។ កត្តាទាំងនេះមិនត្រឹមតែធ្វើឱ្យតម្រូវការអចលនទ្រព្យនៅកម្ពុជាមានការកើនឡើងប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យតម្លៃរបស់វានៅតាមតំបន់ខ្លះខេត្តខ្លះមានការកើនឡើងយ៉ាងគំហុគ។ ទោះជាយ៉ាងណាក្រោយពីការកើតមាននូវការរីករាលដាលនៃជំងឺកូវីដ-១៩ វិស័យអចលនទ្រព្យកម្ពុជាក៏មិនខុសពីវិស័យទេសចរណ៍ ឬវិស័យផ្សេងៗទៀតបានទទួលរងនូវផលប៉ះពាល់ដូចគ្នាគ្រាន់តែទំហំនៃការប៉ះពាល់មានលក្ខណៈធូរស្រាលជាងវិស័យទេសចរណ៍។

### ២.៤.១. ផលប៉ះពាល់លើវិស័យអចនលទ្រព្យ

បើតាមគេហទំព័រ Focus Economics ចេញផ្សាយកាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០២០ កន្លងទៅបានបង្ហាញថាបើប្រៀបធៀបនឹងរយៈពេលដូចគ្នា (មករា-សីហា) កាលពីឆ្នាំ២០១៩កន្លងទៅសកម្មភាពដែលពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យទាំងគម្រោងវិនិយោគថ្មី និងសំណើសុំប្រតិបត្តិការអភិវឌ្ឍលើវិស័យមួយនេះ

មានការថយចុះច្រើន (Focus-Economics, ២០២០)។[32] ជាមួយគ្នានេះដែរលោកឧកញ៉ា **ចេង ខេង** ជាប្រធានក្រុមប្រឹក្សាភិបាលសមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា និងជាអគ្គនាយកក្រុមហ៊ុនអចលនទ្រព្យស៊ីភីអិលបានបញ្ជាក់អះអាងថា វិបត្តិកូវីដ-១៩មួយនេះបានធ្វើឱ្យសកម្មភាពទិញ-លក់អចលនទ្រព្យក្នុងប្រទេសទាំងមូលមានសភាពស្ងប់ស្ងាត់ជាងមុនមានកូវីដ ហើយមានការធ្លាក់ចុះប្រមាណ៥០%។ គួបញ្ជាក់ថាស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩នេះ បានធ្វើឱ្យប៉ះពាល់លើវិស័យអចលនទ្រព្យលើខេត្តជាច្រើន ប៉ុន្តែរាជធានីភ្នំពេញ និងខេត្តព្រះសីហនុបានរងផលប៉ះពាល់ខ្លាំងជាងគេ។ ក្រៅពីភាពអសកម្មមួយចំនួនទៅលើសកម្មភាពសាងសង់ និងអភិវឌ្ឍអចលនទ្រព្យថ្មីៗគេក៏សង្កេតឃើញថាផលប៉ះពាល់នេះក៏មានវិសាលភាពទៅដល់ការជួលអគារផ្ទះល្វែង និងបន្ទប់ការិយាល័យផងដែរ។

ជាក់ស្តែងនៅខេត្តព្រះសីហនុផលប៉ះពាល់ទៅលើវិស័យអចលនទ្រព្យកើតមានចាប់តាំងពី ២ ទៅ ៣ខែមុនការផ្ទុះឡើងនូវជំងឺកូវីដ-១៩ ដោយសារតែការបិទនូវល្បែងភ្នាល់អនឡាញគ្រប់ប្រភេទ។ ដោយឡែកនៅពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩ ការសាងសង់សំណង់អគារប្រមាណ ៩០% ត្រូវបានផ្អាកជាបណ្តោះអាសន្នដោយសារតែមានការរឹតត្បិតទៅលើបញ្ហាសុវត្ថិភាព និងកម្មករជាជនជាតិចិនមួយចំនួនធំបានធ្វើដំណើរត្រឡប់ទៅប្រទេសគេវិញ ហើយខ្លះទៀតពុំអាចត្រឡប់ចូលមកកម្ពុជាវិញបានដោយសារតែមានបម្រាមនានាទាក់ទងនឹងនីតិវិធីក្នុងការធ្វើដំណើរជាដើម។ ការផ្អាកនេះមិនមានរយៈពេលយូរខ្លាំងទេដោយសារតែមានការគ្រប់គ្រងត្រឹមត្រូវមិនឆ្លងក្នុងសហគមន៍អគារសំណង់មួយចំនួនបានចាប់ផ្តើមឡើងវិញ និងខ្លះទៀតក៏បានបញ្ចប់ផងដែរ នេះបើតាមការគូសបញ្ជាក់របស់ប្រធានមន្ទីរដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ។ លោកប្រធានមន្ទីរក៏បានធ្វើការបញ្ជាក់បន្ថែមថាបើទោះជាមានការប៉ះពាល់លើការសាងសង់នេះមែនតែភាគច្រើន គឺជាការសាងសង់អគារសំណង់បែបពាណិជ្ជកម្មធំៗរបស់វិនិយោគិនជនជាតិចិន ដោយឡែកការសាងសង់លំនៅដ្ឋានបែបឯកជន ឬការសាងសង់របស់ប្រជាពលរដ្ឋម្ចាស់ស្រុកនៅដំណើរការធម្មតា។

ភ្នាក់ងារលក់ដូរអចលនទ្រព្យ ក៏ដូចជាបុគ្គលិកក្រុមហ៊ុនប្រកបអាជីវកម្មអចលនទ្រព្យមួយចំនួនក្នុងប្រទេសកម្ពុជាបានធ្វើការគូសបញ្ជាក់ថាបើទោះបីជាកម្ពុជាកំពុងទទួលរងនូវផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩ក្តីក៏ការទិញ-លក់អចលនទ្រព្យនៅពេលបច្ចុប្បន្ននេះពុំមានការប្រែប្រួលខ្លាំងនោះទេ ក៏ប៉ុន្តែសកម្មភាពភាគច្រើនកើតមានតែនៅក្នុងតំបន់ជាយក្រុងហើយអតិថិជនភាគច្រើនជាអតិថិជនក្នុងស្រុក។ ស្រដៀងគ្នាដែរ អគ្គនាយកក្រុមហ៊ុនភ្នាក់ងារអចលនទ្រព្យ Century 21 Fortuna Investment **លោក វ៉ា វីរៈ** បានមានប្រសាសន៍

[32] Focus Economics. (2020, November 17). Cambodia Economic Outlook

បញ្ជាក់ថាទីផ្សារអចលនទ្រព្យនៅចុង ឆ្នាំ២០២០ នេះមានការកម្រើកឡើងវិញបន្តិចបើធៀបនឹងប៉ុន្មានខែដើមឆ្នាំ ក៏ប៉ុន្តែសកម្មភាពទាំងនេះភាគច្រើនមានតែតំបន់ជាយក្រុងតែប៉ុណ្ណោះ។[33]

ដោយឡែកបើពិនិត្យទៅលើរបាយការណ៍ផ្លូវការរបស់ក្រុមហ៊ុនភ្នាក់ងារអចលនទ្រព្យអន្តរជាតិ (CBRE Cambodia) បានបញ្ជាក់ថាចាប់តាំងពីដើមត្រីមាសទី២ រហូតមកដល់ចុងត្រីមាសទី៣ ឆ្នាំ ២០២០ កន្លងទៅនេះក្នុងចំណោមខណ្ឌទាំង១៤នៅទូទាំងរាជធានីភ្នំពេញសន្ទុះនៃការសាងសង់ ក៏ដូចជាការទិញលក់អចលនទ្រព្យដែលរួមមានដីធ្លី និងលំនៅដ្ឋានជាន់ផ្ទាល់ដីស្ថិតនៅក្នុងខណ្ឌចំនួន៤ នៅតែរក្សាបានស្ថានភាពល្អដដែល។[34] របាយការណ៍ដដែលបានបញ្ជាក់ថាខណ្ឌចំនួន៤ ដែលមានអត្រាល្អជាងគេនៅក្នុងទីផ្សារអចលនទ្រព្យរួមមាន ខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌជ្រោយចង្វារ។ ដូចគ្នាដែរអ្នកជំនាញផ្នែកលក់អចលនទ្រព្យនៅក្នុងតំបន់ខណ្ឌដង្កោលោក **សរ បញ្ញា** បានមានប្រសាសន៍ស្រដៀងការលើកឡើងខាងលើនេះផងដែរថា " **ស្ទើរតែគ្រប់គម្រោងនៅតំបន់ជុំវិញរាជធានីភ្នំពេញភាគច្រើននៅតែមានទីផ្សារលើកលែងតែគម្រោងដែលស្ថិតនៅទីតាំងមិនសូវអំណោយផលដែលពិបាកលក់** " ។ តែយ៉ាងណានៅក្នុងរាជធានីភ្នំពេញចរន្តនៃការទិញ-លក់អចលនទ្រព្យមានសកម្មភាពខ្លះៗ នៅជាយក្រុង ឬតំបន់ឧស្សាហកម្មថ្មីដូចជាផ្លូវ ៥១ ផ្លូវជាតិលេខ២ លេខ៣ លេខ៤ ជាដើម។ ចំណែកទីក្រុងភ្នំពេញសកម្មភាពមានច្រើននៅក្នុងខណ្ឌពោធិ៍សែនជ័យ ភ្នំពេញថ្មី និងតំបន់ជ្រោយចង្វារជាដើម។[35]

តាមការសាកសួរបុគ្គលិកក្រុមហ៊ុនអចលនទ្រព្យនានា ក៏ដូចជាភ្នាក់ងារអចលនទ្រព្យទាំងស្ថិតក្រោមទម្រង់ជាក្រុមហ៊ុន និងលក្ខណៈបុគ្គលបានបង្ហាញថាតម្លៃអចលនទ្រព្យនៅកម្ពុជាពុំមានការធ្លាក់ថ្លៃគួរឱ្យកត់សម្គាល់នោះទេ ក៏ប៉ុន្តែចរន្តនៃការទិញ-លក់ពិតជាមានការថមថយខ្លះៗមែន។ ពួកគាត់ក៏បានធ្វើការគូសបញ្ជាក់បន្ថែមថាការចុះថ្លៃមួយចំនួនពិតជាមានមែន ប៉ុន្តែភាគច្រើននៃអចលនទ្រព្យទាំងនោះស្ថិតនៅឆ្ងាយពីក្រុង ឬនៅជាយក្រុងភ្នំពេញ។ ហេតុផលដែលមានការចុះថ្លៃពីក្រុមហ៊ុនទាំងនោះអាចដោយសារតម្លៃមានការហើយរួចស្រេចទៅហើយនៅតាមតំបន់ទាំងនោះដែលតម្លៃជាក់ស្តែងមិនប្រាកដថាដល់កម្រិតនេះទេ។ ដោយសារតែមានការថមថយមួយចំនួននៃការលក់ក្រុមហ៊ុនទាំងនោះសម្រេចបញ្ចុះតម្លៃអចលនទ្រព្យរបស់ខ្លួន

---

[33] (២០២០, ១៥ តុលា). អ្នកប្រតិបត្តិទីផ្សារអះអាងថា ការទិញ-លក់អចលនទ្រព្យភាគច្រើនមានសកម្មភាពមានតែនៅក្នុ និងជាយក្រុងតែប៉ុណ្ណោះ. ដកស្រង់ចេញពីគេហទំព័រ៖ https://www.propertyarea.asia

[34] ( ២០២០ , ១៩ តុលា). តម្លៃជួលការិយាល័យមានការធ្លាក់ចុះ ខណៈពេលការផ្គត់ផ្គង់លើទីផ្សារមានការកើនឡើងខ្ពស់. ដកស្រង់ចេញពីគេហទំព័រ៖ https://www.propertyarea.asia

[35] (២០២០ ,១៣ តុលា). ខណ្ឌ៤ នៅតែមានមានចរន្តទិញ-លក់អចលនទ្រព្យសកម្មជាងគេ តើមានខណ្ឌណាខ្លះ? ដកស្រង់ចេញពី៖ https://www.propertyarea.asia

ដែលដាក់ស្តែងតម្លៃទាំងនេះ គឺស្រួបនឹងតម្លៃទីផ្សារពិតប្រាកដ។ ហេតុផលមួយទៀតដែលមានការលក់បញ្ចុះតម្លៃដោយសារម្ចាស់គម្រោងទាំងនោះអាចនឹងជាប់បំណុលធនាគារ នឹងចាំបាច់ត្រូវបញ្ចេញអចលនទ្រព្យរបស់ខ្លួនដើម្បីបង់ធនាគារ។ ទោះជាយ៉ាងណាក៏មានការប៉ាន់ប្រមាណផងដែរថាប្រសិនបើវិបត្តិនេះនៅតែបន្តវាអាចមាននូវបញ្ហាដូចខាងក្រោម៖

- **តម្លៃនឹងមានការធ្លាក់ចុះយ៉ាងគំហុក**

  ដោយសារតែមានការធ្លាក់ចុះនៃសេដ្ឋកិច្ចជាសកល ដែលកើតឡើងដោយសារវិបត្តិកូវីដ-១៩ នេះអាចនឹងបណ្តាលឱ្យមានអ្នកវិនិយោគមួយចំនួនខាតបង់ ហើយអាចប៉ះពាល់ដល់លទ្ធភាពក្នុងការបណ្តាក់ទុនថ្មីការវិនិយោគនឹងបែរមកផ្តោតការវិនិយោគលើប្រភេទអចលនទ្រព្យដែលមានតម្រូវការខ្ពស់ ដោយឡែកអចលនទ្រព្យប្រភេទខ្លះនឹងថយចុះ។ ជាមួយនឹងការថយចុះនៃការវិនិយោគពីបរទេសតម្លៃអាចនឹងមានការធ្លាក់ចុះខ្លាំងដោយសារពុំមានការប្រកួតប្រជែង។

- **ការកើនឡើងនៃបំណុលខូច (បំណុលក្នុងអចលនទព្យ)**

  ក្នុងប្រទេសកម្ពុជាការវិនិយោគលើអចលនទ្រព្យ គឺខ្ចីលុយធនាគារមកបង្វិលសិនប្រសិនបើវិបត្តិនៅតែបន្តសេដ្ឋកិច្ចមានការធ្លាក់ចុះខ្លាំងនោះអ្នកវិនិយោគមួយចំនួននិងត្រូវបង្ខំចិត្តលក់ចេញ និងខ្លះទៀតអាចប្រឈមនិងគ្មានលទ្ធភាពបង់ធនគារ (អ្នកវិនិយោគធំៗ)។ ដោយឡែកប្រជាពលរដ្ឋដោយសារការបាត់បង់ប្រាក់ចំណូលពីការងារ មុខរបរ និងជាប់បំណុលផងនោះបំណុលខូចអាច នឹងមានការកើនឡើងផងដែរ។

### ២.៤.២. បញ្ហាប្រឈមក្នុងវិស័យអចលនទ្រព្យកម្ពុជា

បើទោះបីជាការផ្ទុះជំងឺឆ្លងកូវីដ-១៩ ដែលរាលដាលពាសពេញពិភពលោកពុំទាន់ធ្វើឱ្យប៉ះពាល់អ្វីធ្ងន់ធ្ងរដល់វិស័យអចលនទ្រព្យនៅកម្ពុជាក្តី ក៏វិស័យមួយនេះបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ។ បញ្ហាប្រឈមទាំងនោះអាចប៉ះពាល់តិច ឬច្រើនដល់ការរីកចម្រើននៃវិស័យនេះ បើទោះបីជាពុំប៉ះពាល់ដល់ចរន្តនៃការលក់ដូរនិងការអភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធក្នុងវិស័យនេះក្តី បើតាមការសម្ភាសផ្ទាល់ជាមួយតំណាងក្រុមហ៊ុនអចលនទ្រព្យក៏ដូចជាភ្នាក់ងារអចលនទ្រព្យដែលបានចូលរួមក្នុងការសិក្សានេះ យើងអាចកំណត់នូវបញ្ហាប្រឈមចម្បងមួយចំនួនដូចខាងក្រោម៖

#### ២.៤.២.១. នីតិវិធីក្នុងការចេញប្លង់កម្មសិទ្ធិ

បញ្ហាចម្បងមួយនៅក្នុងវិស័យអចលនទ្រព្យកម្ពុជា គឺបែបបទរដ្ឋបាលក្នុងការកាន់កាប់អចលនទ្រព្យដែលមានលក្ខណៈស្មុគស្មាញច្រើន និងមានភាពយឺតយ៉ាវ។ ការចំណាយពេលច្រើនក្នុងទទួលបានសិទ្ធិស្រប

ច្បាប់ក្នុងការកាន់កាប់អចលនទ្រព្យណាមួយធ្វើឱ្យរាំងស្ទះនូវចរន្តនៃការលក់ដូរដីធ្លី និងផ្ទះសម្បែងមួយចំនួនផង ដែរ។ ជាក់ស្តែងបែបបទនៃការរត់ការកម្មសិទ្ធិស្របច្បាប់ (ប្លង់រឹង) ទៅលើអចលនទ្រព្យនានាអាចអូសបន្លាយ ដល់ ៥-៦ខែ ឬអាចលើសពីនេះក៏មាន។ ទាំងភ្នាក់ងារអចលនទ្រព្យក៏ដូចជាប្រជាពលរដ្ឋដែលបានចូលរួមក្នុង ការសិក្សានេះបានបញ្ជាក់ប្រហាក់ប្រហែលគ្នាថារយៈពេល នៃការផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីនេះមានភាព មិនប្រក្រតីច្រើន(ពុករលួយ) ដោយសារតែពួកគាត់ចាំបាច់ត្រូវចំណាយថវិកាបន្ថែមក្នុងខ្ទង់ណាមួយជាលក្ខណៈ ឯកជនដើម្បីអាចទទួលបានប្លង់ស្របច្បាប់កាន់តែលឿន។ ទោះជាយ៉ាងណាពួកគាត់ពុំបានបញ្ជាក់ថាមន្ត្រី ដែលទទួលខុសត្រូវកិច្ចការទាំងនេះមានភាពមិនប្រក្រតីបែបនេះទាំងអស់នោះទេ។ ដោយឡែកតម្លៃក្នុងការ ទទួលបានសិទ្ធិស្របច្បាប់(ប្លង់រឹង) ក៏ជាបញ្ហាចោទមួយផងដែរក្នុងវិស័យអចលនទ្រព្យជាពិសេសសម្រាប់ប្រជា ពលរដ្ឋដែលមានប្រាក់ចំណូលទាប។ ប្រជាពលរដ្ឋដែលបានចូលរួមក្នុងការសិក្សាបានសម្តែងការមិនពេញចិត្ត ខ្លាំងទៅលើតម្លៃក្នុងការទទួលបានប្លង់រឹងនេះ ដោយសារវាជាបន្ទុកមួយបន្ថែមទៀតសម្រាប់ពួកគាត់នៅពេល ចង់បានដីដែលស្របច្បាប់ត្រឹមត្រូវ។

### ២.៤.២.២. កង្វះការត្រួតពិនិត្យភាពស្របច្បាប់

បញ្ហាចម្បងមួយទៀតក្នុងវិស័យអចលនទ្រព្យ គឺកង្វះការត្រួតពិនិត្យភាពស្របច្បាប់ក្នុងវិស័យអចលន ទ្រព្យ។ ជារឿយៗ គេតែងសង្កេតឃើញមានករណីឆបោកក្នុងវិស័យមួយនេះក្នុងទម្រង់ដូចជាការលក់ដីខ្យល់ ដី មានទំនាស់ដីគ្មានភាពស្របច្បាប់ ឬមានមនុស្សមួយក្រុមមកឃោសនាលក់ដីដែលមិនមែនជារបស់ខ្លួនជា ដើម។ ភ្នាក់ងារអចលនទ្រព្យព្រមទាំងបុគ្គលិកក្រុមហ៊ុនអចលនទ្រព្យដែលបានចូលរួមក្នុងការសិក្សាទទួល ស្គាល់ថាបញ្ហានេះពិតជាកើតមានមែនហើយបានធ្វើឱ្យកើតមាននូវការមិនទុកចិត្តច្រើនពីអតិថិជន។ បន្ថែមពី លើនេះ ប្រជាពលរដ្ឋដែលបានចូលរួមក្នុងការសិក្សានេះបានធ្វើការគូសបញ្ជាក់បន្ថែមទៀតថា បញ្ហាឆបោកក្នុង វិស័យអចលនទ្រព្យនេះក៏កើតមានក្នុងទម្រង់ ផ្សព្វផ្សាយថាលក់ដីធ្លីក្នុងតំបន់ណាមួយដោយភ្ជាប់ព័ត៌មាន អភិវឌ្ឍន៍ក្នុងពេលឆាប់ៗ ដីមានការសាង សង់ផ្សារ សួនកម្សាន្ត។ល ។ ល។ ប៉ុន្តែជាក់ស្តែងដីទាំងនេះគ្មាននោះ ទេនូវគម្រោងអភិវឌ្ឍន៍តាមការអួតអាងរបស់ពួកគេ។ បញ្ហាទាំងនេះ ក៏បានបង្កើននូវការមិនទុកចិត្តពីអតិថិជនក៏ ដូចជាបង្អាក់នូវការអភិវឌ្ឍនានាក្នុងវិស័យអចលនទ្រព្យផងដែរ។

### ២.៤.២.៣. អត្រាការប្រាក់ធនាគារខ្ពស់

ក្រុមការងារគម្រោងបានធ្វើការសាកសួរ ទាក់ទងទៅនឹងប្រភពថវិកាសម្រាប់ការអភិវឌ្ឍវិស័យអចលន ទ្រព្យ និងសំណង់នានាដោយទាំងភ្នាក់ងារនិងបុគ្គលិកក្រុមហ៊ុនអចលនទ្រព្យទាំងនោះ បានធ្វើការគូសបញ្ជាក់ ដូចៗគ្នាថាគ្មានអ្នករកស៊ីខាងអចលនទ្រព្យណាមិនខ្ចីលុយធនាគារនោះទេ គ្រាន់តថាតិចឬច្រើនទៅតាមស្ថាន

ភាពការរកស៊ី និងទ្រព្យសម្បត្តិរបស់គេ។ ដោយឡែកទាក់ទងនឹងចំណុចនេះគាត់បានធ្វើការគូសបញ្ជាក់បន្ថែមទៅលើអត្រាការប្រាក់ដែលមានលក្ខណៈខ្ពស់បន្តិច ជាពិសេសសម្រាប់ក្រុមហ៊ុនតូចៗអ្នករកស៊ីក្នុងលក្ខណៈជាក្រុមតូចៗ ឬជាបុគ្គល ។ អ្នករកស៊ីក្នុងទម្រង់ខាងលើជាទូទៅមានកង្វះខាតថវិកាដែលចាំបាច់ត្រូវការខ្ចីពីធនាគារក្នុងអត្រាការប្រាក់ខ្ពស់បន្តិច ដើម្បីរៀបចំអចលនទ្រព្យរបស់ខ្លួនដូចជារៀបចំប្រព័ន្ធផ្លូវ ទឹក ភ្លើង ចាក់បំពេញដីជាដើម។ ក្នុងកាលទេសៈមួយចំនួនពួកគាត់អាច នឹងជួបប្រទះបញ្ហាថវិកាសម្រាប់បង្វិលសងទៅធនាគារដោយសារការលក់ដូរដីធ្លី មិនសូវដាច់។ ជាក់ស្តែងក្នុងដំណាក់កាលកូវីដ-១៩នេះមានអ្នករកស៊ីខាងអចលនទ្រព្យមួយចំនួនត្រូវបញ្ចុះតម្លៃដីធ្លីរបស់ខ្លួន ដើម្បីរកប្រាក់មកបង្វិលសងធនាគារដែលនេះជាហានិភ័យខ្លាំងមួយរបស់អ្នករកស៊ីអចលនទ្រព្យ។

#### ២.៤.២.៤. អតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការ

វិបត្តិចម្បងដែលយើងព្រួយបារម្ភ គឺអតុល្យភាពរវាងបរិមាណនៃការផ្គត់ផ្គង់ និងបរិមាណនៃតម្រូវការក្នុងទីផ្សារអចលនទ្រព្យកាលណាដែលក្រុមអ្នកផ្គត់ផ្គង់ផ្តល់បរិមាណច្រើនលើសលទ្ធភាព និងបរិមាណតម្រូវការ។ មួយវិញទៀតវាអាចនឹងបញ្ហាគំរាមកំហែងមកពីក្រៅបងព្រំដែនព្រោះ បើកាលណាប្រទេសជិតខាងក៏ដូចជាប្រទេសក្នុងតំបន់យើងមានវិបត្តិនោះលំហូរទុនសម្រាប់ដាក់ការវិនិយោគលើវិស័យនានា រួមទាំងអចលនទ្រព្យផងនឹងខ្សោយជាងមុនមិនខាន។ ហើយដើម្បីច្បាស់កុំឱ្យមានការភ័ន្តច្រឡំនេះជារឿងទីផ្សារដែលមិនមែនជាអ្វីដែលរដ្ឋាភិបាលត្រូវដាក់បទបញ្ជាតម្រូវសេដ្ឋកិច្ចនោះទេ ស្របពេលដែលកំពុងបង្កបរិយាកាសសេរីភាវូបនីយកម្មលើការវិនិយោគពីសំណាក់វិស័យឯកជន។ អ្វីដែលយើងធ្វើបានមានត្រឹមតែរក្សាស្ថិរភាពអត្រាប្តូរប្រាក់ដូចដែលខ្ញុំបានជម្រាបជូនពីខាងដើម ដើម្បីធានាសុវត្ថិភាពផ្នែកទីផ្សារហើយនឹងរក្សាកំណើនដើម្បីបង្កើនអំណាចទិញរបស់ប្រជាពលរដ្ឋយើង។

### ២.៥. ផលប៉ះពាល់លើវិស័យហិរញ្ញវត្ថុ

នៅក្នុងជំពូកនេះ នឹងបង្ហាញពីផលប៉ះពាល់ទៅលើស្ថានភាពហិរញ្ញវត្ថុកម្ពុជាក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ គួរបញ្ជាក់ថាលទ្ធផលស្តីពីផលប៉ះពាល់លើវិស័យហិរញ្ញវត្ថុកម្ពុជានៅក្នុងជំពូកនេះបានមកពីការវិភាគទៅលើខ្លឹមសារព័ត៌មានដែលទទួលបានពីបណ្តាញសារព័ត៌មានជាតិនិងអន្តរជាតិ ព័ត៌មានទទួលបានពីការសម្ភាសបុគ្គលិកដែលបម្រើការងារក្នុងវិស័យ ធនាគារ និងហិរញ្ញវត្ថុមួយចំនួនក៏ដូចជាការវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុមួយចំនួនក្នុងស្រុកផងដែរ។ ជាការពិតខ្លឹមសារ និងភាពស៊ីជម្រៅនៃការសិក្សានេះពិតជានៅមានកម្រិតលទ្ធផលដែលទទួលបានពីការស្រាវជ្រាវនេះពិតជា

អាចចូលរួមចំណែកក្នុងជ្រុងណាមួយ ដើម្បីស្វែងរកដំណោះស្រាយពិសេសការចូលរួមជាគំនិតយុទ្ធសាស្ត្រសម្រាប់គោលនយោបាយក្នុងការដោះស្រាយបញ្ហាដែលកើតមានពីវិបត្តិកូវីដ-១៩ នេះ។

### ២.៥.១. ផលប៉ះពាល់លើអាជីវកម្មហិរញ្ញវត្ថុ

ដូចដែលបានបង្ហាញនៅខាងលើវិបត្តិកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មព្រមទាំងដំណើរការនៃសហគ្រាសគ្រប់ប្រភេទនៅកម្ពុជា។ ដោយមិនអាចជៀសបានផលប៉ះពាល់ដែលមានលើវិស័យផ្សេងៗក៏បានធ្វើឱ្យប៉ះពាល់ផងដែរដល់វិស័យហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាទាំងមូលជាពិសេសហិរញ្ញវត្ថុរបស់ជាតិ។ ផលប៉ះពាល់នេះក៏ដោយសារតែរចនាសម្ព័ន្ធជារួមនៃសេដ្ឋកិច្ចរបស់ជាតិត្រូវពឹងអាស្រ័យ ឬមានទំនាក់ទំនងលើគ្រប់វិស័យដោយផ្ទាល់ឬដោយ ប្រយោល។ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុហានិភ័យចម្បងដែលអាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថិរភាពក្នុងវិស័យនេះរួមមានការធ្លាក់ចុះនូវប្រាក់ចំណូលរបស់ប្រជាជន និងអាជីវកម្មគ្រប់ប្រភេទដែលអាចនាំឱ្យមានការធ្លាក់ចុះនៃកំណើនប្រាក់កម្ចីនិងប្រាក់បញ្ញើ ការធ្លាក់ចុះនៅក្នុងវិស័យសំណង់ និងអចលនទ្រព្យព្រមទាំងការធ្លាក់ចុះនៃមូលធនបរទេសហូរចូលក្នុងវិស័យធនាគារជាដើម។ តាមការស្រាវជ្រាវនិងវិភាគទៅលើទិន្នន័យដែលទទួលបានលទ្ធផលបានបង្ហាញថា បើទោះបីជាផលប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩កើតមានទៅលើស្ថានភាពសេដ្ឋកិច្ចជាតិជារួមមានលក្ខណៈធ្ងន់ធ្ងរក៏ពិតមែន ក៏ប៉ុន្តែផលប៉ះពាល់មកលើវិស័យហិរញ្ញវត្ថុកម្ពុជាមានសភាពធូរស្រាលជាងវិស័យផ្សេងៗទៀតច្រើនជាពិសេសបើធៀបជាមួយនឹងវិស័យទេសចរណ៍ដែលទទួលរងផលប៉ះពាល់ខ្លាំងជាងគេ។

ចំពោះផលប៉ះពាល់ជាក់ស្តែងដោយគិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២០ មានអតិថិជនក្នុងវិស័យហិរញ្ញវត្ថុជាង២៩ម៉ឺននាក់ ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩បានដាក់ស្នើរៀបចំឥណទានឡើងវិញពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានាដែលជាសមាជិករបស់សមាគមមីក្រូហិរញ្ញវត្ថុទាំង១០៣ស្ថាប័ន។[36] ក្នុងចំណោមអតថិជនទាំង ២៩ម៉ឺននាក់មានអតិថិជនជាង ២៧ ម៉ឺននាក់ត្រូវបានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសម្រេចអនុម័តរៀបចំឥណទានឡើងវិញដែលមានតម្លៃសរុប ជាង ១,៣ពាន់លានដុល្លារអាមេរិក។ មិនខុសពីរបាយការណ៍នេះតាមការសាកសួរដោយផ្ទាល់ទៅលើបុគ្គលិកបម្រើការងារក្នុងស្ថាប័នធនាគារ និងហិរញ្ញវត្ថុមួយចំនួនក៏បានបង្ហាញនូវស្ថានភាពប្រហាក់ប្រហែលនេះដែរ បើទោះបីជាពួកគាត់ពុំអាចបញ្ជាក់បានពីតួលេខជាក់ស្តែងក៏ដោយចុះ។ បុគ្គលិកទាំងនោះបានបញ្ជាក់បន្ថែមថាមូលហេតុដែលអតិថិជនស្នើសុំឱ្យមានការរៀបចំឥណទានឡើងវិញច្រើន ដោយសារការធ្លាក់ចុះនៃប្រាក់ចំណូលពីអាជីវកម្ម និងអតិថិជនដែលត្រូវចំណាយច្រើនក្នុងការ

[36] (២០២០ , ១៦ ធ្នូ ). ការស្នើសុំរៀបចំទានឡើងវិញនៅ CMA ចាប់ផ្តើមធ្លាក់ចុះ, ដកស្រង់ចេញពីគេហទំព័រ https://www.postkhmer.com

បង់រំលស់ដីធ្លី ឬផ្ទះជាដើម។ ទោះជាយ៉ាងណាទំនោរនៃការស្នើរៀបចំឥណទានឡើងវិញក៏បានធ្លាក់ចុះ មកវិញនៅប៉ុន្មានខែចុងក្រោយដែលនេះជាសញ្ញាល្អបង្ហាញឱ្យឃើញពីការថមថយនៃផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើមុខរបរ និងអាជីវកម្មរបស់ប្រជាពលរដ្ឋផងដែរ។ ជាមួយនឹងការថមថយនៃការស្នើសុំរៀបចំឥណទានឡើងវិញពីសំណាក់អតិថិជនព្រមទាំងស្ថានភាពធូរស្រាលនៃសកម្មភាពសេដ្ឋកិច្ចជាទូទៅផងដែរនោះ ក្នុងឆមាសទី២នៃឆ្នាំ២០២០កន្លងទៅយើងក៏សង្កេតឃើញពីសញ្ញាវិជ្ជមានច្រើនក្នុងវិស័យហិរញ្ញវត្ថុនេះផងដែរ។

ក្រៅអំពីការស្នើសុំរៀបចំឥណទានឡើងវិញដែលយើងអាចទាញបានថានេះអាចជារូបភាព ចម្បងមួយដែលបង្ហាញពីផលប៉ះពាល់ទៅលើវិស័យហិរញ្ញវត្ថុ ក៏ប៉ុន្តែក្នុងរូបភាពជាក់ស្តែងការប៉ះពាល់មិនជាធ្ងន់ធ្ងរខ្លាំងនោះទេ ទៅលើស្ថាប័នដែលវិនិយោគលើវិស័យមួយនេះតាមរយៈស្ថានភាពនេះយើងអាចធ្វើការសន្និដ្ឋានថារូបភាពខាងលើបានបង្ហាញពីផលប៉ះពាល់ទៅលើអាជីវកម្មរបស់ប្រជាពលរដ្ឋ ឬប៉ះពាល់ទៅលើប្រាក់ចំណូលរបស់ប្រជាពលរដ្ឋច្រើនជាងបង្ហាញពីប៉ះពាល់ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នធនាគារ និងហិរញ្ញវត្ថុទាំងមូល។ ឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារអភិបាលនៃធនាគារជាតិនៃកម្ពុជាក៏បានធ្វើសេចក្តីថ្លែងការបញ្ជាក់ពីស្ថានភាពនេះដូចគ្នាដោយលោកបានធ្វើការគូសបញ្ជាក់ថាបើទោះបីជាការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ចក្តី ក៏ប៉ុន្តែវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជានៅតែបង្ហាញនូវភាពរីកចម្រើនរឹងមាំព្រមទាំងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់សាច់ប្រាក់ដើម្បីទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិទាំងមូល ។[37] ជាមួយគ្នានេះគិតត្រឹមឆមាសទី១ នៃឆ្នាំ២០២០ នេះទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានបន្តកើនឡើងដល់ ១៧.៤% ហើយការផ្តល់ឥណទានបានបន្តកើនឡើងដល់ ១៩.៦% និងប្រាក់បញ្ញើបានកើនឡើង ១២.៣%។ ទោះជាយ៉ាងនេះក្តីធនាគារជាតិនៃកម្ពុជាក៏បានលើកឡើងពីហានិភ័យនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាក្នុងករណីដែលការរីករាលដាលនៃជំងឺកូវីដ-១៩ នេះនៅតែអូសបន្លាយរយៈពេលយូរ។

បើតាមរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់គិតមកដល់ចុងខែមិថុនាឆ្នាំ ២០២០ គ្រឹះស្ថាននេះទទួលបានលទ្ធផលល្អប្រសើរតាមរយៈកំណើនឥណទានដុល្លារ ដែលមានកំណើនឡើងដល់ ២ ៦៥៩ លានដុល្លារអាមេរិក និងសមតុល្យប្រាក់បញ្ញើពីអតិថិជនចំនួន១៩២៨ លានដុល្លារអាមេរិក។

[37] (២០២០ ១០ តុលា ). ធនគារជាតិនៃកម្ពុជា៖ វិស័យធនគារកម្ពុជា នៅបន្តមានវឌ្ឍនភាពប្រកបដោយទំនុកចិត្ត. ដកស្រង់ចេញពីគេហទំព័រពាវាំងអន្តរជាតិ RFI នៅថ្ងៃទី ១០ តុលា ២០២២

ទ្រព្យសកម្មសរុបរបស់ប្រាសាក់បានកើនឡើងច្រើនជាង ៣ ៣៩០ លានដុល្លារអាមេរិក។[38] បន្ថែមពីលើនេះអនុប្រធានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់លោក **សាយ សូនី** បានឱ្យដឹងថាគិតត្រឹមខែធ្នូផលប័ត្រកម្ចីរបស់ប្រាសាក់កើនឡើងប្រហែល ២១,១៧%ពី ២,៥០១លានដុល្លារកាលពីឆ្នាំ២០១៩ ដល់ ៣,០៣០ លានដុល្លារកាលពីឆ្នាំ ២០២០ និងកំណើនប្រាក់បញ្ញើប្រហែល ១៥,២៥% ពី ១ ៧៨៨ លានដុល្លារទៅដល់ ២ ០៦១ លានដុល្លារ និងកំណើនទ្រព្យសកម្មសរុបប្រហែល ១៦,៩៥% ពី៣ ១១០ ដល់ ៣ ៦៣៧ លានដុល្លារ។

មិនខុសពីមីក្រូហិរញ្ញវត្ថុប្រាសាក់ ធនាគារអេស៊ីលីដា ដែលជាធនាគារពាណិជ្ជធំជាងគេមួយនៅកម្ពុជា បានប្រកាសប្រាក់ចំណេញក្រោយបង់ពន្ធរួចមានរហូតដល់ជាង ១៤១លានដុល្លារអាមេរិកនៅ ឆ្នាំ២០២០ កន្លងទៅនេះដោយចំនួននេះមានកំណើន១៧% ធៀបនឹង ឆ្នាំ២០១៩ ។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០កន្លងទៅ ទ្រព្យសកម្មសរុបរបស់សម្ព័ន្ធធនាគារ អេស៊ីលីដាភីអិលស៊ី មានចំនួន ២៦,៥០ ទ្រីលានរៀលដែលកើនឡើងចំនួន១,៣៤ទ្រីលានរៀលស្មើនឹង៥,៣១% និងមូលធនសរុបចំនួន៤,៤១ទ្រីលានរៀលកើនឡើងចំនួន ៤៧៧,៣៥ ប៊ីលានរៀលស្មើនឹង ១២,១៥%ធៀបនឹងពេលវេលាដូចគ្នាក្នុងឆ្នាំ២០១៩។[39]ជាក់ស្តែងបើតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ដែលបានចេញផ្សាយក្នុងខែមករាឆ្នាំ២០២១ បានបញ្ជាក់ថាគិតត្រឹមចុងឆ្នាំ២០២០ ទ្រព្យសកម្មសរុបរបស់ប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាមានកំណើនប្រមាណ១៥,៧% ដោយសម្រេចបាន៥៩,៤ពាន់លានដុល្លារ ខណៈដែលឥណទានអតិថិជនក្នុងវិស័យនេះបានកើន១៤,៨% ដោយសម្រេចបាន ៣៧,៣ ពាន់លានដុល្លារ និងប្រាក់បញ្ញើបានកើនឡើងប្រមាណ១៥,៤% ដែលមានតម្លៃសរុបចំនួន ៣៣,៨ពាន់លានដុល្លារអាមេរិក។[40]

### ២.៥.២. ផលប៉ះពាល់លើហិរញ្ញវត្ថុជាតិ

ក្រៅពីផលប៉ះពាល់ខ្លះៗទៅលើស្ថាប័នធនាគារ និងហិរញ្ញវត្ថុតាមរយៈនៃការស្មើរៀបចំឥណទានឡើងវិញមួយចំនួន និងបញ្ហាផ្សេងៗទៀតដូចដែលបានរៀបរាប់ខាងលើគេសង្កេតឃើញថា ផលប៉ះពាល់នៃជំងឺកូវីដ-១៩ នេះទៅលើវិស័យហិរញ្ញវត្ថុរបស់ជាតិមានសភាពធ្ងន់ធ្ងរជាងទៅវិស័យហិរញ្ញវត្ថុឯកជន បើទោះបីជាក្នុងឆ្នាំ២០២០ កន្លងទៅនេះការប្រមូលពន្ធដារប្រភេទខ្លះមានការកើនឡើងធៀបនឹង ឆ្នាំ២០១៩ក៏ដោយចុះ។ ជាក់

[38] (២០២០, ២ កក្កដា). ប្រាសាក់ទទួលបានកម្ចីចំនួន ១៥០លានដុល្លារអាមេរិច ពីធនគារ ខេប៊ី គូកមីន ដើម្បីពង្រឹងមូលធនកម្ម សន្ទនីយភាព និងការពង្រឹងការផ្តល់ឥណទាន, ដកស្រង់ចេញពី៖ https://www.prasac.com.kh/kh/news-and-event/prasac-receives-usd-150-million-credit-facilities-from-kb-kookmin-bank

[39] (២០២១ ១១ កុម្ភៈ) របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ របស់សម្ព័នធនាគារ អេស៊ីលីដា. ដកស្រង់ចេញពីគេហទំព័រ៖ https://www.acledabank.com.kh/kh/khm/ir_pr20210211

[40](២០២១,២១, មករា). វិស័យហិរញ្ញវត្ថុកម្ពុជារក្សាកំណើនល្អក្នុងបរិនទកូវិដ. ដកស្រង់ចេញពី៖ https://www.postkhmer.com/

ស្តែងនៅក្នុងរយៈពេល១២ខែនៃ ឆ្នាំ២០២០កន្លងទៅចំណូលពន្ធអាករដែលអគ្គនាយកដ្ឋានពន្ធដារដែលប្រមូលបានមានចំនួន ១១៧០០,៥២ ប៊ីលានរៀល (២៨៨,៩០២ លានដុល្លារ) កើនឡើង៤២,៣២០ ប៊ីលានរៀល (១០,៤៤៩ លានដុល្លារ) ស្មើនឹង ៣,៧៣% ធៀបនឹងឆ្នាំ២០១៩ ។[41] បើទោះបីជាការប្រមូលពន្ធប្រភេទខ្លះមានការកើនឡើងក្នុងរយៈពេល១១ខែនៃឆ្នាំ២០២០ ក៏ប៉ុន្តែការអនុវត្តចំណូលក្នុងស្រុកសរុបថ្នាក់ជាតិមានសភាពថមថយគួរឱ្យកត់សម្គាល់ដែលអាចសម្រេចបានត្រឹមតែ ៨០,០៣% នៃច្បាប់ហិរញ្ញវត្ថុ ឬធ្លាក់ ចុះ២០,៨៩% បើធៀបនឹងរយៈពេលដូចគ្នានៃការអនុវត្តក្នុងរយៈពេលបីឆ្នាំចុងក្រោយ ។ ជាមួយគ្នានេះគិតត្រឹមរយៈពេល១១ខែនៃឆ្នាំ២០២០ កន្លងទៅចំណូលក្នុងស្រុកសរុបថ្នាក់ជាតិអនុវត្តបានចំនួន ១៩ ២៨១,២៥ ប៊ីលានរៀល ឬធ្លាក់ចុះ ១០,៣៥% បើគិតក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០១៩ ដែលក្នុងនោះចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធបានធ្លាក់ចុះ ៧,០០% និង ៣៦,៣៣% រៀងគ្នា។

ដោយសារតែវិបត្តិកូវីដ-១៩ បានវាយប្រហារវិស័យធំៗមួយចំនួនដែលជាសសរទ្រូងសេដ្ឋកិច្ចរបស់ជាតិដូចដែលបានបង្ហាញធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចជារួមទទួលរងនូវផលវិបត្តិយ៉ាងធ្ងន់ធ្ងរ។ ក្រៅពីផលប៉ះពាល់ជាលក្ខណៈម៉ាក្រូសេដ្ឋកិច្ចទៅលើវិស័យធំៗហើយនោះក្នុងទម្រង់មីក្រូសេដ្ឋកិច្ចវិបត្តិកូវីដ-១៩នេះ ក៏បានធ្វើឱ្យប៉ះពាល់ខ្លាំងទៅលើឧស្សាហកម្មខ្នាតតូចនិងមធ្យមលើគ្រប់វិស័យព្រមទាំងការងារ និងមុខរបររបស់ប្រជាពលរដ្ឋផងដែរ។ ដើម្បីចូលរួមកាត់បន្ថយស្ថានភាពលំបាកនេះទាំងលក្ខណៈឯកជនអាជីវកម្ម ឬក្រុមហ៊ុនវិនិយោគនានា រាជរដ្ឋាភិបាលបានអនុវត្តវិធានការសង្គ្រោះមួយចំនួន។ វិធានហិរញ្ញវត្ថុទាំងនេះបានធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ទៅលើហិរញ្ញវត្ថុរបស់ជាតិដែលអាចកត់សម្គាល់ដូចខាងក្រោម។[42]

#### ២.៥.២.១. ការបាត់បង់ប្រាក់ចំណូលជាតិដោយការលើកលែងពន្ធ

ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយផលប៉ះពាល់ដល់វិស័យទេសចរណ៍ ក៏ដូចជាវិស័យផ្សេងទៀត រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តការលើកលែងពន្ធទៅលើអាជីវកម្ម និងក្រុមហ៊ុនក្នុងវិស័យមួយចំនួនដែលរងផលប៉ះពាល់ខ្លាំងជាពិសេសវិស័យទេសចរណ៍។ អាជីវកម្មទាក់ទងនឹងវិស័យទេសចរណ៍ សណ្ឋាគារ និងផ្ទះសំណាក់ចំនួន៧ខេត្ត នឹងត្រូវបានអនុគ្រោះទៅលើការបង់ពន្ធប្រចាំខែក្នុងរយៈពេល៤ខែ គិតចាប់ពីខែកុម្ភៈឆ្នាំ

[41] ២០២១, ១មករា). ចំណូលពន្ធដាឆ្នាំ ២០២០ កើនជិត៤ភាគរយ. ដកស្រង់ចេញពី៖ https://www.postkhmer.com/

[42] (កុម្ភៈ ២០២១). ផលប៉ះពាល់នៃកូវីដ១៩ ទៅលើសង្គម និងសេដ្ឋកិច្ចកម្ពុជា, Impacts of COVID-19 Crisis on Cambodia's Socio-Economy

២០២០ ដល់ខែឧសភាឆ្នាំ ២០២០។[43] គួរបញ្ជាក់ថាការមិនយកពន្ធនេះគឺដើម្បីជួយកាត់បន្ថយផលប៉ះពាល់នៃស្ថានភាពជំងឺឆ្លងកូវីដ-១៩ ដែលធ្វើឱ្យភ្ញៀវទេសចរណ៍ជនជាតិចិនមានការធ្លាក់ចុះយ៉ាងគំហុគ។ ក្រោយមករដ្ឋាភិបាលបានប្រកាសបន្តលើកលែងការបង់ពន្ធ២ខែទៀតពោលគឺ ចាប់ពីខែមិថុនារហូតដល់ខែកក្កដាឆ្នាំ ២០២០ និងក្រោយមកបានបន្តលើកលែង៣ខែ បន្ថែមទៀតចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២០កន្លងទៅ ។[44] ដោយឡែកតាមសេចក្តីប្រកាសរបស់របស់រដ្ឋាភិបាលដែលចេញផ្សាយកាលពីថ្ងៃទី ២៣ ធ្នូឆ្នាំ២០២០ កន្លងទៅរាជរដ្ឋាភិបាលបន្តការលើកលែងពន្ធប្រចាំខែម្រាប់អាជីវកម្មទេសចរណ៍ក្នុងខេត្តក្រុងមួយចំនួនរួមមានរាជធានីភ្នំពេញ សៀមរាប ព្រះសីហនុ កែប កំពត បារិត និងក្រុងប៉ោយប៉ែត ចំនួន៣ខែបន្ថែមទៀតដែលត្រូវបានអនុវត្តចាប់ពីខែ មករា រហូតដល់ខែ មីនា ឆ្នាំ២០២១។

មិនខុសពីវិស័យទេសចរណ៍ការលើកលែងពន្ធនេះ ក៏បានអនុវត្តផងដែរទៅលើឧស្សាហកម្មផ្សេងៗនៅក្នុងវិស័យកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង និងកាបូបជាដើម។ ជាក់ស្តែងឧស្សាហកម្មទាំងនេះត្រូវបានលើកលែងពន្ធក្នុងរយៈពេលចាប់ពី ៦ខែទៅ ១ឆ្នាំ ដែលត្រូវបានផ្តល់ជូនសម្រាប់រោងចក្រដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារកង្វះខាតនូវវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់ខ្សែរសង្វាក់ផលិតកម្មដែលបណ្តាលមកពីវិបត្តិកូវីដ-១៩ ឬដោយសារការព្យួរលក្ខខណ្ឌពិសេស EBA ពីប្រទេសសហគមន៍អឺរ៉ុបកាលពីឆ្នាំ២០២០កន្លងទៅ (ធនាគារជាតិ, ២០២០)។[45]

### ២.៥.២.២. ការត្រៀមទុនបម្រុងសម្រាប់ទប់ទល់ និងឱនភាពសេដ្ឋកិច្ច

ដើម្បីចូលរួមដោះស្រាយនូវផលប៉ះពាល់ទៅលើឱនភាពសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលបានប្រកាសថានឹងបញ្ចេញថវិកាពីទុនបម្រុងរបស់ជាតិ ដើម្បីគាំទ្រដល់ការចំណាយដើម្បីទ្រទ្រង់ជំរុញព្រមទាំងស្តារសេដ្ឋកិច្ចប្រទេសឡើងវិញតាមរយៈការផ្តល់ជាប្រភពទុនដល់សហគ្រាសធុនតូចនិងមធ្យមលើគ្រប់វិស័យដើម្បីស្តារ និងពង្រឹងសមត្ថភាពអាជីវកម្មរបស់ខ្លួនឡើងវិញក្នុងអំឡុងពេលមានវិបត្តិកូវីដ-១៩ ក៏ដូចជាបន្ទាប់ពីវិបត្តិនេះបានបញ្ចប់ទៅវិញជាដើម។

[43] (២០២០, ១២ កុម្ភៈ). អេស៊ីលីដាចំណេញជាង១៤១លានដុល្លារនៅឆ្នាំ ២០២០ ទោះបីមានកូវីដ-19 តាមរំខាន. ដកស្រង់ចេញពីគេហទំព័រ៖https://cambonomist.com/news/acleda-bank-net-profit-2020/?fbclid=IwAR3a3PHF8pcsYIFXubK_umrpLOOVX-DXT5qSmESoUweTzrk031jsPSQnuG8

[44] Construction & Property. (2020, 24,12). រដ្ឋប្រកាសលើកលែងបង់ពន្ធលើអាជីវកម្មសណ្ឋាគារ និងទេសចរណ៍ ៣ខែបន្ថែមទៀតសម្រាប់ឆ្នាំ២០២១.ដកស្រង់ចេញពីគេហទំព័រ៖ https://www.construction-property.com/km/govt-continues-tourism-related-business-tax-exemption-for-another-three-months/

[45] ធនគារជាតិ (២០២០). ការអនុវត្តថវិការដ្ឋឆ្នាំ២០២០, ដកស្រង់ចេញពីគេហទំព័រធនគារជាតិ៖ https://mef.gov.kh/assets/uploads/2021/01/TOFE_November-KH-2020.pdf

### ២.៥.២.៣. កម្មវិធីជំនួយហិរញ្ញវត្ថុសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ

បន្ថែមពីលើវិធានការណ៍ហិរញ្ញវត្ថុដើម្បីគាំទ្រសកម្មភាពសេដ្ឋកិច្ចខាងលើរាជរដ្ឋាភិបាលក៏បានចាប់ផ្តើមកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះចំនួន ៥៦២.៦៨៦ គ្រួសារដែលមានចំនួនជិត ២,៣ លាននាក់។ តាមគេហទំព័ររបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ថារាជរដ្ឋាភិបាលចាំបាច់ត្រូវចំណាយប្រហែល ២៥លានដុល្លារក្នុងមួយខែសម្រាប់កម្មវិធីនេះ។ ដោយឡែកវិបត្តិមួយនេះនៅតែបន្តអូសបន្លាយយើងមិនទាន់អាចសន្និដ្ឋានបានថា តើរដ្ឋាភិបាលកម្ពុជាត្រូវចំណាយអស់ថវិកាប៉ុន្មានដើម្បីគាំទ្រគម្រោងមួយនេះនៅឡើយទេ។

### ២.៥.២.៤. ការឧបត្ថម្ភកម្មករនិយោជិកដែលបានត្រូវព្យួរពីការងារ

ដោយឡែកក្រៅអំពីការប្រកាសលើកលែងពន្ធសម្រាប់អាជីវកម្មនានា ក្នុងវិស័យទេសចរណ៍សណ្ឋាគារ និងឧស្សាហកម្មនានា ហើយរាជរដ្ឋាភិបាលក៏បានចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ឧបត្ថម្ភដល់និយោជកដែលត្រូវបានព្យួរការងារផងដែរ។ សម្រាប់អាជីវកម្មក្នុងវិស័យទេសចរណ៍ ឬរោងចក្រឧស្សាហកម្មដែលបិទទ្វាររដ្ឋាភិបាលនឹងផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៤០ដុល្លារសម្រាប់កម្មករនិយោជិកដែលត្រូវបានព្យួរពីការងារ ហើយម្ចាស់រោងចក្រនឹងត្រូវផ្តល់ប្រាក់ ៣០ ដុល្លារបន្ថែមទៀតសរុបចំនួន ៧០ ដុល្លារក្នុងមួយខែសម្រាប់ម្នាក់ៗ។ យើងសង្កេតឃើញថារហូតមកដល់បច្ចុប្បន្ន (គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២១) រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការឧបត្ថម្ភនិយោជិត កម្មករ និង បុគ្គលិកក្រុមហ៊ុនឯកជនក្នុងវិស័យកាត់ដេរ និងទេសចរណ៍ប្រមាណ៥០លើករួចមកហើយ។ ចំនួន កម្មករដែលទទួលបានការឧបត្ថម្ភមួយលើកៗ មានក្នុងតារាងខាងក្រោម៖

តារាងទី ៤៖ ទិន្នន័យការឧបត្ថម្ភបុគ្គលិក កម្មករ ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍

| ការឧបត្ថម្ភ ( លើក ) | និយោជិត ( នាក់ ) | វិស័យ (ចំនួន) | ការឧបត្ថម្ភ ( លើក ) | និយោជិត ( នាក់ ) | វិស័យ ( ចំនួន ) |
|---|---|---|---|---|---|
| ទី១ | - | - | ទី២៦ | ៥,២៣១ | កាត់ដេរ ( ១៣ ) |
| ទី២ | ២៥,៥៨៨ | កាត់ដេរ និង ទេសចរណ៍ ( ៦៧ ) | ទី២៧ | ១៤,៦០១ | កាត់ដេរ និង ទេសចរណ៍ ( ៥១ ) |
| ទី៣ | ៣៣,២៣១ | កាត់ដេរ និង ទេសចរណ៍ ( ១១១ ) | ទី២៨ | ៥,៤០២ | កាត់ដេរ ( ១៨) |

| | | | | | | |
|---|---|---|---|---|---|---|
| | ៤៩,៩៦០ | កាត់ដេរ និង ទេសចរណ៍ ( ១៦៥ ) | | | | |
| ទី៤ | ១៧,០៥២ | កាត់ដេរ និង ទេសចរណ៍ ( ៥០ ) | | ទី២៩ | ៨,២៧៨ | កាត់ដេរ និង ទេសចរណ៍ ( ៦២ ) |
| ទី៥ | ៧,៦១២ | កាត់ដេរ ( ៨ ) | | ទី៣០ | ៩,២៣២ | កាត់ដេរ និង ទេសចរណ៍ ( ៥៥ ) |
| ទី៦ | ២២,៣៣២ | កាត់ដេរ និង ទេសចរណ៍ ( ៩១ ) | | ទី៣១ | ៣,២០៩ | កាត់ដេរ ( ៣ ) |
| ទី៧ | ១២,៧៦០ | កាត់ដេរ និង ទេសចរណ៍ ( ៣៤ ) | | ទី៣២ | ២២,៦០៨ | កាត់ដេរ និង ទេសចរណ៍ ( ១០១ ) |
| ទី៨ | ៧,០២៨ | កាត់ដេរ និង ទេសចរណ៍ ( ៤៤ ) | | ទី៣៣ | ៣.១៥៨ | កាត់ដេរ (៩ ) |
| ទី៩ | ៣,៥៣៦ | កាត់ដេរ និង ទេសចរណ៍ ( ១៩ ) | | ទី៣៤ | ១,៩៣៧ | កាត់ដេរ ( ៩ ) |
| ទី១០ | ១១,៥៧០ | កាត់ដេរ ( ១៤ ) | | ទី៣៥ | ៨,១០៧ | កាត់ដេរ និង ទេសចរណ៍ ( ៣០ ) |
| ទី១១ | ២,២៩០ | កាត់ដេរ និង ទេសចរណ៍ | | ទី៣៦ | ៨,៥៧៤ | កាត់ដេរ និង ទេសចរណ៍ |

| | | | | | | |
|---|---|---|---|---|---|---|
| | | ( ៩៦ ) | | | | ( ៦៣ ) |
| ទី១២ | ៣០,៧០៤ | កាត់ដេរ និង ទេសចរណ៍ ( ៩៦ ) | | ទី៣៧ | ៩,០៥១ | កាត់ដេរ និង ទេសចរណ៍ ( ៦៦ ) |
| ទី១៣ | ១៩,៧០៨ | កាត់ដេរ និង ទេសចរណ៍ ( ៦០ ) | | ទី៣៨ | ១,៥៧១ | កាត់ដេរ ( ៣ ) |
| ទី១៤ | ៣១,៧៦៤ | កាត់ដេរ និង ទេសចរណ៍ ( ១៤០ ) | | ទី៣៩ | ៤,៧៨៦ | កាត់ដេរ ( ១៩ ) |
| ទី១៥ | ៧,២៧៧ | កាត់ដេរ ( ៧ ) | | ទី៤០ | ២,៦១៩ | កាត់ដេរ និង ទេសចរណ៍ ( ២២ ) |
| ទី១៦ | ១៤.៦៨៣ | កាត់ដេរ និង ទេសចរណ៍ ( ៤៤ ) | | ទី៤១ | ២,២៣៦ | កាត់ដេរ ( ១២ ) |
| ទី១៧ | ១២,៤១០ | កាត់ដេរ និង ទេសចរណ៍ ( ៤៤ ) | | ទី៤២ | ៩,៩៤៦ | កាត់ដេរ និង ទេសចរណ៍ ( ៦៥ ) |
| ទី១៨ | ២៧.៩៣៧ | កាត់ដេរ និង ទេសចរណ៍ ( ៨៥ ) | | ទី៤៣ | ៣,១៤០ | កាត់ដេរ ( ៥ ) |
| ទី១៩ | ១៨,៨១៤ | កាត់ដេរ និង ទេសចរណ៍ ( ៦២ ) | | ទី៤៤ | ៤,៨៣៨ | កាត់ដេរ និង ទេសចរណ៍ ( ២៨ ) |

| | | | | | |
|---|---|---|---|---|---|
| ទី២០ | ១២,៤៥៥ | កាត់ដេរ និង ទេសចរណ៍ ( ៧៩ ) | ទី៤៥ | ៨,៤៨៤ | កាត់ដេរ និង ទេសចរណ៍ ( ៦៦ ) |
| ទី២១ | ៧,២៧៩ | កាត់ដេរ និង ទេសចរណ៍ ( ១០ ) | ទី៤៦ | ២,៣២៨ | កាត់ដេរ និង ទេសចរណ៍ ( ២៧ ) |
| ទី២២ | ៨,០៨៩ | កាត់ដេរ និង ទេសចរណ៍ ( ៤៦ ) | ទី៤៧ | ១,១៣៣ | កាត់ដេរ និង ទេសចរណ៍ ( ១៤ ) |
| ទី២៣ | ១៥,៤៨៤ | កាត់ដេរ និង ទេសចរណ៍ ( ៦៦ ) | ទី៤៨ | ២,០៧៧ | កាត់ដេរ ( ៦ ) |
| ទី២៤ | ១០,៥០១ | កាត់ដេរ និង ទេសចរណ៍ ( ៤៤ ) | ទី៤៩ | ៦,០៤០ | កាត់ដេរ និង ទេសចរណ៍ ( ៣៩ ) |
| ទី២៥ | ១០,៥៩២ | កាត់ដេរ និង ទេសចរណ៍ ( ៤៣ ) | ទី៥០ | ៤,២៥៦ | កាត់ដេរ និង ទេសចរណ៍ ( ៣៤ ) |
| ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | | | |

### ២.៥.២.៥. ការចំណាយទៅលើការបង្ការជំងឺកូវីដ-១៩

យើងសង្កេតឃើញថាដើម្បីកិច្ចការងារព្យាបាល និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងទ្រង់ទ្រាយធំជាពិសេសការឆ្លងក្នុងសហគមន៍រាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ខ្ទង់ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់កិច្ចការធំៗ មួយចំនួនដូចខាងក្រោម៖

- បោះពុម្ពលិខិតប័ណ្ណ ឬរៀបចំសារផ្សព្វផ្សាយពីវិធានការការពារ

- ចំណាយនៅតាមមូលដ្ឋានជាពិសេសតំបន់ព្រំដែនជាមួយប្រទេសជិតខាងក្នុងការទប់ស្កាត់
- រៀបចំមណ្ឌលធ្វើចត្តាឡីស័កនៅទូទាំងប្រទេស
- ចំណាយទៅលើការធ្វើតេស្តរកមេរោគកូវីដ-១៩
- ចំណាយទៅលើការឧបត្ថម្ភមន្ត្រីសុខាភិបាល និងបុគ្គលពាក់ព័ន្ធលើកិច្ចការនេះ
- ចំណាយទៅលើបរិក្ខារពេទ្យចាំបាច់ (ម៉ាស់ អាល់កុល ។ល។)
- ចំណាយលើការដឹកជញ្ជូនបងប្អូនកម្មករទៅកាន់គោលដៅសម្រាប់ការរៀបចំធ្វើចត្តាឡីស័កជាដើម។

ជាក់ស្តែងថ្លៃចំណាយចំពោះអ្នកជំងឺកូវីដ-១៩ ម្នាក់ៗគិតចាប់តាំងពីការធ្វើតេស្តលើកដំបូងរហូតដល់ព្យាបាលជាសះស្បើយ គឺត្រូវការថវិកាប្រមាណជាង ២០០០ដុល្លាឬអាចឈានដល់២៥០០ដុល្លារក្នុងម្នាក់ៗ។[46] ការចំណាយនេះប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង របស់អ្នកជំងឺដូចជាបើអ្នកជំងឺអស់កម្លាំង ក្រសួងនឹងផ្តល់ថ្នាំ ឬសេរ៉ូមកម្លាំង វីតាមីន និងថ្នាំផ្សេងៗ ទៀតបំប៉នសុខភាព និងព្យាបាលទៅតាមរោគសញ្ញាព្រមទាំងអាហារហូបចុកទៀតក្រៅពីការចំណាយទៅលើថ្លៃព្យាបាលអ្នកជំងឺ រដ្ឋាភិបាលក៏បានចំណាយថវិកាសម្រាប់ការលើកទឹកចិត្តចិត្តចំពោះក្រុមគ្រូពេទ្យជួរមុខ និងមន្ត្រីសុខាភិបាលពាក់ព័ន្ធចំនួន២០ម៉ឺនរៀលក្នុងមួយថ្ងៃបន្ថែមពីលើប្រាក់បៀវត្សប្រចាំខែរបស់ពួកគាត់ផងដែរ។

#### ២.៥.២.៦. ការចំណាយសម្រាប់គោលដៅផ្សេងៗទៀត

ក្រៅពីការចំណាយទៅលើកិច្ចការធំៗខាងលើរាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំកញ្ចប់ថវិកាមួយចំនួននៅក្នុងវិស័យសង្គមកិច្ចដោយធ្វើការបញ្ចេញនូវគម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ និងគាំទ្រកសិករនៅខេត្តគោលដៅខេត្តគោលដៅចំនួន១៨ ផងដែរ។ ក្រៅពីនេះរាជរដ្ឋាភិបាលបានសម្រេចបង្កើនទំហំថវិកាសម្រាប់គម្រោងនេះពីប្រមាណជិត ៣៨ លានដុល្លារ ទៅដល់ប្រមាណ ១០០ លានដុល្លារ។ ក្នុងឆ្នាំ២០២០គម្រោងនេះនឹងផ្តល់ជូនប្រជាពលរដ្ឋដែលបានបាត់បង់ការងារហើយវិលត្រឡប់ទៅស្រុកកំណើតវិញ(ទាំងពីក្នុងនិងក្រៅប្រទេស) ក៏ដូចជាប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍នូវឱកាសទទួលបានការងាររយៈពេលខ្លីជាមួយ នឹងប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃក្នុងចំនួនរហូតដល់ប្រមាណជិត ១ លាននាក់។

## ២.៦. ផលប៉ះពាល់លើការងារ និងមុខរបរ

[46] (២០២០, ២០ មេសា) តើក្រសួងចំណាយថ្លៃព្យាបាលអ្នកផ្ទុក Covid-19 ម្នាក់អស់ប៉ុន្មាន? ដកស្រង់ចេញពីគេហទំព័រ https://hellokrupet.com/

ផលប៉ះពាល់លើការងារនិងមុខរបរក្រៅពីផលប៉ះពាល់ទៅលើវិស័យនានា ដូចដែលបានរៀបរាប់ខាងលើថាវិបត្តិកូវីដ-១៩ នេះក៏បានវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើការងារ និងមុខរបរប្រជាពលរដ្ឋទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធគ្រប់ប្រភេទ។ អង្គការស្បៀងអាហារនិងកសិកម្មពិភពលោក (FAO) បានធ្វើការគូសបញ្ជាក់ថាជំងឺរាតត្បាតកូវីដ-១៩ នឹងធ្វើឱ្យមានផលប៉ះពាល់ខ្លាំងទៅលើក្រុមជនងាយរងគ្រោះ ដូចជាស្ត្រី កុមារ ជនជាតិដើមភាគតិច និងពលករចំណាកស្រុកជាដើម ។[47]

### ២.៦.១. ផលប៉ះពាល់លើការងារក្នុងវិស័យឧស្សាហកម្ម

ក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ឧស្សាហកម្មកាត់ដេរ ក៏ដូចជាឧស្សាហកម្មផ្សេងៗទៀតបានដើរតួយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងអភិវឌ្ឍសង្គមកម្ពុជា។ តាមទិន្នន័យនៃការនាំចេញផលិតផលកាត់ដេរកម្ពុជាក្នុងរយៈពេល ១០ឆ្នាំចុងក្រោយការនាំចេញផលិតផលកាត់ដេរមានការកើនឡើងជារៀងរាល់ឆ្នាំ ដោយមានប្រមាណជាង ៣ ប៊ីលានដុល្លានៅឆ្នាំ២០១០ ហើយបានកើនឡើងដល់ជាង១០ប៊ីលានដុល្លាក្នុងឆ្នាំ២០១៩ កន្លងទៅ។

ក្រាហ្វិកទី ១៣៖ ការនាំចេញផលិតផលកាត់ដេរ និងស្បែកជើង ២០១០ ដល់ ២០១៩




*ប្រភព៖ ក្រសួងពាណិជ្ជកម្ម ២០២០*

ក្នុងន័យនេះយើងអាចធ្វើការសន្និដ្ឋានបានថាវិស័យឧស្សាហកម្មកាត់ដេរបានបង្កើតការងារដល់ពលរដ្ឋកម្ពុជារាប់សិបម៉ឺននាក់ព្រមទាំងបានចូលរួមដោយផ្ទាល់ និងដោយប្រយោលផងដែរក្នុងការបង្កើតនូវមុខរបរ

47Open Development Cambodia. (2020,29 ,09) https://opendevelopmentcambodia.net/km/profiles/socio-economic-impact-of-covid-19-on-cambodia/

និងអាជីវកម្មដល់ប្រជាពលរដ្ឋដែលរស់នៅជុំវិញមជ្ឈមណ្ឌលឬសួនឧស្សាហកម្មតូចធំនានា ក៏ដូចជាតំបន់ដែលស្ថិតនៅក្បែរៗនោះផងដែរ។ ដោយឡែកវិបត្តិកូវីដ-១៩បានធ្វើឱ្យរោងចក្រកាត់ដេរជាច្រើនបានផ្អាកសកម្មភាព និងមួយចំនួនទៀតឈានទៅដល់ការបិទដំណើរការផលិតកម្មទាំងស្រុងដោយសារតែខ្វះវត្ថុធាតុដើមនិបាត់បង់ ឬពន្យាបញ្ជាទិញទំនិញពីបរទេសជាដើម ។ តាមព័ត៌មានពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈវិបត្តិកូវីដ-១៩នេះបានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចរាជធានីខេត្តចំនួន១២ នៅទូទាំងប្រទេសកម្ពុជាហើយបានប៉ះពាល់លើការងារ និងជីវភាពរបស់កម្មករ-កម្មការិនីរាប់ម៉ឺននាក់។

គិតត្រឹមថ្ងៃទី៧ ខែសីហាឆ្នាំ២០២០នេះ កម្មករ-កម្មការិនីដែលបានផ្អាកការងារមានចំនួនសរុប ២៨៣ ៣២០ នាក់ ក្នុងនោះមានកម្មការិនី ២៣២ ៤៦៣នាក់។ តាមទិន្នន័យដដែលនេះ យើងឃើញមានរោងចក្រដែលបានផ្អាកសកម្មភាពជិត ៥០០រោងចក្រ និងរោងចក្រដែលបានដាក់ពាក្យបិទដំណើរការរបស់ខ្លួនទាំងស្រុងមានចំនួន ៨៣រោងចក្រ។ ដោយឡែកសហគ្រាសតូច និងមធ្យមដែលបានផ្អាកដំណើរការរបស់ខ្លួនមានប្រមាណជា ៩០៥ សហគ្រាស និងធ្វើឱ្យប៉ះពាល់ដល់បុគ្គលិកសរុបប្រមាណជាង ៣ម៉ឺននាក់។

តារាងទី ៥ ៖ ទិន្នន័យសហគ្រាសរបស់ក្រុមហ៊ុនដែលរងផលប៉ះពាល់ពីកូវីដ-១៩

| ប្រភេទទិន្នន័យ | ចំនួនសហគ្រាស/ក្រុមហ៊ុន | ប្រភេទទិន្នន័យ | ចំនួនសរុប ( ភេទស្រី ) |
|---|---|---|---|
| រោងចក្រផ្អាកសកម្មភាព | ៤៨៧ | កម្មករផ្អាកការងារ | ២៨៣ ៣២០ ( ២៣២ ៤៦៣ ) |
| រោងចក្របានបិទ | ៨៣ | កម្មករបាត់បង់ការងារ | ៣១ ៥៣៨ ( ២៥ ៣៥៥ ) |
| រោងចក្រទទួលបានប្រាក់ឧបត្ថម្ភដល់កម្មករ | ៤៨៧ | កម្មករទទួលបានប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល | ២៨៣ ៣២០ ( ២៣២ ៤៦៣ ) |
| សហគ្រាសតូចមធ្យមដែលបានផ្អាកដំណើរការ | ៩០៥ | បុគ្គលិកសហគ្រាសតូចមធ្យមដែលផ្អាក់ការងារ | ៣០ ៨១៩ ( ១៣ ៩៥៦ ) |
| ទិន្នន័យគិតត្រឹម ថ្ងៃទី៧ សីហា | | | |

ក្នុងបរិបទនេះផលប៉ះពាល់មិនត្រឹមតែការងារប៉ុណ្ណោះទេ វិបត្តិមួយនេះបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាព និងការរស់នៅកម្មករ-កម្មការិនីទាំងឡាយ។ កម្មករ-កម្មការិនីក៏ដូចជាប្រធាន និងអនុប្រធានសហជីពកម្មករមួយចំនួនបានសង្កត់ធ្ងន់ថា កម្មករភាគច្រើនជួបប្រទះនឹងកង្វះថវិកាចំណាយប្រចាំថ្ងៃក៏ដូចជាការសងបំណុលជាដើម។ ជាក់ស្តែងកម្មករ-កម្មការិនីជាច្រើនមានជាប់បំណុលធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗតាមរយៈកម្ចី បង់រំលស់ម៉ូតូ ទូរសព្ទដៃ ដីឡូត៍ និងផ្ទះល្វែង ជាដើម។ ដូច្នេះការបាត់បង់ការងារស្ទួលបានធ្វើឱ្យកម្រិតជីវភាពរបស់ពួកគេកាន់តែធ្លាក់ចុះថមមួយកម្រិតទៀត។ បើទោះបីជាមានការឧបត្ថម្ភខ្លះៗជាថវិកាចំនួន ៤០ដុល្លារពីរាជរដ្ឋាភិបាលនិងមួយភាគពីសំណាក់ម្ចាស់រោងចក្រក្តីក៏ស្ថានភាពបែបនេះបានត្រឹមតែដោះស្រាយមួយរយៈពេលខ្លីប៉ុណ្ណោះ។ ប្រសិនបើវិបត្តិមួយនេះកាន់តែរីករាលដាល ឬបន្តអូសបន្លាយក្នុងរយៈពេលវែងបន្តទៀតកម្មករក៏ដូចជាបុគ្គលិកឯកជនកាន់តែច្រើនថែមទៀត នឹងប្រឈមមុខនឹងបញ្ហាជីវភាពកាន់តែធ្ងន់ធ្ងរ។

### ២.៦.២. ផលប៉ះពាល់លើមុខរបរ និងអាជីវកម្មក្នុងវិស័យទេសចរណ៍

ក្រៅពីការប៉ះពាល់ដល់វិស័យទេសចរណ៍ជាតិ ក្នុងទម្រង់ជាម៉ាក្រូសេដ្ឋកិច្ចហើយយើងសង្កេតឃើញថាផលប៉ះពាល់នេះក៏បានធ្លាក់ទៅលើអាជីវកម្មខ្នាតតូច មធ្យម ក៏ដូចជាការវិនិយោគកម្រិតធំក្នុងវិស័យទេសចរណ៍នេះផងដែរអាជីវកម្មដូចជាផ្ទះសំណាក់ សណ្ឋាគារ អាជីវកម្មលក់វត្ថុ អនុស្សាវរីយ ហាងអាហារភោជនីយដ្ឋាន ព្រមទាំងប្រជាពលរដ្ឋប្រកបរបរតូចតាចដូចជា រត់ម៉ូតូឌុប រត់ កង់បី រត់តាក់ស៊ីជាដើមសុទ្ធតែទទួលរងផលប៉ះពាល់ដូចគ្នា ជាពិសេសនៅក្នុងខេត្តសៀមរាបតែម្តង។ ជាមួយគ្នានេះដែរលោក **សឿង ស៊ីថា** ដែលជាប្រធានការិយាល័យទីក្រុងស្អាតនៃមន្ទីរទេសចរណ៍ខេត្តសៀមរាបបានគូសបញ្ជាក់ថាចាប់ពីខែមេសា ២០២០ មកអាជីវកម្មដែលបម្រើវិស័យទេសចរណ៍ត្រូវផ្អាកដំណើរការក្នុងចន្លោះពី ៧៥%-៩០% ហើយបុគ្គលិកបម្រើការងារក្នុងអាជីវកម្មទាំងនេះប្រមាណ ៩០% ត្រូវបានផ្អាកការងារ។ គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០០អាជីវកម្មបម្រើឱ្យ វិស័យទេសចរណ៍សរុបចំនួន ២ ៨៣៨ ទីតាំងស្មើនឹង ២៩.៦៣% នៃអាជីវកម្មសរុបបានបិទព្យួរដែលធ្វើឱ្យប៉ះពាល់ដល់បុគ្គលិកសរុប ៥០៩៩៦នាក់។ ជាក់ស្តែងអាជីវកម្មទេសចរណ៍នៅក្នុងខេត្តសៀមរាបដែលជាទីតាំងទេសចរណ៍គោលដៅសំខាន់ជាងគេមានអាជីវកម្មទេសចរណ៍ចំនួន ៦៥៨ទីតាំងត្រូវបានបិទព្យួរដែលស្មើនឹង៦២.១៣% នៃអាជីវកម្មសរុបក្នុងខេត្តសៀមរាប។ ការបិទនិងផ្អាកអាជីវកម្មក្នុងខេត្តសៀមរាបនេះបណ្តាលឱ្យបុគ្គលិកសរុបចំនួនជាង ១៤ ៧០២ នាក់បានបាត់បង់ការងារផងដែរ ។[48] វិបត្តិនៃជំងឺកូវីដ១៩ បាន

[48] (២០២០,៦ វិច្ឆិកា) វិស័យទេសចរណ៍២០២០ កម្ពុជាខាតចំណូលជាង៣ពាន់លានដុល្លារ ស្របពេលអាជីវកម្មទេសចរណ៍ត្រូវបានតិទទ្វារជិត៣ពាន់ទីទាំង ប៉ះពាល់ដល់បុគ្គលជិត ៥មឺននាក់.ដកស្រង់ចេញពីគេហទំព័រ៖ https://www.cpc-news.com/archives/115804

ធ្វើឱ្យអាជីវកម្មទេសចរណ៍ទាំងឡាយនៅទូទាំងប្រទេស ត្រូវបានផ្អាកដំណើរការនិងបិទបញ្ចប់អាជីវកម្មមានចំនួនសរុប២,៨៦៥ ទីតាំងដោយបានធ្វើឱ្យប៉ះពាល់ការងាររបស់បុគ្គលិកចំនួន ៤៦,៣៦៩នាក់ចំណែកឯមគ្គុទ្ទេសក៍ទេសចរណ៍ដែលបានព្យួរអាជ្ញាបណ្ណទេសចរណ៍មានចំនួនសរុប ៩៦នាក់។

បើតាមឯកឧត្តម **ថោង ខុន** រដ្ឋមន្រ្តីក្រសួងទេសចរណ៍ ដែលបានថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាននាថ្ងៃទី ២៩ ខែមេសា កន្លងទៅនេះបានឱ្យដឹងថា *«គិតត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ អាជីវកម្មទេសចរណ៍ដែលត្រូវបានបិទ (បិទដោយការផ្អាកដំណើរការ និងបិទបញ្ចប់អាជីវកម្ម) នៅទូទាំងប្រទេសមានចំនួនសរុប ២,៨៦៥ទីតាំង ស្មើនឹង ២៩. ៥៧% ធៀបនឹងទីតាំងអាជីវកម្មទេសចរណ៍សរុបដែលមាន ៩,៦៨៩ទីតាំង (សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ម៉ាស្សា ស្ប៉ា ទីភ្នាក់ងារទេសចរណ៍ ខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀហ្គាឌិន និងកីឡាទេសចរណ៍) និងបានប៉ះពាល់ដល់បុគ្គលិកចំនួន ៤៦,៣៦៩នាក់ស្មើនឹង៤២.៦% ធៀបនឹងបុគ្គលិកសរុប១០៨,៨៤៧នាក់ និងមគ្គុទ្ទេសក៍ទេសចរណ៍ព្យួរអាជ្ញាបណ្ណទេសចរណ៍សរុបចំនួន៩៦នាក់ស្មើនឹង១.៥%ធៀបនឹងចំនួនមគ្គុទ្ទេសក៍ ទេសចរណ៍សរុប៦,៤១៦ នាក់»*។

- ចំពោះសេវាកម្មស្នាក់នៅផ្នែកសណ្ឋាគារ ត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ២៨២សណ្ឋាគារ (១៥, ៤៨៨ បន្ទប់) ស្មើនឹង២៧% ធៀបនឹងចំនួនសណ្ឋាគារសរុបដែលមាន ១,០៤៤ទីតាំង (៤៨,៧៩១បន្ទប់) និងប៉ះពាល់បុគ្គលិក ១៦,២០៣នាក់ស្មើនឹង៤១% ធៀបនឹងបុគ្គលិកសរុប៣៩,១៥១ នាក់។
- ចំពោះផ្ទះភ្ញៀវ (ផ្ទះសំណាក់) ត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ៤០៥ទីតាំង (៥,៦៤៤បន្ទប់) ស្មើនឹង១៥% ធៀបនឹងចំនួនផ្ទះភ្ញៀវសរុបដែលមាន ២,៦៤៣ទីតាំង (៣៤,៩៥៧បន្ទប់) និងប៉ះពាល់បុគ្គលិក ២,០៨៧នាក់ស្មើនឹង១៩.៥% ធៀបនឹងបុគ្គលិកសរុប១០,៦៦៩ នាក់។
- ចំពោះភោជនីយដ្ឋាន ត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ៣៧១ទីតាំង (១៧,០២៧កៅអី) ស្មើនឹង ១០.៨% ធៀបនឹងចំនួនភោជនីយដ្ឋានសរុបដែលមាន ៣,៤១៥ទីតាំង (១៦៧,៦៣៨កៅអី)ប៉ះពាល់បុគ្គលិក ចំនួន ៣,២០១នាក់ ស្មើនឹង១១.១១% ធៀបនឹងបុគ្គលិកសរុប២៨,៧៣៨ នាក់។
- ចំពោះទីភ្នាក់ងារទេសចរណ៍ ត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ៤៧ ទីតាំងស្មើនឹង ៦.៤៧% ធៀបនឹងចំនួនអាជីវកម្មទីភ្នាក់ងារទេសចរណ៍សរុប ៧២៦ទីតាំង ប៉ះពាល់បុគ្គលិក ២០៨នាក់ស្មើនឹង៦%ធៀបនឹងបុគ្គលិកសរុប ៣,៤៤៤ នាក់។
- ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ បានព្យួរអាជ្ញាបណ្ណទេសចរណ៍នៅទូទាំងប្រទេសមានចំនួន ៩៦នាក់ ស្មើនឹង ១.៥% ធៀប នឹងចំនួនមគ្គុទ្ទេសក៍ទេសចរណ៍សរុប ៦,៤១៦នាក់។
- ចំពោះសេវាកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ( ខារ៉ាអូខេ រង្គសាលឌីស្កូតែក បៀហ្គាឌិន ) ត្រូវបានបិទ អាជីវកម្មទាំងស្រុងនៅទូទាំងប្រទេសមានចំនួន ១,១៤៧ទីតាំង ប៉ះពាល់បុគ្គលិកសរុប១៨,២០៤នាក់។ ប្រភេទសេវាកម្មខារ៉ាអូខេត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ៨៨០ទីតាំង (ស្មើនឹង១០០%) និងប៉ះពាល់បុគ្គលិក សរុប ១៤,១៦១នាក់ ប្រភេទសេវាកម្មរង្គសាលឌីស្កូតែកត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ២០០ទីតាំង (ស្មើនឹង

១០០%) និងប៉ះពាល់បុគ្គលិកសរុប ៣,០៧៨នាក់ប្រភេទសេវាកម្មបៀហ្គាឌិនត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ៦៧ទីតាំង (ស្មើនឹង ១០០%) និងប៉ះពាល់បុគ្គលិកសរុប៩៦៥ នាក់។

- ចំពោះសេវាកម្មស្ប៉ា និងម៉ាស្សាត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន ៥៩០ទីតាំង (៤,៦៤៤គ្រែ) ស្មើនឹង ៨៨% ធៀបនឹងចំនួនអាជីវកម្មស្ប៉ា និងម៉ាស្សាសរុបដែលមាន ៦៦៨ទីតាំង (៥,២៩៣គ្រែ) ប៉ះពាល់បុគ្គលិកចំនួន ៥, ៩៤៨ នាក់ ស្មើនឹង៩៥% ធៀបនឹងបុគ្គលិកសរុប៦,២៤៧ នាក់។
- ចំពោះអាជីវកម្មកីឡាទេសចរណ៍ (កីឡាប៊ូលីង អាងហែលទឹក ទូកកែយ៉ាក់ បាឡុងបង្ហោះ ស្ទូកឃ័រ ម៉ាស៊ីនហ្គេម) ត្រូវបានផ្អាកបណ្តោះអាសន្ននៅទូទាំងប្រទេសមានចំនួន ២៣ទីតាំង ស្មើនឹង៥០%ធៀបនឹងចំនួនអាជីវកម្មកីឡាទេសចរណ៍សរុប៤៦ទីតាំងនិងប៉ះពាល់បុគ្គលិក៥១៨នាក់ស្មើនឹង២២%ធៀបនឹងបុគ្គលិកសរុប ២,៣ ២២នាក់។

បន្ថែមលើនេះទៀត ប្រជាពលរដ្ឋដែលកំពុងមានមុខរបរក្នុងលក្ខណៈជាសេដ្ឋកិច្ចក្រៅប្រព័ន្ធដូចជា អ្នករត់ ម៉ូតូកង់បី នឹងអ្នកលក់ដូរកំបិកកំប៉ុក រទេះរុញ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហានុក៏កំពុងប្រឈម នឹងបញ្ហាថវិកានេះខ្លាំងដែរ។[49]

## ២.៦.៣. ផលប៉ះពាល់លើមុខរបរ និងការងារក្រៅប្រព័ន្ធ

ក្រៅពីផលប៉ះពាល់ទៅលើការងារ និងមុខរបរក្នុងប្រព័ន្ធទាំងនេះប្រជាពលរដ្ឋដែលប្រកបការងាររកស៊ីជាលក្ខណៈផ្ទាល់ខ្លួន ដូចជាអ្នករត់ម៉ូតូឌុប កង់បី និងតាក់ស៊ីជាដើមក៏ទទួលរងនូវផលប៉ះពាល់នេះធ្ងន់ធ្ងរដូចគ្នា។ ជាធម្មតាពួកគាត់ធ្លាប់តែទទួលបានប្រាក់ចំណូលគ្រប់គ្រាន់ពីមុខរបរប្រចាំថ្ងៃ និងអាចទុកដាក់បានខ្លះប៉ុន្តែចាប់តាំងពីមានវិបត្តិមួយនេះចំនួនភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិបានធ្លាក់ចុះដែលធ្វើឱ្យពួកគេបាត់បង់ប្រាក់ចំណូលទាំងស្រុងតែម្តង។ មិនខុសពីកម្មករ-កម្មការិនីរោងចក្រអ្វីដែលកាន់តែធ្ងន់ធ្ងរសម្រាប់ពួកគាត់គឺប្រជាពលរដ្ឋដែលប្រកបមុខរបរប្រចាំថ្ងៃទាំងនេះកំពុងជួបប្រទះ នឹងបញ្ហាធ្ងន់ធ្ងរជាមួយនឹងបំណុលធនាគារឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត។

[49] (២៩ មេសា ២០២២ ) FRESH NEWS (freshnewsasia.com)

# ជំពូកទី៣

# ការវិភាគ និងការពិភាក្សាលើយុទ្ធសាស្ត្រសេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩

# ជំពូកទី៣
# ការវិភាគ និងការពិភាក្សាលើយុទ្ធសាស្ត្រសេដ្ឋកិច្ចជាតិអំឡុងពេលកូវីដ-១៩

## ៣.១. មេរៀនយុទ្ធសាស្ត្រសម្រាប់កម្ពុជា

នៅក្នុងជំពូកនេះ យើងនឹងលើកយកគោលនយោបាយក៏ដូចជាយុទ្ធសាស្ត្ររបស់ប្រទេសនានាក៏ដូចជាស្ថាប័នផ្សេងៗក្នុងសកលលោកដែលបានដាក់ចេញ ដើម្បីស្តារនិងពង្រឹងស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសឡើងវិញក្រោយការកើតមាននូវវិបត្តិនានា។ បន្ថែមពីលើនេះ យើងក៏ធ្វើការសិក្សាផងដែរនូវយុទ្ធសាស្ត្រនានារបស់ប្រទេសមួយចំនួនដែលគ្រោងនឹងដាក់ចេញដើម្បីស្តារស្ថានភាពសេដ្ឋកិច្ចទៅ តាមវិស័យនានាក្រោយទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩នេះផងដែរ។ គោលនយោបាយក៏ដូចជាយុទ្ធសាស្ត្រនានាដែលបង្ហាញក្នុងជំពូកនេះ អាចជាមេរៀនដ៏ល្អសម្រាប់កម្ពុជាក្នុងការរៀបចំគោលនយោបាយ ឬយុទ្ធសាស្ត្រនានាដើម្បីស្តារក៏ដូចជាពង្រឹងស្ថានភាពសេដ្ឋកិច្ចជាតិទៅតាមវិស័យនានា ដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ឡើងវិញក៏ដូចជាដើម្បីអភិវឌ្ឍវិស័យនានាដើម្បីនិរន្តរភាពសេដ្ឋកិច្ច និងសង្គម។

### ៣.១.១. យុទ្ធសាស្ត្រក្នុងវិស័យទេសចរណ៍

**ក) ករណីប្រទេសម៉ាឡេស៊ី**

ក្រោយពីការបញ្ចប់នូវការរីករាលដាលនៃជំងឺ **SARS** ក្នុងឆ្នាំ ២០០២-២០០៣ រដ្ឋាភិបាលរបស់ប្រទេសម៉ាឡេស៊ីបានកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនដើម្បីស្តារនិងពង្រឹងវិស័យទេសចរណ៍ជាតិដែលបានធ្លាក់ចុះយ៉ាងគំហុកដូចខាងក្រោម៖ [50]

- ទី១៖ រៀបចំឱ្យមានការបណ្តុះបណ្តាលជំនាញនានាទាក់ទងនឹងវិស័យទេសចរណ៍ ក៏ដូចជាវិធានការចាំបាច់មួយចំនួនដូចជាពង្រឹងសុវត្ថិភាពនៅតាមតំបន់ទេសចរណ៍ពង្រឹងគុណភាពទៅលើផលិតផលអនុស្សាវរីយ៍ ព្រមទាំងពង្រឹងគុណភាពនៃសេវាកម្មផ្សេងៗទៀត។
- ទី២៖ រៀបចំដំណើរការជើងហោះហើរឱ្យមានភាពប្រក្រតីឡើងវិញឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានប្រយោជន៍បម្រើនូវការដឹកជញ្ជូននានា ជាពិសេសភ្ញៀវទេសចរណ៍ដែលនឹងធ្វើដំណើរមកកំសាន្តនៅក្នុងប្រទេសម៉ាឡេស៊ី។

[50] Travel Daily News. (2007).ទាញយកពីសៀវភៅ"ផលប៉ះពាល់នៃកូវីដ១៩ ទៅលើសង្គម និងសេដ្ឋកិច្ចកម្ពុជា" ដែលដកស្រង់ចេញពី៖ Post-SARS tourism recovery to attract Chinese tourists. Retrieved on June 16th, 2020 from: https://www.traveldailynews.asia/post-sars-tourism-recovery-to-attract-chinese-tourists.

ទី៣៖ បង្កើនជើងយន្តហោះដែលធ្វើដំណើរហោះហើរដោយផ្ទាល់ពីប្រទេសផ្សេងឱ្យបានកាន់តែច្រើន ដើម្បីជៀសវាងនូវការផ្ទេរជើងហោះហើរនៅប្រទេសទីបី។

ទី៤៖ ពង្រឹងយុទ្ធសាស្ត្រទេសចរណ៍ "Mega FAM"[51] ឡើងវិញដោយផ្តោតសំខាន់ទៅលើគោលដៅទេសចរណ៍ជាក់លាក់មួយចំនួនសម្រាប់ភ្ញៀវសញ្ជាតិចិនដែលមានប្រភពមកពីប្រទេសចិន ទីក្រុងហុងកុង និងតៃវ៉ាន់ជាដើម។

**ខ) ករណីប្រទេសក្នុងតំបន់អាមេរិកឡាទីន**

ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ ក្នុងន័យស្តារឡើងវិញនូវវិស័យទេសចរណ៍របស់ជាតិក៏ដូចជាវិស័យទេសចរណ៍ក្នុងតំបន់ទាំងមូលប្រទេសនានាក្នុងតំបន់អាមេរិកឡាទីនបានកំណត់ចេញនូវយុទ្ធសាស្ត្រចំនួនប្រាំមួយដូចខាងក្រោម៖[52]

- **ផ្តោតលើក្រុមអ្នកទេសចរណ៍លំដាប់ខ្ពស់**

មូលហេតុដែលប្រទេសទាំងឡាយនៅក្នុងតំបន់អាមេរិកឡាទីនផ្តោតជាចម្បងលើយុទ្ធសាស្ត្រមួយនេះគឺដោយសារតែចំនួនភ្ញៀវដែលស្ថិតក្នុងលំដាប់នេះ មានការកើនឡើងខ្លាំងជាពិសេសកាលពីឆ្នាំ២០១៩កន្លងទៅ។ ប្រទេសនានានៅក្នុងតំបន់នេះទទួលបានអត្ថប្រយោជន៍ច្រើនពីកំណើនភ្ញៀវដែលមានកម្រិតជីវភាពខ្ពស់ៗ ឬក្រុមលំដាប់សេដ្ឋី។ យុទ្ធសាស្ត្រមួយនេះអាចអនុវត្តបានជោគជ័យគឺ អាស្រ័យលើកត្តាមួយចំនួនដូចជាការយល់ឱ្យបានច្បាស់ពីតម្រូវការ និងចំណូលចិត្តរបស់ភ្ញៀវដែលស្ថិតក្នុងលំដាប់នេះនិងការរៀបចំគោលដៅទេសចរណ៍នានាដើម្បីបំពេញទៅតាមតម្រូវការរបស់ពួកគេផងដែរ។

- **ពង្រឹងអាជីវកម្មខ្នាតតូចៗ**

ប្រទេសក្នុងតំបន់អាមេរិកឡាទីនយល់ថា ការពង្រឹងនូវឱកាសអាជីវកម្មខ្នាតតូចៗជាលក្ខណៈគ្រួសារ និងអាជីវកម្មផ្សេងៗទៀតដែលបម្រើឱ្យវិស័យទេសចរណ៍ដូចជា អាជីវកម្មសណ្ឋាគារតូចៗ ឬផ្ទះសំណាក់ជាដើម អាចចូលរួមយ៉ាងសកម្មក្នុងការធ្វើឱ្យមានស្ថិរភាពលើវិស័យនេះ។ នៅក្នុងតំបន់នេះផ្ទះសំណាក់ ឬសណ្ឋាគារ

---

[51] Mega FAM (Malaysia Megan Familiarsator Frogramin) គឺជាយុទ្ធសាស្ត្រទេសចរណ៍មួយរបស់ប្រទេសម៉ាឡេស៊ីក្នុងការទាក់ទាញភ្ញៀវទេសចរ និងបានដាក់ដំណើរការក្នុងអំឡុងឆ្នាំ១៩៩៩។ យុទ្ធសាស្ត្រនេះផ្តោតសំខាន់លើជនជាតិចិន ដោយសារតែចំនួនភ្ញៀវទេសចរជនជាតិចិន ចូលមកប្រទេសម៉ាឡេស៊ី មានចំនួនច្រើនជាងគេ ធៀបនឹងភ្ញៀវមកពីប្រទេសផ្សេងទៀត។

[52] Dan Fenton. (2020, 15 October).ទាញយកពីសៀវភៅ"ផលប៉ះពាល់នៃកូវីដ១៩ ទៅលើសង្គម និងសេដ្ឋកិច្ចកម្ពុជា" ដែលដកស្រង់ចេញពី៖ These 6 strategies can help tourism recover in Latin America. Retrieved from: https://www.weforum.org/agenda/2020/10/these-6-strategies-can-help-tourism-recover-in-latin-america-df689974cd/

ខ្នាតតូចៗជាច្រើនបានរួមគ្នាជាសម្ព័ន្ធដើម្បីបង្កើតជាបណ្តាញអាជីវកម្មដែលផ្តល់សេវានេះឱ្យកាន់តែធំ ដោយមានការគោរពទៅតាមគោលការណ៍ និងស្តង់ដារដែលបានកំណត់របស់សម្ព័ន្ធអាជីវកម្មរបស់ពួកគេ។ ការអនុវត្តបែបនេះអាចធ្វើឱ្យសណ្ឋាគារតូចៗ ឬខ្សត់ធនធានជាងគេមានឱកាសច្រើនជាងមុនក្នុងការផ្តល់សេវារបស់ខ្លួនទៅកាន់ភ្ញៀវទេសចរណ៍តាមរយៈបណ្តាញធំៗព្រមទាំងទទួលបាននូវបរិក្ខារនានា ឬការវិនិយោគបន្ថែមលើចំណុចចាំបាច់ដើម្បីរក្សាបាននូវស្តង់ដាររបស់សម្ព័ន្ធអាជីវកម្មទាំងមូល។

- **ធ្វើខ្លួនឱ្យមានប្រៀបជានិច្ច**

នៅត្រង់ចំណុចនេះប្រទេសនានាក្នុងតំបន់អាមេរិកឡាទីនបានស្វែងយល់ពីចំណុចខ្លាំងចំណុចទាក់ទាញព្រមទាំងសេវាកម្មនានានៃវិស័យទេសចរណ៍របស់ខ្លួនព្រមទាំងបន្តការវិនិយោគបន្ថែមទៀត ដោយកែច្នៃគោលដៅទេសចរណ៍ព្រមទាំងសេវាកម្មនានាប្រកបដោយភាពច្នៃប្រឌិត ដើម្បីអាចទាញយកឱកាសប្រកួតប្រជែងលើវិស័យទេសចរណ៍នេះបាន។

- **ពង្រឹងផ្នែកអនាម័យនិងសុខភាពសាធារណៈ**

ក្រោយពីការបញ្ចប់នូវវិបត្តិកូវីដ-១៩បញ្ហាសុខភាពនិងអនាម័យ គឺជាបញ្ហាចម្បងបំផុតសម្រាប់ភ្ញៀវទេសចរណ៍ដូចនេះប្រទេសក្នុងតំបន់អាមេរិកឡាទីនទាំងឡាយបានយកចិត្តទៅលើបញ្ហានេះ និងលើកយកចំណុចមួយនេះជាយុទ្ធសាស្ត្រដែលមានអត្ថិភាពខ្ពស់បំផុតទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិ។ ប្រទេសនានាក្នុងតំបន់នេះនឹងពង្រឹងការយកចិត្តទុកដាក់បន្ថែមទៀត អំពីអនុសាសន៍ទាំងឡាយដែលផ្តល់ដោយអាជ្ញាធរសុខាភិបាលក្នុងប្រទេស ឬតំបន់អង្គការសុខភាពពិភពលោកក៏ដូចជាមជ្ឈមណ្ឌលជំងឺឆ្លងជាដើម។ ជាក់ស្តែងប្រទេសទាំងឡាយនៅក្នុងតំបន់នេះមិនត្រឹមតែពង្រឹងយន្តការសុខភាព និងអនាម័យនៅក្នុងកម្រិតនៃក្របខណ្ឌបដិសណ្ឋារកិច្ចប៉ុណ្ណោះទេ ប៉ុន្តែវិស័យសុខាភិបាលទាំងមូលរបស់ប្រទេសនានាក្នុងតំបន់ក៏បានយកចិត្តទុកដាក់ខ្ពស់ផងដែរ តាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខភាពជាដើម។

អាជីវកម្មទាំងឡាយក្នុងវិស័យទេសចរណ៍បដិសណ្ឋារកិច្ចដូចជា ភោជនីយដ្ឋានផ្ទះសំណាក់ សណ្ឋាគារ កន្លែងកម្សាន្ត និងរមណីយដ្ឋានគ្រប់ប្រភេទចាំបាច់ត្រូវពង្រឹងបន្ថែមនូវវិធានការអនាម័យនិងសុខភាពទៅតាមគោលការណ៍ និងអនុសាសន៍របស់មជ្ឈមណ្ឌលជំងឺឆ្លងក្រសួងសុខាភិបាលឬអង្គការសុខភាពពិភពលោកដើម្បីអាចទទួលបាននូវវិញ្ញាបនបត្របញ្ជាក់ស្តង់ដារគុណភាពនិងសុវត្ថិភាពខាងផ្នែកអនាម័យ និងសុខភាពពីស្ថាប័នទាំងនេះ។

- **ពង្រឹងការវិនិយោគលើវិស័យបច្ចេកវិទ្យា**

ដើម្បីស្តារឡើងវិញ ក៏ដូចជាពង្រឹងនូវវិស័យទេសចរណ៍ប្រទេសក្នុងតំបន់អាមេរិកឡាទីនយល់ឃើញដូចគ្នាការវិនិយោគទៅលើបច្ចេកវិទ្យាឌីជីថលសម្រាប់បម្រើការក្នុងវិស័យនេះគឺជារឿងចាំបាច់បំផុត។ ការពង្រីកយុទ្ធសាស្ត្រអាជីវកម្មសេវាកម្មទេសចរណ៍តាមប្រព័ន្ធអនឡាញដូចជា ការកក់សំបុត្រ ការរៀបចំដំណើរកម្សាន្ត ការកក់ផ្ទះសំណាក់ សណ្ឋាគារ ការស្វែងរកទីតាំងស្នាក់នៅអំឡុងពេលដំណើរកម្សាន្តជាដើម នឹងដើរតួយ៉ាងសំខាន់នៅក្នុងការជំរុញនូវសកម្មភាពទេសចរណ៍។ សេវាកម្មដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនេះ (រាប់បញ្ចូលទាំងការកុម៉ង់ទំនិញអាហារ ឬសេវាកម្មផ្សេងៗតាមប្រព័ន្ធអនឡាញ ) នឹងធ្វើឱ្យភ្ញៀវទទួលបាននូវបទពិសោធន៍ថ្មីកាត់បន្ថយការចំណាយដែលមិនចាំបាច់ និងងាយស្រួលទាំងសម្រាប់ភាគីភ្ញៀវ និងអ្នកផ្តល់សេវាកម្មផងដែរ។

**គ) ចក្ខុវិស័យសកលក្នុងការអភិវឌ្ឍទេសចរណ៍**

ជាមួយកិច្ចការចាំបាច់ដែលត្រូវប្រឈមមុខនឹងការស្តារឡើងវិញ នូវវិស័យទេសចរណ៍ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារវិបត្តិកូវីដ-១៩នេះទាំងអាជីវកម្មនានាក្នុងវិស័យទេសចរណ៍រដ្ឋាភិបាលក៏ដូចជាស្ថាប័នជាតិអន្តរជាតិស្ថាប័នអប់រំ និងស្ថាប័នស្រាវជ្រាវទាំងអស់ត្រូវសហការគ្នាចែករំលែកចំណេះដឹងបទពិសោធន៍ដើម្បីអភិវឌ្ឍវិស័យនេះឱ្យមានស្ថេរភាព និងនិរន្តរភាព។[53] ជាមួយនឹងចក្ខុវិស័យនេះគេហទំព័រ One Planet Network បានរៀបចំជាអនុសាសន៍សកលមួយចំនួនដែលរដ្ឋាភិបាលនៃប្រទេសនានា អាចពិចារណាអនុវត្តដើម្បីអភិវឌ្ឍវិស័យទេសចរណ៍របស់ជាតិខ្លួនបាន។

- **វិធានការសុខភាពសាធារណៈ**

វិបត្តិកូវីដ-១៩ជាសកលបានបង្ហាញឱ្យយើងដឹងថាស្ថិរភាពក្នុងវិស័យទេសចរណ៍មានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយនឹងវិធានការអនាម័យ និងសុខភាពសាធារណៈ។ យន្តការអនាម័យ និងសុខភាពសាធារណៈទាំងនេះ អាចអនុវត្តបានតាមរយៈ៖

- ផ្សារភ្ជាប់សូចនាកររោគរាតត្បាតទៅក្នុងវិស័យទេសចរណ៍
- ផ្សារភ្ជាប់វិធានអនាម័យ និងសុខមាលភាពជាមួយនឹងនិរន្តរភាពទេសចរណ៍តាមរយៈបទពិសោធន៍នៃវិបត្តិកូវីដ-១៩នេះ គេអាចសន្និដ្ឋានបានថានិរន្តរភាពនៃវិស័យទេសចរណ៍ពឹងផ្អែកខ្លាំងលើវិធានអនាម័យ និងសុខមាលភាពសាធារណៈ។

[53] One Planet Network. (2020). How tourism can recover responsibly from COVID-19. Retrieved from: https://www.oneplanetnetwork.org/sustainable-tourism/covid-19-how-tourism-can-recover-responsibly

- ការស្តារឡើងវិញនូវភាពជឿជាក់តាមរយៈទំនាក់ទំនង ដំណោះស្រាយបញ្ហានានាទាក់ទងនឹងការព្រួយបារម្ភអំពីសុខភាពសាធារណៈ ពីសំណាក់ភ្ញៀវទេសចរណ៍បុគ្គលិកក៏ដូចជាសហគមន៍ជាដើមអាចធ្វើបានតាមរយៈការផ្តល់ព័ត៌មាននិងទំនាក់ទំនងប្រកបដោយតម្លាភាពនិងច្បាស់លាស់។ គោលដៅទេសចរណ៍ទាំងឡាយគប្បីបញ្ជូនព័ត៌មានឱ្យបានសមស្រប និងត្រឹមត្រូវពីវិធានការអនាម័យសុខភាពនិងកិច្ចការផ្សេងៗទាក់ទងនឹងសុខភាពសាធារណៈ ដល់ទីផ្សារទេសចរណ៍ឱ្យមានតម្លាភាពនិងច្បាស់លាស់ដើម្បីពង្រឹងនូវការជឿជាក់ពីភ្ញៀវឡើងវិញ។

➢ **វិធានការគាំពារសង្គម**

វិបត្តិកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់ការងារ និងអាជីវកម្មតូច និងមធ្យមក្នុងវិស័យទេសចរណ៍សកលប្រមាណជាង៨០%។ ម្ចាស់អាជីវកម្មក៏ដូចជាក្រុមហ៊ុននានាដែលប្រកបអាជីវកម្មលើវិស័យទេសចរណ៍ជាច្រើនបានចាប់ផ្តើមគិតគូរដល់ការគាំពារបុគ្គលិករបស់ខ្លួន និងទ្រទ្រង់ដល់សហគមន៍ដែលពួកគេកំពុងប្រតិបត្តិការ។ ការធ្វើបែបនេះ នឹងលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យទេសចរណ៍ដែលអាចផ្តល់ផលប្រយោជន៍ និងជួយអភិវឌ្ឍសហគមន៍បានយ៉ាងពិតប្រាកដ។ ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងចូលរួមអភិវឌ្ឍសហគមន៍ផងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធជាមួយវិស័យទេសចរណ៍អាចពិចារណានូវយន្តការមួយចំនួនដូចខាងក្រោម៖

- បង្កើតយន្តការគាំទ្រដល់ក្រុមគោលដៅដែលងាយរងគ្រោះ៖ ការងារនៅក្នុងវិស័យទេសចរណ៍ជាច្រើនបានផ្តល់នូវប្រភពចំណូលដ៏ច្រើនដល់សហគមន៍ និងការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍នោះ ជាពិសេសស្ត្រីពីយុវជនជនជាតិដើមភាគតិចនិងជនងាយរងគ្រោះនៅតាមទីជនបទទាំងក្នុងទម្រង់សេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។
- បង្កើននូវយន្តការរយៈពេលវែងដើម្បីគាំទ្រសហគ្រាសតូចនិងមធ្យម៖ ការរៀបចំយន្តការចាំបាច់រយៈពេលវែងដោយសម្លឹងមើលវែងឆ្ងាយជាងវិធានការស្តារ និងកាត់បន្ថយការលំបាកនានារបស់សហគ្រាសតូច និងមធ្យមដែលមានស្រាប់ គឺជារឿងសំខាន់ដើម្បីឱ្យសហគ្រាសទាំងនោះអាចបន្តនិរន្តរភាពសកម្មភាពទេសចរណ៍របស់ខ្លួនបានក្នុងរយៈពេលវែង។
- ពង្រឹងវិស័យទេសចរណ៍ដោយគាំពារសហគមន៍៖ អត្ថប្រយោជន៍ពីសេវាកម្មទេសចរណ៍ថ្មីៗប្លែកៗប្រកបដោយភាពច្នៃប្រឌិត ដែលអាជីវកម្មនានានៅក្នុងវិស័យទេសចរណ៍អាចផ្តល់ដល់គោលដៅទេសចរណ៍ក៏ដូចជាសហគមន៍ជុំវិញ គឺជាការរឹតចំណងដ៏រឹងមាំមួយក្នុងអំឡុងពេលមានវិបត្តិនេះ។ ការធ្វើបែបនេះ មិនត្រឹមតែផ្តល់នូវទំនុកចិត្តនិងអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង

ពង្រឹងនូវគំនិតច្នៃប្រឌិតដល់សហគមន៍ និងការពេញចិត្តពីសំណាក់សហគមន៍ផងដែរ។ វិធានការនៃការគាំពារសង្គមទាំងនេះ នឹងធ្វើឱ្យវិស័យទេសចរណ៍របស់ជាតិទាំងមូលក៏ដូចជាសហគមន៍មានការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

➢ **អនុវត្តយន្តការសេដ្ឋកិច្ចវិលជុំ**

វិបត្តិកូវីដ-១៩ បានធ្វើឱ្យយើងបង្កើនការយកចិត្តទុកដាក់ទៅលើសារៈសំខាន់ទៅលើសង្វាក់នៃការផ្គត់ផ្គង់ក្នុងស្រុកដែលស្ថានភាពនេះចាំបាច់ឱ្យយើងត្រូវគិតពិចារណាឡើងវិញនូវវិធីដែលសេវាកម្មនានាផលិតផលដែលត្រូវបានផលិត និងផ្គត់ផ្គង់ដោយផលិតករក្នុងស្រុក។ ការដែលសេវាកម្មទេសចរណ៍និងផលិតផលគ្រប់ប្រភេទផលិតក្នុងស្រុក និងប្រើប្រាស់ក្នុងស្រុកដើម្បីប្រយោជន៍ទេសចរណ៍ក្នុងស្រុកនេះគឺជាធាតុដ៏សំខាន់សម្រាប់សេដ្ឋកិច្ចវិលជុំការអនុវត្តខ្សែសង្វាក់សេដ្ឋកិច្ចវិលជុំនិងការពង្រឹងប្រសិទ្ធភាពធនធាន ដែលផលិតនិងប្រើប្រាស់ក្នុងវិស័យទេសចរណ៍ គឺជាការផ្តល់ឱកាសសម្រាប់វិស័យមួយនេះដើម្បីអាចឈានទៅរកការអភិវឌ្ឍទាំងអាជីវកម្ម ក៏ដូចជាសហគមន៍ប្រកបដោយនិរន្តរភាព។ ដើម្បីធានាបាននូវគុណតម្លៃនៃសេដ្ឋកិច្ចវិលជុំក្នុងវិស័យទេសចរណ៍រដ្ឋាភិបាល ក៏ដូចជាអ្នកពាក់ព័ន្ធនានាអាចពិចារណានូវយនការមួយចំនួនដូចខាងក្រោម៖

- វិនិយោគក្នុងការកែប្រែខ្សែសង្វាក់នៃគុណតម្លៃទេសចរណ៍៖ ការអនុវត្តនូវសេដ្ឋកិច្ចវិលជុំដែលបានលើកឡើងខាងលើអាចអនុវត្តបានតាមរយៈ ការកាត់បន្ថយនិងប្រើប្រាស់ឡើងវិញ ការជួសជុល ការធ្វើឱ្យប្រសើរឡើងវិញ ទៅលើផលិតផលនានាក្នុងវិស័យទេសចរណ៍។ ការធ្វើបែបនេះ គឺអាចចូលរួមកាត់បន្ថយនូវការលេចធ្លាយផ្នែកសេដ្ឋកិច្ចនៅក្នុងខ្សែសង្វាក់នៃគុណតម្លៃទេសចរណ៍ ក៏ដូចជាកាត់បន្ថយនូវកាកសំណល់ និងការប៉ះពាល់ដល់បរិស្ថានផងដែរ។
- ផ្តល់អត្ថិភាពខ្ពស់លើយន្តការអាហារដែលមាននិរន្តរភាពដើម្បីការប្រើប្រាស់ឡើងវិញ៖ អាហារនឹងតំណាងឱ្យខ្សែសង្វាក់វិលជុំមួយនៃគុណតម្លៃទេសចរណ៍តាមរយៈការរៀបចំទុកដាក់ការបែងចែក ការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីកាត់បន្ថយនូវកាកសំណល់អាហារ និងការខូចខាតដោយឥតប្រយោជន៍ជាដើម។ ការជំរុញនូវយន្តការកាត់បន្ថយការខូចខាតអាហារ និងកាកសំណល់នានាក្នុងវិស័យទេសចរណ៍មានសក្តានុពលខ្ពស់ក្នុងការគាំទ្រនូវការស្តារឡើងវិញនូវអាជីវកម្មខ្នាតតូចនិងមធ្យមនានា ក៏ដូចជាចូលរួមក្នុងការកាត់បន្ថយការបំពុលបរិយាកាសដែលបណ្តាលមកពីឧស្ម័នកាបូនិកចេញពីកាកសំណល់អាហារទាំងនេះផងដែរ។
- ជំរុញការប្រើប្រាស់ឡើងវិញនូវសម្រាមផ្លាស្ទិកក្នុងវិស័យទេសចរណ៍៖ ការយកចិត្តទុកដាក់នៅក្នុងការគ្រប់គ្រងកាកសំណល់ផ្លាស្ទិក និងបំពុលបរិយាកាស គឺជាកម្លាំងចលករមួយក្នុងការជំរុញនូវសេដ្ឋកិច្ច

វិលជុំក្នុងវិស័យទេសចរណ៍តាមរយៈការលុបបំបាត់នូវសម្រាមផ្លាស្ទិកដែលមិនចាំបាច់ ឬការបង្កើតនូវគំរូនៃការប្រើប្រាស់ផ្លាស្ទិកឡើងវិញជាដើម។ ការគាំទ្រនូវយន្តការការប្រើប្រាស់ផ្លាស្ទិកឡើងវិញអាចកាត់បន្ថយយ៉ាងច្រើននូវសំរាមនៅតាមទឹក និងការបំពុលដោយនានាសំរាមផ្លាស្ទិក ដែលយន្តការនេះមិនត្រឹមតែបានចូលរួមថែរក្សានូវសោភ័ណភាពគោលដៅទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែក៏បានចូលរួមកាត់បន្ថយនូវផលអវិជ្ជមានដែលអាចកើតមានទៅលើសុខភាពផងដែរ។

- **ការគ្រប់គ្រង និងហិរញ្ញវត្ថុ**

ការផ្តល់ប្រភពថវិកាសម្រាប់ស្តារឡើងវិញនូវវិស័យទេសចរណ៍ គឺជាគន្លឹះសំខាន់បំផុតមួយក្នុងការស្តារវិស័យនេះឡើងវិញប្រកបដោយប្រសិទ្ធភាពខ្ពស់ក៏ដូចជាចូលរួមអភិវឌ្ឍបន្ថែម និងពង្រឹងសមត្ថភាពនៃអាជីវកម្មដែលបម្រើឱ្យវិស័យនេះក្នុងការតស៊ូជាមួយនឹងស្ថានភាពដ៏លំបាកដែលកើតមានពីវិបត្តិកូវីដ-១៩នេះ។ យ៉ាងណាការផ្តល់នូវថវិកាសម្រាប់ទ្រទ្រង់នូវវិស័យនេះ ក៏ចាំបាច់គិតគូរដល់ចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោមផងដែរ៖

- ធ្វើការវិភាគឱ្យស៊ីជម្រៅលើសពីផលប៉ះពាល់លើសេដ្ឋកិច្ច៖ ត្រូវពិចារណាឱ្យបានស៊ីជម្រៅមិនត្រឹមតែផលប៉ះពាល់លើសេដ្ឋកិច្ចចេញពីវិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតដល់បញ្ហាអនាម័យសុខភាពបញ្ហាបរិស្ថាន ជីវចម្រុះ និងផលប៉ះពាល់ទៅលើសហគមន៍ផងដែរ ។
- ទម្លាក់ថវិកាសង្គ្រោះសម្រាប់ភាពប្រសើរឡើងនៃទេសចរណ៍៖ការផ្តល់ថវិកាសម្រាប់សង្គ្រោះវិស័យទេសចរណ៍គឺជា រឿងចាំបាច់និងអត្ថិភាពបំផុតមួយសម្រាប់ស្ថិរភាពអាជីវកម្មការងារនិងសកម្មភាពគ្រប់យ៉ាងក្នុងវិស័យនេះទាំងនៅក្នុងគោលដៅរយៈពេលខ្លី មធ្យម ឬវែង។
- ជំរុញការអនុវត្តកិច្ចសហការរដ្ឋ-ឯកជន៖ ដើម្បីទទួលបានជោគជ័យកាន់តែប្រសើរក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពទាមទារឱ្យមានការសហការគ្នាខ្ពស់រវាងរដ្ឋ និងវិស័យឯកជនទៅលើកិច្ចការងារសំខាន់ៗ ដែលជំរុញការងារអភិវឌ្ឍនានាក្នុងវិស័យទេសចរណ៍។

### ៣.១.២. យុទ្ធសាស្ត្រសម្រាប់វិស័យអចលនទ្រព្យ

#### ក) យុទ្ធសាស្ត្រប្រទេសឥណ្ឌា

នៅក្នុងប្រទេសឥណ្ឌា វិស័យអចលទ្រព្យបានចូលរួមចំណែកយ៉ាងច្រើនដល់ការរីកចម្រើននៃសេដ្ឋកិច្ច និងសង្គម ជាពិសេសការបង្កើតការងារជូនប្រជាពលរដ្ឋ។ វិស័យអចលនទ្រព្យ គឺជាវិស័យធំបំផុតទីពីរដែល

បានបង្កើតការងារជូនប្រជាពលរដ្ឋឥណ្ឌា ។[54] បើទោះបីជាមានការអភិវឌ្ឍខ្លាំងក្នុងវិស័យនេះក៏ប៉ុន្តែ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យរាំងស្ទះ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យផងដែរ។ អ្នកជំនាញមួយចំនួននៅក្នុងប្រទេសនេះបានយល់ថាជាការចាំបាច់បំផុតដែលត្រូវមានការកែសម្រួលនូវយុទ្ធសាស្ត្រ ឬដាក់ចេញនូវគោលនយោបាយសមស្របដើម្បីស្តារ និងពង្រឹងវិស័យនេះឡើងវិញ។ ខាងក្រោមនេះជាអនុសាសន៍មួយចំនួនដែលអ្នកជំនាញលើវិស័យអចលនទ្រព្យបានផ្តល់ជូនចំពោះអ្នករកស៊ីអភិវឌ្ឍលើវិស័យនេះ ក៏ដូចជារដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត។

- **យកចិត្តទុកដាក់ខ្ពស់លើកម្លាំងពលកម្មបម្រើវិស័យនេះ**

អ្នកប្រកបអាជីវកម្មក្នុងវិស័យអចលនទ្រព្យចាំបាច់ត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើសុខមាលភាពរបស់បុគ្គលិក កម្មករ ជាពិសេសបន្ទាប់ស្ថានភាពកូវីដ-១៩ មានភាពប្រសើរឡើង។ អ្នកអភិវឌ្ឍនានាចាំបាច់ត្រូវរៀបចំបែបបទការងារ និងផែនការឡើងវិញឱ្យស្របទៅតាមស្ថានការណ៍ជាក់ស្តែងបន្ទាប់ពីវិបត្តិកូវីដ-១៩ បានធូរស្រាល ឬបានបញ្ចប់។ វិធានការសុខមាលភាពកម្មករការបែងចែកកាលវិភាគធ្វើការ ក៏ដូចជាការតាមដានការធ្វើដំណើររបស់បុគ្គលិកកម្មករជាប្រចាំ គឺជារឿងចាំបាច់ដើម្បីជៀសវាងការឆ្លងជំងឺនេះឡើងវិញ។

- **ត្រូវប្រមើលមើលទុកមុនពីការប្រែប្រួលនៃបច្ចេកវិទ្យាឌីជីថល**

អ្នកជំនាញលើវិស័យអចលនទ្រព្យយល់ឃើញថា ដើម្បីធ្វើឱ្យសកម្មភាពលើវិស័យនេះមានភាពប្រសើរឡើងវិញប្រកបដោយប្រសិទ្ធភាពគឺ ចាំបាច់ត្រូវប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដូចនេះអ្នកអភិវឌ្ឍទាំងឡាយចាំបាច់ត្រូវគិតគូរពីបច្ចេកវិទ្យា ដែលបានធ្វើការអភិវឌ្ឍឡើងថ្មីៗជាពិសេសទាក់ទងនឹងបញ្ញាសិប្បនិម្មិត (Artificial Intelligence) និងការវិភាគទិន្នន័យជាដើម (Data Analytics) ជាដើម។ ជាមួយនឹងការបន្តកើតមាននូវជំងឺកូវីដ ១៩ ការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ ជាពិសេសទាក់ទងនឹងការគ្រប់គ្រងគម្រោងសេវាអតិថិជនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក ការបង្កើតការិយាល័យទំនាក់ទំនងដោយប្រើបច្ចេកវិទ្យាជាដើម គឺអាចជួយសម្រួលការងារនិងកាត់បន្ថយចំណាយបានច្រើន ជាពិសេសជាមួយនឹងបរិបទនៃការរឹតត្បិតការធ្វើដំណើរបែបនេះ។

- **បង្កើតនូវភាពបត់បែនក្នុងការទំនាក់ទំនងល្អជាមួយអតិថិជន**

---

[54] Rakesh REDDY. (2020, 27th July). ទាញយកពីសៀវភៅ"ផលប៉ះពាល់នៃកូវីដ១៩ ទៅលើសង្គម និងសេដ្ឋកិច្ចកម្ពុជា" ដែលដកស្រង់ចេញពី៖How can the real estate sector recover from the COVID-19 pandemic? Retrieved from: https://housing.com/news/how-can-the-real-estate-sector-recover-from-the-covid-19-pandemic/

ការបន្តធ្វើទំនាក់ទំនងល្អជាមួយអតិថិជន គឺជាកម្លាំងចលករដ៏សំខាន់មួយសម្រាប់អាជីវកម្មគ្រប់ប្រភេទជាពិសេសក្នុងបរិបទដែលការជួបជុំផ្ទាល់មិនអាចធ្វើទៅបាន ឬពិបាកក្នុងការអនុវត្ត។ ការប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យាដ៏សម្បូរបែបក្នុងការធ្វើទំនាក់ទំនងជាមួយអតិថិជនការធ្វើពាណិជ្ជកម្មការផ្សព្វផ្សាយអំពីផលិតផលនានាទៅកាន់អតិថិជន នឹងធ្វើកាន់តែធ្វើឱ្យអាជីវកម្មមានភាពរឹងមាំបន្ថែមទៀត។

- **រដ្ឋាភិបាលចាំបាច់ត្រូវធ្វើកំណែទម្រង់**

ដើម្បីជួយសម្រាលបន្ទុកក្រុមហ៊ុនក៏ដូចជា អ្នកវិនិយោគលើវិស័យអចលនទ្រព្យរដ្ឋាភិបាលរបស់ប្រទេសឥណ្ឌាបានចាត់វិធានការមួយចំនួនរួចមកហើយ ក៏ប៉ុន្តែបើតាមអ្នកជំនាញលើវិស័យនេះបានយល់ថាវិធានការ ឬយន្តការនេះមានអត្ថប្រយោជន៍ក្នុងរយៈពេលខ្លីប៉ុណ្ណោះ និងមិនអាចជាដំណោះស្រាយក្នុងពេលវែងបាននោះទេ។ ដូចនេះពួកគេយល់ថារដ្ឋាភិបាលគួរមានវិធានការបន្ថែមទៀតដើម្បីពង្រឹងវិស័យអចលនទ្រព្យក្នុងរយៈពេលវែង។ ឧទាហរណ៍៖ ការពង្រឹងលទ្ធភាពក្នុងការរក្សាទ្រព្យសកម្ម និងទុនបម្រុងទុកសម្រាប់ចំណាយប្រតិបត្តិការនានាក៏ដូចជាផ្តល់សម្បទាដល់អ្នកអភិវឌ្ឍអាចពន្យារពេលក្នុងការសាងសង់ដោយស្របច្បាប់។ ល។ នឹងធ្វើឱ្យអ្នកអភិវឌ្ឍអចលនទ្រព្យផ្តោតទៅនឹងការបញ្ចប់គម្រោងដោយមិនខ្វល់ពីសម្ពាធនានា។ ជាការពិតការកែសម្រួលមូលដ្ឋានក្នុងទម្រង់ធំបែបនេះ គឺមានភាពចាំបាច់បំផុត ក្នុងការជំរុញនូវអត្រាកំណើននាពេលអនាគត។ គោលនយោបាយរបស់រដ្ឋាភិបាលត្រូវផ្តោតបន្ថែមផងដែរលើ ការឡើងថ្លៃវត្ថុធាតុដើមតម្លៃដើមផលិតកម្ម ពន្ធនាំចូលនិងការកាត់បន្ថយពន្ធលើទំនិញ និងសេវាកម្មនានាផងដែរ។

**ខ) យុទ្ធសាស្ត្រប្រទេសវៀតណាម**

ការរឹតត្បិតនូវការធ្វើដំណើរជាលក្ខណៈសាកលការផ្អាកសកម្មភាពអាជីវកម្ម សកម្មភាពពាណិជ្ជកម្ម និងការជួបជុំផ្លូវការនានាជាដើម បានធ្វើឱ្យប៉ះពាល់ដល់គ្រប់ប្រទេសនៅលើពិភពលោកក្នុងនោះប្រទេសវៀតណាម ក៏ទទួលរងនូវផលប៉ះពាល់ខ្លាំងដូចគ្នា។ ផលប៉ះពាល់នេះក៏កើតមានខ្លាំងផងដែរទៅលើវិស័យអចលនទ្រព្យនៅក្នុងប្រទេសវៀតណាម ។[55] ជាមួយនឹងការរឹតត្បិតការធ្វើដំណើរពីបរទេស បានធ្វើឱ្យលំហូរអតិថិជនបរទេសជាពិសេសអតិថិជនជនជាតិចិនកូរ៉េខាងត្បូង និងជប៉ុនជាដើមដែលជាអតិថិជនធំៗក្នុងវិស័យអចលនទ្រព្យរបស់វៀតណាមត្រូវអាក់ខានក្នុងការសម្រេចបាននូវការទិញលក់គម្រោងអចលនទ្រព្យនានា។ គម្រោងសាងសង់ថ្មីៗត្រូវផ្អាកដោយសារតែការជៀសវាងនូវការជួបជុំក្នុងទ្រង់ទ្រាយធំ។

[55] Vietnam News. (2020, March 23). ទាញយកពីសៀវភៅ "ផលប៉ះពាល់នៃកូវីដ១៩ ទៅលើសង្គម និងសេដ្ឋកិច្ចកម្ពុជា" ដែលដកស្រង់ចេញពី៖How can Vietnam's real estate market brave the cold. Retrieved on February 3rd from: https://vietnamnews.vn/indochinacapital/654120/how-can-vietnams-real-estate-market-brave-the-cold.html.

ជាជាងរង់ចាំ ឬផ្អាកដំណើរការរហូតដល់ជំងឺមួយនេះត្រូវបានបញ្ចប់វិស័យអចលនទ្រព្យចាំបាច់ត្រូវមានវិធានការចាំបាច់នានា ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាបណ្តោះអាសន្ននៃវិបត្តិកូវីដ១៩ ព្រមទាំងវិធានការ ឬយុទ្ធសាស្ត្ររយៈពេលយូរ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ដែលអាចនឹងពន្យាពេលពីបញ្ហានេះទៅលើទីផ្សារអចលនទ្រព្យទាំងមូល។ ខាងក្រោមនេះជាអនុសាសន៍ដែលអ្នកជំនាញក្នុងវិស័យអចលនទ្រព្យវៀតណាមបានផ្តល់ជូនដល់អ្នករកស៊ីលើវិស័យនេះក៏ដូចជាសម្រាប់អ្នកពាក់ព័ន្ធនានាផងដែរ។

- **យុទ្ធសាស្ត្ររយៈពេលខ្លី**

ក្នុងរយៈពេលខ្លីអ្នកលក់រាយ ក៏ដូចជាម្ចាស់អចលទ្រព្យចាំបាច់ត្រូវពិនិត្យឡើងវិញនូវតម្លៃថេរការកាត់បន្ថយនូវការផ្តល់សេវាផ្សេងៗ នឹងបិទនូវផ្នែកខ្លះនៃសកម្មភាពការងាររបស់ខ្លួនដែលមិនចាំបាច់ខ្លាំងគឺជាវិធានការមួយដើម្បីកាត់បន្ថយចំណាយ និងទំហំការងាររបស់បុគ្គលិក។ វិធានការដែលមានភាពបត់បែនដូចជាការធ្វើការងារពីចម្ងាយការផ្លាស់ប្តូរវេនធ្វើការជាដើម ក៏ជាវិធានការដែលមានប្រសិទ្ធភាពក្នុងការរក្សាបាននូវចរន្តការងារ និងរក្សាប្រាក់ចំណូលរបស់បុគ្គលិកផងដែរ។

- **យុទ្ធសាស្ត្ររយៈពេលវែង**

ក្នុងរយៈពេលវែងក្រុមហ៊ុនប្រកបអាជីវកម្មផ្នែកអចលនទ្រព្យត្រូវពិចារណាឡើងវិញនូវផែនការហិរញ្ញវត្ថុនិងការរំពឹងទុកនៃវិស័យហិរញ្ញវត្ថុសម្រាប់រយៈពេល ១២-២៤ ខែខាងមុខ។ ជាមួយគ្នានេះការបែងចែកអតិថិជនរបស់ខ្លួនទៅតាមក្រុមដោយឡែកៗ និងតាមប្រភេទនៃផលិតផលរបស់ខ្លួនគឺជារឿងចាំបាច់បំផុតដែលអ្នករកស៊ីក្នុងវិស័យនេះ ត្រូវធ្វើការសិក្សាឱ្យបានច្បាស់លាស់។ បន្ថែមពីលើយុទ្ធសាស្ត្រនេះវៀតណាមនឹងអនុវត្តគម្រោងសាងសង់លំនៅដ្ឋានដែលមានតម្លៃទាប ដើម្បីស្តារឡើងវិញនូវផលប៉ះពាល់ទៅលើវិស័យអចលនទ្រព្យដោយសារវិបត្តិកូវីដ-១៩ ។ ជាមួយគ្នានេះរដ្ឋាភិបាលរបស់ប្រទេសវៀតណាមបានប្រកាសថានឹងផ្តល់ប្រាក់កម្ចីសម្រាប់គម្រោងសាងសង់លំនៅដ្ឋានមានតម្លៃទាបសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប និងកម្មកររោងចក្រដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលឧស្សាហកម្មនានានៅទូទាំងប្រទេសថែមទៀត ។[56]

- **បង្កើនទំនុកចិត្តតាមរយៈកិច្ចសហការរវាងរដ្ឋ និងឯកជន**

សំណើមួយរបស់អ្នកអភិវឌ្ឍក្នុងវិស័យអចលនទ្រព្យក្នុងប្រទេសវៀតណាម គឺទាមទារឱ្យមានការសហការគ្នាឱ្យបានកាន់តែជិតស្និតបន្ថែមទៀតរវាងរដ្ឋ និងស្ថាប័នឯកជន។ ការសហការគ្នាកាន់តែជិតស្និទ្ធរវាងភាគីទាំងពីរនឹងបង្កើនទំនុកចិត្តដល់អតិថិជនអ្នកវិនិយោគ ក៏ដូចជាដើរតួជាយន្តការដើម្បីទាក់ទាញការវិនិយោគ

[56] The Phnom Penh Post. (2020, June 17). Vietnam to encourage construction of cheap apartments. Retrieved on January 4th

បរទេសបន្ថែមទៀតផងដែរ។ កិច្ចសហការនេះរួមបញ្ចូលទាំងដំណើរការស្នើសុំវិញ្ញាបនបត្រដើម្បីអភិវឌ្ឍអចលនទ្រព្យប្រកបដោយតម្លាភាពផងដែរ។ ការធ្វើបែបនេះនឹងបង្កើនទំនុកចិត្តដល់អ្នកអភិវឌ្ឍលើវិស័យនេះក្នុងការសាងសង់របស់ខ្លួនឱ្យទាន់ពេលវេលាកាត់បន្ថយបញ្ហាការផ្គត់ផ្គង់មិនទាន់តម្រូវការជាដើម។

- **ហេដ្ឋារចនាសម្ព័ន្ធវិនិយោគ**

ដើម្បីជំរុញនូវការអភិវឌ្ឍក្នុងវិស័យអចលនទ្រព្យរដ្ឋាភិបាលរបស់ប្រទេសវៀតណាមបានបន្តអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់វិស័យនេះដូចជា៖ កំពង់ផែ អាកាសយានដ្ឋានៈ ផ្លូវរថភ្លើងនិងផ្លូវថ្នល់ភ្ជាប់តំបន់ឧស្សាហកម្ម ឬផ្លូវក្រវាត់ក្រុងនានាជាដើម។ ការពង្រីកនូវហេដ្ឋារចនាសម្ព័ន្ធវិនិយោគទាំងនេះ នឹងចូលរួមកាត់បន្ថយការចំណាយលើដឹកជញ្ជូនព្រមទាំងបង្កើននូវសក្តានុពលតំបន់ដែលអាចនឹងទាក់ទាញការវិនិយោគបានបន្ថែមទៀត។

- **ពង្រឹងដំណើរការដើម្បីទទួលបានទុនវិនិយោគ**

យន្តការមួយទៀត គឺការបង្កនូវដំណើរការងាយស្រួលសម្រាប់អ្នកអភិវឌ្ឍនានាក្នុងការទទួលបានទុនវិនិយោគបន្ថែម។ ដំណើរការដើម្បីទទួលបាននូវទុនវិនិយោគសម្រាប់អ្នកអភិវឌ្ឍក៏ដូចជាម្ចាស់ទ្រព្យគឺជាគន្លឹះមួយសម្រាប់វិស័យអចលនទ្រព្យរបស់វៀតណាម។ ក៏ប៉ុន្តែយន្តការនេះក៏បានគិតគូរល្អិតល្អន់ផងដែរនូវហានិភ័យនានាដែលអាចកើតមានក្រោយពីការផ្តល់កម្ចីដូចជាភាពមិនប្រក្រតីនៃទ្រព្យបញ្ចាំការរឹបអូសទ្រព្យបញ្ចាំជាដើម។

## ៣.២. លទ្ធផលនៃការស្រាវជ្រាវ

ក្នុងបរិបទម៉ាក្រូសេដ្ឋកិច្ច វិស័យដែលជាកម្លាំងចលករជំរុញសេដ្ឋកិច្ចកម្ពុជាបានទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដែលកើតចេញពីការរីករាលដាលនៃជំងឺកូវីដ-១៩ តាំងពីចុងឆ្នាំ២០១៩ រហូតមកជាពិសេសត្រីមាសទី១ នៃឆ្នាំ២០២០។ ជាមួយនឹងផលប៉ះពាល់លើស្ថានភាពសេដ្ឋកិច្ចសកលលោកទាំងមូលមានស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិមួយចំនួនបានធ្វើការព្យាករណ៍ពីកំណើនសេដ្ឋកិច្ចកម្ពុជាដូចបង្ហាញក្នុងតារាងខាងក្រោម។

តារាងទី៦ ៖ ការប៉ាន់ស្មាន និងព្យាករមកលើសេដ្ឋកិច្ចកម្ពុជា គិតជា(%)

| ស្ថាប័ន | មុនពេលកូវីដ ១៩ | | ក្រោយពេលកូវីដ ១៩ | |
|---|---|---|---|---|
| | ២០២០.ប៉ាន់ | ២០២០.ព្យា. | ២០២០.ព្យា. | ២០២០.ព្យា. |
| រាជរដ្ឋាភិបាលកម្ពុជា ( RGC ) | ៦.៥ | ៧.០ | -១,៩ | ៣.៥ |
| ធនគារអភិវឌ្ឍអាស៊ី ( ADB ) | ៦.៨ | N/A | -៤.០ | ៥.៩ |

| | | | | |
|---|---|---|---|---|
| ធនាគារពិភពលោក ( WB ) | ៦.៩ | ៦.៨ | -២.០ | ៤.៣ |
| មូលនិធិរូបិយវត្ថុអន្តរជាតិ ( IMF ) | ៦.៧ | ៦.៧ | -២.៨ | ៦.៨ |
| កំណត់សំគាល់៖ ( ប៉ាន់= ការប៉ាន់ស្មាន, ព្យា=ការព្យាករ ) | | | | |

ប្រភពទិន្នន័យ ៖ Open Development Cambodia

### ៣.៣. ការបកស្រាយលទ្ធផលនៃការស្រាវជ្រាវ

ជុំវិញការព្យាករណ៍កំណើនសេដ្ឋកិច្ចមុន និងក្រោយពេលមានការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ត្រូវបានគេមើលឃើញថាមានភាពខុសគ្នាទៅតាមស្ថាប័នផ្សេងៗគ្នា។ សម្រាប់កម្ពុជាវិស័យទេសចរណ៍បានទទួលរងផលប៉ះពាល់ខ្លាំងជាងវិស័យផ្សេងៗ ដោយសារការរីករាលដាលនៃជំងឺនេះបានរឹតត្បិតសកម្មភាពធ្វើដំណើររបស់មនុស្សនៅទូទាំងពិភពលោករួមទាំងកម្ពុជាផងដែរ។ ដោយឡែកក្នុងកម្រិតអាជីវកម្មវិញយើងឃើញថាអាជីវកម្មអាកាសចរណ៍ហាក់ទទួលរងការប៉ះទង្គិចខ្លាំងជាងគេ ដែលក្នុងនោះមានក្រុមហ៊ុនអាកាសចរណ៍មួយចំនួនបានប្រកាសផ្អាកដំណើរការសកម្មភាពអាជីវកម្មរបស់ខ្លួនទាំងមូល ឬដោយផ្នែកជាដើម។ ក្រៅពីនេះមានអាជីវកម្មជាច្រើនទៀតដែលទ្រទ្រង់ ឬទទួលអត្ថប្រយោជន៍ពីការរីកចម្រើននៃវិស័យទេសចរណ៍បានរងផលប៉ះពាល់ហើយជាបន្តបន្ទាប់អាជីវកម្មមួយចំនួនធំបានប្រកាសផ្អាកដំណើរការ ខ្លះទៀតបាត់បង់ប្រាក់ចំណូលយ៉ាងសន្ធឹកសន្ធាប់ពីភាពអសកម្មនៃវិស័យទេសចរណ៍។ គេសង្កេតឃើញថាវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុរាប់ទាំងចរន្តភ្ញៀវទេសចរជាតិ និងអន្តរជាតិព្រមទាំងអាជីវកម្មនានា ដែលបម្រើឱ្យវិស័យទេសចរណ៍បានរងផលប៉ះពាល់ខ្លាំងជាងខេត្តផ្សេងៗដោយសារតែការពឹងផ្អែកខ្លាំងទៅលើវិស័យទេសចរណ៍របស់ខេត្តទាំងពីរនេះ។ ក្រៅពីវិស័យទេសចរណ៍ការស្រាវជ្រាវជ្រាវនេះក៏បានបង្ហាញផងដែរពីផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ មកលើវិស័យដែលជាសសរទ្រូងសេដ្ឋកិច្ចជាតិដូចជា ឧស្សាហកម្មកាត់ដេរ វិស័យហិរញ្ញវត្ថុ និងវិស័យអចលនទ្រព្យជាដើម។ ដោយឡែកផលប៉ះពាល់លើវិស័យហិរញ្ញវត្ថុរបស់ជាតិមានសភាពធ្ងន់ធ្ងរជាងវិស័យហិរញ្ញវត្ថុឯកជន ដោយសារតែការចំណាយថវិកាជាតិដ៏ច្រើនសន្ធឹកសន្ធាប់របស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ចូលសហគមន៍ការលើកលែងពន្ធសម្រាប់ឧស្សាហកម្មកាត់ដេរ និងអាជីវកម្មក្នុងវិស័យទេសចរណ៍ការចូលរួមឧបត្ថម្ភជាថវិកាដល់កម្មករ និងបុគ្គលិកឯកជនក្នុងវិស័យកាត់ដេរ ទេសចរណ៍និងការឧបត្ថម្ភប្រជាពលរដ្ឋងាយរងគ្រោះជាដើម។ បន្ថែមពីការប៉ះពាល់ដោយផ្ទាល់ទៅលើកម្រិតម៉ាក្រូសេដ្ឋកិច្ចនេះវិបត្តិកូវីដ-១៩ ក៏បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរដល់ការងារ និងមុខរបរប្រជាពលរដ្ឋនៅទូទាំងប្រទេសរាប់ទាំងការងារ និងមុខរបស់ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ ក៏ដូចជាបែបគ្រួសារ។ ក្រៅពីផលប៉ះពាល់

ទៅលើវិស័យចម្បងខាងលើ វិបត្តិមួយនេះក៏បានធ្វើឱ្យប៉ះពាល់ផងដែរដល់វិស័យអប់រំដែលជាក់ស្តែងដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាឱ្យសាលារៀននៅទូទាំងប្រទេសផ្អាកដំណើរការជាបណ្តោះអាសន្ន។ នៅតំបន់មួយចំនួនជាពិសេសរាជធានីភ្នំពេញការប្រកាសផ្អាកសកម្មភាពអប់រំបានកើតឡើងម្តងហើយម្តងទៀត ដែលចុងក្រោយហួតដល់មានការលើកមិនឱ្យរៀបចំការប្រឡងថ្នាក់ជាតិសម្រាប់សិស្សបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិថែមទៀត។ បន្ថែមពីលើផលប៉ះពាល់លើការអប់រំនេះផលប៉ះពាល់ក្នុងសង្គមខាងផ្នែកស្មារតីរបស់ប្រជាពលរដ្ឋក៏មានសភាពធ្ងន់ធ្ងរផងដែរ ដោយសារតែកើតមាននូវការរើសអើងលើអ្នកជំងឺកូវីដ-១៩ បើទោះបីជាពួកគាត់(អ្នកដែលឆ្លងជំងឺកូវីដ-១៩) បានជាសះស្បើយពីជំងឺនេះហើយក៏ដោយចុះ។ យើងសង្កេតឃើញថាបើទោះបីជាក្នុងរូបភាពដោយឡែកវិស័យទេសចរណ៍ហាក់រងគ្រោះខ្លាំងជាងគេ ក៏ប៉ុន្តែក្នុងរូបភាពទូទៅវិញវិស័យដែលជាសរសរទ្រូងសេដ្ឋកិច្ចទាំងនេះមានទំនាក់ទំនងនឹងគ្នាដោយផ្ទាល់និងដោយប្រយោលដែលផលប៉ះពាល់ទៅលើវិស័យណាមួយអាចនឹងនាំមកនូវផលប៉ះពាល់ដល់វិស័យដទៃទៀត។ ជាក់ស្តែងដោយសារតែមានភាពអសកម្មលើវិស័យទេសចរណ៍បានធ្វើឱ្យអាជីវកម្មជាច្រើនរងផលប៉ះពាល់រួចបញ្ហានេះបានបន្តដល់អាជីវកម្មក្នុងវិស័យដទៃទៀតដូចជា វិស័យអចលនទ្រព្យដែលមានការថមថយនូវការទិញ-លក់ វិស័យហិរញ្ញវត្ថុតាមរយៈការស្នើឱ្យមានការរៀបបចំតណទានឡើងវិញ ការស្នើសុំពន្យាការបង់ប្រាក់ ឬបំណុលខូចខាតជាដើម។ ដូចនេះដើម្បីស្តារស្ថានភាពសេដ្ឋកិច្ចកម្ពុជាឱ្យប្រសើរឡើងវិញយើងចាំបាច់ត្រូវអនុវត្តជាប្រព័ន្ធហើយការស្តារ និងពង្រឹងវិស័យណាមួយអាចជះឥទ្ធិពលវិជ្ជមានផងដែរទៅលើវិស័យផ្សេងទៀត។ ឧទាហរណ៍៖ ការទាក់ទាញភ្ញៀវទេសចរមកទស្សនាប្រទេសកម្ពុជាមិនត្រឹមតែអាចធ្វើឱ្យកើននូវប្រាក់ចំណូលជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏រួមចំណែកធ្វើឱ្យអាជីវកម្មមុខរបរព្រមទាំងការងារនានា ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធលើវិស័យក្រៅពីទេសចរណ៍មានដំណើរការឡើងវិញហើយអាចនឹងបង្កើតការងារបានច្រើនបន្ថែមទៀតផងដែរ។ ដោយឡែកបើពិនិត្យមើលលើមេរៀនអនុសាសន៍របស់ប្រទេសនានា ដែលបានដាក់ចេញដើម្បីស្តារស្ថានភាពវិស័យទេសចរណ៍ និងអចលនទ្រព្យវិញយើងសង្កេតឃើញថាអនុសាសន៍មួយចំនួនបានបង្ហាញនូវគតិគួរពិចារណា ដើម្បីអនុវត្តក្នុងប្រទេសកម្ពុជាផងដែរ។ លើសពីនេះអនុសាសន៍មួយចំនួនក្នុងវិស័យទេសចរណ៍ដែលបានធ្វើសំយោគខាងលើមានវិសាលភាពការអនុវត្តទូលំទូលាយដោយមិនត្រឹមតែអាចប្រើប្រាស់បានក្នុងកិច្ចការងារស្តារឡើងវិញនូវវិស័យទេសចរណ៍ក្នុងរយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចផ្តល់ជាគំនិតក្នុងការអភិវឌ្ឍវិស័យនេះប្រកបដោយនិរន្តរភាពក្នុងរយៈពេលវែងផងដែរ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើផលប៉ះពាល់នៃជំងឺកូវីដ១៩ សេដ្ឋកិច្ចជាតិនៃការក្រោយពីបានសិក្សាលើប្រធានបទខាងលើ ឃើញថាប្រទេសកម្ពុជាមានការប៉ះពាល់សេដ្ឋកិច្ចជាតិយ៉ាងខ្លាំងចាប់ពីពេលដែលមានជំងឺកូវីត-១៩។ សម្រាប់កម្ពុជាវិស័យទេសចរណ៍បានទទួលរងផលប៉ះពាល់ខ្លាំងជាងវិស័យផ្សេងៗ ដោយសារការរីករាលដាលនៃជំងឺនេះ បានរឹតត្បិតសកម្មភាពធ្វើដំណើររបស់មនុស្សនៅទូទាំងពិភពលោករួមទាំងកម្ពុជាផងដែរ។ អាជីវកម្មអាកាសចរណ៍ហាក់ទទួលរងការប៉ះទង្គិចខ្លាំងជាងគេដែលក្នុងនោះមានក្រុមហ៊ុនអាកាសចរណ៍មួយចំនួន បានប្រកាសផ្អាកដំណើរការសកម្មភាពអាជីវកម្មរបស់ខ្លួនទាំងមូល ឬដោយផ្អែកជាដើម។ ក្រៅពីនេះមានអាជីវកម្មជាច្រើនទៀតដែលទ្រទ្រង់ ឬទទួលអត្ថប្រយោជន៍ពីការរីកចម្រើននៃវិស័យទេសចរណ៍បានរងផលប៉ះពាល់ហើយជាបន្តបន្ទាប់អាជីវកម្មមួយចំនួនធំបានប្រកាសផ្អាកដំណើរការ ខ្លះទៀតបាត់បង់ប្រាក់ចំណូលយ៉ាងសន្ធឹកសន្ធាប់ពីភាពអសកម្មនៃវិស័យទេសចរណ៍។ គេសង្កេតឃើញថាវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុរាប់ទាំងចរន្តភ្ញៀវទេសចរជាតិ និងអន្តរជាតិព្រមទាំងអាជីវកម្មនានាដែលបម្រើឱ្យវិស័យទេសចរណ៍បានរងផលប៉ះពាល់ខ្លាំងជាងខេត្តផ្សេងៗ ដោយសារតែការពឹងផ្អែកខ្លាំងទៅលើវិស័យទេសចរណ៍របស់ខេត្តទាំងពីរនេះ។ ដោយឡែកផលប៉ះពាល់លើវិស័យហិរញ្ញវត្ថុរបស់ជាតិមានសភាពធ្ងន់ធ្ងរជាងវិស័យហិរញ្ញវត្ថុឯកជន ដោយសារតែការចំណាយថវិកាជាតិដ៏ច្រើនសន្ធឹកសន្ធាប់របស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ចូលសហគមន៍ការលើកលែងពន្ធសម្រាប់ឧស្សាហកម្មកាត់ដេរ និងអាជីវកម្មក្នុងវិស័យទេសចរណ៍ការចូលរួមឧបត្ថម្ភជាថវិកាដល់កម្មករ និងបុគ្គលិកឯកជនក្នុងវិស័យកាត់ដេរ និងទេសចរណ៍ និងការឧបត្ថម្ភប្រជាពលរដ្ឋងាយរងគ្រោះជាដើម។ បន្ថែមពីការប៉ះពាល់ដោយផ្ទាល់ទៅលើកម្រិតម៉ាក្រូសេដ្ឋកិច្ចនេះ វិបត្តិកូវីដ-១៩ ក៏បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរ ដល់ការងានិងមុខរបរប្រជាពលរដ្ឋនៅទូទាំងប្រទេសរាប់ទាំងការងារ និងមុខរបស់ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ ក៏ដូចជាបែបគ្រួសារ។ បើទោះបីជាក្នុងរូបភាពដោយឡែកវិស័យទេសចរណ៍ហាក់រងគ្រោះខ្លាំងជាងគេ ក៏ប៉ុន្តែក្នុងរូបភាពទូទៅវិញវិស័យដែលជាសរសរទ្រូងសេដ្ឋកិច្ចទាំងនេះមានទំនាក់ទំនងនឹងគ្នាដោយផ្ទាល់ និងដោយប្រយោលដែលផលប៉ះពាល់ទៅលើវិស័យណាមួយអាចនឹងនាំមកនូវផលប៉ះពាល់ដល់វិស័យដទៃទៀត។ ជាក់ស្តែងដោយសារតែមានភាពអសកម្មលើវិស័យទេសចរណ៍បានធ្វើឱ្យអាជីវកម្មជាច្រើនរងផលប៉ះពាល់រួចបញ្ហានេះបានបន្តដល់អាជីវកម្មក្នុងវិស័យដទៃទៀតដូចជា វិស័យអចលនទ្រព្យដែលមានការថមថយនូវការទិញ-លក់ វិស័យហិរញ្ញវត្ថុតាមរយៈការស្នើឱ្យមានការរៀបចំឥណទានឡើងវិញ ការស្នើសុំពន្យាការបង់ប្រាក់ ឬបំណុល

ខូចខាតជាដើម។ ដូចនេះ ដើម្បីស្តារស្ថានភាពសេដ្ឋកិច្ចកម្ពុជាឱ្យប្រសើរឡើងវិញយើងចាំបាច់ត្រូវអនុវត្តជាប្រព័ន្ធហើយការស្តារ និងពង្រឹងវិស័យណាមួយអាចជះឥទ្ធិពលវិជ្ជមានផងដែរ ទៅលើវិស័យផ្សេងទៀត។ ឧទាហរណ៍៖ ការទាក់ទាញភ្ញៀវទេសចរមកទស្សនាប្រទេសកម្ពុជាមិនត្រឹមតែអាចធ្វើឱ្យកើននូវប្រាក់ចំណូលជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏រួមចំណែកធ្វើឱ្យអាជីវកម្ម មុខរបរ ព្រមទាំងការងារនានាទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធលើវិស័យក្រៅពីទេសចរណ៍មានដំណើរការឡើងវិញ ហើយអាចនឹងបង្កើតការងារបានច្រើនបន្ថែមទៀតផងដែរ។

## ២. អនុសាសន៍

ជាការពិតដោយសារតែវិបត្តិមួយនេះនៅមិនទាន់ត្រូវបានបិទបញ្ចប់ វិធានការចម្បងជាងគេនាពេលបច្ចុប្បន្នគឺវិធានការសុខាភិបាលក្នុងការបង្ការការរីករាលដាលនៃជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។ វិធានការនេះចាំបាច់ត្រូវតែអនុវត្តឱ្យបានខ្ជាប់ខ្ជួនលើគ្រប់វិស័យទាំងអស់ និងគ្រប់មជ្ឈដ្ឋានទាំងប្រជាពលរដ្ឋ អាជីវករ កម្មករ ក៏ដូចជាបុគ្គលិកធ្វើការតាមស្ថាប័នរដ្ឋ ឯកជន និងអង្គការជាតិ និងអន្តរជាតិផងដែរ។ ដោយឡែកនេះ គឺជាវិធានការមានស្រាប់ ដែលយើងចាំបាច់ត្រូវអនុវត្តដូចនេះគំនិតយុទ្ធសាស្ត្រនៅក្នុងជំពូកនេះផ្តោតជាសំខាន់ទៅយុទ្ធសាស្ត្រយូរអង្វែងជាជាងយុទ្ធសាស្ត្រដែលប្រើក្នុងអំឡុងនៃការរីករាលដាលនៃជំងឺកូវីដ១៩ ឬត្រឹមតែការស្តារស្ថានភាពវិស័យនានាដែលរងគ្រោះដោយសារជំងឺកូវីដ-១៩។ យុទ្ធសាស្ត្រមួយចំនួនដែលបានលើកឡើងអាចប្រើប្រាស់បានក្នុងរយៈពេលខ្លី មធ្យម ឬរយៈពេលវែងដោយអាស្រ័យទៅតាមការប្រែប្រួលនៃស្ថានភាពជាក់ស្តែង។

### ក) អនុសាសន៍សម្រាប់វិស័យទេសចរណ៍

ខាងក្រោមនេះ គឺជាគំនិតយុទ្ធសាស្ត្រមួយចំនួនដែលក្រុមយើងខ្ញុំបានស្រាវជ្រាវសម្រាប់ការស្តារឡើងវិញនូវវិស័យទេសចរណ៍ក៏ដូចជាដើម្បីពង្រឹង និងអភិវឌ្ឍវិស័យនេះឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀត។ គំនិតយុទ្ធសាស្ត្រទាំងនេះមួយចំនួនអាចប្រើប្រាស់បានក្នុងកាលៈទេសៈនៃវិបត្តិជំងឺកូវីដ-១៩ មិនទាន់អាចគ្រប់គ្រងបានទាំងស្រុង និងមួយចំនួនទៀតអាចប្រើប្រាស់បានក្នុងរយៈពេលវែងដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ជាតិឱ្យកាន់តែមានភាពប្រសើរឡើងប្រកបដោយនិរន្តរភាព។

### ❖ វិធានការ អនាម័យ និងសុខាភិបាល

ក្នុងដំណាក់កាលនៃវិបត្តិកូវីដ-១៩ នៅមិនទាន់ចប់វិធានការអនាម័យ និងសុខាភិបាលដែលមានស្រាប់មានសារៈសំខាន់បំផុតក្នុងការការពារការរីករាលដាលនៃជំងឺនេះបន្តទៀត ក៏ដូចជាពង្រឹងនូវជំនឿចិត្តពីភ្ញៀវទេសចរណ៍បុគ្គលិក ដែលបម្រើការក្នុងវិស័យនេះនិងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។ បើទោះបីជាវិបត្តិកូវីដ-១៩នេះបានបញ្ចប់ជាស្ថាពរក្តីកម្ពុជាគួរតែបន្តអនុវត្តនូវវិធានការអនាម័យ និងសុខមាលភាពសាធារណៈឱ្យបាន

ខ្ទាប់ខ្លួនទាំងនៅតាមគោលដៅទេសចរណ៍អាជីវកម្ម និងសកម្មភាពទេសចរណ៍ផ្សេងទៀតផងដែរ ដើម្បីធានានូវសុវត្ថិភាពដល់អ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋានក្នុងករណីកើតមាននូវវិបត្តិស្រដៀងគ្នានេះនាពេលអនាគត។

❖ **សុក្រឹតភាព និងតម្លាភាពព័ត៌មាន**

មេរៀនពីប្រទេសម៉ាឡេស៊ីក្នុងអំឡុងពេលនៃការកើតមាននូវជំងឺSARSបានប្រាប់យើងថាការផ្តល់ព័ត៌មានអំពីស្ថានភាពជាក់លាក់នៃការវិវត្តរបស់ជំងឺក្នុងប្រទេសពិតជាមានសារៈសំខាន់ក្នុងការ បង្កើននូវទំនុកចិត្តពីភ្ញៀវទេសចរអន្តរជាតិ។ តាមរយៈនេះកម្ពុជាចាំបាច់ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយស្ថាប័នសុខមាលភាពជាតិ និងអន្តរជាតិក្នុងការផ្តល់ព័ត៌មានប្រកបដោយតម្លាភាពទាក់ទងនឹង ការវិវត្តថ្មីៗនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេស។ ការផ្តល់ព័ត៌មានច្បាស់លាស់ និងតម្លាភាពទាក់ទងនឹងស្ថានភាពនេះអាចធ្វើឱ្យកម្ពុជាអាចទទួលបានអត្ថប្រយោជន៍ច្រើនទាំងការងារការពារការឆ្លងរាលដាលនៃជំងឺនេះ ក៏ដូចជាការទទួលស្គាល់ពីសុវត្ថិភាពនៃជំងឺពីស្ថាប័នអន្តរជាតិ ជាពិសេសអង្គការសុខភាពពិភពលោក។ ប្រាកដណាស់ការផ្តល់ព័ត៌មានទាំងនេះទៅកាន់ពិភពលោកអាចរាប់បញ្ចូលទាំងវិធានការអនាម័យ និងសុខមាលភាពសាធារណៈដែលបានអនុវត្តកិច្ចការនេះនឹងកាន់តែធ្វើឱ្យកម្ពុជាទទួលបាននូវទំនុកចិត្តពីសំណាក់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។

❖ **ជំរុញទេសចរណ៍ក្នុងស្រុក**

ជាក់ស្តែងទេសចរណ៍ក្នុងស្រុក គឺជាកម្លាំងចលករដ៏សំខាន់ក្នុងការពង្រឹងវិស័យទេសចរណ៍ជាតិជាពិសេសក្នុងដំណាក់កាលនេះតែម្តង។ បើទោះបីជាវិបត្តិកូវីដ-១៩ត្រូវបានបញ្ចប់ក្នុងពេលខាងមុខក្តីប៉ុន្តែក្នុងរយៈពេលខ្លីនេះទេសចរណ៍ក្នុងស្រុក នឹងដើរតួសំខាន់ជាងទេសចរណ៍ក្រៅស្រុក។ ដើម្បីជំរុញសកម្មភាពទេសចរណ៍ក្នុងស្រុកឡើងវិញ ស្ថាប័នការងារទាំងឡាយទាំងរដ្ឋ និងឯកជន អាចពិចារណា ឬលើកទឹកចិត្តបុគ្គលិកឱ្យមានការឈប់សម្រាកជាលក្ខណៈគ្រួសារ ដើម្បីបង្កើនឱកាសក្នុងការធ្វើដំណើរកំសាន្តក្នុងស្រុក។ ជាមួយគ្នានេះប្រតិបត្តិករទេសចរណ៍ទាំងឡាយ គួររៀបចំឱ្យមាននូវកញ្ចប់ទេសចរណ៍ពិសេសៗជាលក្ខណៈគ្រួសារ ឬក្រុមដើម្បីជំរុញការធ្វើដំណើរក្នុងស្រុកឱ្យកាន់តែសកម្មថែមទៀត។ ដើម្បីជំរុញសកម្មភាពនេះបន្ថែមទៀតស្ថាប័នរដ្ឋដែលពាក់ព័ន្ធក្រុមហ៊ុនឯកជន ដែលប្រកបអាជីវកម្មក្នុងវិស័យនេះក៏ដូចជាអ្នកគ្រប់គ្រងគោលដៅទេសចរណ៍ផ្ទាល់ត្រូវយកចិត្តទុកដាក់ខ្ពស់លើការផ្សព្វផ្សាយអំពីសេវាកម្មទេសចរណ៍ឱ្យបានកាន់តែទូលំទូលាយថែមទៀត។ ដោយសារសម័យនេះជាយុគសម័យឌីជីថលការប្រើប្រាស់យន្តការឌីជីថលក្នុងការផ្តល់ព័ត៌មាន និងផ្សព្វផ្សាយសកម្មភាពទេសចរណ៍គួរតែត្រូវបានអនុវត្តឱ្យបានទូលំទូលាយ។

ជាក់ស្តែងវិស័យទេសចរណ៍របស់ជាតិអាស្រ័យកំណើននៃភ្ញៀវទេសចរណ៍អន្តរជាតិក៏ប៉ុន្តែការលើកទឹកចិត្តនិងទទួលយកភ្ញៀវទេសចរណ៍បរទេសក្នុងបរិបទនៃវិបត្តិនេះមិនទាន់បញ្ចប់ចាំបាច់ត្រូវថ្លឹងថ្លែងលើបញ្ហាសុខភាព និងសុវត្ថិភាពសាធារណៈផងដែរ។ យ៉ាងណាការលើកទឹកចិត្តទេសចរណ៍អន្តរជាតិគឺជារឿងចាំបាច់ដែលត្រូវធ្វើជាពិសេសបន្ទាប់ពីការរាលដាលនៃជំងឺកូវីដ-១៩ត្រូវបានបញ្ចប់ ។ ខាងក្រោមនេះជាអនុសាសន៍មួយចំនួនដែលអាចចូលរួមជាធាតុចូលក្នុងការរៀបចំផែនការក៏ដូចជា យុទ្ធសាស្ត្រដើម្បីទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិមកទស្សនាប្រទេសកម្ពុជា។

- ពង្រឹងវិធានការអនាម័យ និងសុខមាលភាពសាធារណៈដូចដែលបានរៀបរាប់ខាងដើម។
- ពិចារណាលើការបើកទំនាក់ទំនងទេសចរណ៍ ជាមួយប្រទេសក្នុងតំបន់ដែលមានកម្រិតហានិភ័យទាបក្នុងទម្រង់ជាទ្វេភាគី ឬត្រីភាគីជាដើម។
- រៀបចំដំណើរការជើងហោះហើរឱ្យមានភាពប្រក្រតីឡើងវិញឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានប្រយោជន៍បម្រើនូវការដឹកជញ្ជូននានា ជាពិសេសភ្ញៀវទេសចរដែលនឹងធ្វើដំណើរមកកំសាន្តនៅក្នុងប្រទេសកម្ពុជា។
- បង្កើនជើងហោះហើរដោយផ្ទាល់ពីប្រទេសផ្សេងៗមកកាន់កម្ពុជាឱ្យបានកាន់តែច្រើន ដើម្បីជៀសវាងនូវការផ្ទេរភ្ញៀវនៅតាមប្រទេសជិតខាង។
- សម្រួលបែបបទអន្តោប្រវេសន៍នៅតាមព្រលានយន្តហោះក៏ដូចជាតាមច្រកទ្វារអន្តរជាតិនានាប្រកបដោយសេវាកម្មល្អផ្តល់ភាពកក់ក្តៅ និងឆាប់រហ័ស។
- ពង្រឹងសុវត្ថិភាព និងសណ្តាប់ធ្នាប់នៅតាមរមណីយដ្ឋានក៏ដូចជាតំបន់ទេសចរណ៍ដទៃទៀតនៅតាមខេត្តផ្សេងៗឱ្យមានប្រសិទ្ធភាពខ្ពស់។
- ប្រតិបត្តិករទេសចរណ៍ត្រូវរៀបចំឱ្យមានកញ្ចប់ទេសចរណ៍សម្បូរបែប និងមានតម្លៃសមរម្យដោយភ្ញៀវអាចមានឱកាសកាន់តែច្រើនក្នុងការធ្វើដំណើរទេសចរណ៍បានច្រើនកន្លែងនៅតាមប៉ូលទេសចរណ៍សំខាន់ៗរបស់កម្ពុជា។

❖ **ពង្រឹងការផ្សព្វផ្សាយពីទេសចរណ៍នៅក្រៅប្រទេស**

តាមរយៈការសម្ភាស៍ប្រតិបត្តិករទេសចរណ៍មួយចំនួនបង្ហាញថា បញ្ហាប្រឈមធំមួយនៃវិស័យទេសចរណ៍កម្ពុជា គឺកង្វះការផ្សព្វផ្សាយពីផលិតផលនិងសេវាកម្មទេសចរណ៍របស់ជាតិនៅទីផ្សារក្នុងប្រទេស។ ជាផ្នែកមួយនៃការជំរុញ និងលើកទឹកចិត្តទេសចរណ៍អន្តរជាតិ ការផ្សព្វផ្សាយពីទេសចរណ៍ជាតិនៅតាមបណ្តា

ប្រទេសនានា ពិតជាមានសារៈសំខាន់បំផុត។ ជាមួយនឹងចំណុចនេះ ដើម្បីបង្កើនការផ្សព្វផ្សាយពីទេសចរណ៍ឱ្យបានកាន់តែទូលំទូលាយនៅក្រៅប្រទេសយើងគួរតែអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ប្រតិបត្តិករទេសចរណ៍ក្នុងស្រុក គួរពិចារណាបង្កើតសាខាក្រុមហ៊ុននៅក្រៅប្រទេសឱ្យបានកាន់តែច្រើន ជាពិសេសនៅតាមប្រទេសដែលជាគោលដៅទេសចរណ៍សំខាន់ៗ។
- ស្ថានទូត ស្ថានកុងស៊ុលក្រសួងទេសចរណ៍ និងប្រតិបត្តិករទេសចរក្នុងស្រុកត្រូវសហការគ្នា
- រៀបចំផលិតជាខ្សែវីឌីអូខ្លីៗ អំពីតំបន់ទេសចរណ៍ក្នុងប្រទេសកម្ពុជា និងផ្សព្វផ្សាយទៅកាន់ពិភពលោកតាមបណ្តាញសារព័ត៌មានបរទេសក្នុងស្រុកក៏ដូចជាបណ្តាញសង្គមនានា។

❖ **បណ្តុះបណ្តាលជំនាញទេសចរណ៍ពាក់ព័ន្ធ**

ដើម្បីបង្កើនភាពទាក់ទាញ ព្រមទាំងពង្រឹងនូវសេវាកម្មទេសចរណ៍របស់ខ្លួនឡើងវិញរាជរដ្ឋាភិបាលក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា ត្រូវរៀបចំឱ្យមានការបណ្តុះបណ្តាលជំនាញផ្សេងៗទាក់ទងទៅនឹងវិស័យទេសចរណ៍ដូចខាងក្រោម៖

- បណ្តុះបណ្តាលមគ្គុទេសក៍ទេសចរណ៍ឱ្យយល់ឱ្យបានច្បាស់នូវវប្បធម៌របស់ខ្លួនដើម្បីផ្សព្វផ្សាយទៅកាន់ពិភពលោក ហើយខ្លឹមសារដែលត្រូវបណ្តុះបណ្តាលត្រូវមានឯកលក្ខណៈភាព
- ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាកម្មទេសចរណ៍ រួមមានមគ្គុទេសន៍ អាហារដ្ឋាន
- ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈអ្នកប្រកបអាជីវកម្មក្នុងវិស័យទេសចរណ៍ ។ ល។

❖ **បង្កើនភាពទាក់ទាញលើសេវាកម្មទេសចរណ៍**

រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានាគួរបន្ថែមភាពទាក់ទាញលើវិស័យទេសចរណ៍ជាតិតាមរយៈយន្តការមួយចំនួនដូចខាងក្រោម៖

- រៀបចំឱ្យមានកម្មវិធីបង្ហាញ និងផ្សព្វផ្សាយពីផលិតផលសិប្បកម្មក្នុងស្រុកគ្រប់ប្រភេទដូចជា ចម្លាក់ឈើ ផលិតកម្មសូត្រ និងផលិតផលសិប្បកម្មបែបវប្បធម៌ សិល្បៈនានានៅតាមតំបន់ទេសចរណ៍នានា។
- រៀបចំឱ្យមានកម្មវិធីបែបសង្គម និងវប្បធម៌ដែលជាអត្តសញ្ញាណរបស់ជាតិឱ្យបានគ្រប់ខេត្ត ក្រុង និងជាពិសេសបង្ហាញពីអត្តសញ្ញាណរបស់ខេត្តនីមួយៗ តំបន់នីមួយៗ វប្បធម៌ ប្រពៃណីរបស់ជនជាតិភាគតិចរបស់កម្ពុជា តាមរយៈកម្មវិធីទាំងនោះដល់ភ្ញៀវទេសចរណ៍។

- សម្រួលសកម្មភាពមួយចំនួនរបស់ភ្ញៀវដូចជា ការស្នើសុំថតវិឌីអូអាពាហ៍ពិពាហ៍ ឬការស្នើសុំរៀបចំកម្មវិធីអាពាហ៍ពិពាហ៍ជាតំណាងក្រោមរូបភាពតូចៗ នៅតំបន់ប្រាសាទជាដើម។
- រៀបចំផ្លូវនៅក្នុងតំបន់ទេសចរណ៍ឱ្យបានស្អាត ព្រមទាំងសុវត្ថិភាពជាពិសេសផ្លូវនានានៅតាមប្រាសាទ ឬតំបន់អង្គរទាំងមូល។
- ត្រូវយកចិត្តទុកដាក់ខ្ពស់ពីអនាម័យ និងសុវត្ថិភាពចំណីអាហារព្រមទាំងកន្លែងស្នាក់នៅអភិវឌ្ឍតំបន់ទេសចរណ៍ប្រកបដោយនិរន្តរភាពដោយគិតគូរពីផលប៉ះពាល់លើបរិស្ថាន និងសុខមាលភាពសាធារណៈជាគោល។

❖ **ពង្រឹងឯកលក្ខណៈភាព និងគុណភាពវត្ថុអនុស្សាវរីយ៍**

ការពង្រឹងនូវផលិតកម្មវត្ថុអនុស្សាវរីយ៍ទេសចរណ៍ដែលផលិតដោយសិប្បកម្ម ឬផលិតករក្នុងស្រុកក៏ជាយុទ្ធសាស្ត្រមួយដែលអាចធ្វើឱ្យមានភាពទាក់ទាញខ្លាំងលើវិស័យទេសចរណ៍ជាតិផងដែរ។ យុទ្ធសាស្ត្រនេះចាំបាច់ត្រូវផ្សារភ្ជាប់ជាមួយនឹងគុណភាពការច្នៃប្រឌិត និងឯកលក្ខណៈលើផលិតផលទាំងនោះផងដែរ ជាពិសេសវត្ថុអនុស្សាវរីយ៍ដែលមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណរបស់ជាតិ។កម្ពុជាគួរមានការត្រួតពិនិត្យឱ្យបានខ្ពស់ទៅលើគុណភាពគុណតម្លៃរបស់ផលិតផលវត្ថុអនុស្សាវរីយ៍ ដែលបង្កប់នូវអត្តសញ្ញាណរបស់ជាតិក្នុងគោលបំណងពង្រឹងទំនុកចិត្តពីសំណាក់ភ្ញៀវទេសចរណ៍ក៏ដូចជា ផ្សព្វផ្សាយនូវវប្បធម៌ជាតិទៅកាន់ពិភពលោកផងដែរ។

❖ **រៀបចំផែនទីទេសចរណ៍**

ក្នុងគោលដៅយូរអង្វែងកម្ពុជាចាំបាច់ត្រូវរៀបចំឱ្យមានផែនទីទេសចរណ៍សម្រាប់គ្រប់គោលដៅទេសចរណ៍ទាំងអស់នៅក្នុងប្រទេស។ ការរៀបចំផែនទីបង្ហាញផ្លូវចាំបាច់ត្រូវមានព័ត៌មានគ្រប់ជ្រុងជ្រោយរាប់ទាំងទីតាំងរម្មណីយដ្ឋានសកម្មភាពកំសាន្តសំខាន់ៗនៅតាមរមណីយដ្ឋានឬគោលដៅទេសចរណ៍នីមួយៗព័ត៌មានពីទីកន្លែងស្នាក់នៅហាងអាហារមធ្យោបាយធ្វើដំណើរ និងតម្លៃជាដើម។ ជាមួយនឹងសកម្មភាពសំខាន់ៗជាពិសេសគោលដៅទេសចរណ៍ដែលមានលក្ខណៈផ្សងព្រេងគួរមានបញ្ចូលពីសម្ភារៈ ដែលអ្នកទេសចរណ៍គួរត្រៀមសម្រាប់ដំណើរទេសចរណ៍នេះ។ លើសពីនេះការរៀបចំផែនទីបង្ហាញផ្លូវត្រូវបញ្ចូលឱ្យមានភាសាច្រើនជាពិសេសភាសាសម្រាប់ក្រុមគោលដៅទេសចរណ៍សំខាន់ៗរបស់កម្ពុជាមានដូចជា៖ ភាសាអង់គ្លេស បារាំង ចិន អេស្បាញ កូរ៉េ និងភាសាថៃជាដើម។

❖ **ផ្តោតលើនិរន្តរភាពវិស័យទេសចរណ៍**

ដាក់ស្តែងទេសចរណ៍បែបធម្មជាតិកំពុងតែទទួលបានការចាប់អារម្មណ៍ច្រើនឡើងៗពីសំណាក់ភ្ញៀវទាំងភ្ញៀវជាតិ និងអន្តរជាតិដូចនេះកម្ពុជាគួរពិចារណាប្រកាន់យកនូវការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចបាននូវកិច្ចការទាំងនេះរាជរដ្ឋាភិបាលក៏ដូចជាអ្នកពាក់ព័ន្ធលើវិស័យនេះ គួរពិចារណាលើវិធានការដូចខាងក្រោម៖

- ពង្រឹងការវិនិយោគលើទេសចរណ៍បែបសហគមន៍កម្ពុជាមានសក្តានុពលខ្ពស់លើទេសចរណ៍បែបសហគមន៍ដោយសារយើងមានសហគមន៍ជនជាតិភាគតិច និងវប្បធម៌បែបចម្រុះ។
- ពង្រឹងការអនុវត្តច្បាប់ការពារបរិស្ថាន និងជីវចម្រុះព្រមទាំងសកម្មភាពខុសច្បាប់លើធនធានធម្មជាតិគ្រប់ប្រភេទជាពិសេសនៅតាមគោលដៅទេសចរណ៍ទាំងឡាយ។
- បង្កើនការវិនិយោគក្នុងការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពទាញយកអត្ថប្រយោជន៍ពីធម្មជាតិដើម្បីបម្រើឱ្យវិស័យទេសចរណ៍។
- ការពារសហគមន៍ងាយរងគ្រោះ ឬតំបន់ជនជាតិដើមភាគតិចពីការបំផ្លិចបំផ្លាញតាមគ្រប់រូបភាពដើម្បីប្រយោជន៍លើវិស័យទេសចរណ៍។

❖ **ពង្រឹងការស្រាវជ្រាវ**

ក្រសួងទេសចរណ៍ស្ថាប័នអប់រំ ស្ថាប័នស្រាវជ្រាវព្រមទាំងស្ថាប័នពាក់ព័ន្ធនានា ចាំបាច់ត្រូវពង្រឹងកិច្ចការងារស្រាវជ្រាវទាក់ទងនឹងវិស័យទេសចរណ៍ឱ្យបានទូលំទូលាយជាងមុន។ ការសិក្សាស្វែងយល់ពីបញ្ហាប្រឈមនានា ទំនោរក្នុងវិស័យទេសចរណ៍ជាពិសេសទៅលើចំណង់ចំណូលចិត្តរបស់ភ្ញៀវទាំងទៅលើម្ហូបអាហារសេវាកម្មកញ្ចប់ទេសចរណ៍រម្មណីយដ្ឋាន និងកង្វះខាតផ្សេងទៀតរបស់កម្ពុជាក្នុងវិស័យទេសចរណ៍គឺជាកិច្ចការចាំបាច់បំផុតមួយ។ ការធ្វើបែបនេះ នឹងអាចឱ្យកម្ពុជាធ្វើការឆ្លើយតបទៅតាមតម្រូវការចំណូលចិត្តក៏ដូចជាការប្រែប្រួលនានាទាំងនៅលើកត្តាភ្ញៀវទេសចរណ៍តំបន់ទេសចរណ៍ ឬសេវាកម្មនានានៅក្នុងវិស័យនេះផងដែរ។

**ខ) អនុសាសន៍សម្រាប់វិស័យអចលនទព្យ**

❖ **ចំពោះរដ្ឋាភិបាល**

- ផ្តល់ប្រាក់កម្ចីមានអត្រាការប្រាក់ទាប៖ ដាក់ស្តែងការផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបចំពោះអ្នកវិនិយោគពិតជាអាចជួយជំរុញនូវអាជីវកម្មបានច្រើនមិនត្រឹមតែក្នុងវិស័យអចលនទ្រព្យប៉ុណ្ណោះទេ។ ភ្នាក់ងារនិងបុគ្គលិកក្រុមហ៊ុនអចលនទ្រព្យដែលបានចូលរួមក្នុងការសិក្សានេះ បានធ្វើ

ការគូសបញ្ជាក់ថាប្រសិនបើធនាគារ ឬស្ថាប័នហិរញ្ញវត្ថុនានាផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបជាងនេះបន្តិច អ្នករកស៊ីខាងអចលនទ្រព្យអាចមានលទ្ធភាពប្រសើរជាងមុនក្នុងការអភិវឌ្ឍអចលនទ្រព្យរបស់ខ្លួនជាពិសេសមានលទ្ធភាពខ្ពស់ក្នុងការទប់ទល់ នឹងហានិភ័យនានាដូចករណីកូវីដ-១៩នេះ ជាដើម។ ម្យ៉ាងទៀតការផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបក្នុងវិស័យអចលនទ្រព្យ (រួមទាំងអ្នកអភិវឌ្ឍ ក៏ដូចជាប្រជាពលរដ្ឋ)នឹងធ្វើឱ្យវិស័យមួយនេះកាន់តែរីកចម្រើនដោយសារអ្នកអភិវឌ្ឍមានលទ្ធភាពច្រើនជាងមុនចំណែកអតិថិជនអាចទទួលបានថវិកាពីធនាគារក្នុងអត្រាការប្រាក់ទាបដើម្បីទិញដីធ្លី ផ្ទះ ឬខុនដូ ជាដើមជាពិសេសចំពោះអតិថិជនដែលមានប្រាក់ចំណូលមធ្យម ឬប្រាក់ចំណូលទាប។

- ពន្លឿននីតិវិធីក្នុងការផ្តល់ឯកសារកាន់កាប់
- កែសម្រួលពន្ធលើសម្ភារៈសំណង់៖ ជាមួយនឹងបរិបទនៃជំងឺកូវីដ-១៩ នេះមានការប៉ះពាល់ដល់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋច្រើនដូចនេះ វិធានការកាត់បន្ថយអត្រាពន្ធលើអាជីវកម្មអចលនទ្រព្យលើសម្ភារៈសំណង់ជាដើម អាចធ្វើឱ្យតម្លៃដើមនៃការសាងសង់មានការធ្លាក់ចុះបន្តិច ដែលនេះអាចជួយជម្រុញការផលិត និងតម្រូវការផងដែរ។ ជាការពិតការធ្វើបែបនេះ នឹងប៉ះពាល់ខ្លាំងដល់ថវិកាជាតិដែលបានរងផលប៉ះពាល់ខ្លាំងដូចគ្នាពីវិស័យនេះ ក៏ប៉ុន្តែការជួយសម្រួលបែបនេះអាចធ្វើឱ្យអាជីវកម្មមានលំនឹង និងមានស្ថិរភាពទៅអនាគត។

❖ **សម្រាប់ប្រតិបត្តិករអចលនទព្យ**

- បង្កើតផលិតផលអតិថិជន៖ អនុសាសន៍មួយនេះផ្តោតជាសំខាន់លើអ្នករកស៊ីអចលនទ្រព្យខាងសាងសង់លំនៅដ្ឋានគ្រប់ប្រភេទ ដោយគួរផ្តោតលើប្រភេទសំណង់ដែលត្រូវនឹងតម្រូវការស្ថានភាពរបស់អតិថិជនព្រមទាំងនិន្នាការសង្គមផងដែរ។ បច្ចុប្បន្នសំណង់ដែលមានតម្លៃខ្ពស់ ឬផ្តោតលើអតិថិជនមានប្រាក់ចំណូលខ្ពស់មានទីផ្សារចង្អៀតជាងសំណង់សម្រាប់អតិថិជនដែលមានប្រាក់ចំណូលមធ្យមឬទាប។ គួបផ្សំជាមួយនឹងការប៉ះពាល់លើប្រាក់ចំណូលដោយសារវិបត្តិកូវីដ-១៩ ទៀតអ្នកវិនិយោគគួរផ្តោតលើអ្នកមានចំណូលទាបឱ្យបានច្រើនដើម្បីពង្រឹងឱកាសរបស់ខ្លួនជាមួយ នឹងបរិបទមួយនេះ។
- បង្កើនទំនុកចិត្តដល់អិថិជន៖ ការបង្កើនទំនុកចិត្តដល់អតិថិជន គឺជាចំណុចសំខាន់បំផុតសម្រាប់គ្រប់អាជីវកម្មដូចនេះ អ្នករកស៊ីផ្នែកអចលនទ្រព្យគប្បីពិចារណាលើកត្តាមួយនេះជាចម្បង។ ត្រង់ចំណុចនេះដែរលោក **អ៊ឹកសុខនីម** ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា (CVEA) បាន

លើកឡើងថាដើម្បីអាចទទួលបានទំនុកចិត្ត និងទទួលបានផលចំណេញខ្ពស់ពីអតិថិជនភ្នាក់ងារអចលនទ្រព្យ ឬក្រុមហ៊ុនផ្តល់សេវាអចលនទ្រព្យត្រូវផ្តល់សេវាកម្មផ្សេងៗលើសពីការរំពឹងទុកទៅកាន់អតិថិជនរបស់ខ្លួនតាមរយៈផ្តល់ប្រឹក្សាយោបល់ និងមានភាពស្មោះត្រង់បំផុតនិងភាពរួសរាយរាក់ទាក់ជាទីបំផុត ។[57] លោកបានមានប្រសាសន៍ថា "ភ្នាក់អចលនទ្រព្យ ឬក្រុមហ៊ុនផ្តល់សេវាអចលនទ្រព្យគឺត្រូវផ្តល់សេវាជាកញ្ចប់មានទាំងរត់ឯកសារលិខិតកក់ប្រាក់ កិច្ចសន្យាទិញ-លក់ និងមានទាំងប្រថាប់ត្រាពីសំណាក់មេធាវី ដើម្បីឱ្យអតិថិជនមានភាពកក់ក្តៅនិងការទិញលក់របស់ពួកគេមានសុវត្ថិភាព និងមានភាពងាយស្រួល" ។

- សហការជាមួយធនាគារដៃគូ៖ ដើម្បីបង្កើតនូវឱកាសក្នុងការវិនិយោគ និងទាក់ទាញអតិថិជនឱ្យបានកាន់តែច្រើន អ្នកអភិវឌ្ឍវិស័យអចលនទ្រព្យគួរស្វែងរកដៃគូធនាគារ ឬស្ថាប័នហិរញ្ញវត្ថុមួយ ឬច្រើនដើម្បីសម្រួលកិច្ចការបង់រំលស់របស់អតិថិជនក្នុងអត្រាការប្រាក់ទាបសមរម្យ និងមានភាពងាយស្រួលជាពិសេសរឿងការងារឯកសារ។ការសហការជាមួយធនាគារអាចជួយសម្រួលអតិថិជនក្នុងការចំណាយលើការបង់ប្រាក់ច្រើនប្រចាំខែទៅលើម្ចាស់គម្រោងដែល ជាទូទៅមានអត្រាការប្រាក់ខ្ពស់ជាង។ ទោះជាយ៉ាងណាការផ្តល់នូវអត្រាការប្រាក់ទាបសម្រាប់អតិថិជនក្នុងការបង់រំលោះអចលនទ្រព្យនានាក៏អាចបង្កើតឱ្យមាននូវហានិភ័យផងដែរទាក់ទងនឹងការកើនឡើងនៃបំណុលសាធារណៈ ដូចនេះ ទាំងអ្នកអភិវឌ្ឍក៏ដូចជាដៃគូធនាគារត្រូវពិចារណា ទៅលើលទ្ធភាពនៃការបង់របស់អតិថិជនរបស់ខ្លួនឱ្យបានល្អិតល្អន់ផងដែរ។
- កុំវិនិយោគហួសប្រមាណ៖ ដើម្បីជៀសវាងហានិភ័យដែលអាចកើតមានជាយថាហេតុអ្នកវិនិយោគក្នុងវិស័យអចលនទ្រព្យមិនគួរស្នើសុំប្រាក់កម្ចីពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុនានាឱ្យលើសពីសមត្ថភាពដើមទុន ឬលទ្ធភាពសងត្រឡប់របស់ខ្លួននោះទេ។ ទាក់ទងនឹងចំណុចនេះ លោក **មី វ៉ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់អនុសាសន៍ថាក្រៅពីជៀសវាងនូវការប្រើប្រាស់ប្រាក់កម្ចីវិនិយោគពីស្ថាប័នហិរញ្ញវត្ថុដែលលើសពីសមត្ថភាព អ្នកវិនិយោគក៏មិនគួរវិនិយោគដោយមិនគិតពីតម្រូវការទីផ្សារក្នុងស្រុក និងការរីកចម្រើននៃបរិបទសកលលោកនោះទេ។ លោកបានធ្វើការគូសបញ្ជាក់បន្ថែមថា ប្រសិនជាបរិបទខាងក្រៅមានវិបត្តិនោះលំហូរទុនវិនិ

---

[57] (២០២០ ១៩ តុលា) ប្រធានសមាគម CVEA , ភ្នាក់ងារអចលនទ្រព្យត្រូវបង្កើនទៅទំនុកចិត្តដល់អតិថិជន.ដកស្រង់ចេញពី៖ https://www.propertyarea.asia

យោគមកក្នុងស្រុកនឹងថមថយ ហើយកំណើនប្រាក់ចំណូលសម្រាប់ប្រជាជនក៏តិចតួចនាំឱ្យអំណាចទិញរបស់គាត់ទាបទៅតាមនេះដែរ ។[58]

**គ) អនុសាសន៍ដើម្បីបង្កើតការងារនិងមុខរបរ**

**❖ ជំរុញសហគ្រាសតូចនិងមធ្យម**

សហគ្រាសខ្នាតតូច និងមធ្យមដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាខណៈដែលវាបានបង្កើតការងារស្មើនឹងចំនួន៧០% នៃការងារសរុបក្នុងស្រុក។ ផ្អែកលើទឡ្ហីករណ៍នេះ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ខ្ពស់លើការជំរុញសហគ្រាសធុនតូចនិងមធ្យមលើគ្រប់វិស័យរួមមាន ទេសចរណ៍ អចលនទ្រព្យ បច្ចេកវិទ្យា អប់រំ កសិកម្ម និងសិប្បកម្មជាដើម។ ការសម្រួលនីតិវិធីអាជីវកម្ម និងការផ្តល់ទុនវិនិយោគដែលមានអត្រាការប្រាក់ទាប ក៏ជាយន្តការមួយដើម្បីជំរុញសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាបានច្រើនផងដែរ។

**❖ ពង្រឹងយន្តការទាក់ទាញវិនិយោគិនបរទេស**

ការទាក់ទាញការវិនិយោគលើវិស័យឧស្សាហកម្មគឺជារឿងចាំបាច់មួយរបស់រាជរដ្ឋាភិបាលជាពិសេសការកៀរគរការវិនិយោគទុនពីបរទេសឱ្យបានកាន់តែច្រើន។ រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការពិនិត្យនិងរៀបចំគោលនយោបាយវិនិយោគទុន ដែលអាចមានភាពទាក់ទាញច្រើនជាងមុនសម្រាប់អ្នកវិនិយោគបរទេសជាពិសេសសម្រាប់ការវិនិយោគដែលអាចបង្កើតការងារបានច្រើនសម្រាប់ប្រជាពលរដ្ឋកម្ពុជាដើម្បីសម្រេចកិច្ចការនេះបានកម្ពុជាអាចពិចារណាលើគំនិតយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- បង្កើតនូវបរិស្ថានវិនិយោគដែលមានតម្លាភាព សម្រាប់អ្នកវិនិយោគទុនបរទេសតាមរយៈការពង្រឹងវិធានការផ្លូវច្បាប់សម្រាប់ការវិនិយោគជាដើម។
- ត្រូវមានផែនការច្បាស់លាស់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស កម្មករជំនាញដែលស្របទៅតាមតម្រូវការជាក់ស្តែងរបស់ទីផ្សារការងារសម្រាប់ពេលបច្ចុប្បន្ននិងអនាគត។ ត្រូវពិនិត្យមើលលើគោលនយោបាយសម្បទានផ្នែកវិនិយោគ ដើម្បីធានាឱ្យបាននូវបរិស្ថានដែលមានគុណភាពសម្រាប់ទាក់ទាញវិនិយោគិនបរទេស។

[58] (២០១៧ ១៧ កុម្ភៈ) វិធានការសម្រាប់អចលនទ្រព្យកម្ពុជា. ដកស្រង់ចេញពីគេហទំព័រ៖ https://www.realestate.com.kh/km/news/governments-property-market-prospects-2016-with-mr-mey-vann/

- ត្រូវអនុវត្តគោលនយោបាយទ្រទ្រង់ផលិតករនិងអ្នកផ្គត់ផ្គង់ក្នុងស្រុកនិងផ្សារភ្ជាប់ជាមួយនឹងការវិនិយោគបរទេស។
- ពង្រាយតំបន់ឧស្សាហកម្មឱ្យបានរាយប៉ាយទៅតាមខេត្ត ឬតំបន់ជនបទនានាដែលយន្តការនេះមិនត្រឹមតែអាចបង្កើតការងារបន្ថែមទៀតនោះទេ ប៉ុន្តែថែមទាំងអាចជំរុញវិស័យអចលនទ្រព្យ និងបង្កើតមុខរបរ ឬអាជីវកម្មជូនប្រជាពលរដ្ឋរស់នៅតំបន់ក្បែរៗនោះផងដែរ។

❖ **អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធវិនិយោគ**

ដើម្បីទាក់ទាញការវិនិយោគ កម្ពុជាចាំបាច់ត្រូវមានហេដ្ឋារចនាសម្ព័ន្ធវិនិយោគឱ្យបានសមស្របផងដែរ។ ការអភិវឌ្ឍលើប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទទាំងផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក (កំពង់ផែ) ការវិនិយោគលើការផលិតថាមពលអគ្គិសនីពង្រីកប្រព័ន្ធទឹកស្អាតជាដើម នឹងបង្កើនភាពទាក់ទាញបន្ថែមទៀតទៅលើឱកាសក្នុងការទាក់ទាញវិនិយោគទុនបរទេស។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ នឹងដើរតួយ៉ាងសំខាន់ក្នុងការកាត់បន្ថយការចំណាយលើថ្លៃដើមផលិតកម្ម និងសម្រួលដល់ការដឹកជញ្ជូនផងដែរ។

# ឯកសារយោង

# ឯកសារយោង

- **ឯកសារជាភាសាខ្មែរ**


- ដកស្រង់ចេញពីសៀវភៅសេដ្ឋកិច្ចនយោបាយ )POLITICAL ECONOMY)
- ក្រសួងទេសចរណ៍ (សេចក្តីព្រាង ថ្ងៃទី១២ សីហា ២០២២ ) ៖ ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយកូវីដ-១៩
- របាយការណ៍ប្រចាំឆ្នាំធានាគាជាតិនៃកម្ពុជា https://www.nbc.org.kh/publications/annual_reports.php
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥ ទំព័រទី១០ https://www.tourismecertificate.org/upload/files/1568954247_2736_.35715pdf
- ( ២០២១,២១ កុម្ភៈ) ផលប៉ះពាល់នៃកូវីដ-១៩ទៅលើសង្គមនិងសេដ្ឋកិច្ចកម្ពុជា, Impacts of COVID-19 Crisis on Cambodia´s Socio-Economy
- (២០២០, ៣ វិច្ឆកា). អ្នកទេសចរណ៍ជាង៦៨នាក់ធ្វើដំណើរកម្សាន្តនៅថ្ងៃឈប់សំរាកនៃព្រះរាជពិធីគ្រងសម្បិត្តនិងបុណ្យអុំទូក
- (២០១៩). ក្រសួងទេសចរណ៍ និងចាត់វិធានការក្តៅ ចំពោះប្រតិបត្តិករទេសចរណ៍ "ការរកស៊ីកាប់ភ្ញៀវ" ដោយផ្តល់បែបសេវាបែប Zero Package Tour.
- (កុម្ភៈ ២០២១). ផលប៉ះពាល់នៃកូវីដ-១៩ ទៅលើសង្គម និងសេដ្ឋកិច្ចកម្ពុជា, Impacts of COVID-19 Crisis on Cambodia´s Socio-Economy


- **ឯកសារជាភាសាបរទេស**


- Worlddometers.(2020).COVID-19CORONAVIRUSPANDEMIC.Retrievedfrom https://www.worldometers.info/coronavirus/#countries
- Laura Oliver. (2020, March 18). Most people see COVID-19 as an economic crisis first, healthrisksecond,surveyfinds,retrievedonSeptember02,2020from https://www.weforum.org/agenda/2020/03/covid-19-public-perception-economic-health-crisis-coronavirus-pandemic-ipsos/

- Spencer Anderson. (2013, August 20). A history of the past 40 years in financial crises. Retrieved on September 02, 2020 from https://www.ifre.com/story/1291951/a-history-of-the-past-40-years-in-financial-crises-0dxjlzsrcx.
- Cambodianess. (2020). The Asian Development Bank maps out economic impacts of various scenarios as the coronavirus spreads to over 70 countries. Retrieved on April 20th, 2020 from; https://cambodianess.com/article/how-will-covid-19-affect-cambodias-economy
- WB.(2020,Oct14).CambodiaOverview.Retrievedfrom: https://www.worldbank.org/en/country/cambodia/overview
- OpenDevelopment Cambodia. (2020, June 3). Small and medium enterprises (SME). Retrieved from: https://opendevelopmentcambodia.net/topics/small-and-medium-enterprises-sme/#return-note-136409-14
- Asean Today. (2020). COVID-19 lessons for Cambodia: Boosting resilience and economicrecovery.RecievedonApril20th,2020from: https://www.aseantoday.com/2020/04/covid-19-lessons-for-cambodia-boosting-resilience-and-economic-recovery/
- H. Plecher.(2020, Nov 18). Cambodia: Share of economic sectors in the gross domestic product (GDP) from 2009 to 2019.
- Knoema.com. (nd). Cambodia - Contribution of travel and tourism to GDP as a share of GDP
- Sovannou Pich. (2019, 29 May). Tourism′s Contribution to the GDP. Retrieved from: https://cambodianeconomy.org/topic/latest-post/tourism/1021/
- Covid-19Socio-EconomicImpactAssessment https://www.unicef.org/cambodia/reports/covid-19-socio-economic-impact-assessment

- SheithKhidhir.(2019,22July).MadeinChina:Zero-dollartourists. https://theaseanpost.com/article/made-china-zero-dollar-tourists
- Focus Economics. (2020, November 17). Cambodia Economic Outlook
- One Planet Network. (2020). How tourism can recover responsibly from COVID-19. Retrieved from: https://www.oneplanetnetwork.org/sustainable-tourism/covid-19-how-tourism-can-recover-responsibly
- The Phnom Penh Post. (2020, June 17). Vietnam to encourage construction of cheap apartments. Retrieved on January 4th

• **ឯកសារជាគេហទំព័រ**

- Open Development Cambodia. ( ២០២០ កញ្ញា, ២០ ), ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមនៃជំម៉ឺកូវីដ-១៩មកលើប្រទេសកម្ពុជា៖ដកស្រង់ចេញពីគេហទំព័រ: https://opendevelopmentcambodia.net/km/profiles/socio-economic-impact-of-covid-19-on-cambodia/
- ប្រវត្តិសង្ខេបនៃសេដ្ឋកិច្ច(June22,2022)ដកស្រង់ចេញពី៖ https://www.investopedia.com/articles/economics//08economic-thought.asp
- (២០១៩ ៣០ តុលា), ទីផ្សារអចលនទ្រព្យកម្ពុជាស្ថិតក្នុងដំណើរលូតលាស់ដោយភាពរឹងមាំនៅឆ្នាំ , ដកស្រង់ចេញពីគេហទំព័រ ៖**ទីផ្សារអចលនទ្រព្យកម្ពុជាស្ថិតក្នុងដំណើរលូតលាស់ដោយភាពរឹងមាំនៅឆ្នាំ ២០១៩នេះ -CNC News**
- Open Development Cambodia. (2020, ២៩ កញ្ញា). ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមនៃជំម៉ឺកូវីដ-១៩មកលើប្រទេសកម្ពុជា.ដកស្រង់ពីគេហទំព័រ៖ https://opendevelopmentcambodia.net/km/profiles/socio-economic-impact-of-covid-19-on-cambodia/
- ប្រវត្តិសង្ខេបនៃសេដ្ឋកិច្ច(June22,2022)ដកស្រង់ចេញពី៖ https://www.investopedia.com/articles/economics/08/economic-thought.asp
- (May 16, 2019) ដកស្រង់ចេញពីគេហទំព័រ៖ របាយការណ៍ CBRE៖ ទស្សនវិស័យនៃទីផ្សារអចលនទ្រព្យកម្ពុជាឆ្នាំ២០១៩ realestate.com.kh

- របាយការណ៍ប្រចាំឆ្នាំធនាគាជាតិនៃកម្ពុជា៖ https://www.nbc.org.kh/publications/annual_reports.php
- វិស័យទេសចរណ៍នៅកម្ពុជា. ដកស្រង់ចេញពីគេហទំព័រ៖ អំពីកម្ពុជា - Realestate.com.kh
- កោះសិន្តភាព. (២០២០) .កូវិដ-១៩ បញ្ចាប់ភាពរីកចម្រើនខ្លាំងរបស់កម្ពុជាក្នុងរយៈពេលពីរទសវត្សរ៍
- (២០២០ ១៩ កញ្ញា) ៣ថ្ងៃនៃបុណ្យភ្ជុំបិណ្ឌមានភ្ញៀវទេសចរណ៍ដើរកម្សាន្តជាង ១លាននាក់. ដកស្រង់ចេញពីគេហទំព័រ: https://vayofm.com/news/detail/104628-446316336.
- (២០២០, ៣ វិច្ឆកា) អ្នកទេសចរណ៍ជាង៦មឺននាក់ធ្វើដំណើរកំសាន្តនៅថ្ងៃឈប់សម្រាកនៃព្រះរាជពិធីគ្រង់រាជសម្បត្តនិងបុណ្យអុំទូក. ដកស្រង់ចេញពីគេហទំព័រ៖ http://news.pnn.com.kh/news/3454
- (២០២០, ១៥ តុលា). អ្នកប្រតិបត្តិទីផ្សារអះអាងថា ការទិញ-លក់អចលនទ្រព្យភាគច្រើនមានសកម្មភាពមានតែនៅក្នុនិងជាយក្រុងតែប៉ុណ្ណោះ.ដកស្រង់ចេញពីគេហទំព័រ៖ https://www.propertyarea.asia
- ( ២០២០ , ១៩ តុលា). តម្លៃជួលការិយាល័យមានការធ្លាក់ចុះ ខណៈពេលការផ្គត់ផ្គង់លើទីផ្សារមានការកើនឡើងខ្ពស់. ដកស្រង់ចេញពីគេហទំព័រ៖ https://www.propertyarea.asia
- (២០២០ ,១៣ តុលា). ខណ្ឌ៤ នៅតែមានមានចរន្តទិញ-លក់អចលនទ្រព្យសកម្មជាងគេ តើមានខណ្ឌណាខ្លះ? ដកស្រង់ចេញពី៖ https://www.propertyarea.asia
- (២០២០ , ១៦ ធ្នូ ). ការស្នើសុំរៀបចំទានឡើងវិញនៅ CMA ចាប់ផ្តើមធ្លាក់ចុះ, ដកស្រង់ចេញពីគេហទំព័រ៖ https://www.postkhmer.com
- (២០២០ ១០ តុលា ). ធនគារជាតិនៃកម្ពុជា៖ វិស័យធនគារកម្ពុជា នៅបន្តមានវឌ្ឍនភាពប្រកបដោយទំនុកចិត្ត. ដកស្រង់ចេញពីគេហទំព័រពារាំងអន្តរជាតិ RFI នៅថ្ងៃទី ១០ តុលា ២០២២
- (២០២០, ២ កក្កដា). ប្រាសាក់ទទួលបានកម្ចីចំនួន ១៥០លានដុល្លារអាមេរិច ពីធនគារ ខេប៊ី គូកមីនដើម្បីពង្រឹងមូលធនកម្មសន្ទនីយភាពនិងការពង្រឹងការផ្តល់តណទាន,ដកស្រង់ចេញពី៖ https://www.prasac.com.kh/kh/news-and-event/prasac-receives-usd-150-million-credit-facilities-from-kb-kookmin-bank
- (២០២១ ១១ កុម្ភៈ) របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ របស់សម្ព័នធនាគារ អេស៊ីលីដា. ដកស្រង់ចេញពីគេហទំព័រ៖ https://www.acledabank.com.kh/kh/khm/ir_pr20210211

- (២០២១,២១,មករា).វិស័យហិរញ្ញវត្ថុកម្ពុជារក្សាកំណើនល្អក្នុងបរិបទកូវីដ.ដកស្រង់ចេញពី៖ https://www.postkhmer.com/
- (២០២១,១មករា).ចំណូលពន្ធដាឆ្នាំ២០២០កើនជិត៤ភាគរយ.ដកស្រង់ចេញពី៖ https://www.postkhmer.com/
- (២០២០, ១២ កុម្ភៈ). អេស៊ីលីដាចំណេញជាង១៤១លានដុល្លារនៅឆ្នាំ ២០២០ ទោះបីមានកូវីដ-១៩ តាមរំខាន. ដកស្រង់ចេញពីគេហទំព័រ៖ https://cambonomist.com/news/acleda-bank-net-profit-2020/?fbclid=IwAR3a3PHF8pcsYIFXubK_umrpLOOVX-DXT5qSmESoUweTzrk031jsPSQnuG8
- Construction&Property. (២០២០, ២៤,១២). រដ្ឋប្រកាសលើកលែងបង់ពន្ធលើអាជីវកម្មសណ្ឋាគារនិងទេសចរណ៍៣ខែបន្ថែមទៀតសម្រាប់ឆ្នាំ២០២១.ដកស្រង់ចេញពីគេហទំព័រ៖ https://www.construction-property.com/km/govt-continues-tourism-related-business-tax-exemption-for-another-three-months/
- ធនគារជាតិ(២០២០).ការអនុវត្តថវិការដ្ឋឆ្នាំ២០២០,ដកស្រង់ចេញពីគេហទំព័រធនគារជាតិ៖ https://mef.gov.kh/assets/uploads/2021/01/TOFE_November-KH-2020.pdf
- (២០២០, ២០ មេសា) តើត្រសួងចំណាយថ្លៃព្យាបាលអ្នកផ្ទុក Covid-19 ម្នាក់អស់ប៉ុន្មាន? ដកស្រង់ចេញពីគេហទំព័រ៖ https://hellokrupet.com/
- (២០២០,៦ វិច្ឆិកា) វិស័យទេសចរណ៍២០២០ កម្ពុជាខាតចំណូលជាង៣ពាន់លានដុល្លារ ស្របពេលអារជីវកម្មទេសចរណ៍ត្រូវបានតិទទ្វារជិត៣ពាន់ទីតាំងប៉ះពាល់ដល់បុគ្គលជិត៥មឺននាក់.ដកស្រង់ចេញពីគេហទំព័រ៖ https://www.cpc-news.com/archives/115804
- Travel Daily News. (2007).ទាញយកពីសៀវភៅ"ផលប៉ះពាល់នៃកូវិដ១៩ ទៅលើសង្គម និងសេដ្ឋកិច្ចកម្ពុជា" ដែលដកស្រង់ចេញពី៖ Post-SARS tourism recovery to attract Chinese tourists. Retrieved on June 16th, 2020 from: https://www.traveldailynews.asia/post-sars-tourism-recovery-to-attract-chinese-tourists
- OpenDevelopmentCambodia(ODC) (https://opendevelopmentcambodia.net/km/profiles/socio-economic-impact-of-covid-19-on-cambodia/)

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន

| | |
|---|---|
| ឧបសម្ព័ន្ធទី១ ៖ | កម្រងទិន្នន័យនានា |
| ឧបសម្ព័ន្ធទី២ ៖ | ស្ថិតិភ្ញៀវទេសចរណ៍បរទេសនិងចំណូលដែលទទួលបានពីការលក់ប័ណ្ណចូលទស្សនារមណីដ្ឋានអង្គរប្រចាំខែតុលាឆ្នាំ២០២០ |
| ឧបសម្ព័ន្ធទី៣៖ | ស្ថិតិភ្ញៀវទេសចរណ៍បរទេស និងចំណូលដែលទទួលបានពីការលក់ប័ណ្ណចូលទស្សនារមណីដ្ឋានអង្គរប្រចាំខែ វិច្ឆិកា ឆ្នាំ ២០២០ |
| ឧបសម្ព័ន្ធទី៤៖ | របាយការណ៍ស្ថិតិទេសចរណ៍ក្នុងខែ កញ្ញា ឆ្នាំ២០២០ |
| ឧបសម្ព័ន្ធទី៥៖ | ការប្រកាសស្តីពីការប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ |

ឧបសម្ព័ន្ធទី១ ៖ កម្រងទិន្នន័យនានា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ..............................

**សេចក្តីប្រកាសព័ត៌មាន**

**ស្តីពី**

**សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា**

**ស្តីពីវិធានការបន្ថែម សំដៅជួយដល់វិស័យឯកជន និង កម្មករ-និយោជិត ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ-១៩, និង វិធានការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចក្រោយពីវិបត្តិនៃជំងឺនេះ**

**(ជុំទី ៤, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០)**

កម្ពុជាគ្រប់គ្រង និង ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ ខណៈដែលស្ថានភាពនៃការរីករាលដាលនៃជំងឺនេះ ក្នុងកម្រិតតំបន់ និង សកលលោក ក៏ហាក់ដូចជាមានភាពធូរស្បើយជាងមុន ។ ទោះជាយ៉ាងនេះក្តី, ផលប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ច និង សង្គម ពីការរាតត្បាតនៃជំងឺនេះលើគ្រប់ប្រទេសទាំងអស់ក្នុងសកលលោក រួមទាំងកម្ពុជាផង នៅតែបន្តអូសបន្លាយនៅឡើយ ។

ក្នុងគោលដៅធានាលំនឹងនៃសេដ្ឋកិច្ច និង សង្គម ពិសេសរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុន, រោងចក្រ និង សហគ្រាស ឲ្យអាចបន្តអាជីវកម្ម ឆ្លងផុតពីវិបត្តិនៃជំងឺកូវីដ-១៩ នេះ, រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញនូវវិធានការជុំទី ៤ ដើម្បីកាត់បន្ថយផលប៉ះពាល់នានាដែលអាជីវកម្ម-ធុរកិច្ចក្នុងវិស័យសំខាន់ៗកំពុងជួបប្រឈម ។ កញ្ចប់នៃវិធានការនេះ រួមបញ្ចូលនូវសមាសភាគធំៗពីរ គឺ៖ (១)-ការបន្តសុពលភាពនៃវិធានការមួយចំនួនដែលរាជរដ្ឋាភិបាលបានដាក់ចេញកន្លងមក; និង (២)-ការដាក់ចេញនូវវិធានការថ្មីបន្ថែម ។ ជាមួយគ្នានេះ, វិធានការជុំទី ៤ នេះ ក៏បានគិតគូរដល់ការបង្កើននូវការចូលរួមចំណែកបន្ធូរបន្ទុក នៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលមានជីវភាពក្រីក្រ តាមរយៈកម្មវិធីជំនួយសង្គម (Social Assistance) ផងដែរ ។

ជាងនេះទៅទៀត, ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ អាចនឹងវិវត្តទៅដល់ដំណាក់កាលមួយដែលកាន់តែធូរស្បើយ ហើយសេដ្ឋកិច្ចអាចដំណើរការបានប្រក្រតីឡើងវិញនាពេលឆាប់ៗខាងមុខ, វិធានការជុំទី ៤ នេះ ក៏ផ្តោតផងដែរ លើការជួយស្តារ និង ជំរុញលទ្ធភាពអាជីវកម្ម និង ធុរកិច្ច ឲ្យងើបឡើងវិញ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍ក្រោយវិបត្តិនៃជំងឺនេះ ។

វិធានការជុំទី ៤ ដែលត្រូវបានរៀបចំឡើងក្នុងស្មារតីបុរេសកម្ម និង ដោយមានការពិគ្រោះយោបល់ទូលំទូលាយជាមួយគ្រប់តួអង្គពាក់ព័ន្ធ ដូចបានគូសបញ្ជាក់ខាងលើ រួមមានដូចខាងក្រោម ៖

១. វិធានការជួយរក្សាលំនឹងអាជីវកម្ម និង ជីវភាពកម្មករ-និយោជិត

*១.១. វិធានការបន្តជួយវិស័យទេសចរណ៍*

- បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ចំពោះ សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និង ក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និង មាន សកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត និង ក្រុងប៉ោយប៉ែត សម្រាប់រយៈពេល ២ ខែ បន្ថែមទៀត ចាប់ពីខែ មិថុនា ដល់ខែ កក្កដា ឆ្នាំ ២០២០;
- បន្តអនុញ្ញាតឲ្យមិនបង់ប្រាក់ភាគទានធានារ៉ាប់រងរបបហានិភ័យការងារ និង ថែទាំសុខភាព (បសស) ក្នុងអំឡុងពេលព្យួរអាជីវកម្ម;
- លើកលែងការបង់ថ្លៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ នៅក្នុងវិស័យទេសចរណ៍ សម្រាប់ឆ្នាំ ២០២១ ។

*១.២. វិធានការជួយវិស័យអាកាសចរណ៍*

- លើកលែងការបង់ពន្ធអប្បបរមា (Minimum tax) សម្រាប់រយៈពេល ២ ខែ បន្តទៀត ចាប់ពីខែ មិថុនា ដល់ខែ កក្កដា ឆ្នាំ ២០២០ ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ ដែលបានចុះបញ្ជីនៅកម្ពុជា ។

២. វិធានការផ្តល់ហិរញ្ញប្បទានសម្រាប់អាជីវកម្ម

*២.១. កែសម្រួលកម្មវិធីហិរញ្ញប្បទានពិសេស ៥០ លានដុល្លារអាមេរិក តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) ដោយពង្រីកវិសាលភាពគ្របដណ្តប់ និង កែសម្រួលលក្ខខណ្ឌឥណទាន ដូចខាងក្រោម ៖*

- បន្ថយអត្រាការប្រាក់សម្រាប់កម្ចីទុនបង្វិល (Working Capital) ពី ៦% មក ៥% និង សម្រាប់ទុនវិនិយោគ ពី ៦,៥% មក ៥,៥% ដោយមិនគិតកម្រៃសេវាផ្សេងៗ;
- កែសម្រួលរយៈពេលឥណទានអតិបរមាពី ៥ ឆ្នាំ ទៅ ៧ ឆ្នាំសម្រាប់ទុនវិនិយោគ ខណៈរក្សាទុករយៈពេលខ្លី អតិបរមា ២ ឆ្នាំ សម្រាប់ទុនបង្វិល;
- បន្តមិនអនុញ្ញាតឱ្យអតិថិជនដែលទទួលកម្ចីនៅក្នុងកម្មវិធីពិសេសនេះ យកកម្ចីទៅប្រើប្រាស់ធ្វើបុនហិរញ្ញប្បទាន (Refinancing);
- ផ្តល់ភាពទន់ភ្លន់លើលក្ខខណ្ឌចុះបញ្ជី ដែលក្នុងនោះ សហគ្រាសធុនតូច និង មធ្យម ដែលមិនទាន់ចុះបញ្ជីផ្លូវការ អាចដាក់ពាក្យស្នើសុំឥណទានបាន ដោយបំពេញលក្ខខណ្ឌចុះបញ្ជីតាមក្រោយ ក្នុងរយៈពេល ១ ខែ បន្ទាប់ពីទទួលបានឥណទាន;

- កែសម្រួលលក្ខខណ្ឌតម្រូវឲ្យ "សហគ្រាសធុនតូច និង មធ្យម បង្កើតឱកាសការងារថ្មីចាប់ពី ៥ នាក់ឡើងទៅ" ទៅជា "លើកទឹកចិត្តឲ្យសហគ្រាសធុនតូច និង មធ្យម ដែលទទួលបានឥណទាន ខិតខំបង្កើតឱកាសការងារថ្មី";

- ពង្រីកវិសាលភាពនៃការផ្តល់ឥណទានក្នុងគម្រោងនេះ ដល់បណ្តុំសហគ្រាសធុនតូច និង មធ្យម (SME Cluster) ដោយលើកទឹកចិត្តសហគ្រាសធុនតូច និង មធ្យម ដែលមានការពាក់ព័ន្ធឲ្យប្រើប្រាស់សេវាបច្ចេកទេសរបស់មជ្ឈមណ្ឌល «សហគ្រិនខ្មែរ» (Khmer Entrepreneur) ដើម្បីសម្រួលដល់ការទទួលបាននូវឥណទាននេះ ។

*២.២. កែសម្រួលកម្មវិធីសហហិរញ្ញប្បទានពិសេស ១០០ លានដុល្លារអាមេរិក រវាងធនាគារសហគ្រាសធុនតូច និង មធ្យម ជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុ ដោយពង្រីកវិសាលភាពគ្របដណ្តប់ និងកែសម្រួលលក្ខខណ្ឌឥណទាន ដូចខាងក្រោម ៖*

- អនុញ្ញាតឲ្យមានការកែសម្រួលលក្ខខណ្ឌឥណទាន ចំពោះឥណទានដែលកំពុងដំណើរការ (Loan Restructuring);

- បន្តមិនអនុញ្ញាតឲ្យអតិថិជនដែលទទួលកម្ចីនៅក្នុងកម្មវិធីពិសេសនេះ យកកម្ចីទៅប្រើប្រាស់ធ្វើបុនហិរញ្ញប្បទាន (Refinancing);

- ផ្តល់ភាពទន់ភ្លន់ក្នុងការសងត្រលប់ ដោយប្តូរពីការតម្រូវឲ្យសងប្រចាំខែ ទៅជាត្រីមាស ឬឆមាស ហើយយ៉ាងយូរបំផុតត្រឹម ១២ ខែ ចំពោះដើមទុន និង ការប្រាក់;

- កែសម្រួលរយៈពេលឥណទានពី ៤ ឆ្នាំ ទៅ ៧ ឆ្នាំ ដោយអនុញ្ញាតឲ្យគ្រឹះស្ថានហិរញ្ញវត្ថុ (PFIs) ជាអ្នកធ្វើការវាយតម្លៃខ្លួនឯង លើរយៈពេលឥណទាន សម្រាប់ឥណទានទុនបង្វិល និង ឥណទានទុនវិនិយោគ;

- ពង្រីកវិសាលភាពនៃការផ្តល់ឥណទាន ឲ្យគ្របដណ្តប់ទៅដល់សហគ្រាសក្នុងវិស័យផលិតឧបករណ៍វេជ្ជសាស្ត្រ និង ផលិតឱសថ បន្ថែមលើវិស័យអាទិភាពដែលមានចែងក្នុងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ២០១៨ ស្តីអំពី "ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និង មធ្យមក្នុងវិស័យអាទិភាព";

- កែសម្រួលលក្ខខណ្ឌតម្រូវឲ្យ "សហគ្រាសធុនតូច និង មធ្យម បង្កើតឱកាសការងារថ្មីចាប់ពី ៥ នាក់ឡើងទៅ" ទៅជា "លើកទឹកចិត្តឱ្យសហគ្រាសធុនតូច និង មធ្យម ដែលទទួលបានឥណទានខិតខំបង្កើតឱកាសការងារថ្មី" ។

៣. ការបង្កើនហិរញ្ញប្បទានបន្ថែម ដើម្បីស្តារ និង ជំរុញកំណើនក្រោយវិបត្តិនៃជំងឺកូវីដ-១៩

*៣.១. វិធានការបង្កើន និង សម្រួលលំហូរសាច់ប្រាក់*

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិនិត្យលទ្ធភាពបន្ថយបន្ថយ និង កែសម្រួលនូវលក្ខខណ្ឌមួយចំនួន ដើម្បីបង្កើន និង សម្រួលលំហូរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារបន្ថែមទៀត ។

*៣.២.ការបន្ធូរបន្ថយការអនុវត្តពន្ធកាត់ទុកលើការប្រាក់សម្រាប់អ្នកផ្តល់កម្ចីក្នុងស្រុក និង ក្រៅស្រុក (Withholding Tax)*

សម្រាប់កម្ចីថ្មី :

- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, មកនៅត្រឹម ៥% ( ទាំងការខ្ចីពីប្រទេសដែលមានកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និង ការបង្ការការគេចវេះពន្ធ និងការគេចវេះពន្ធ (DTA) និង ការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២០;
- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និងខាងក្នុងស្រុក, មកនៅត្រឹម ១០% ( ទាំងការខ្ចីពីប្រទេសដែលមាន DTA និង ការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២១; និង
- កែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, ឲ្យឡើងដល់កម្រិតធម្មតា ស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានវិញ នៅឆ្នាំ ២០២២ ។

សម្រាប់កម្ចីចាស់ :

- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, មកនៅត្រឹម ១០% ( ទាំងការខ្ចីពីប្រទេសដែលមាន DTA និង ការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២០;
- កែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, ឲ្យឡើងដល់កម្រិតធម្មតា ស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានវិញ នៅឆ្នាំ ២០២១ ។

*៣.៣. ប្រភពហិរញ្ញប្បទានសម្រាប់ទុនបង្វិល (Working Capital)*

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំបង្កើត «មូលនិធិធានាឥណទាន» (Credit Guarantee Fund) ជាមួយថវិកា ២០០ លានដុល្លារអាមេរិក ។ មូលនិធិនេះ អាចធានាឥណទានកម្ចីតាមរយៈធនាគារ និង មីក្រូហិរញ្ញវត្ថុ ដោយប្រើគោលការណ៍ទីផ្សារ ដើម្បីជួយសម្រាលសម្ពាធលំហូរសាច់ប្រាក់ និង ទុនបង្វិលរបស់អាជីវកម្ម-ធុរកិច្ចក្នុងគ្រប់វិស័យ បានយ៉ាងតិចចំនួន ២.០០០ លានដុល្លារអាមេរិក ។

*៣.៤. ត្រៀមឧបករណ៍ផ្តល់ហិរញ្ញប្បទាន (Financing Facility) បន្ថែម*

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងត្រៀមថវិកាសម្រាប់ហិរញ្ញប្បទានបន្ថែមចំនួន ៣០០ លានដុល្លារអាមេរិក ដើម្បីគាំទ្រ និង ដើរតួជាកាតាលីករជំរុញកំណើនតាមវិស័យសំខាន់ៗ ក្នុងអំឡុងពេលវិបត្តិ និង ក្រោយពេលវិបត្តិ ។

៤. វិធានការជំនួយសង្គម

- រាជរដ្ឋាភិបាលសម្រេចពង្រីកវិសាលភាពគ្របដណ្តប់ និង ទំហំថវិកា សម្រាប់ «កម្មវិធីសាច់ប្រាក់ពលកម្ម» (Cash for Work) នៅក្នុងឆ្នាំ ២០២០ ឲ្យឡើងដល់ ១០០ លានដុល្លារអាមេរិក ដើម្បីស្រូបយកកម្លាំងពលកម្ម ដែលបាត់បង់ការងារពីរោងចក្រ-សហគ្រាស និង ដែលបានវិលត្រលប់ពីបរទេសមកស្រុកកំណើតវិញផង ព្រមទាំងដើម្បីជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាទូទៅផង និង ដើម្បីបង្កើតនូវសមិទ្ធផលសង្គម-សេដ្ឋកិច្ច តាមរយៈការអនុវត្តគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតូចៗនៅតាមមូលដ្ឋាន សំដៅលើកស្ទួយវិស័យកសិកម្ម និង សេដ្ឋកិច្ចផងដែរ;
- ជាមួយនឹងការប្តេជ្ញាបន្តអនុវត្តរាល់កម្មវិធីគាំពារសង្គមទាំងឡាយដែលមានស្រាប់ មិនឲ្យខកខាន, រាជរដ្ឋាភិបាលនឹងរៀបចំដាក់ឲ្យអនុវត្ត នៅក្នុងខែ មិថុនា ឆ្នាំ ២០២០ នេះ នូវកម្មវិធីជំនួយសង្គមសំដៅជួយសម្រួលជីវភាពប្រចាំថ្ងៃ នៅក្នុងអំឡុងពេលនៃវិបត្តិដោយសារជំងឺកូវីដ-១៩ នេះ ជូនដល់គ្រួសារប្រជាពលរដ្ឋក្រីក្រ និង ក្រុមជនងាយរងគ្រោះ ដែលមានបណ្ណសមធម៌ទូទាំងប្រទេស ដោយយកចិត្តទុកដាក់បន្ថែមដល់កុមារអាយុក្រោម ៥ ឆ្នាំ, ជនពិការ, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំឡើង និង អ្នកផ្ទុកមេរោគអេដស៍ នៅក្នុងគ្រួសារប្រជាពលរដ្ឋក្រីក្រទាំងនោះផងដែរ ។

៥. ការដាក់ឱ្យអនុវត្តថ្នាលចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក

- រាជរដ្ឋាភិបាលនឹងដាក់ឲ្យដំណើរការជាជំហានទី ១ នូវថ្នាលចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក (IT Business Registration Platform) នៅដើមខែ មិថុនា ឆ្នាំ ២០២០ នេះ ដើម្បីសម្រួល និង ជំរុញដល់ការចុះបញ្ជីក្រុមហ៊ុនជាទូទៅ និងជាពិសេសជួយសម្រួលដល់ក្រុមហ៊ុនទាំងឡាយណាដែលមានបំណងចុះបញ្ជី ដើម្បីទទួលបានកម្ចីពីកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល ។

ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តនូវសេចក្តីណែនាំនេះ ទៅតាមសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រាជរដ្ឋាភិបាលនឹងបន្តតាមដានយ៉ាងខ្ជាប់ខ្ជួននូវសភាពការណ៍ផលប៉ះពាល់ពីជំងឺកូវីដ-១៩ លើសេដ្ឋកិច្ច និង សង្គមជាតិ និង ត្រៀមជាស្រេចក្នុងការដាក់ចេញវិធានការបន្ថែមទៀត ដើម្បីផ្តល់នូវការជួយគាំទ្រសមស្រប និង តាមការចាំបាច់ ដល់ក្រុមហ៊ុនអាជីវកម្ម, កម្មករ-និយោជិត និង ក្រុមប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ។

ឧបសម្ព័ន្ធទី២៖ ស្ថិតិភ្ញៀវទេសចរបរទេសនិងចំណូលដែលទទួលបានពីការលក់ប័ណ្ណចូលទស្សនារមណីដ្ឋាន អង្គរប្រចាំខែតុលាឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គ្រឹះស្ថានអង្គរ**
លេខ: ..០៧៥៨... គសអ.....

ថ្ងៃអាទិត្យ ០១រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សៀមរាប ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ស្ថិតិភ្ញៀវទេសចរបរទេស និងចំណូលដែលទទួលបានពីការលក់បណ្ណចូលទស្សនា រមណីយដ្ឋានអង្គរប្រចាំ ខែតុលា ឆ្នាំ ២០២០**

គ្រឹះស្ថានអង្គរ សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ចំនួនភ្ញៀវទេសចរបរទេស និងចំណូលដែលបានពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ទទួលបានលទ្ធផលដូចខាងក្រោម÷

១.ក្នុងខែតុលា ឆ្នាំ២០២០ ចំនួនភ្ញៀវទេសចរបរទេស និងចំណូលដែលទទួលបានពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ដូចមានក្នុងតារាងខាងក្រោម÷

| ទេសចរទិញបណ្ណ | | ចំណូល(ដុល្លារ) | |
|---|---|---|---|
| ចំនួនភ្ញៀវ | ប្រៀបធៀបខែ តុលា ២០១៩ | ចំណូល | ប្រៀបធៀបខែ តុលា ២០១៩ |
| ២,២៤៤ នាក់ | -៩៨,៤១ % | ៩៣,៥៩៨ ដុល្លារ | -៩៨,៥៣ % |

* ចំណូលឧបត្ថម្ភមូលនិធិ គន្ធបុប្ផាកម្ពុជា សម្រាប់ខែតុលា មានចំនួន =៤,៨៨៨ ដុល្លារ ។

២. រយៈពេល១០ខែ ឆ្នាំ២០២០ ចំនួនភ្ញៀវទេសចរ បរទេស និងចំណូលដែលទទួលបានពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ដូចមានក្នុងតារាងខាងក្រោម÷

| ទេសចរទិញបណ្ណ | | ចំណូល(ដុល្លារ) | |
|---|---|---|---|
| ចំនួនភ្ញៀវសរុប | ធៀបរយៈពេលដូចគ្នា ២០១៩ | ចំណូលសរុប | ធៀបរយៈពេលដូចគ្នា ២០១៩ |
| ៣៩៨,៨៨៥ នាក់ | -៧៧,៩១ % | ១៨,៥៤៩,៩០៥ ដុល្លារ | -៧៧,០១ % |

* សរុប ចំណូលឧបត្ថម្ភមូលនិធិ គន្ធបុប្ផាកម្ពុជា រយៈពេល ១០ខែ ក្នុងឆ្នាំ២០២០ មានចំនួន សរុប = ៧៩៦,៩៧០ ដុល្លារ ។

៣. ចំណូលពីការលក់បណ្ណនៅប្រាសាទកោះ កែរ សម្រាប់ខែតុលា មានចំនួន ៦៩ នាក់ =៦៩០ ដុល្លារ ។

* សរុប ចំណូលលក់បណ្ណនៅប្រាសាទកោះ កែរ រយៈពេល១០ខែ ក្នុងឆ្នាំ២០២០ មានចំនួន ៤,៩៨៣ នាក់= ៨៩,៨៣០ ដុល្លារ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជាតិ និងអន្តរជាតិមេត្តាជ្រាបជាព័ត៌មាន ។

**គ្រឹះស្ថានអង្គរ**

ផ្លូវ៦០ម៉ែត្រ ភូមិត្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
St 60m, Treang Village, Slor Kram Commune, Siem Reap City, Siem Reap Province, Kingdom of Cambodia
www.angkorenterprise.gov.kh
ទូរស័ព្ទលេខ: ០១២-៦០៦-៨៥២, ០៦៩-៥៦៣-៣៤៦
Phone:855-12-606-852, 855-69-563-346
Email: angkorenterprisekh@gmail.com

ឧបសម្ព័ន្ធទី៣ ៖ស្ថិតិភ្ញៀវទេសចរណ៍បរទេស និងចំណូលដែលទទួលបានពីការលក់ប័ណ្ណចូលទស្សនារមណីដ្ឋានអង្គរប្រចាំខែ វិច្ឆិកា ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គ្រឹះស្ថានអង្គរ
លេខ: ០៩៣ គសអ

ថ្ងៃអង្គារ ០១រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សៀមរាប ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០

**សេចក្ដីប្រកាសព័ត៌មាន**

**ស្ដីពី**

**ស្ថិតិភ្ញៀវទេសចរបរទេស និងចំណូលដែលទទួលបានពីការលក់បណ្ណចូលទស្សនា**
**រមណីយដ្ឋានអង្គរប្រចាំ ខែវិច្ឆិកា ឆ្នាំ ២០២០**

គ្រឹះស្ថានអង្គរ សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ចំនួនភ្ញៀវទេសចរបរទេស និងចំណូលដែលបានពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ទទួលបានលទ្ធផលដូចខាងក្រោម÷

**១.** ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ចំនួនភ្ញៀវទេសចរបរទេស និងចំណូលដែលទទួលបានពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ដូចមានក្នុងតារាងខាងក្រោម÷

| ទេសចរទិញបណ្ណ | | ចំណូល(ដុល្លារ) | |
|---|---|---|---|
| ចំនួនភ្ញៀវ | ប្រៀបធៀបខែ វិច្ឆិកា ២០១៩ | ចំណូល | ប្រៀបធៀបខែ វិច្ឆិកា ២០១៩ |
| ១,២៣៥ នាក់ | -៩៩,៣៦ % | ៥២,៣៨០ ដុល្លារ | -៩៩,៤១ % |

*** ចំណូលឧបត្ថម្ភមូលនិធិ គន្ធបុប្ផាកម្ពុជា សម្រាប់ខែវិច្ឆិកា មានចំនួន =២,៤៧០ ដុល្លារ ។**

**២.** រយៈពេល១១ខែ ឆ្នាំ២០២០ ចំនួនភ្ញៀវទេសចរ បរទេស និងចំណូលដែលទទួលបានពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ដូចមានក្នុងតារាងខាងក្រោម÷

| ទេសចរទិញបណ្ណ | | ចំណូល(ដុល្លារ) | |
|---|---|---|---|
| ចំនួនភ្ញៀវសរុប | ធៀបរយៈពេលដូចគ្នា ២០១៩ | ចំណូលសរុប | ធៀបរយៈពេលដូចគ្នា ២០១៩ |
| ៣៩៩,៧២០ នាក់ | -៧៩,៩៩ % | ១៨,៦០២,២៨៥ ដុល្លារ | -៧៩,២៣ % |

*** សរុប ចំណូលឧបត្ថម្ភមូលនិធិ គន្ធបុប្ផាកម្ពុជា រយៈពេល ១១ខែ ក្នុងឆ្នាំ២០២០ មានចំនួន សរុប = ៧៩៩,៤៤០ ដុល្លារ ។**

**៣. ចំណូលពីការលក់បណ្ណនៅប្រាសាទកោះ កែរ សម្រាប់ខែវិច្ឆិកា មានចំនួន ៥១ នាក់ = ៥១០ ដុល្លារ ។**

*** សរុប ចំណូលលក់បណ្ណនៅប្រាសាទកោះ កែរ រយៈពេល១១ខែ ក្នុងឆ្នាំ២០២០ មានចំនួន ៩,០៣៤ នាក់ = ៩០,៣៤០ ដុល្លារ ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជាតិ និងអន្តរជាតិមេត្តាជ្រាបជាព័ត៌មាន ។

គ្រឹះស្ថានអង្គរ

ផ្លូវ៦០ម៉ែត្រ ភូមិត្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
St 60m, Treang Village, Slor Kram Commune, Siem Reap City, Siem Reap Province, Kingdom of Cambodia
www.angkorenterprise.gov.kh
ទូរស័ព្ទលេខ: ០១២-៦០៦-៨៥២, ០៦៩-៥៦៣-៣៤៦
Phone:855-12-606-852, 855-69-563-346
Email: angkorenterprisekh@gmail.com

ឧបសម្ព័ន្ធទី៤ ៖ របាយការណ៍ស្ថិតិទេសចរណ៍ក្នុងខែកញ្ញា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០៧៤៦ របក

ថ្ងៃ អង្គារ ១១កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០២០

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

**កម្មវត្ថុ:** របាយការណ៍ស្ថិតិទេសចរក្នុងខែកញ្ញា និងរយៈពេល០៩ខែ ដើមឆ្នាំ២០២០។

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពជំរាបជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់អំពីស្ថិតិទេសចរអន្តរជាតិមកទស្សនាកម្ពុជាក្នុងខែកញ្ញា ឆ្នាំ២០២០ និងរយៈពេល០៩ខែ ដើមឆ្នាំ២០២០ ដូចខាងក្រោម:

**ក-ស្ថិតិទេសចរអន្តរជាតិក្នុងខែកញ្ញា ឆ្នាំ២០២០**

ទេសចរអន្តរជាតិមកទស្សនាកម្ពុជាក្នុងខែកញ្ញា ឆ្នាំ២០២០ មានចំនួន ២១.១៣៧នាក់ ថយចុះ ៩៥,៣% ធៀបនឹងខែកញ្ញា ឆ្នាំ២០១៩។

| | | | | | |
|---|---|---|---|---|---|
| ១-តាមអាកាស: | ១៣.៩៩៥នាក់ | ស្មើនឹង ៦៦,២% | នៃចំនួនសរុប | *ថយចុះ:* | *៩៥,២%* |
| -ច្រកភ្នំពេញ: | ១១.០២៨នាក់ | ស្មើនឹង ៥២,២% | នៃចំនួនសរុប | *ថយចុះ:* | *៩២,១%* |
| -ច្រកសៀមរាប: | ២នាក់ | ស្មើនឹង ០% | នៃចំនួនសរុប | *ថយចុះ:* | *១០០%* |
| -ច្រកកងកេង: | ២.៩៦៥នាក់ | ស្មើនឹង ១៤,០% | នៃចំនួនសរុប | *ថយចុះ:* | *៩៥,១%* |
| ២-តាមផ្លូវគោក: | ៧.១៤២នាក់ | ស្មើនឹង ៣៣,៨% | នៃចំនួនសរុប | *ថយចុះ:* | *៩៥,៥%* |
| ៣-តាមផ្លូវទឹក: | ០នាក់ | ស្មើនឹង ០% | នៃចំនួនសរុប | *ថយចុះ:* | *១០០%* |

**ខ-ស្ថិតិទេសចររយៈពេល០៩ខែ ដើមឆ្នាំ២០២០**

ទេសចរអន្តរជាតិមកទស្សនាកម្ពុជារយៈពេល០៩ខែ ដើមឆ្នាំ២០២០ មានចំនួន ១.២៤៧.៦៨០នាក់ ថយចុះ: ៧៤,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩ ក្នុងនោះ:

| | | | |
|---|---|---|---|
| ១-តាមអាកាស: | ៧១៩.១៧៧ នាក់ | ស្មើនឹង ៥៧,៦នៃចំនួនសរុប % | *ថយចុះ: ៧៨,៨%* |
| -ច្រកភ្នំពេញ: | ៤១០.៦៦១ នាក់ | ស្មើនឹង ៣២,៩នៃចំនួនសរុប % | *ថយចុះ: ៧៣៨,%* |
| -ច្រកសៀមរាប: | ២៤០.៨៨៤ នាក់ | ស្មើនឹង ១៩,៣នៃចំនួនសរុប % | *ថយចុះ: ៨១,១%* |
| -ច្រកកងកេង: | ៦៧.៦៣២ នាក់ | ស្មើនឹង ៥,៤នៃចំនួនសរុប % | *ថយចុះ: ៨៧,៧%* |
| ២-តាមផ្លូវគោក: | ៤៧៧.០០៩ នាក់ | ស្មើនឹង ៣៨,២នៃចំនួនសរុប % | *ថយចុះ: ៦៣,៨%* |
| ៣-តាមផ្លូវទឹក: | ៥១.៤៩៤ នាក់ | ស្មើនឹង ៤,១នៃចំនួនសរុប % | *ថយចុះ: ៤៩,៨%* |

ទីស្តីការលេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ:+ ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

* <u>អំពីទីផ្សារទេសចរណ៍សំខាន់ៗទាំង១០មកកម្ពុជា(០៩ខែ ដើមឆ្នាំ២០២០ ធៀបនឹង ០៩ខែ ដើមឆ្នាំ២០២០)</u>

| | | | |
|---|---|---|---|
| ១-ចិន | ៣០២.៨២៦ នាក់ | ស្មើនឹង ២៤,៣នៃចំនួនសរុប % | *ថយចុះ: ៨៣,៨%* |
| ២-ថៃ | ១៨៩.៤៤២ នាក់ | ស្មើនឹង ១៥,២នៃចំនួនសរុប % | *ថយចុះ: ៣៤,២%* |
| ៣-វៀតណាម | ១៨០.៧៦១ នាក់ | ស្មើនឹង ១៤,៥នៃចំនួនសរុប % | *ថយចុះ: ៧១,៦%* |
| ៤-អាមេរិក | ៥៤.៦៦៦ នាក់ | ស្មើនឹង ៤,៤នៃចំនួនសរុប % | *ថយចុះ: ៦៩,២%* |
| ៥-កូរ៉េ | ៥៤.៤១៤ នាក់ | ស្មើនឹង ៤,៤នៃចំនួនសរុប % | *ថយចុះ: ៧០,៩%* |
| ៦-អង់គ្លេស | ៤៤.៥៧៩ នាក់ | ស្មើនឹង ៣,៦នៃចំនួនសរុប % | *ថយចុះ: ៥៩,៥%* |
| ៧-បារាំង | ៤២.៥៨១ នាក់ | ស្មើនឹង ៣,៤នៃចំនួនសរុប % | *ថយចុះ: ៦២,៥%* |
| ៨-ជប៉ុន | ៤០.៦១៩ នាក់ | ស្មើនឹង ៣,៣នៃចំនួនសរុប % | *ថយចុះ: ៧២,៨%* |
| ៩-ឡាវ | ៣៤.៣១៣ នាក់ | ស្មើនឹង ២,៨នៃចំនួនសរុប % | *ថយចុះ: ៨៦,២%* |
| ១០-អាឡឺម៉ង់ | ២៧.១៤០ នាក់ | ស្មើនឹង ២,២នៃចំនួនសរុប % | *ថយចុះ: ៥៣,៨%* |

* <u>អំពីប្រភពទីផ្សារទេសចរណ៍សំខាន់ៗមកកម្ពុជា (រយៈពេល០៩ខែ ដើមឆ្នាំ២០២០)</u>

-មកពីតំបន់អាស៊ីប៉ាស៊ីហ្វិក ៩៣៧.៩២១ នាក់ ស្មើនឹង ៧៥,២នៃចំនួនសរុប % *ថយចុះ: ៧៦,៥%*

ក្នុងនោះមកពីតំបន់អាស៊ាន ៤៧១.៦០៤ នាក់ ស្មើនឹង ៣៧,៨នៃចំនួនសរុប % *ថយចុះ: ៦៨៧,%*

-មកពីតំបន់អឺរុប ២២៣.៤៨៥ នាក់ ស្មើនឹង ១៧,៩នៃចំនួនសរុប % *ថយចុះ: ៥៨,៦%*

-មកពីតំបន់អាមេរិក ៨១.៨៦៦ នាក់ ស្មើនឹង ៦,៦ %នៃចំនួនសរុប *ថយចុះ: ៦៧,៧%*

❖ **កំណត់សំគាល់អំពីគោលបំណងទេសចរណ៍**

- **ឆ្នាំ២០១៩** ទេសចរសម្រាក់លំហែកម្សាន្ត (Holiday and Leisure) មានរហូតដល់ ៧៦,២% ទេសចរធុរៈកិច្ច និងទេសចរការទូត (Business) មាន ២០,៧% និងផ្សេងៗមាន ៣,១%។
- **ក្នុងដំណាក់កាលកូវីដ-១៩** ចាប់ពីខែមេសា ដល់ ខែកញ្ញា ឆ្នាំ២០២០ គោលបំណងទេសចរណ៍មានការប្រែប្រួល ជាក់ស្តែងទេសចរសម្រាក់លំហែកម្សាន្ត មាន ៤៣,៤% (៤០.០៩៥នាក់)ទេសចរធុរៈកិច្ច និងការទូត មាន ៥៤,៦% (៥០.២៦៣នាក់) និងផ្សេងៗ ២,៣% (២.០៩៦នាក់)។
- **តាមការព្យាករណ៏ក្នុងឆ្នាំ២០២០** ទេសចរអន្តរជាតិមកទស្សនាកម្ពុជាមានចំនួនប្រមាណ **១,៣២ លាននាក់** ថយចុះ: ៨០% ធៀបនឹងឆ្នាំ២០១៩។

❖ **<u>កំណត់សំគាល់អំពីចំនួនទេសចរផ្ទៃក្នុង (Internal Tourist)</u>**

- **រយៈពេល ០៩ខែដើមឆ្នាំ២០២០** ទេសចរផ្ទៃក្នុង (Internal Tourist) **មានចំនួន ៧.២៨៤.៤០៩នាក់ ថយចុះ: ៥១,៩%។**
- **តាមការព្យាករណ៏ ក្នុងឆ្នាំ២០២០** ទេសចរផ្ទៃក្នុង (Internal Tourist) **មានចំនួនប្រមាណ ៩,២ លាននាក់ ថយចុះ: ២០%។**

* <u>អំពីចំនួនទេសចរជាតិចេញទៅក្រៅប្រទេស (Cambodia Outbound Tourists)</u>

**រយៈពេល០៩ខែ ដើមឆ្នាំ២០២០** មានទេសចរជាតិចេញទៅក្រៅប្រទេសចំនួន **៣១៧.៥០២** នាក់ **ថយចុះ ៧៩,៣%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

អាស្រ័យដូចបានគោរពជំរាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
-ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
-ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-សាលារាជធានីភ្នំពេញ
-សាលាខេត្តសៀមរាប
-សាលាខេត្តព្រះសីហនុ
-សាលាខេត្តព្រះវិហារ
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី៥ ៖ ការប្រកាសស្តីពីការប្រើប្រាស់សៀវភៅជំនាញទេសចរណ៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

ក្រសួងទេសចរណ៍

លេខ ២១៦ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ២០១៤

**ប្រកាស**

**ស្តីពី**

**ការប្រើប្រាស់សៀវភៅជំនាញទេសចរណ៍**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**និងជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

- *បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍*
- *បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍*
- *បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍*
- *បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍*
- *បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៤ សសរ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍*
- *យោងតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មការជាតិអ្នកជំនាញទេសចរណ៍ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ និងយោងតាមតម្រូវការចាំបាច់នៃការងាររបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍*

**សម្រេច**

**ប្រការ ១**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីលើកកម្ពស់ និងអភិវឌ្ឍជំនាញទេសចរណ៍ ប្រកបដោយប្រសិទ្ធិភាព និងគុណភាពខ្ពស់។

សៀវភៅជំនាញទេសចរណ៍ គឺជាសក្ខីបណ្ណដែលបញ្ជាក់អំពីសមាសធាតុនៃគុណវុឌ្ឍិរបស់អ្នកជំនាញទេសចរណ៍។

**ប្រការ ២._**

សៀវភៅជំនាញទេសចរណ៍ត្រូវបានដាក់ឱ្យប្រើប្រាស់ដល់អ្នកជំនាញទេសចរណ៍ និយោជកនៃវិស័យទេសចរណ៍ អង្គភាព ឬកម្មវិធីបណ្ដុះបណ្ដាលជំនាញទេសចរណ៍។

កំណត់ត្រាក្នុងសៀវភៅជំនាញទេសចរណ៍ អាចយកទៅប្រើប្រាស់ជាភស្តុតាងនៃការវាយតម្លៃសមត្ថភាព ការជ្រើសរើសបុគ្គលិក ការផ្ដល់រង្វាន់ ឬការធ្វើផែនការអភិវឌ្ឍជំនាញ។

**ប្រការ ៣._**

សៀវភៅជំនាញទេសចរណ៍នេះ ប្រើប្រាស់សម្រាប់កត់ត្រាគុណសម្បត្តិចំនួនបីសំខាន់ៗ របស់អ្នកជំនាញទេសចរណ៍ដូចជា៖

**(១) ការចូលរួមវគ្គបណ្ដុះបណ្ដាល**

វគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈរយៈពេលខ្លី មធ្យម និងវែង ទាំងក្នុង និងក្រៅប្រទេសស្ដីពីជំនាញជាក់លាក់ណាមួយ កម្មសិក្សា ព្រមទាំងវគ្គបណ្ដុះបណ្ដាលដែលរៀបចំដោយផ្ទាល់នៅក្នុងស្ថាប័ន។

**(២) លិខិតសរសើរ ឬពានរង្វាន់ផ្សេងៗ**

អ្នកជំនាញទេសចរណ៍ ឬស្ថាប័នអាចស្នើសុំឱ្យមានការកត់ត្រាអំពី លិខិតសរសើរ ស្នាដៃ ឬពានរង្វាន់ផ្សេងៗដែលខ្លួនទទួលបាន។ លិខិតសរសើរ ស្នាដៃ ឬពានរង្វាន់គឺជាផ្នែកមួយនៃសក្ខីបណ្ណ ដែលបញ្ជាក់អំពីសមត្ថភាពអ្នកជំនាញ ហើយដែលនឹងអាចត្រូវបានប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃសមត្ថភាពផងដែរ។

**(៣) បទពិសោធន៍ការងារ**

បទពិសោធន៍ការងារ ដែលអ្នកជំនាញទេសចរណ៍បានទទួលនៅក្នុងអាជីពការងាររបស់ខ្លួនអាចស្នើសុំការបញ្ជាក់ ឬកត់ត្រាក្នុងសៀវភៅជំនាញទេសចរណ៍។

**ប្រការ ៤._**

ដើម្បីទទួលបានការកត់ត្រារាល់គុណសម្បត្តិដូចមានចែងក្នុង ប្រការ ៣ សាម៉ីខ្លួន ឬអង្គភាពរបស់ខ្លួនត្រូវធ្វើការស្នើសុំតាមរយៈលិខិតទៅប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ (គ.ជ.អ.ទ.) ដោយភ្ជាប់នូវឯកសារយោង ឬសក្ខីបណ្ណផ្សេងៗ។

បន្ទាប់ពីបានទទួលការឯកភាពពីប្រធាន គ.ជ.អ.ទ. លេខាធិការដ្ឋានអាចចុះកត់ត្រារាល់គុណសម្បត្តិដែលទទួលបានការឯកភាព ក្នុងសៀវភៅជំនាញទេសចរណ៍ ដោយមានចុះហត្ថលេខាទទួលស្គាល់ដោយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ទ. ។

លេខាធិការដ្ឋាន គ.ជ.អ.ទ. អាចបញ្ចូលរាល់ទិន្នន័យអំពីការកត់ត្រាទាំងនេះក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ខ្លួន។

**ប្រការ ៥._**

រាល់ទិន្នន័យ ដែលបានកត់ត្រានៅក្នុងសៀវភៅជំនាញទេសចរណ៍នេះមានសុពលភាព ដរាបណាមានការទទួលស្គាល់ពី គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។

**ប្រការ ៦._**

គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ប្រើប្រាស់សៀវភៅនេះដើម្បីជាសក្ខីបណ្ណបញ្ជាក់សមត្ថភាពក្នុងដំណើរការវាយតម្លៃអ្នកជំនាញទេសចរណ៍អាស៊ាន។

**ប្រការ ៧._**

អ្នកជំនាញទេសចរណ៍ និយោជក អង្គភាព ឬកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ ដើម្បីចូលរួមលើកកម្ពស់ និងអភិវឌ្ឍជំនាញទេសចរណ៍ ព្រមទាំងផ្តល់ជាភស្តុតាងសម្រាប់ធ្វើការវាយតម្លៃអ្នកជំនាញទេសចរណ៍កម្ពុជា និងអាស៊ាន។

**ប្រការ ៨._**

សៀវភៅជំនាញទេសចរណ៍ អាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាពតាមតម្រូវការចាំបាច់។

**ប្រការ ៩._**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០._**

សមាជិក គ.ជ.អ.ទ. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ គ្រប់ប្រធាននាយកដ្ឋាន ប្រធានក្រុមអ្នកច្បាប់នៃក្រសួងទេសចរណ៍ លេខាធិការដ្ឋាន គ.ជ.អ.ទ. ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

***កន្លែងទទួល៖***

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ